# រូបំ ជីរតិ មច្ចានំ នាមគោត្តំ នជិរតិ

## រូបរបស់សត្វទាំងឡាយតែងគ្រាំគ្រា ឯនាមនិងគោត្តមិនចេះគ្រាំគ្រាឡើយ

ការផ្សាយរបស់
អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ
អាសយដ្ឋាន៖ #៣៩៥ តិរវិថីព្រះស៊ីសុវត្ថិ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ

លទ្ធផលការងារពុទ្ធិកសិក្សាឆ្នាំសិក្សា២០២៣-២០២៤ និងទិសដៅបន្តឆ្នាំសិក្សា២០២៤-២០២៥

ព.ស.២៥៦៨ - គ.ស.២០២៤

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រសួងធម្មការ និងសាសនា
## អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ



# លទ្ធផលការងារពុទ្ធិកសិក្សា

## ឆ្នាំសិក្សា២០២៣-២០២៤ និងទិសដៅបន្ត
## ឆ្នាំសិក្សា២០២៤-២០២៥

រៀបចំដោយ៖ អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ

ព.ស.២៥៦៨ គ.ស.២០២៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការនិងសាសនា
អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ

# លទ្ធផលការងារពុទ្ធិកសិក្សា
## ឆ្នាំសិក្សា២០២៣-២០២៤ និងទិសដៅបន្ត
## ឆ្នាំសិក្សា២០២៤-២០២៥

រៀបចំដោយ៖ អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ

ពុទ្ធសករាជ ២៥៦៨ គ.ស.២០២៤

# គណៈកម្មការរបាយការណ៍

## គណៈកម្មការដឹកនាំ

| | | |
|---|---|---|
| សម្តេចព្រះពោធិវ័ង្ស **អ៊ំ លឹមហេង** | ព្រះអគ្គាធិការ | ប្រធាន |
| សម្តេចព្រះមង្គលមុនីវង្ស៍ **ហ៊ូ ឈីវនាថ** | ព្រះអគ្គាធិការរងនិងជាព្រះនាយកនៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត | អនុប្រធាន |
| ព្រះសុមេធវង្សបណ្ឌិត **សុខ ប៊ុនធឿន** | ប្រធានផ្នែកពុទ្ធិកឧត្តមសិក្សានិងក្រោយពុទ្ធិកឧត្តមសិក្សា | សមាជិក |
| ព្រះសង្ឃាលង្ការមុនីបណ្ឌិត **យ៉ន កុសល្យ** | ព្រះធានផ្នែកពុទ្ធិកមធ្យមសិក្សា | សមាជិក |
| ព្រះពុទ្ធវង្ស **សុខ សុភាព** | ប្រធានផ្នែកពុទ្ធិកបឋមសិក្សានិងធម្មវិន័យ | សមាជិក |
| លោក **ទន់ ផាន់លី** | ប្រធានផ្នែករដ្ឋបាលនិងគណនេយ្យ | សមាជិក |

## គណៈកម្មការត្រួតពិនិត្យ

| | | |
|---|---|---|
| លោក **ម៉េង សាម៉េត** | អនុប្រធានផ្នែករដ្ឋបាលនិងគណនេយ្យ | ប្រធាន |
| ព្រះសមណឧត្តម **ឆេង សុម៉ើ** | ប្រធានការិយាល័យរដ្ឋបាលនិងសរុប | អនុប្រធាន |
| ព្រះបាលិមុនី **ហ៊ី ហុង** | អនុប្រធានផ្នែកពុទ្ធិកមធ្យមសិក្សា | សមាជិក |
| ព្រះមហា **ខន សារ៉ាត់** | អនុប្រធានការិយាល័យ | សមាជិក |

## គណៈកម្មការរៀបចំចងក្រងឯកសារ

| | | |
|---|---|---|
| លោក **គួន គីម** | មន្ត្រីការិយាល័យរដ្ឋបាលនិងសរុប | ប្រធាន |
| លោក **ហេង រតនៈ** | នាយករងពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត | អនុប្រធាន |
| លោក **យឹម ច័ន្ទថុល** | មន្ត្រីការិយាល័យរបៀបនិងអធិការកិច្ច | សមាជិក |
| ព្រះមហា **ម៉ុន សុមាស** | មន្ត្រីការិយាល័យរបៀបនិងអធិការកិច្ច | សមាជិក |
| លោក **តេល សុខា** | មន្ត្រីការិយាល័យរបៀបនិងអធិការកិច្ច | សមាជិក |

# អារម្ភកថា

កិច្ចខិតខំប្រឹងប្រែងរបស់ផ្នែកជំនាញនិងអង្គភាពពាក់ព័ន្ធទាំងអស់ បានធ្វើឱ្យសម្រេចជោគជ័យគួរឱ្យកត់សម្គាល់។ ដូច្នេះដើម្បីបង្ហាញឱ្យឃើញពី សមិទ្ធផលដែលសម្រេចបាននៅក្នុងការអនុវត្តការងារ គណៈកម្មការស្រាវជ្រាវនិងចងក្រងរបាយការណ៍បានប្រមូលចងក្រងរាល់ឯកសារពាក់ព័ន្ធនិងលទ្ធផលនានាដែលវិស័យអប់រំពុទ្ធិកសិក្សាបានអនុវត្តកន្លងមក ដើម្បីផលិតបានជាសៀវភៅរបាយការណ៍នាពេលនេះ។

សៀវភៅរបាយការណ៍បូកសរុបលទ្ធផលការងារពុទ្ធិកសិក្សានេះ ត្រូវបានផលិតឡើងជារៀងរាល់ឆ្នាំ ឱ្យស្របទៅតាមកម្មវិធីពុទ្ធិកសិក្សា ដោយអនុលោមទៅតាមនិយាមអប់រំរបស់ពុទ្ធិកសិក្សាដែលចាប់ផ្ដើមបវេសនកាលនៅរៀងរាល់ថ្ងៃទី៥ ខែឧសភា នៃឆ្នាំនីមួយៗនិងបញ្ចប់ទៅវិញនៅរៀងរាល់ថ្ងៃទី៣០ ខែមេសានៃឆ្នាំបន្ទាប់ ដែលជានិយាមនៃការអប់រំមួយនេះ គោរពទៅតាមចន្ទគតិ ដូច្នេះរាល់ការបញ្ចប់ឆ្នាំសិក្សានីមួយៗតែងមានការឆ្លងឆ្នាំ។ ជាងនេះទៅទៀត សៀវភៅរបាយការណ៍នេះត្រូវបានបែងចែកជាបីផ្នែកសំខាន់ៗ គឺផ្នែកទី១ ផ្ដោតសំខាន់ទៅលើលទ្ធផលការងារនិងទិសដៅបន្ត ផ្នែកទី២ សទ្ទានុក្រមបច្ចេកស័ព្ទនិងឧបសម្ព័ន្ធ ដែលមានភ្ជាប់មកជាមួយនូវលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធទៅនឹងការងារពុទ្ធិកសិក្សា និងផ្នែកទី៣ ស្ថិតិពុទ្ធិកសិក្សាសង្ខេប ដើម្បីបង្ហាញឱ្យឃើញនូវសក្ខីកម្ម ដែលវិស័យពុទ្ធិកសិក្សាបានខិតខំអស់ពីកម្លាំងកាយចិត្តក្នុងការផលិតធនធានមនុស្ស ជាពិសេសធនធានព្រះសង្ឃប្រកបដោយគុណភាព សមត្ថភាពនិងសីលធម៌ដែលជាប្រយោជន៍ដ៏សំខាន់សម្រាប់សង្គមជាតិនិងព្រះពុទ្ធសាសនា។

របាយការណ៍លទ្ធផលការងារពុទ្ធិកសិក្សាសម្រាប់ឆ្នាំសិក្សា២០២៣-២០២៤ ធ្វើឡើងដោយឈរលើមូលដ្ឋានសំខាន់ៗចំនួន **៦** គឺទី១ ប្រមូលចងក្រងរាល់របាយការណ៍របស់ផ្នែកជំនាញនិងពុទ្ធិកសាកលវិទ្យាល័យ ដែលបានបញ្ជូនមកកាន់អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ ទាំងប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងរបាយការណ៍ប្រចាំឆ្នាំ ទី២ របាយការណ៍អធិការកិច្ចដែលផ្នែកជំនាញនីមួយៗបានចុះធ្វើការត្រួតពិនិត្យនិងវាយតម្លៃដោយផ្ទាល់ នៅតាមសាលាពុទ្ធិកនានាទូទាំងប្រទេស ទី៣ ការចុះអង្កេតដោយផ្ទាល់របស់មន្ត្រីជំនាញតាមរយៈការប្រឡងនិងការធ្វើបទសម្ភាសន៍ជាមួយមន្ត្រីជំនាញទទួលបន្ទុកការិយាល័យពុទ្ធិកសិក្សា នៅតាមបណ្ដាមន្ទីររាជធានីខេត្ត ទី៤ ស្ថិតិពុទ្ធិកសិក្សាប្រចាំឆ្នាំដែលមន្ទីរធម្មការនិងសាសនាតាមបណ្ដារាជធានី ខេត្តបានធ្វើការបូកសរុបនិងបញ្ជូនមកកាន់អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ ព្រមទាំងមានការផ្ទៀងផ្ទាត់យ៉ាងយកចិត្តទុកដាក់ ដើម្បីបង្ហាញឱ្យឃើញពីសុក្រឹតភាពនិងវឌ្ឍនភាពវិស័យពុទ្ធិកសិក្សាប្រចាំឆ្នាំសិក្សា២០២៣-២០២៤ ទី៥ ការពិគ្រោះយោបល់តាមរយៈកិច្ចប្រជុំនិងកិច្ចពិភាក្សាជាមួយផ្នែកជំនាញដើម្បីធ្វើការផ្ទៀងផ្ទាត់ទិន្នន័យធ្វើយ៉ាងណាឱ្យមានសង្គតិភាព ទី៦ ការពិនិត្យកែសម្រួលទៅលើស្ថិតិនិងខ្លឹម

សារនៃរបាយការណ៍ទាំងមូល ទៅតាមផ្នែកជំនាញរៀងៗខ្លួន ដើម្បីជៀសវាងកំហុសកើតឡើងដោយអចេតនា។

ចំពោះគោលការណ៍នៅក្នុងការសរសេររបាយការណ៍នេះ បានផ្តោតទៅលើវិធីសាស្ត្រចំនួន **២** សំខាន់ គឺទី១ វិធីសាស្ត្របរិមាណវិស័យ ដោយបានដាក់បញ្ចូលនូវទិន្នន័យជាចំនួន ដែលរាប់ចាប់តាំងពីចំនួនសិស្ស សាលានិងចំនួនថ្នាក់ជាដើម ទី២ វិធីសាស្ត្រគុណវិស័យ មានការពិពណ៌នាយ៉ាងលម្អិតទៅលើទិន្នន័យដែលបានធ្វើការវិភាគរួចរាល់ហើយនោះ ដើម្បីបង្កលក្ខណៈងាយស្រួលដល់ថ្នាក់ដឹកនាំនិងអ្នកសិក្សាស្រាវជ្រាវទូទៅ ក្នុងការសិក្សាស្វែងយល់បន្ថែមឱ្យកាន់តែច្បាស់អំពីកត្តាសំខាន់ៗ ដែលនាំឱ្យមានមន្ទិលសង្ស័យ ព្រមទាំងបានជាមូលដ្ឋាននៃគំនិតដ៏សំខាន់ក្នុងការសម្រេចចិត្តផងដែរ។ មិនត្រឹមតែប៉ុណ្ណោះ គណៈកម្មការស្រាវជ្រាវនិងចងក្រងរបាយការណ៍បានធ្វើការប្រៀបធៀបទិន្នន័យពុទ្ធិកសិក្សាសម្រាប់ឆ្នាំសិក្សា២០២៣-២០២៤ ទៅនឹងឆ្នាំសិក្សា២០២២-២០២៣ ដើម្បីបញ្ជាក់ឱ្យកាន់តែច្បាស់អំពីវឌ្ឍនភាព ឬឱនភាពវិស័យអប់រំពុទ្ធិកសិក្សារវាងឆ្នាំនីមួយៗ។

ដូច្នេះរបាយការណ៍នេះ ពិតជាមានសារៈសំខាន់ណាស់សម្រាប់ថ្នាក់ដឹកនាំ អង្គភាព ឬស្ថាប័នពាក់ព័ន្ធ ក្នុងការរៀបចំផែនការអភិវឌ្ឍធនធានមនុស្សប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផល។ មិនត្រឹមតែប៉ុណ្ណោះ ក៏ជាសូចនាករដ៏សំខាន់ដែលមិនអាចខ្វះបាន ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយក្នុងការអភិវឌ្ឍជាតិ។ ជាងនេះទៅទៀត របាយការណ៍នេះនឹងបានជាមូលដ្ឋានប្រវត្តិសាស្ត្រដ៏សំខាន់ ដែលបានធ្វើកំណត់ត្រាអំពីដំណើរវិវឌ្ឍនៃការអប់រំរបស់វិស័យពុទ្ធិកសិក្សាមានលក្ខណៈជាវិទ្យាសាស្ត្រ បង្កភាពងាយស្រួលដល់សាធារណជន ក៏ដូចជាអ្នកស្រាវជ្រាវទូទៅបានជាគតិក្នុងការវិភាគ ពិចារណានិងការឆ្លុះបញ្ចាំងអំពីវឌ្ឍនភាពពុទ្ធិកសិក្សាពីមួយឆ្នាំទៅមួយឆ្នាំថាតើមានការប្រែប្រួលបែបណា? តើភាគីណាខ្លះដែលអាចរួមចំណែកក្នុងការទ្រទ្រង់និងគាំទ្រលើកម្មវិធីបណ្តុះបណ្តាលរបស់ពុទ្ធិកសិក្សា ឱ្យកាន់តែមានភាពប្រសើរឡើងបន្ថែមទៅទៀត? ថាតើឆ្នាំបន្តទៅទៀតវិស័យពុទ្ធិកសិក្សាគួរត្រៀមលក្ខណៈបែបណា ដើម្បីធានាឱ្យបាននូវនិរន្តរភាពរបស់ខ្លួន ក្នុងនាមជាអង្គភាពអប់រំដ៏មានសក្តានុពលរបស់ក្រសួងធម្មការនិងសាសនា? ទាំងនេះគឺជាគោលដៅដ៏សំខាន់ដែលត្រូវធ្វើការវិភាគពិចារណានិងឆ្លើយតប ប្រកបដោយការទទួលខុសត្រូវខ្ពស់ ដើម្បីអនាគតវិស័យអប់រំពុទ្ធិកសិក្សា។

សមិទ្ធផលនៃរបាយការណ៍នេះអាចលេចចេញជារូបរាងទៅបាន អាស្រ័យដោយមានការចូលរួមយ៉ាងសកម្មពីថ្នាក់ដឹកនាំតាមឋានានុក្រម ផ្នែកជំនាញ ពុទ្ធិកសាកលវិទ្យាល័យ មន្ទីរធម្មការនិងសាសនារាជធានី ខេត្តបានយកចិត្តទុកដាក់និងសហការយ៉ាងស្អិតរមួតប្រកបដោយការទទួលខុសត្រូវខ្ពស់។

ការផលិតបាននូវឯកសាររបាយការណ៍លទ្ធផលការងារដែលមានកម្រាស់ជាង១០០ទំព័រនេះ ពិតជាជួបប្រទះនូវបញ្ហាប្រឈមជាច្រើន ដែលគណៈកម្មការគ្រប់ផ្នែកទាំងអស់ត្រូវយកចិត្តទុកដាក់ខ្ពស់ក្នុងការដោះស្រាយនិងរក្សាការអត់ធ្មត់ជំរុញនិងលើកទឹកចិត្ត ធ្វើយ៉ាងណា ឱ្យការស្រាវជ្រាវនិងចងក្រងឯកសាររបាយការណ៍នេះមានសុក្រឹតភាព សមស្របទៅតាមដំណើរវិវឌ្ឍជាក់ស្តែងរបស់វិស័យពុទ្ធិកសិក្សា។ ទោះបីជាយ៉ាងណាក៏ដោយ ការបង្កកំហុសដោយអចេតនាអាចនឹងកើតឡើងដោយប្រការណាមួយជាក់ជាពុំខានឡើយ អាស្រ័យហេតុនេះ គណៈកម្មការស្រាវជ្រាវនិងចងក្រងរបាយការណ៍សូមស្វាគមន៍និងទទួលយករាល់មតិរិះគន់ក្នុងនៃស្ថាបនា ដើម្បីធ្វើឱ្យរបាយការណ៍សម្រាប់ឆ្នាំបន្តបន្ទាប់ទៀតកាន់តែមានភាពល្អប្រសើរបន្ថែមទៀត។

អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ នៅតែមានជំនឿយ៉ាងមុតមាំថា របាយការណ៍នេះពិតជាមានតម្លៃមហាសាលសម្រាប់ការងារពុទ្ធិកសិក្សា និងបានជាមូលដ្ឋានដ៏សំខាន់សម្រាប់ថ្នាក់ដឹកនាំតាមឋានានុក្រមក្នុងការសម្រេចចិត្ត ដើម្បីអភិរក្សនិងអភិវឌ្ឍវិស័យសាសនា ក៏ដូចជាវិស័យអប់រំពុទ្ធិកសិក្សាកាន់តែល្អប្រសើរបន្ថែមទៀត។ ម្យ៉ាងទៀតវិស័យអប់រំពុទ្ធិកសិក្សានៅតែបន្តដើរតួនាទីយ៉ាងសំខាន់ក្នុងការបណ្តុះបណ្តាលនិងការអភិវឌ្ឍមូលធនមនុស្ស ប្រកបដោយគុណភាព សមត្ថភាព ជំនាញ និងសីលធម៌សម្រាប់សង្គមជាតិនិងព្រះពុទ្ធសាសនា។

# សេចក្តីថ្លែងអំណរគុណ

លទ្ធផលការងារពុទ្ធិកសិក្សា ដែលគណៈកម្មការស្រាវជ្រាវនិងចងក្រងរបាយការណ៍បាន ផលិតចេញជារូបរាងនាពេលនេះ ដោយមានការចូលរួមយ៉ាងសកម្មពីប្រភពនានា ដែលបានផ្តល់ ទាំងឯកសារ ប្រាជ្ញាស្មារតីនិងវិភាគទានគំនិតដ៏សំខាន់ ដើម្បីលើកកម្ពស់គុណតម្លៃនៃការប្រមូល ចងក្រងនិងការវិភាគទិន្នន័យឱ្យបានល្អប្រសើរនិងមានភាពសុក្រឹត ស្របទៅតាមដំណើរវិវឌ្ឍ ជាក់ស្តែងរបស់ពុទ្ធិកសិក្សានាពេលបច្ចុប្បន្ន។

ក្នុងនាមអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ សូមថ្លែងអំណរព្រះករុណាទិគុណដ៏ខ្ពង់ខ្ពស់បំផុត របស់សម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជានិង ប្រមុខដឹកនាំរាជរដ្ឋាភិបាលកម្ពុជា ដែលតែងតែលើកស្ទួយ ទ្រទ្រង់ គាំទ្រព្រះពុទ្ធសាសនា និង ពុទ្ធិកសិក្សាឱ្យមានការរីកចម្រើនជាបន្តបន្ទាប់។

សូមថ្លែងអំណរព្រះគុណសម្តេចព្រះអគ្គាធិការ សម្តេចព្រះអគ្គាធិការរង ព្រះអគ្គាធិការរង ព្រះមន្ត្រីសង្ឃ មន្ត្រីរាជការតាមឋានានុក្រម និងមន្ទីរធម្មការនិងសាសនាតាមបណ្តារាជធានី ខេត្ត ទាំងអស់ ដែលបានយកចិត្តទុកដាក់ខ្ពស់ក្នុងការអភិរក្សនិងអភិវឌ្ឍវិស័យអប់រំពុទ្ធិកសិក្សាឱ្យមាន និរន្តរភាព។

សូមថ្លែងអំណរគុណដល់ផ្នែកជំនាញ ពុទ្ធិកវិទ្យាល័យ និងពុទ្ធិកសាកលវិទ្យាល័យទាំង អស់ ដែលបានសហការផ្តល់ជូនរាល់ឯកសារនិងតម្រូវការចាំបាច់ផ្សេងៗ ប្រកបដោយការទទួល ខុសត្រូវខ្ពស់ ដើម្បីធានាបាននូវសង្គតិភាពនៃទិន្នន័យនិងខ្លឹមសារ របាយការណ៍លទ្ធផលការងារ ពុទ្ធិកសិក្សាសម្រាប់ឆ្នាំសិក្សា២០២៣-២០២៤ នេះ។

ជាចុងក្រោយ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសហការីនិងឧបការបុគ្គលទាំង អស់ដែលបានរួមចំណែកក្នុងការត្រួតពិនិត្យនិងកែលម្អ ធ្វើឱ្យរបាយការណ៍លទ្ធផលការងារពុទ្ធិក សិក្សាសម្រាប់ឆ្នាំសិក្សា២០២៣-២០២៤ កាន់តែមានភាពល្អប្រសើរ និងបានជាប្រយោជន៍ដល់ សាធុជនទូទៅសិក្សាស្វែងយល់បន្ថែមទៀតអំពីការងារពុទ្ធិកសិក្សា។

សូមថ្វាយ ប្រគេន និងជូនពរ សម្តេចថ្នាក់ដឹកនាំ ព្រះមន្ត្រីសង្ឃ មន្ត្រីរាជការ និងមន្ទីរធម្ម-ការនិងសាសនារាជធានី ខេត្តទាំងអស់បានជួបប្រទះនូវពរទាំងឡាយ ៤ ប្រការ គឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ៕

*សូមអរព្រះគុណ និងសូមអរគុណ!*

# ឧទ្ទិសកថា

ក្នុងនាមអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ និងក្នុងនាមគណៈកម្មការស្រាវជ្រាវនិងចងក្រងរបាយការណ៍ សូមឧទ្ទិសស្នាដៃនៃកម្រងសៀវភៅរបាយការណ៍លទ្ធផលការងារពុទ្ធិកសិក្សានេះ ថ្វាយ ប្រគេន ជូនចំពោះវិបាកវិញ្ញាណរបស់បុព្វវីរសង្ឃនិងបុព្វបុរសខ្មែរទាំងអស់ ដែលបានកសាងស្នាដៃនិងបូជាព្រះកាយពល កម្លាំងប្រាជ្ញា ស្មារតី ដើម្បីបុព្វហេតុជាតិមាតុនិងព្រះពុទ្ធសាសនា ជាពិសេសវិស័យពុទ្ធិកសិក្សា ប្រតិស្ឋានទុករហូតមកដល់បច្ចុប្បន្ន សូមវិបាកវិញ្ញាណនៃបុព្វវីរសង្ឃនិងបុព្វបុរសខ្មែរទាំងអស់នោះ បានចុតិបដិសន្ធិក្នុងសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ៕

# សេចក្តីសង្ខេប

តាំងពីអតីតកាលរហូតមកដល់បច្ចុប្បន្ន វិស័យពុទ្ធិកសិក្សា នៅតែជាវិស័យអប់រំដ៏មានសក្តានុពលក្នុងសង្គមខ្មែរ និងបានកប់ជ្រៅនៅក្នុងជំនឿប្រពៃណីព្រះពុទ្ធសាសនាខ្មែរ ដែលត្រូវបានគេកត់សម្គាល់ថា ជាឃ្លាំងបណ្តុះបណ្តាលនូវវប្បធម៌ ប្រពៃណីព្រះពុទ្ធសាសនានិងបណ្តុះនូវសីលធម៌ ចរិយាធម៌ និងអភិសមាចារ ដ៏សំខាន់សម្រាប់ពលរដ្ឋខ្មែរទូទៅផងដែរ។ ជាងនេះទៅទៀត គេតែងកត់សម្គាល់ថា វិស័យអប់រំមួយនេះសម្រាប់តែព្រះសង្ឃប៉ុណ្ណោះ ផ្ទុយទៅវិញពុទ្ធិកសិក្សាត្រូវបានបើកទូលាយសម្រាប់សាធារណជនទូទៅ ចូលមកសិក្សារៀនសូត្រនិងទទួលបានចំណេះដឹងទាំងផ្លូវលោកនិងផ្លូវធម៌ ដោយមិនប្រកាន់រើសអើងវណ្ណៈ ពណ៌សម្បុរ ឬសាសនាឡើយ។

ពុទ្ធិកសិក្សាបានបើកបណ្តុះបណ្តាលចាប់ពីកម្រិតសាលាធម្មវិន័យ ពុទ្ធិកបឋមសិក្សារហូតដល់កម្រិតពុទ្ធិកឧត្តមសិក្សានិងក្រោយពុទ្ធិកឧត្តមសិក្សា ដោយទទួលបានការគាំទ្រហិរញ្ញវត្ថុមួយផ្នែកធំពីរាជរដ្ឋាភិបាល និងមួយចំណែកទៀត ពីពុទ្ធបរិស័ទមកពីប្រភពផ្សេងៗផងដែរ។ ដើម្បី គ្រប់គ្រងនិងដឹកនាំការងារពុទ្ធិកសិក្សា ឱ្យប្រព្រឹត្តិទៅប្រកបដោយប្រសិទ្ធភាពខ្ពស់និងមានការរីកចម្រើនជាបន្តបន្ទាប់រហូតមកដល់ពេលនេះ អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ មានសម្តេចព្រះមហាសុមេធាធិបតីកិត្តិឧទ្ទេសបណ្ឌិត **នន្ទ ង៉ែត** ជាព្រះអធិបតីកិត្តិយស សម្តេចព្រះពោធិវ័ង្ស **អំ លឹមហេង** ជាព្រះអគ្គាធិការនិងអមដោយសម្តេចព្រះអគ្គាធិការរងចំនួន ១០ អង្គ ព្រះមន្ត្រីសង្ឃចំនួន **៣៨** អង្គ និងមន្ត្រីរាជការចំនួន **៦៣** នាក់ (ស្រី **០៧** នាក់) សរុបទាំងអស់មានចំនួន **១១២** រូប។ ដោយឡែក មន្ត្រីសង្ឃកំពុងបំពេញការងារនៅក្នុងវិស័យពុទ្ធិកសិក្សាទាំងថ្នាក់កណ្តាល ពុទ្ធិកសាកលវិទ្យាល័យ និងនៅតាមបណ្តារាជធានី ខេត្តសរុបមានចំនួន **៣៥២** អង្គ។

វិស័យពុទ្ធិកសិក្សាបាននិងកំពុងបណ្តុះបណ្តាលចាប់ពីសាលាធម្មវិន័យ ពុទ្ធិកបឋមសិក្សារហូតដល់ពុទ្ធិកឧត្តមសិក្សានិងក្រោយពុទ្ធិកឧត្តមសិក្សា ក្នុងនោះ មានសាលាធម្មវិន័យចំនួន **៥២៨** កន្លែង សមណសិស្ស សិស្សចំនួន **១១,០០១** រូប គ្រូជួលចំនួន **៦៧៧** រូប សាលាពុទ្ធិកបឋមសិក្សាមានចំនួន **៩៥០** កន្លែង សមណសិស្ស សិស្សចំនួន **២៥,០៤៥** រូប គ្រូកិច្ចសន្យាចំនួន **១,៤៦២** រូប សាលាពុទ្ធិកមធ្យមសិក្សាបឋមភូមិមានចំនួន **៣៩** កន្លែង សមណសិស្ស សិស្ស **៥,៩២២** រូប គ្រូក្របខណ្ឌចំនួន **១១៨** រូប គ្រូជួលចំនួន **៣៨៣** រូប ពុទ្ធិកមធ្យមសិក្សាទុតិយភូមិចំនួន **១៤** កន្លែង សមណសិស្ស សិស្សចំនួន **២,០៦៩** រូប គ្រូក្របខណ្ឌចំនួន **៣៥** រូប គ្រូជួលចំនួន **២០៧** រូប និងពុទ្ធិកសាកលវិទ្យាល័យចំនួន **០៣** កន្លែង សមណនិស្សិត និស្សិតចំនួន **៦,២៣៣** រូប គ្រូក្របខណ្ឌចំនួន **៤៧** រូប គ្រូជួលចំនួន **៤៦២** រូប។

ចំពោះដំណើរការបណ្តុះបណ្តាលរបស់ពុទ្ធិកសិក្សា ក៏ជួបប្រទះនូវបញ្ហាប្រឈមមួយចំនួន រួមមានការខ្វះមន្ត្រីនិងគ្រូក្របខណ្ឌ របបប្រាក់ម៉ោងបន្ថែមមានកម្រិតទាប និងសមត្ថភាពមន្ត្រីសង្ឃ មន្ត្រីរាជការនៅមានកម្រិត ដែលជាកត្តារារាំងនាំឱ្យដំណើរការអភិវឌ្ឍពុទ្ធិកសិក្សាមានភាពយឺតយ៉ាវ។ ដើម្បីឆ្លើយតបទៅនឹងបញ្ហាខាងលើ អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិបានប្រើប្រាស់មន្ត្រីក្របខណ្ឌនិងមន្ត្រីជាប់កិច្ចសន្យាទៅតាមលទ្ធភាព អភិវឌ្ឍសមត្ថភាពមន្ត្រីសង្ឃនិងមន្ត្រីរាជការបន្ថែមទៀត ជំរុញនិងលើកទឹកចិត្តដល់ផ្នែកជំនាញនិងអង្គភាពពាក់ព័ន្ធទាំងអស់ ធ្វើយ៉ាងណាត្រូវមានការសហការគ្នាឱ្យបានល្អ និងពន្លឿនការងារដែលពាក់ព័ន្ធទៅនឹងប្រាក់ម៉ោងឱ្យឆាប់រហ័សតាមដែលអាចធ្វើបាន។ ម្យ៉ាងទៀត ស្នើសុំឱ្យអង្គភាពពាក់ព័ន្ធទាំងអស់ ត្រូវយកចិត្តទុកដាក់បំពេញការងារប្រកបដោយការទទួលខុសត្រូវខ្ពស់ និងឆ្លើយតបឱ្យបានទាន់ពេលវេលា ដើម្បីរួមចំណែកអភិវឌ្ឍវិស័យពុទ្ធិកសិក្សាឱ្យកាន់តែមានភាពប្រសើរឡើងបន្ថែមទៀត។

ព្រមជាមួយគ្នានេះដែរ អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ នឹងខិតខំឱ្យអស់ពីកម្លាំងកាយចិត្ត ដើម្បីជំរុញនិងលើកទឹកចិត្តដល់អង្គភាពពាក់ព័ន្ធទាំងអស់ ឱ្យបំពេញការងាររបស់ខ្លួនឱ្យបានល្អប្រសើរ ដើម្បីគាំទ្រដល់យុទ្ធសាស្ត្រកំណែទម្រង់របស់រាជរដ្ឋាភិបាលដំណាក់កាលទី១ ប្រកបដោយប្រសិទ្ធភាពខ្ពស់។ ការចូលរួមរបស់ថ្នាក់ដឹកនាំតាមឋានានុក្រម មន្ត្រីសង្ឃ មន្ត្រីរាជការមន្ទីរធម្មការនិងសាសនារាជធានី ខេត្ត គឺជាថាមពលដ៏សំខាន់ដែលជួយទ្រទ្រង់វិស័យអប់រំពុទ្ធិកសិក្សាឱ្យកាន់តែមានភាពរឹងមាំនិងមាននិរន្តរភាពយូរអង្វែងបន្ថែមទៀត។

អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ នៅតែបន្តបំពេញតួនាទីរបស់ខ្លួនឱ្យកាន់តែល្អប្រសើរ ដើម្បីលើកកម្ពស់គុណភាពអប់រំពុទ្ធិកសិក្សា ឱ្យមានការអភិវឌ្ឍប្រកបដោយចីរភាព សម្របសម្រួលនិងផ្តល់សេវារដ្ឋបាលទូទៅនិងការងារបច្ចេកទេសផ្សេងៗឱ្យកាន់តែមានភាពងាយស្រួល ធានាបាននូវភាពរហ័ស ប្រសិទ្ធភាពនិងប្រសិទ្ធផលផងដែរ។

# ផ្នែកទី១
# លទ្ធផលការងារ
# និងទិសដៅបន្ត

# មាតិកា


ចំណងជើងអត្ថបទ ទំព័រ

អារម្ភកថា ....... I

សេចក្តីថ្លែងអំណរគុណ ....... IV

ឧទ្ទិសកថា ....... V

សេចក្តីសង្ខេប ....... VI


## ផ្នែកទី១

## លទ្ធផលការងារនិងទិសដៅបន្ត


១- បរិបទអប់រំកម្ពុជា ....... ១

២- វឌ្ឍនភាព ....... ៥

២.១- រចនាសម្ពន្ធគ្រប់គ្រង ....... ៥

២.២-លទ្ធផលការងារឆ្នាំសិក្សា២០២៣-២០២៤ ....... ៨

២.២.១- ផ្នែកពុទ្ធិកបឋមសិក្សានិងធម្មវិន័យ ....... ៨

២.២.២- ផ្នែកពុទ្ធិកមធ្យមសិក្សា ....... ២៣

២.២.៣- ផ្នែកពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ....... ៤០

២.២.៤- ផ្នែកពុទ្ធិកឧត្តមសិក្សានិងក្រោយពុទ្ធិកឧត្តមសិក្សា ....... ៤៧

២.២.៥-ផ្នែករដ្ឋបាលនិងគណនេយ្យ ....... ៨៥

៣- បញ្ហាប្រឈម ....... ៩៦

៤- ទិសដៅឆ្នាំសិក្សា ២០២៤-២០២៥ ....... ៩៩

៥- សេចក្តីសន្និដ្ឋាន ....... ៩៩


## ផ្នែកទី២

### សន្ធានុក្រម

### កម្រងរូបភាព

### ឧបសម្ពន្ធ

## ផ្នែកទី៣

### ស្ថិតិពុទ្ធិកសិក្សាសង្ខេប

# ១- បរិបទអប់រំកម្ពុជា

ដំណើរវិវឌ្ឍន៍នៃប្រព័ន្ធអប់រំកម្ពុជានាពេលបច្ចុប្បន្ន មានការរីកចម្រើនជាបន្តបន្ទាប់ ក្នុងនោះវិស័យអប់រំចំណេះទូទៅបានធ្វើកំណែទម្រង់ទៅតាមដំណាក់កាល ដែលជាដំណើរមួយឆ្ពោះទៅរកការអភិវឌ្ឍប្រព័ន្ធអប់រំឌីជីថល ដើម្បីឱ្យស្របទៅតាមដំណើរវិវឌ្ឍនៃសកលភាវូបនីយកម្មរបស់ពិភពលោកនាពេលបច្ចុប្បន្ន។ យ៉ាងណាក៏ដោយ យោងទៅលើរបាយការណ៍របស់អង្គការយូនីស្កូ (UNESCO) បានបង្ហាញថា បច្ចុប្បន្ន ប្រព័ន្ធអប់រំឌីជីថលពិតជាសំខាន់ណាស់ ប៉ុន្តែមានសាលាបឋមសិក្សាត្រឹមតែ ៤០% ប៉ុណ្ណោះនៅទូទាំងពិភពលោកដែលអាចប្រើប្រាស់ប្រព័ន្ធអ៊ីនធើ-ណេតបាន។[១] ទោះបីជាយ៉ាងនេះក្តី ប្រព័ន្ធអប់រំទូទាំងពិភពលោកបានវិនិយោគការអប់រំ ដោយប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឌីជីថល[២]ស្របពេលជាមួយគ្នានេះដែរយោងទៅលើផែនការយុទ្ធសាស្ត្របញ្ចកោណនៃរាជរដ្ឋាភិបាលថ្មីអាណត្តិទី៧ ត្រង់បញ្ចកោណទី១ អភិវឌ្ឍមូលធនមនុស្ស ដោយផ្តោតការយកចិត្តទុកដាក់ទៅលើអាទិភាពសំខាន់ៗចំនួន ៥ រួមមាន៖ ការពង្រឹងគុណភាពវិស័យអប់រំ កីឡា វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា និងការពង្រឹងភាពជាពលរដ្ឋក្នុងសង្គមដែលមានអារ្យធម៌ខ្ពស់ ប្រកបដោយសីលធម៌ សមធម៌ និងបរិយាបន្នជាដើម។[៣] ត្រង់មុំទី១ផ្តោតទៅលើចំណុចអាទិ-ភាព៧ផ្សេងក្នុងនោះមាន (១) ការបន្តពង្រឹងគុណភាពអប់រំនិងការបណ្តុះបណ្តាលគ្រប់កម្រិត ការធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សា (២) ការបន្តកែទម្រង់សាលារៀន (៣) ការពង្រឹងគុណភាពនៃការបណ្តុះបណ្តាលគ្រូបង្រៀននិងវិធីសាស្ត្របង្រៀន (៤)ការបន្តលើកកម្ពស់ការអប់រំឌីជីថល (៥) ការលើកកម្ពស់សុខភាពសិក្សានិងអាហារូបករណ៍ (៦) ការពង្រឹងអភិបាលកិច្ចគ្រឹះស្ថានឧត្តមសិក្សា ការលើកកម្ពស់ការស្រាវជ្រាវ ការអភិវឌ្ឍនិងនវានុវត្ត (៧) ការលើកកម្ពស់វិស័យកីឡាផ្សារភ្ជាប់នឹងការអប់រំជាដើម។[៤] ទាំងនេះគឺជាវិស័យអាទិភាពដ៏សំខាន់ដែលក្រសួង ស្ថាប័ន ធ្វើការងារពាក់ព័ន្ធទៅនឹងវិស័យអប់រំទាំងសាធារណៈនិងឯកជន គប្បីចូលរួមយ៉ាងសកម្មក្នុងការអនុវត្តផែនការយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ប្រកបដោយការទទួលខុសត្រូវនិងប្រសិទ្ធភាពខ្ពស់ដើម្បីឈានទៅសម្រេចចក្ខុវិស័យរបស់រាជរដ្ឋាភិបាលនៅឆ្នាំ២០៥០។ រាជរដ្ឋាភិបាលបានយកចិត្តទុកយ៉ាងខ្លាំង បានអនុមតិលើផែនការថវិកា ដើម្បីគាំទ្រដល់ដំណើរការអប់រំបណ្តុះបណ្តាលនិងការអភិវឌ្ឍធនធានមនុស្សទៅតាមតួនាទី ភារកិច្ចរបស់ក្រសួងសាមីនីមួយៗ ដែលមានសមត្ថ-កិច្ច ក្នុងនោះដែរក្រសួងអប់រំ យុវជន និងកីឡា ដែលជាវិស័យអាទិភាពទី១ ត្រូវបានផ្តោតការយកចិត្តទុកដាក់ខ្ពស់និងផ្តល់ការគាំទ្រយ៉ាងច្រើន។[៥]

---

[១] Global Education monitoring report in 2023 P. VII.

[២] Global Education monitoring report in 2023 P.14.

[៣] យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ទំ.៣២។

[៤] យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ទំ.៥១-៥២។

[៥] ថវិកាសង្ខេបឆ្នាំ២០២៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទំ.៣៣-៣៥។

យ៉ាងណាក៏ដោយ ការលើកឡើងអំពីគម្រោងនៃការចំណាយថវិកាលើវិស័យអប់រំនេះ បង្ហាញឱ្យឃើញពីការបង្កើនការយកចិត្តទុកដាក់បន្ថែមទៀតរបស់រាជរដ្ឋាភិបាល ទៅលើវិស័យអប់រំកម្ពុជា ដើម្បីពង្រឹងបន្ថែមចំពោះការអភិវឌ្ឍមូលធនមនុស្សប្រកបដោយចក្ខុវិស័យច្បាស់លាស់។ ក្នុងនោះដែរ ក្រសួងអប់រំ យុវជន និងកីឡាបានដាក់ចេញឱ្យអនុវត្តស្តង់ដាសាលារៀនគំរូ ដើម្បីពង្រឹងគុណភាពអប់រំ ស្តង់ដានេះចាំបាច់ត្រូវចាប់ផ្តើមពីថ្នាក់មត្តេយ្យសិក្សារហូតដល់មធ្យមសិក្សាដោយផ្តោតទៅលើស្តង់ដាចំនួន ៥ ចំណុចរួមមាន៖ លទ្ធផលសិក្សារបស់សិស្ស ការបង្រៀន និងរៀន ការចូលរួមរបស់សហគមន៍ ដំណើរប្រតិបត្តិការនិងរដ្ឋបាលសាលារៀន និងចុងក្រោយផ្តោតលើគណនេយ្យភាពរបស់សាលារៀន។ ដើម្បីធ្វើឱ្យការអនុវត្តគោលដៅស្តង់ដាគំរូប្រកបដោយប្រសិទ្ធភាពខ្ពស់ សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានផ្តល់អនុសាសន៍មួយចំនួនរួមមាន៖ *ការពង្រឹងអភិបាលកិច្ចសាលារៀន ការពិនិត្យកែសម្រួលនិងរៀបចំកម្មវិធីសិក្សា និងសកម្មភាពក្រៅម៉ោងសិក្សាឱ្យស្របទៅតាមតម្រូវការក្នុងការពង្រឹងចំណេះដឹងរបស់សិស្ស*។[៦]ជាងនេះទៅទៀតឯកឧត្តមបណ្ឌិតសភាចារ្យ**ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានបញ្ជាក់បន្ថែមអំពីការពង្រឹងប្រសិទ្ធភាពវិស័យអប់រំនៅកម្ពុជា ដែលមានភាពរឹងមាំទៅបានដោយអាស្រ័យទៅលើ ភាគីសំខាន់ៗ ចំនួន **៤** គឺ សាលារៀនល្អ គ្រូបង្រៀនមានសមត្ថភាព សិស្សខិតខំរៀនសូត្រ និងអាណាព្យាបាលចូលរួមសហការ។ មិនត្រឹមតែប៉ុណ្ណោះឯកឧត្តមរដ្ឋមន្ត្រីបានរំឭកផងដែរថា កន្លងមកក្រសួងអប់រំ យុវជន និងកីឡា បានធ្វើកំណែទម្រង់ជាបន្តបន្ទាប់ចាប់តាំងពីឆ្នាំ២០១៣ កន្លងមក ក្នុងនោះមាន៖(ទី១)កំណែទម្រង់ការប្រឡងសម្រាប់សិស្សថ្នាក់ទី១២ (ទី២) ការពិនិត្យឡើងវិញទៅលើកម្មវិធីសិក្សារបស់សិស្សគ្រប់កម្រិត (ទី៣) ការធ្វើអធិការកិច្ចតាមសាលារៀន ដោយផ្តោតលើគុណភាពអប់រំ សំណង់អគារ កិច្ចការសាលា (ទី៤) ការធ្វើវង្វាយតម្លៃការសិក្សារបស់សិស្ស (ទី៥) កំណែទម្រង់ថ្នាក់ឧត្តមសិក្សា(ទី៦) ការពង្រឹងជំនាញរបស់យុវជនជាដើម។[៧] ទាំងនេះគឺជាចំណុចលេចធ្លោដែលក្រសួងអប់រំយុវជន និងកីឡា បានខិតខំប្រឹងប្រែងក្នុងការអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព ដើម្បីជាប្រយោជន៍ដល់ការអភិវឌ្ឍសង្គម និងប្រទេសជាតិទាំងមូល។

លើសពីនេះទៅទៀតរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដែលដឹកនាំដោយសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** ជានាយករដ្ឋមន្ត្រី បានកំណត់ទិសដៅប្រែក្លាយគ្រឹះស្ថានសិក្សារដ្ឋពី **៥០០** ទៅ **១,០០០** សាលា ឱ្យក្លាយទៅជាសាលារៀនគំរូនៅទូទាំងប្រទេស។ សម្តេចធិបតីបានបញ្ជាក់ថា សាលារៀនគំរូ គឺសាលារៀនដែលមានដំណើរការពេញលេញរួមមាន៖ ទី១- សាលារៀន មានគណនេយ្យភាពជាមួយសហគមន៍ និងធ្វើការកែលម្អសាលារៀនស្របតាមស្តង់ដាសាលា

---

[៦] ភ្នំពេញប៉ុស្តិ៍ ចេញផ្សាយនៅថ្ងៃទី២ ខែមករាឆ្នាំ ២០២៤ តាមរយៈវេបសាយៈ https://m.postkhmer.com/national/2024-1-1-2037-257215

[៧] សារព័ត៌មានថ្មីៗ ចេញផ្សាយថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២២ តាមរយៈវេបសាយៈ https://thmeythmey.com/?page=detail&id=119010

រៀនគំរូ ដោយមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ ជាពិសេសមាតាបិតា ឬអាណាព្យាបាល តាមរយៈការបង្កើត និងដំណើរការគណៈកម្មការគ្រប់គ្រងសាលារៀន និងគណៈកម្មការគ្រប់គ្រងថ្នាក់រៀន។ ទី២- សាលារៀនមានស្វ័យភាពក្នុងការងារផែនការកែលម្អសាលារៀន និងថ្នាក់រៀន ព្រមទាំងការផ្តល់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ដល់គណៈគ្រប់គ្រងសាលារៀននិងគ្រូបង្រៀន។ ទី៣- សាលារៀនអនុវត្តតេស្តស្តង់ដាជាប្រចាំ និងប្រើប្រាស់លទ្ធផលនៃតេស្តស្តង់ដា ដើម្បីធ្វើការកែលម្អការបង្រៀន និងរៀន ការជួយដល់សិស្សដែលរៀនយឺត និងផ្តល់ព័ត៌មានដល់មាតាបិតា ឬអាណាព្យាបាល និងសហគមន៍ឱ្យចូលរួមគាំទ្របន្ថែម។ ទី៤- សាលារៀនមានស្វ័យភាពក្នុងការអនុវត្តកម្មវិធីសិក្សា និងការរៀបចំកម្មវិធីក្រៅម៉ោងសិក្សាដោយផ្តោតលើកម្មវិធីអភិវឌ្ឍន៍យុវជន កម្មវិធីអប់រំច្បាប់ចរាចរណ៍ ការងារស្ម័គ្រចិត្ត ការងារសហគមន៍ និងការអប់រំសីលធម៌។ ទី៥៖ សាលារៀនយកចិត្តទុកដាក់លើការអប់រំសុខភាព អនាម័យ បរិស្ថានស្អាត សាលារៀនគ្មានសំរាម និងគិតគូរដល់អាហារូបត្ថម្ភដល់សិស្សានុសិស្ស និង ទី៦- ការជំរុញការចូលរួមរបស់មាតាបិតា ឬអាណាព្យាបាល និងសហគមន៍ ក្នុងការគាំទ្រ និងការអភិវឌ្ឍសាលារៀន។[៨]

ដោយឡែក ក្រសួងធម្មការនិងសាសនា គឺជាស្ថាប័នមួយដែលមានអគ្គនាយកដ្ឋានអប់រំ ដ៏មានសក្តានុពល ធ្វើការងារយ៉ាងសកម្ម ដើម្បីរួមចំណែកអភិវឌ្ឍមូលធនមនុស្សឱ្យស្របទៅតាមផែនការយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា។ ក្រសួងធម្មការនិងសាសនាមានកម្មវិធីមួយគឺ *“សុខដុមនីយកម្មសាសនានៅកម្ពុជា”* ដែលមានអនុកម្មវិធីចំនួន៤ ដើម្បីគាំទ្រឱ្យសម្រេចបាននូវគោលដៅកម្មវិធី ក្នុងនោះដែរ អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ ជាអគ្គនាយកដ្ឋានដ៏សំខាន់ធ្វើការងារផ្តោតទៅលើការអប់រំជាចម្បងស្ថិតនៅក្នុងអនុកម្មវិធីទី១ *ការអប់រំវិស័យពុទ្ធិកសិក្សា*។

ក្នុងចំណោមអនុកម្មវិធីទាំង ៤ នេះ អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ គឺជាអង្គភាពមួយដែលធ្វើការងារសម្របសម្រួល និងអភិវឌ្ឍលើវិស័យអប់រំពុទ្ធិកសិក្សា ដែលត្រូវបានគេស្គាល់ជាទូទៅថា ជាវិស័យអប់រំមួយ សម្រាប់តែព្រះសង្ឃសិក្សាប៉ុណ្ណោះ។ ថ្វីដ្បិតតែ វិស័យអប់រំមួយនេះ មិនត្រូវបានគេស្គាល់យ៉ាងទូលំទូលាយក៏ពិតមែន ប៉ុន្តែវិស័យអប់រំពុទ្ធិកសិក្សាបានរួមចំណែកយ៉ាងច្រើនក្នុងការបណ្តុះបណ្តាល និងអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព សមត្ថភាព និងសីលធម៌ ព្រមទាំងក្លាយជាបុគ្គលដ៏មានឥទ្ធិពលនៅក្នុងសង្គមផងដែរ។ កត្តាដ៏សំខាន់ទាំងនេះហើយដែលរាជរដ្ឋាភិបាលកម្ពុជាតែងយកចិត្តទុកដាក់និងលើកទឹកចិត្តដល់មន្ត្រីសង្ឃ មន្ត្រីរាជការកំពុងបំពេញការងារក្នុងវិស័យនេះឱ្យខិតខំប្រឹងប្រែងបន្ថែមទៀត។

បច្ចុប្បន្ន ក្រសួងធម្មការនិងសាសនាដែលដឹកនាំដោយឯកឧត្តម **ចាយ បូរិន** ជារដ្ឋមន្ត្រី បានយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើដំណើរការអប់រំរបស់ពុទ្ធិកសិក្សា ធ្វើយ៉ាងណាឱ្យការបណ្តុះ

[៨] សេចក្តីប្រកាសព័ត៌មានលេខ:០០៧/២៣ ប្រ.ក.អ.អ.រ នៃទីស្តីការគណៈរដ្ឋមន្ត្រីចុះថ្ងៃទី ១ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីលទ្ធផលសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី។

បណ្តាលរបស់វិស័យពុទ្ធិកសិក្សា មានគុណភាព និងសមត្ថភាពដែលអាចប្រកួតប្រជែងជាមួយនឹងវិស័យដទៃទៀតបាន។ មិនត្រឹមតែប៉ុណ្ណោះ ឯកឧត្តមបានបញ្ជាក់ថា វិស័យពុទ្ធិកសិក្សាគឺជាប្រព័ន្ធអប់រំមួយដ៏សំខាន់ ដែលមានរចនាសម្ពន្ធច្បាស់លាស់ ធ្វើការបណ្តុះបណ្តាលចាប់ពីកម្រិតពុទ្ធិកបឋមសិក្សារហូតដល់ពុទ្ធិកឧត្តមសិក្សា និងក្រោយពុទ្ធិកឧត្តមសិក្សា ហើយការបណ្តុះបណ្តាលនេះទៀតសោតមិនមែនសម្រាប់តែព្រះសង្ឃប៉ុណ្ណោះទេ បច្ចុប្បន្ន សូម្បីសិស្សានុសិស្សដែលជាគ្រហស្ថក៏អាចចូលរៀនក្នុងវិស័យពុទ្ធិកសិក្សាបានដែរ។ សម្រាប់ឆ្នាំសិក្សា២០២៣-២០២៤ វិស័យពុទ្ធិកសិក្សាមានការកែទម្រង់ជាច្រើន កំណែទម្រង់នេះ ចាប់ផ្តើមចេញពីការរៀបចំប្រឡងនានាមានការប្រឡងវិញ្ញាបនបត្រធម្មវិន័យការប្រឡងវិញ្ញាបនបត្រពុទ្ធិកបឋមសិក្សា រហូតដល់កម្រិតពុទ្ធិកឧត្តមសិក្សាជាដើម។ សម្តេចព្រះពោធិវង្ស កិត្តិបណ្ឌិត **អំ លីមហេង** ព្រះអគ្គាធិការនៃអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិមានថេរដីកាថា"*គ្រហស្ថដាំស្រូវចង់បានគ្រាប់ស្រូវមិនមែនចង់បានចំបើងទេ*" ចំណែកឯ "*ការសិក្សាត្រូវការចំណេះដឹង និងគុណវុឌ្ឍិពិតប្រាកដ*" ដូច្នេះ ចំពោះការប្រឡងទាំងអស់របស់វិស័យពុទ្ធិកសិក្សាយើងផ្តោតយក"*គុណភាពប្រសើរជាងបរិមាណ*" ហេតុនេះហើយ បេក្ខសមណៈ បេក្ខជនទាំងអស់ចាំបាច់ត្រូវខិតខំប្រឹងប្រែងឱ្យអស់ពីសមត្ថភាព។[៩] ការយកចិត្តទុកដាក់របស់ថ្នាក់ដឹកនាំក្រសួងធម្មការនិងសាសនានិងកម្រិតអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិក្នុងការពង្រឹងគុណភាពអប់រំពុទ្ធិកសិក្សាឱ្យកាន់តែមានភាពល្អប្រសើរឡើង ទទួលបានការសាទរជាច្រើនពីមហាជនទូទៅ ក៏ដូចជាសមណសិស្ស សិស្ស សមណនិស្សិត និស្សិតផងដែរ។ មិនត្រឹមតែប៉ុណ្ណោះ មានការបង្ហាញនូវការសាទរ ដោយបានបញ្ចេញមតិនៅក្នុងបណ្តាញសង្គម ដែលមានខ្លឹមសារផ្សេងៗជាច្រើនទៀត។

នៅក្នុងដំណើរវិវឌ្ឍនៃសកលភាវូបនីយកម្មនេះ ក្នុងនាមអង្គភាពអប់រំ ចាំបាច់ត្រូវតែសិក្សាស្វែងយល់ និងត្រួតពិនិត្យបន្ថែមទៅលើនីតិវិធីថ្មីៗជាច្រើន ដែលអាចជំរុញដល់ការអភិវឌ្ឍលើវិស័យអប់រំឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់បន្ថែមទៀត ឱ្យស្របទៅនឹងភាពរីកចម្រើននៃពិភពលោកនាពេលបច្ចុប្បន្ន។ ដើម្បីអាចឆ្លើយតបទៅនឹងការអភិវឌ្ឍនៃប្រព័ន្ធឌីជីថលនេះបាន អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិបាននិងកំពុងពង្រឹងស្ថាប័នរបស់ខ្លួនឱ្យកាន់តែរឹងមាំបន្ថែមទៀត តាមរយៈការបង្កើតផែនការយុទ្ធសាស្ត្រនិងទិសដៅអភិវឌ្ឍ ដើម្បីលើកកម្ពស់គុណវុឌ្ឍិ និងសមត្ថភាពមន្ត្រីសង្ឃ មន្ត្រីរាជការព្រមទាំងពង្រឹងគុណភាពអប់រំពុទ្ធិកសិក្សាឱ្យកាន់តែមានភាពល្អប្រសើរបន្ថែមទៀត។

ដូច្នេះ វិស័យអប់រំកម្ពុជានាពេលបច្ចុប្បន្ន ទាំងផ្នែកពុទ្ធចក្រនិងអាណាចក្រកំពុងមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ បើទោះបីជាវិស័យពុទ្ធិកសិក្សាមានការវិវឌ្ឍយឺតយ៉ាវបន្តិចក៏ពិតមែន ប៉ុន្តែយ៉ាងហោចណាស់ក៏មានដំណើរឆ្ពោះទៅមុខជានិច្ចផងដែរ។ នេះគឺជាសក្ខីកម្មដែលមិនអាចមើលរំលង នៅក្នុងដំណើរការអនុវត្តផែនការយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី៧ នៃរដ្ឋសភា ឆ្ពោះទៅរកការអភិវឌ្ឍមូលធនមនុស្សប្រកបដោយគុណភាព ប្រសិទ្ធភាព និងប្រសិទ្ធផល។

[៩] ចេញផ្សាយថ្ងៃទី២០ ខែមករា ឆ្នាំ២០២៤ តាមរយៈទំព័រហ្វេកប៊ុកផ្លូវការរបស់អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ តំណភ្ជាប់: https://www.facebook.com/ginbec.gov.kh

## ២- ខឿ្លនភាព

សកម្មភាពអប់រំរបស់វិស័យពុទ្ធិកសិក្សា បានបន្តដំណើរសន្សឹមៗ ក្នុងការពង្រីកនិងពង្រឹងគុណភាពអប់រំឱ្យកាន់តែមានភាពប្រសើរឡើង ដើម្បីលើកស្ទួយព្រះពុទ្ធសាសនាកម្ពុជាឱ្យមានការរីកចម្រើន បណ្តុះនូវមូលធនព្រះសង្ឃ និងមូលធនមនុស្សទូទៅឱ្យមានសក្តានុពលពេញលេញក្នុងការរួមចំណែកអភិវឌ្ឍប្រទេសជាតិឱ្យមានភាពរីកចម្រើនប្រកបដោយនិរន្តរភាព។ វិស័យអប់រំពុទ្ធិកសិក្សាបានបើកចំហ ផ្តល់ឱកាសឱ្យកុលបុត្រពុទ្ធសាសនិកខ្មែរទូទៅទទួលបានការអប់រំប្រកបដោយគុណភាព សមត្ថភាព សមភាព សមធម៌និងសីលធម៌ ព្រមទាំងជាថ្នាលបណ្តុះបណ្តាលដែលមិនប្រកាន់រើសអើង វណ្ណៈ សាសនា និងពណ៌សម្បុរឡើយ។

កិច្ចដំណើរការបណ្តុះបណ្តាលរបស់វិស័យពុទ្ធិកសិក្សា បានពង្រីកខ្លួនជាលំដាប់ ចាប់តាំងពីវិស័យមួយនេះ មានវត្តមានឡើងវិញ ក្រោយពីរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានផ្តួលរលំនៅឆ្នាំ ១៩៧៩ ហើយវិស័យអប់រំពុទ្ធិកសិក្សាក៏ទទួលបានឱកាសចាប់ផ្តើមដំណើរការឡើងវិញនៅឆ្នាំ ១៩៨៩ ផងដែរ។ ទាំងនេះ គឺជាការយកចិត្តទុកដ៏សំខាន់របស់ប្រមុខរាជរដ្ឋាភិបាលនិងមន្ត្រីសង្ឃជាន់ខ្ពស់ នៃព្រះរាជាណាចក្រកម្ពុជា ដែលបានខិតខំប្រឹងប្រែងអភិវឌ្ឍធនធានមនុស្ស ជាពិសេសធនធានព្រះសង្ឃដើម្បីរក្សា ផ្សព្វផ្សាយ និងអភិវឌ្ឍព្រះពុទ្ធសាសនាកម្ពុជាឱ្យមានការរីកចម្រើនរហូតមកដល់បច្ចុប្បន្ន។

នៅក្នុងកិច្ចដំណើរការ អស់រយៈកាលជាច្រើនឆ្នាំកន្លងមកនេះ វិស័យអប់រំពុទ្ធិកសិក្សា បានរួមចំណែកយ៉ាងច្រើន ក្នុងការអភិវឌ្ឍធនធានមនុស្សដែលបាត់បង់ឱកាសបន្តការសិក្សាឱ្យក្លាយទៅជាធម្មកោវិទ បណ្ឌិត បញ្ញវន្តដ៏មានសក្តានុពលក្នុងការដឹកនាំមនុស្សនៅក្នុងសង្គមឱ្យប្រព្រឹត្តនូវអំពើល្អផ្សេងៗ គេចផុតពីអំពើអបាយមុខទាំងឡាយ មានស្រី ស្រា ល្បែងជាដើម។ មិនត្រឹមតែប៉ុណ្ណោះ ជាបុគ្គលគំរូសម្រាប់សង្គម ដែលបានបណ្តុះស្មារតី និងឆន្ទៈ មនសិការឱ្យមនុស្សចេះស្រឡាញ់រាប់អានគ្នា ចេះជួយយកអាសាគ្នានៅពេលមានអាសន្នអន់ក្រ និងមានសាមគ្គីភាពនៅក្នុងសង្គម ធ្វើឱ្យសង្គមនិងប្រទេសជាតិកាន់តែមានភាពរឹងមាំ ព្រមទាំងរីកចម្រើនជាលំដាប់។

សមិទ្ធផលដែលទទួលបានទាំងនេះគឺជាការរៀបចំ និងការដាក់ចេញនូវផែនការអភិវឌ្ឍប្រកបដោយទស្សនវិស័យវែងឆ្ងាយរបស់ថ្នាក់ដឹកនាំតាមឋានានុក្រម ដើម្បីបុព្វហេតុនៃការអភិរក្សនិងអភិវឌ្ឍប្រទេសជាតិ និងព្រះពុទ្ធសាសនាប្រកបដោយនិរន្តរភាព។

## ២.១- រចនាសម្ពន្ធគ្រប់គ្រង

ការអប់រំវិស័យពុទ្ធិកសិក្សា អាចដំណើរការបណ្តុះបណ្តាលប្រកបដោយប្រសិទ្ធភាពទៅបានដោយអាស្រ័យទៅលើការចាត់ចែងនិងការរៀបចំរបស់ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ បានគិតគូរ និងបង្កើតឱ្យមានរចនាសម្ពន្ធគ្រប់គ្រងច្បាស់លាស់ ដើម្បីធ្វើការសម្របសម្រួលការងារពុទ្ធិកសិក្សា ចាប់តាំងពីកម្រិតពុទ្ធិកបឋមសិក្សា ដល់កម្រិតពុទ្ធិកឧត្តមសិក្សានិងក្រោយពុទ្ធិកឧត្តម

សិក្សា។[១០] ដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការគ្រប់គ្រង ដឹកនាំ សម្របសម្រួល និងអភិវឌ្ឍវិស័យពុទ្ធិកសិក្សាប្រកបដោយចីរភាព ឆ្ពោះទៅរកការអភិវឌ្ឍមូលធនមនុស្ស ដើម្បីឆ្លើយតបទៅនឹងតម្រូវការចាំបាច់នៃការអនុវត្តផែនការយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលកម្ពុជា។ មន្ត្រីសង្ឃនិងមន្ត្រីរាជការកំពុងបំពេញការងារនៅក្នុងអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិសរុបមានចំនួន **១១២** រូប ក្នុងនោះមន្ត្រីសង្ឃមានចំនួន **៤៩** រូប និងមន្ត្រីរាជការចំនួន **៦៣** នាក់ (ស្ត្រី**០៧**នាក់)។ ចំពោះមន្ត្រីសង្ឃទាំង **៤៩** រូប ត្រូវបានបែងចែកជា **២** ប្រភេទ គឺមន្ត្រីសង្ឃដែលមានក្របខណ្ឌ និងមន្ត្រីសង្ឃដែលមានមុខតំណែងតែគ្មានក្របខណ្ឌ។ មន្ត្រីសង្ឃ និងមន្ត្រីរាជការនៃអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិទាំងអស់កំពុងបំពេញមុខតំណែងដូចខាងក្រោម៖

- សម្តេចព្រះអធិបតីកិត្តិយស **០១** អង្គ[១១]
- សម្តេចព្រះអគ្គាធិការ **០១** អង្គ[១២]
- ព្រះអគ្គាធិការរង **១០** អង្គ
- ប្រធានផ្នែក **០៤** អង្គ/នាក់
- អនុប្រធានផ្នែក **១៣** អង្គ/នាក់
- ប្រធានការិយាល័យ **១០** អង្គ/នាក់
- អនុប្រធានការិយាល័យ **២៧** អង្គ/នាក់
- នាយករង **០៤** អង្គ/នាក់
- គ្រូបង្រៀន **២៣** អង្គ/នាក់
- មន្ត្រី **១៩** អង្គ/នាក់

ចំពោះ មន្ត្រីសង្ឃដែលទទួលបច្ច័យនិច្ចភត្ត កំពុងបំពេញការងារនៅក្នុងវិស័យពុទ្ធិកសិក្សាទាំងថ្នាក់កណ្តាល ពុទ្ធិកសាកលវិទ្យាល័យ និងនៅតាមបណ្តារាជធានី ខេត្តសរុបមានចំនួន **៣៥២** អង្គ។[១៣]

ដើម្បីធ្វើការងារលើវិស័យអប់រំឱ្យកាន់តែមានលក្ខណៈល្អប្រសើរ បន្ថែមទៀត អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ នាពេលបច្ចុប្បន្នមានផ្នែកជំនាញសំខាន់ៗ ចំនួន **៥** ក្នុងការដឹកនាំការងារជំនាញរៀងៗខ្លួន ដោយផ្តោតទៅលើកម្រិតនៃការបណ្តុះបណ្តាល ចាប់ពីកម្រិតពុទ្ធិកបឋមសិក្សា

---

[១០] មាត្រា ៧ នៃអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីការបង្កើតអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ នៃព្រះរាជាណាចក្រកម្ពុជា។

[១១] ព្រះរាជក្រឹត្យលេខ នស/រកត/០១២៤/១២៩ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៤ មាត្រា១ តែងតាំងមុខតំណែង សម្តេចព្រះមហាសុមធាធិបតីកិត្តិឧទ្ទេសបណ្ឌិត **នន្ទ ង៉ែត** ជាព្រះអធិបតីកិត្តិយស នៃអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ។

[១២] ព្រះរាជក្រឹត្យលេខ នស/រកត/០១២៤/១៣០ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៤ មាត្រា១ តែងតាំងមុខតំណែង សម្តេចព្រះពោធិវង្សកិត្តិបណ្ឌិត **អំ លីមហេង** ជាព្រះអគ្គាធិការ នៃអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ។

[១៣] ប្រកាសលេខ ៧៩/២៣ ក.ធ.ស.ប្រក ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពី ការបែងចែកចំនួនព្រះមន្ត្រីសង្ឃ គ្រូពុទ្ធិកសិក្សា និងគណៈគ្រប់គ្រងសាលានៅអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ និងមន្ទីរធម្មការ និងសាសនារាជធានី ខេត្ត។

របៀតដល់កម្រិតពុទ្ធិកឧត្តមសិក្សា ព្រមទាំងការងារសម្របសម្រួលលើសេវាកម្មអប់រំផ្សេងៗមានពង្រឹងគុណភាពអប់រំ ការអភិវឌ្ឍកម្មវិធីសិក្សា ការរៀបចំផែនការចំណាយថវិកាលើការងារអប់រំរបស់វិស័យពុទ្ធិកសិក្សាទាំងមូលជាដើម។ ចំពោះផ្នែកជំនាញដែលបានបញ្ជាក់ខាងដើមនោះរួមមាន៖ ផ្នែកពុទ្ធិកបឋមសិក្សានិងធម្មវិន័យ ផ្នែកពុទ្ធិកមធ្យមសិក្សា ផ្នែកពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ផ្នែកពុទ្ធិកឧត្តមសិក្សានិងក្រោយពុទ្ធិកឧត្តមសិក្សា និងផ្នែករដ្ឋបាលនិងគណនេយ្យ។




ផ្នែក និងការិយាល័យជំនាញដែលបានបង្ហាញខាងលើ បាននិងកំពុងបំពេញការងាររបស់ខ្លួនយ៉ាងសកម្ម ដើម្បីទ្រទ្រង់ គ្រប់គ្រង និងសម្របសម្រួលការងារពុទ្ធិកសិក្សាឱ្យមានដំណើរការល្អឈានទៅរកការអភិវឌ្ឍប្រកបដោយចីរភាព។ ផ្នែកជំនាញទាំងអស់ គឺជាសេនាធិការដ៏សំខាន់ដែលមិនអាចខ្វះបាន ក្នុងការជំរុញយន្តការការងារពុទ្ធិកសិក្សាឱ្យមានភាពរស់រវើកនិងមានភាពច្នៃប្រឌិតដើម្បីរួមចំណែកក្នុងការអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព សមត្ថភាព និងសីលធម៌ដែលជាធនធានចាំបាច់ ក្នុងការអប់រំបណ្តុះបណ្តាលបច្ឆាជនជំនាន់ក្រោយឱ្យមានការគោរពប្រតិបត្តិទៅតាមចំណេះដឹង ជំនាញនិងអភិសមាចារ ដែលខ្លួនទទួលបាន ក្នុងការប្រកបរបរចិញ្ចឹមជីវិត ក៏ដូចជាការរស់នៅប្រកបដោយភាពសុខដុមរមនានៅក្នុងសង្គម។

អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ បានឈរលើគោលការអប់រំ ស្របទៅតាមគោលនយោបាយអភិវឌ្ឍជាតិ នៃក្រសួងធម្មការនិងសាសនាស្តីពី *"ការលើកកម្ពស់សាសនារបស់រដ្ឋ តម្លៃសីលធម៌សង្គម និងសុខដុមនីយកម្មសាសនា"* ដែលជាគោលនយោបាយដ៏សំខាន់ តម្រូវឱ្យស្ថាប័នអប់រំពុទ្ធិកសិក្សាដ៏មានសក្តានុពលក្នុងការអនុវត្តឱ្យសម្រេចជោគជ័យទៅតាមអនុកម្មវិធីទី១ ដែលជាការទទួលខុសត្រូវរបស់ខ្លួនក្នុង *"ការពង្រឹងគុណភាព និងពង្រីកវិស័យពុទ្ធិកសិក្សា"* ឱ្យមានការរីកដុះដាលសមស្របទៅតាមការអភិវឌ្ឍនៃសកលភាវូបនីយកម្ម និងការវិវឌ្ឍនៃវិស័យឌីជីថល៤.០នាពេលបច្ចុប្បន្ន។

## ២.២-លទ្ធផលការងារឆ្នាំសិក្សា២០២៣-២០២៤

ភាពជោគជ័យនៃការអភិវឌ្ឍអប់រំវិស័យពុទ្ធិកសិក្សា គឺឆ្លុះបញ្ចាំងអំពីការយកចិត្តទុកដាក់របស់ថ្នាក់ដឹកនាំតាមឋានានុក្រម គណៈគ្រប់គ្រងសាលា ព្រះមេគណ ព្រះបាឡាត់គណ ព្រះអនុគណ និងមន្ទីរធម្មការនិងសាសនាតាមបណ្តារាជធានី ខេត្ត បានធ្វើឱ្យដំណើរការបណ្តុះបណ្តាលរបស់វិស័យពុទ្ធិកសិក្សាទទួលបានលទ្ធផលគាប់ប្រសើរសមគួរនិងអាចទទួលយកបាន។ មិនត្រឹមតែប៉ុណ្ណោះ ផ្នែកជំនាញទាំង ៥ ផ្នែកនៃអគ្គាធិការដ្ឋានពុទ្ធិកសិក្សាបានធ្វើការយ៉ាងយកចិត្តទុកដាក់ដើម្បីដឹកនាំ គ្រប់គ្រង សម្របសម្រួល និងផ្តល់សេវាគ្រប់បែបយ៉ាង ធ្វើយ៉ាងណាជំរុញឱ្យការបណ្តុះបណ្តាលរបស់វិស័យអប់រំពុទ្ធិកសិក្សាកាន់តែមានប្រសិទ្ធភាពខ្ពស់ និងទទួលបានការគាំទ្រពីប្រភពនានាទាំងក្នុងស្រុក និងអន្តរជាតិជាដើម។

ផ្នែកជំនាញនីមួយៗ នៃអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិបានធ្វើការទៅតាមជំនាញរបស់ខ្លួនប្រកបដោយការទទួលខុសត្រូវខ្ពស់ ដើម្បីបុព្វហេតុនៃការអភិវឌ្ឍសង្គមជាតិនិងព្រះពុទ្ធសាសនាខ្មែរឱ្យមានស្ថិរភាពជានិរន្តរ៍ផងដែរ។

### ២.២.១- ផ្នែកពុទ្ធិកបឋមសិក្សានិងធម្មវិន័យ

ការដឹកនាំ ការគ្រប់គ្រង ការសម្របសម្រួលនិងការផ្តល់សេវាលើការងារបច្ចេកទេស គឺជាគោលការណ៍ដ៏សំខាន់ ដើម្បីទ្រទ្រង់ដំណើរការបណ្តុះបណ្តាលកម្រិតពុទ្ធិកបឋមសិក្សានិងធម្មវិន័យប្រកបដោយប្រសិទ្ធភាពខ្ពស់ ក្នុងនោះដែរ ផ្នែកក៏បានសម្របសម្រួលលើការងាររដ្ឋបាលទូទៅដោយបានទទួលលិខិតចូលចំនួន **៣៧** ច្បាប់ ចេញលិខិតទៅកាន់អង្គភាពនិងស្ថាប័ននានាចំនួន **១៩** ច្បាប់ចូលរួមកិច្ចប្រជុំបច្ចេកទេសខាងក្រៅនិងក្នុងអង្គភាពចំនួន**៦៥** លើក ក្រសួងធម្មការនិងសាសនាក៏បានចេញប្រកាសអនុញ្ញាតឱ្យបើកសាលាពុទ្ធិកបឋមសិក្សាចំនួន **០៧** សាលា បានធ្វើវិញ្ញាបនបត្រពុទ្ធិកបឋមសិក្សាបណ្តោះអាសន្នចំនួន **៦០៩** សន្លឹក បានធ្វើវិញ្ញាបនបត្រធម្មវិន័យចំនួន **៨,០០៣** សន្លឹក សមណសិស្ស សិស្សបានដកវិញ្ញាបនបត្រពុទ្ធិកបឋមសិក្សាចំនួន **១៨៩** សន្លឹកនិងសមណសិស្ស សិស្សមកដកវិញ្ញាបនបត្របណ្តោះអាសន្នចំនួន **៣១៩** សន្លឹកផងដែរ។

ម្យ៉ាងទៀត ដើម្បីងាយស្រួលដល់ការត្រួតពិនិត្យ តាមដាននិងការវាយតម្លៃ ផ្នែកជំនាញបានរៀបចំចែកប្រគេន ជូនសៀវភៅសិក្ខាគារិកចំនួន **៨,៦៥៤** ក្បាលនិងសៀវភៅតាមដានការសិក្សាចំនួន **១១,៥៧៤** ក្បាលដល់បណ្តាសាលាពុទ្ធិកទាំងឡាយនៅតាមរាជធានី ខេត្ត ព្រមទាំងធ្វើការសម្រួលដល់ការសិក្សានិងជួយកាត់បន្ថយការចំណាយផ្សេងៗរបស់សមណសិស្ស សិស្ស ផ្នែកបានចែកប្រគេន ជូន សៀវភៅសិក្សាភាសាបាលី ពុទ្ធវិន័យ ពុទ្ធប្បវត្តិ និងពុទ្ធសាសនាសរុបចំនួន **២,២៦២** ក្បាលនិងសៀវភៅកម្មវិធីសិក្សាចំនួន **៩៩២** ក្បាល។ លើសពីនេះទៅទៀត ដើម្បីពិនិត្យអង្កេតឱ្យបានច្បាស់លាស់ អំពីដំណើរវិវឌ្ឍនៃការអប់រំកម្រិតពុទ្ធិកបឋមសិក្សានិងសាលា

ធម្មវិន័យប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាពនិងស្របតាមកម្មវិធីសិក្សា ផ្នែកជំនាញបានចុះធ្វើអធិការកិច្ចបច្ចេកទេសទៅកាន់បណ្តារាជធានី ខេត្តទៅតាមផែនការដែលបានដាក់ចេញផងដែរ។ ក្នុងនោះដែរ ផ្នែកក៏បានពិនិត្យឃើញថា សាលាពុទ្ធិកមួយចំនួន នៅពុំទាន់អាចអនុវត្តបានទាំងស្រុង ទៅតាមកម្មវិធីសិក្សាដែលចេញដោយអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិឡើយ ដោយសារមានកត្តាជាច្រើន ក្នុងនោះរួមមាន ការខ្វះខាតគ្រូទៅលើឯកទេសដែលតម្រូវដូចជាគណិតវិទ្យា ភាសាអង់គ្លេស ជាដើម។ ដើម្បីលើកកម្ពស់ដំណើរការបណ្តុះបណ្តាលឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់បន្ថែមទៀត ផ្នែកជំនាញបានរៀបចំវគ្គវិក្រឹតការគ្រូចំនួន ១ វគ្គដែលមានសិក្ខាកាមចូលរួមសរុបចំនួន **៨៥** រូប។ យ៉ាងណាក៏ដោយ គណៈគ្រប់គ្រងសាលា ព្រះគ្រូចៅអធិការវត្ត និងព្រះមេគណ ព្រះអនុគណ និងអ្នកពាក់ព័ន្ធទាំងអស់បានយកចិត្តទុកដាក់ខ្ពស់ក្នុងការពង្រឹងនិងពង្រីកការបណ្តុះបណ្តាល ឱ្យកាន់តែមានភាពប្រសើរឡើងបន្ថែមទៀត។

### ក-ពុទ្ធិកបឋមសិក្សា

ដំណើរការបណ្តុះបណ្តាលនៃពុទ្ធិកបឋមសិក្សាបានប្រព្រឹត្តទៅតាមនិយាមអប់រំ ដោយកំណត់យកបវេសនកាល ឬវិស្សមកាលតាមចន្ទគតិ ដែលជានិយាមមួយត្រូវបានអនុវត្តទៅតាមទំនៀមអប់រំរបស់វិស័យពុទ្ធិកសិក្សាតាំងពីអតីតរហូតមកដល់បច្ចុប្បន្ន។ កិច្ចដំណើរការនៃវិស័យអប់រំពុទ្ធិកសិក្សាកម្រិតបឋមសិក្សានេះ បាននិងកំពុងរីកលូតលាស់យ៉ាងសន្សឹមៗទៅតាមដំណើរវិវឌ្ឍនៃស្ថានភាពសង្គមនិងបច្ចេកវិទ្យាផងដែរ។ ជាលទ្ធផលកិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំតាមឋានានុក្រម បានធ្វើឱ្យសាលាពុទ្ធិកបឋមសិក្សាបន្តនិរន្តរភាពរបស់ខ្លួនក្នុងការបណ្តុះបណ្តាលនៅតាមបណ្តារាជធានី ខេត្តនៅទូទាំងប្រទេសដែលមានទិន្នន័យដូចខាងក្រោម៖

| ល.រ | រាជធានី-ខេត្ត | សមណសិស្ស សិស្ស | | | សរុប | | សាលា |
|---|---|---|---|---|---|---|---|
| | | ថ្នាក់ទី១ | ថ្នាក់ទី២ | ថ្នាក់ទី៣ | ថ្នាក់ | សិស្ស | |
| ១ | រាជធានីភ្នំពេញ | ១,០៥៥ | ៦០៦ | ៣៥៨ | **៩៥** | **២,០១៩** | **៥០** |
| ២ | កណ្តាល | ១,៤៥៨ | ៥៥៦ | ៤៩៩ | **១២៥** | **២,៥១៣** | **៧៥** |
| ៣ | បាត់ដំបង | ១,០៦៨ | ៣២៥ | ៣៧៨ | **៩៦** | **១,៧៧១** | **៥៨** |
| ៤ | សៀមរាប | ៧៤៨ | ៤៨៣ | ២៦៣ | **៧៩** | **១,៤៩៤** | **៥១** |
| ៥ | បន្ទាយមានជ័យ | ១,០៩៦ | ៥៦៦ | ២៨៦ | **១២៣** | **១,៩៤៨** | **៩៥** |
| ៦ | ពោធិ៍សាត់ | ៤៦៦ | ៥៧ | ១០២ | **៤៧** | **៦២៥** | **៣៩** |
| ៧ | ព្រៃវែង | ៧០៣ | ១៩៤ | ២៧៩ | **៨៤** | **១,១៧៦** | **៤៩** |
| ៨ | ស្វាយរៀង | ៥១៤ | ៣៣០ | ១៩១ | **៥៣** | **១,០៣៥** | **៣១** |
| ៩ | តាកែវ | ១,០៤៧ | ៦៥៣ | ២៧៩ | **១២៤** | **១,៩៧៩** | **៥៤** |
| ១០ | ត្បូងឃ្មុំ | ៣៩០ | ១៥៥ | ១៦៨ | **៣៨** | **៧១៣** | **២៣** |
| ១១ | កំពង់ចាម | ១,០៩៣ | ៥៦៨ | ៤៩២ | **១០១** | **២,១៥៣** | **៦៧** |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១២ | កំពង់ធំ | ១,២៨៨ | ៣៥៩ | ១១០ | **១៣៧** | **១,៧៥៧** | **៩៩** |
| ១៣ | កំពង់ឆ្នាំង | ១,០៣៣ | ១៨១ | ៩២ | **៩០** | **១,៣០៦** | **៨២** |
| ១៤ | កំពង់ស្ពឺ | ១,១១៧ | ៣០៤ | ២៧៩ | **១០០** | **១,៧០០** | **៦៩** |
| ១៥ | កំពត | ៣០២ | ១៩២ | ២១១ | **៣៩** | **៧០៥** | **២៦** |
| ១៦ | កោះកុង | ៦១ | ២២ | ០ | **៧** | **៨៣** | **៥** |
| ១៧ | ព្រះសីហនុ | ២៣៥ | ៨២ | ២៦ | **១៣** | **៣៤៣** | **១១** |
| ១៨ | ក្រចេះ | ៣១២ | ៩៣ | ៦៩ | **២១** | **៤៧៤** | **១៥** |
| ១៩ | ស្ទឹងត្រែង | ១១៥ | ៣៨ | ២០ | **១០** | **១៧៣** | **៩** |
| ២០ | ព្រះវិហារ | ២១៦ | ២២ | ៦៥ | **១៩** | **៣០៣** | **៩** |
| ២១ | ឧត្តរមានជ័យ | ១៤៧ | ១៩ | ១៨ | **១១** | **១៨៤** | **៩** |
| ២២ | មណ្ឌលគិរី | ៧៥ | ១៨ | ០ | **៤** | **៩៣** | **២** |
| ២៣ | រតនគិរី | ៧៤ | ៣៦ | ២០ | **៩** | **១៣០** | **៤** |
| ២៤ | ប៉ៃលិន | ១៧១ | ៣៣ | ៤៤ | **១៧** | **២៤៨** | **១៣** |
| ២៥ | កែប | ៧៩ | ២០ | ២១ | **៥** | **១២០** | **៥** |
| **សរុប** | | **១៤,៨៦៣** | **៥,៩១២** | **៤,២៧០** | **១,៤៤៧** | **២៥,០៤៥** | **៩៥០** |

ខាងលើនេះ គឺជាលទ្ធផលនៃកិច្ចសហការនិងការជំរុញលើកទឹកចិត្ត ព្រមទាំងជាការយកចិត្តទុកដាក់ខ្ពស់ របស់ថ្នាក់ដឹកនាំគ្រប់ឋានានុក្រមជាពិសេសសម្តេចព្រះអគ្គាធិការពុទ្ធិកសិក្សា និងឯកឧត្តមរដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា ព្រមទាំងមន្ត្រីសង្ឃ មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ដែលជាអ្នកមានកាតព្វកិច្ច ក្នុងការលើកកម្ពស់ការអភិវឌ្ឍវិស័យអប់រំពុទ្ធិកសិក្សាឱ្យមានភាពរីកចម្រើនប្រកបដោយចីរភាព។ ទាំងនេះគឺជាការរួមចំណែកដ៏សំខាន់ដែលវិស័យពុទ្ធិកសិក្សាបានកៀរគរសមណសិស្ស សិស្សដែលបាត់បង់ឱកាសទទួលបានការអប់រំប្រកបដោយភាពស្មើគ្នា ឱ្យមានឱកាសក្នុងការកសាងនិងអភិវឌ្ឍចំណេះដឹង សមត្ថភាព និងជំនាញរបស់ខ្លួនឡើងវិញបានដើម្បីអាចចូលរួមអភិវឌ្ឍប្រទេសជាតិនិងព្រះពុទ្ធសាសនា ប្រកបដោយទស្សនវិស័យវែងឆ្ងាយ ព្រមទាំងបានជាមូលធនមនុស្សដ៏មានសក្តានុពល ពោរពេញដោយសមត្ថភាពនិងជំនាញពិតប្រាកដក្នុងការដឹកនាំសម្របសម្រួលនិងចង្អុលផ្លូវដល់សមាជិកសង្គមដទៃទៀតឱ្យប្រព្រឹត្តសេចក្តីល្អ រក្សាបាននូវសន្តិសុខ និងសន្តិភាពយូរអង្វែងសម្រាប់ប្រទេសជាតិរបស់ខ្លួន។

ដូច្នេះ ដើម្បីងាយស្រួលដល់ការពិនិត្យ ការអង្កេត វិភាគ ពិចារណានិងការវាយតម្លៃប្រកបដោយតម្លាភាពនិងគណនេយ្យភាព គណៈកម្មការស្រាវជ្រាវនិងចងក្រងរបាយការណ៍ សូមធ្វើការប្រៀបធៀបទិន្នន័យដូចការបង្ហាញខាងក្រោម៖




យោងតាមទិន្នន័យដែលបានបង្ហាញខាងលើនេះសបញ្ជាក់ឱ្យឃើញថា ឆ្នាំសិក្សា២០២៣-២០២៤ សមណសិស្ស សិស្សនៅតាមបណ្តាសាលាពុទ្ធិកបឋមសិក្សាទាំងអស់មានការកើនឡើង ដូច្នេះបើយើងអង្កេតជារួម យើងពិនិត្យឃើញថា សមណសិស្ស សិស្សមានការកើនឡើង **២.៤០%** ចំពោះការកើនឡើងនៃសមណសិស្ស សិស្សនៅក្នុងវិស័យពុទ្ធិកសិក្សាមិនមានសន្ទុះខ្លាំងឡើយ ដោយសារមានកត្តារួមផ្សំជាច្រើនក្នុងនោះ កត្តានៃការចូលមកបួសរបស់កុលបុត្រពុទ្ធសាសនិក កត្តាសេដ្ឋកិច្ច និងភាពរីកចម្រើនផ្នែកបច្ចេកវិទ្យាជាដើម។ ព្រោះវិស័យពុទ្ធិកសិក្សាពឹងផ្អែកស្ទើរតែទាំងស្រុងលើអ្នកបួស ប្រសិនបើអ្នកបួសមានកំណើនតិចតួច ឬថយចុះនោះ ចំនួនសមណសិស្ស ក៏នឹងវិវត្តទៅតាមស្ថានភាពទាំងនោះដែរ។ ព្រោះការចូលមកសិក្សានៅក្នុងវិស័យពុទ្ធិកសិក្សាគឺជាការស្ម័គ្រចិត្ត មិនមែនជាកាតព្វកិច្ចឡើយ ម្យ៉ាងទៀត កុលបុត្រពុទ្ធសាសនិកដែលបានបួសនៅក្នុងព្រះពុទ្ធសាសនាហើយនោះ មិនប្រាកដថា បានចូលរៀននៅសាលាពុទ្ធិកនោះទេ ព្រោះអាស្រ័យទៅលើឆន្ទៈរបស់បុគ្គលខ្លួនឯងជាអ្នកសម្រេចចិត្តប៉ុណ្ណោះ កត្តាទាំងប៉ុន្មានដែលបានលើកឡើងខាងលើ គឺជាចំណុចដ៏សំខាន់ដែលនាំឱ្យវិស័យអប់រំពុទ្ធិកសិក្សាមានការរីកចម្រើនតិចតួចក្នុងមួយឆ្នាំៗ។

ដោយឡែក បើយើងប្រៀបទៅនឹងការបន្តការសិក្សារបស់សមណសិស្ស សិស្សពីឆ្នាំទី១ទៅឆ្នាំទី២ ពីឆ្នាំទី២ទៅឆ្នាំទី៣វិញនោះ យើងនឹងអាចមើលឃើញថា តើសមណសិស្ស សិស្សចំនួនប៉ុន្មានអង្គ/នាក់ដែលត្រូវបោះបង់ការសិក្សា? តើកត្តាអ្វីខ្លះដែលនាំឱ្យមានការបោះបង់បែបនេះ។ ដូច្នេះ ដើម្បីឱ្យមើលឃើញកាន់តែច្បាស់គណៈកម្មការស្រាវជ្រាវនិងចងក្រងរបាយការណ៍សូមធ្វើការប្រៀបធៀបដូចមានទិន្នន័យបង្ហាញខាងក្រោម៖




ទិន្នន័យនេះ សបញ្ជាក់ឱ្យឃើញពីស្ថានភាពនៃការបោះបង់ការសិក្សារបស់សមណសិស្ស សិស្សពីឆ្នាំទី១ មកឆ្នាំទី២ មានកម្រិតខ្ពស់រហូតដល់ទៅ **៦០%** សម្រាប់ពីឆ្នាំទី២ មកឆ្នាំទី៣ មានត្រឹមតែ **៣១%** ប៉ុណ្ណោះ។ ត្រង់ចំណុចដែលលើកមកបង្ហាញខាងលើនេះ គណៈកម្មការស្រាវជ្រាវនិងចងក្រងរបាយការណ៍ចង់បញ្ជាក់ថា សមណសិស្ស សិស្សដែលបោះបង់ការសិក្សាអាចបណ្ដាលមកពីកត្តាជាច្រើន រួមមានការលាចាកសិក្ខាបទជាដើម ព្រោះការបួស ឬការលាចាកសិក្ខាបទសម្រាប់ព្រះសង្ឃដែលបព្វជ្ជានៅក្នុងព្រះពុទ្ធសាសនានេះ មិនមានអ្នកណាអាចបង្ខំបានឡើយ ដោយអាស្រ័យទៅលើឧបនិស្ស័យរបស់បុគ្គលខ្លួនឯងផ្ទាល់ប៉ុណ្ណោះ។ ម្យ៉ាងទៀត ព្រះសង្ឃដែលបួសនៅក្នុងព្រះពុទ្ធសាសនា ភាគច្រើនមានវ័យច្រើន ហើយការសិក្សាភាសាបាលីមានការលំបាកព្រោះត្រូវការទន្ទេញចាំស្ទាត់រត់មាត់ ទើបងាយយល់ចូលចិត្តក្នុងការសិក្សារៀនសូត្រភាសាបាលី បើពុំនោះទេ ធ្វើឱ្យអ្នកសិក្សាមានការធុញទ្រាន់មិនចង់បន្តការសិក្សារបស់ខ្លួនទៅមុខទៀត។ លើសពីនេះទៅទៀត ការលើកទឹកចិត្តពីសំណាក់ព្រះគ្រូចៅអធិការវត្ត ឬលោកគ្រូ អ្នកគ្រូដែលបង្រៀនផ្ទាល់ក៏ជារឿងចាំបាច់ផងដែរ ព្រោះសម្រាប់អ្នករៀនភាសាបាលីជាទូទៅតែងធ្លាប់ឮចាស់ៗនិយាយតៗគ្នាថា "**មុននឹងអ្នកចេញទៅរៀនភាសាបាលី អ្នកត្រូវដាំដើមដូងទុកឱ្យហើយទៅ ដរាបណាដូងនោះមានផ្កាមានផ្លែ ទើបការសិក្សារបស់អ្នកទទួលបានផលដែរ**" ពាក្យទាំងនេះក៏ជាកត្តារួមផ្សំធ្វើឱ្យអ្នកសិក្សាបាក់ទឹកចិត្តមិនចង់បន្តការសិក្សាទៅមុខទៀតឡើយ។ មួយវិញទៀត ក្នុងចំណោមអ្នកបួស ហើយបានរៀនរហូតដល់ចប់ថ្នាក់ពុទ្ធិកមធ្យមសិក្សាទុតិយភូមិ ឬបន្តការសិក្សាដល់មហាវិទ្យាល័យនោះ មានមិនច្រើនប៉ុន្មានឡើយ ហេតុនេះហើយ អ្នកសិក្សាភាសាបាលីនៅទី

ជនបទដាច់ស្រយាលពុំសូវបានយល់ដឹងពីគុណតម្លៃនៃការសិក្សា មិនត្រឹមតែប៉ុណ្ណោះពុំបានយល់ច្បាស់ថា តើការសិក្សាភាសាបាលី ឬការសិក្សានៅក្នុងវិស័យពុទ្ធិកសិក្សាមានកម្មវិធីសិក្សាអ្វីខ្លះនោះឡើយ? កត្តាទាំងនេះជាចំណុចស្នូល ដែលធ្វើឱ្យសមណសិស្ស សិស្សបោះបង់ការសិក្សាពីឆ្នាំនីមួយៗមានកម្រិតខ្ពស់។

ពុទ្ធិកបឋមសិក្សាដែលអាចបំពេញតួនាទីក្នុងការបណ្តុះបណ្តាលសមណសិស្ស សិស្សប្រកបដោយប្រសិទ្ធភាពទៅបាន ដោយអាស្រ័យទៅលើការចូលរួមយ៉ាងសកម្មរបស់ព្រះអង្គគ្រូ លោកគ្រូ អ្នកគ្រូ និងភាគីពាក់ព័ន្ធដទៃជាច្រើនទៀត។ ចំពោះការប្រើប្រាស់ធនធានគ្រូបង្រៀននៅក្នុងវិស័យពុទ្ធិកបឋមសិក្សាត្រូវបានបែងចែងជា **៣** ប្រភេទគឺ គ្រូក្របខណ្ឌ គ្រូបង្រៀនជាប់កិច្ចសន្យា និងគ្រូជួលដែលមានទិន្នន័យបង្ហាញដូចខាងក្រោមៈ

| **ល.រ** | **រាជធានី-ខេត្ត** | **គ្រូ** | | | **សរុប** |
|---|---|---|---|---|---|
| | | **ក្របខណ្ឌ** | **កិច្ចសន្យា** | **ជួល** | |
| ១ | រាជធានីភ្នំពេញ | ១៩ | ១២៣ | ១៥៥ | **២៩៧** |
| ២ | កណ្តាល | ១៨ | ១២៥ | ១៧៣ | **៣១៦** |
| ៣ | បាត់ដំបង | ៩ | ៨៣ | ១២៩ | **២២១** |
| ៤ | សៀមរាប | ១៣ | ៧៨ | ០ | **៩១** |
| ៥ | បន្ទាយមានជ័យ | ៥ | ១១៩ | ៥៦ | **១៨០** |
| ៦ | ពោធិ៍សាត់ | ៥ | ៤៤ | ១១ | **៦០** |
| ៧ | ព្រៃវែង | ១៤ | ៦៣ | ៦ | **៨៣** |
| ៨ | ស្វាយរៀង | ៦ | ៥៤ | ០ | **៦០** |
| ៩ | តាកែវ | ១០ | ១០៣ | ៣៦ | **១៤៩** |
| ១០ | ត្បូងឃ្មុំ | ៧ | ៤៣ | ៣៦ | **៨៦** |
| ១១ | កំពង់ចាម | ១៥ | ១០៥ | ៤៥ | **១៦៥** |
| ១២ | កំពង់ធំ | ១១ | ១១៩ | ៥ | **១៣៥** |
| ១៣ | កំពង់ឆ្នាំង | ៦ | ៨៤ | ០ | **៩០** |
| ១៤ | កំពង់ស្ពឺ | ៩ | ៨០ | ៤០ | **១២៩** |
| ១៥ | កំពត | ៨ | ២៩ | ៣៤ | **៧១** |
| ១៦ | កោះកុង | ២ | ៨ | ១ | **១១** |
| ១៧ | ព្រះសីហនុ | ៤ | ១៣ | ០ | **១៧** |
| ១៨ | ក្រចេះ | ៧ | ១៤ | ៤ | **២៥** |
| ១៩ | ស្ទឹងត្រែង | ០ | ១៤ | ០ | **១៤** |
| ២០ | ព្រះវិហារ | ១ | ១៥ | ១ | **១៧** |

| | | | | | |
|---|---|---|---|---|---|
| ២១ | ឧត្ដរមានជ័យ | ២ | ១៣ | ១ | **១៦** |
| ២២ | មណ្ឌលគិរី | ១ | ៧ | ០ | **៨** |
| ២៣ | រតនគិរី | ០ | ៧ | ២ | **៩** |
| ២៤ | ប៉ៃលិន | ១ | ១៨ | ៦ | **២៥** |
| ២៥ | កែប | ០ | ៧ | ០ | **៧** |
| **សរុប** | | **១៧៣** | **១,៣៦៨** | **៧៤១** | **២,២៨២** |

សម្រាប់គ្រូបង្រៀនពុទ្ធិកបឋមសិក្សាទាំង ៣ ប្រភេទខាងលើនេះ ចំពោះគ្រូ ២ ប្រភេទ ទទួលបានការគាំទ្រពីរាជរដ្ឋាភិបាល ដែលតែងតែផ្ដល់ប្រគេន ជូនទៅតាមគោលការណ៍នៃផែនការអភិវឌ្ឍជាតិ។ ដោយឡែកសម្រាប់គ្រូជួល គឺជាកិច្ចខិតខំប្រឹងប្រែងរបស់គណៈគ្រប់គ្រងសាលាព្រះគ្រូចៅអធិការវត្ត និងពុទ្ធបរិស័ទចំណុះជើងវត្ត ព្រមទាំងពុទ្ធបរិស័ទដែលមកពីទីឋានផ្សេងៗ បានលះបង់ធនធានផ្ទាល់ខ្លួន ដើម្បីឧបត្ថម្ភគាំទ្រដល់ការជួលគ្រូ ក្នុងការបើកបណ្ដុះបណ្ដាលដល់សមណសិស្ស សិស្សក្នុងវិស័យពុទ្ធិកសិក្សា ធ្វើយ៉ាងណាឱ្យកុលបុត្រពុទ្ធសាសនិកដែលបានចូលមកសាងផ្នួសហើយ មានឱកាសទទួលបានការអប់រំដោយស្មើភាពគ្នា។ ដូច្នេះ វិស័យពុទ្ធិកសិក្សាដែលអាចបន្តនិរន្តរភាពរបស់ខ្លួនទៅបាន ដោយអាស្រ័យលើការចូលរួមយ៉ាងសកម្មពីសំណាក់ព្រះអង្គគ្រូ លោកគ្រូ និងអ្នកគ្រូ ទាំងគ្រូក្របខណ្ឌ គ្រូបង្រៀនជាប់កិច្ចសន្យា និងគ្រូជួល ដែលជាធនធានដ៏សំខាន់មិនអាចខ្វះបាន។

បច្ចុប្បន្ន ការប្រើប្រាស់គ្រូក្នុងវិស័យអប់រំពុទ្ធិកសិក្សាកម្រិតពុទ្ធិកបឋមសិក្សាមានតម្រូវការកើនឡើង ឬថយចុះទៅតាមស្ថានភាពជាក់ស្ដែងនៃចំនួនសមណសិស្ស សិស្ស នៅតាមសាលាពុទ្ធិកនីមួយៗដែលមានទិន្នន័យប្រៀបធៀបបង្ហាញដូចខាងក្រោម៖



ផ្អែកទៅលើទិន្នន័យដែលបានប្រៀបធៀបខាងលើនេះ បានបញ្ជាក់ថា គ្រូក្របខណ្ឌមានការថយចុះ **៤.៤២%** ការថយចុះនេះបណ្ដាលមកពីកត្តាពីរសំខាន់ ទី១ គ្រូបានធ្វើនិយ័តទៅជាមន្ត្រីទៅបម្រើការនៅតាមបណ្ដាមន្ទីរធម្មការនិងសាសនារាជធានី ខេត្ត និងកត្តាទី២ គ្រូមួយចំនួនគាត់ដល់វ័យចូលនិវត្តន៍។ កត្តាទាំងពីរនេះគឺជាមូលហេតុដ៏សំខាន់ដែលបណ្ដាលឱ្យចំនួនគ្រូក្របខណ្ឌមានការថយចុះ ម្យ៉ាងទៀត នៅក្នុងវិស័យពុទ្ធិកសិក្សាបានខកខានចំពោះការជ្រើសរើសគ្រូក្របខណ្ឌឱ្យបំពេញការងារនៅក្នុងវិស័យពុទ្ធិកសិក្សាគ្រប់កម្រិតសិក្សាអស់រយៈពេលជាង **៥** ឆ្នាំកន្លងទៅហើយ ហេតុនេះចំនួនគ្រូក្របខណ្ឌមានកម្រិតនៃការថយចុះខ្ពស់ជាងការកើនឡើង។ មិនត្រឹមតែប៉ុណ្ណោះ ចំនួនគ្រូបង្រៀនជាប់កិច្ចសន្យាដែលអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិតែងតែទទួលបានពីផែនការផ្ដល់ជូនរបស់ក្រសួងមុខងារសាធារណៈក៏ត្រូវបានកាត់បន្ថយផងដែរ នេះគឺជាមូលហេតុធ្វើឱ្យកំណើនគ្រូជួលមានការកើនឡើងរហូតដល់ទៅ **៤.២២%** ដើម្បីអាចឆ្លើយតបតាមតម្រូវការជាក់ស្ដែងរបស់វិស័យពុទ្ធិកសិក្សាបាន។

កិច្ចខិតខំប្រឹងប្រែងក្នុងការបណ្ដុះបណ្ដាលសមណសិស្ស សិស្សរបស់វិស័យពុទ្ធិកសិក្សាមានដំណើរការយ៉ាងសន្សឹមៗ ពីមួយឆ្នាំទៅមួយឆ្នាំ ដូច្នេះដើម្បីអាចវាស់ស្ទង់ពីកម្រិតចំណេះដឹងនិងសមត្ថភាពរបស់សមណសិស្ស សិស្សថាតើមានការប្រែប្រួល ឬមានភាពរីកចម្រើនយ៉ាងណានោះ? ផ្នែកជំនាញ បានរៀបចំឱ្យមានការប្រឡងវិញ្ញាបនបត្រពុទ្ធិកបឋមសិក្សា (សាលាបាលីរង) ទៅតាមនិយាមនៃការអប់រំរបស់វិស័យពុទ្ធិក ដែលមានតាំងពីអតីតកាលបន្តរហូតមកដល់បច្ចុប្បន្ន។ ក្នុងនោះដែរ អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិបានរៀបចំការប្រឡងវិញ្ញាបនបត្រពុទ្ធិកបឋមសិក្សាសម័យប្រឡងថ្ងៃទី២០-២១ ខែមករា ឆ្នាំ២០២៤ ដែលបានទទួលលទ្ធផលដូចខាងក្រោម៖




ចំពោះសមណសិស្ស សិស្សដែលប្រឡងជាប់គិតជាភាគរយស្មើនឹង **៧៤.៥៨%** និងប្រឡងធ្លាក់ស្មើនឹង **២៥.៤២%**។

ដោយឡែក សម្រាប់សមណសិស្ស សិស្សដែលបានប្រឡងជាប់ជាស្ថាពរទទួលបាននិទ្ទេសដូចខាងក្រោម៖




ដូច្នេះចំពោះការប្រឡងវិញ្ញាបនបត្រពុទ្ធិកបឋមសិក្សាសម្រាប់ឆ្នាំសិក្សា២០២៣-២០២៤ បេក្ខសមណៈ បេក្ខជនដែលប្រឡងជាប់និទ្ទេសមធ្យមមានដល់ទៅ **៤៣.២៦%** ឯណោះ ដោយឡែកបេក្ខសមណៈ បេក្ខជនដែលប្រឡងជាប់និទ្ទេសល្អប្រសើរមានត្រឹមតែ **០.៣៦%** ប៉ុណ្ណោះ។ ករណីនេះ យើងអាចបញ្ជាក់បានថា ការបណ្តុះបណ្តាលរបស់ពុទ្ធិកបឋមសិក្សានៅមានកម្រិតដែលត្រូវពង្រឹងបន្ថែម ដើម្បីជំរុញដំណើរការបណ្តុះបណ្តាលឱ្យកាន់តែមានគុណភាពនិងប្រសិទ្ធភាពខ្ពស់។

ជាងនេះទៅទៀត ដើម្បីងាយស្រួលដល់ការពិនិត្យ តាមដាន និងការវាយតម្លៃ គណៈកម្មការស្រាវជ្រាវនិងចងក្រងរបាយការណ៍នឹងធ្វើការប្រៀបធៀបអំពីកម្រិតសមត្ថភាពសមណសិស្ស សិស្សនៅក្នុងការប្រឡងវិញ្ញាបនបត្រពុទ្ធិកបឋមសិក្សា ដែលទទួលបានលទ្ធផលដូចខាងក្រោម៖



ដូច្នេះ ចំពោះការប្រឡងវិញ្ញាបនបត្រពុទ្ធិកបឋមសិក្សា សមណសិស្ស សិស្សចូលរួមការប្រឡងមានការកើនឡើង ៦% ការប្រឡងជាប់កើនឡើង ២% ប៉ុន្តែចំពោះការប្រឡងធ្លាក់បានកើនឡើងរហូតដល់ទៅ ២០% នេះជាកំណើនមួយខ្ពស់ដែលគួរឱ្យចាប់អារម្មណ៍។ ប៉ុន្តែយ៉ាងណាក៏ដោយ ចំពោះកំណើននៃការប្រឡងធ្លាក់របស់បេក្ខសមណៈ បេក្ខជននេះ មិនមែនកើតឡើងដោយចៃដន្យឡើយ ដោយសារឆ្នាំសិក្សា២០២៣-២០២៤ នីតិវិធីនៃការប្រឡងមានការរឹតបន្តឹងខ្លាំង ហើយក៏ជាកាលៈទេសៈនៃកំណែទម្រង់ការប្រឡងនានាក្នុងវិស័យពុទ្ធិកសិក្សាផងដែរ។

ម្យ៉ាងទៀត បើយើងប្រៀបធៀបទៅលើនិទ្ទេសនៃលទ្ធផលដែលបេក្ខសមណៈ បេក្ខជនបានប្រឡងជាប់មានការប្រែប្រួលដូចខាងក្រោម៖




លទ្ធផលបានបង្ហាញថា បេក្ខសមណៈ បេក្ខជនដែលប្រឡងជាប់និទ្ទេសមធ្យមបានកើនឡើងរហូតដល់ទៅ **៦៤%** និងប្រឡងជាប់និទ្ទេសល្អប្រសើរបានធ្លាក់ចុះរហូតដល់ទៅ **៧៦%** ទាំងនេះជាសញ្ញាណបានបង្ហាញឱ្យឃើញគុណភាពនៃការបណ្តុះបណ្តាលសមណសិស្ស សិស្សរបស់ពុទ្ធិកបឋមសិក្សានៅមានកម្រិតនៅឡើយ ដែលតម្រូវឱ្យថ្នាក់ដឹកនាំតាមឋានានុក្រមនិងគណៈគ្រប់គ្រងសាលាទាំងអស់ ត្រូវយកចិត្តទុកដាក់ខ្ពស់ក្នុងការពង្រឹងគុណភាពអប់រំឱ្យកាន់តែមានភាពប្រសើរឡើង ដើម្បីឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍមូលធនមនុស្សរបស់រាជរដ្ឋាភិបាលអាណត្តិទី៧។

ទោះបីជាវិស័យអប់រំពុទ្ធិកសិក្សាកំពុងស្ថិតនៅក្នុងដំណាក់កាលនៃការកែទម្រង់ក៏ដោយ ក៏យើងអាចវាយតម្លៃបានថា ដំណើរការបណ្តុះបណ្តាលជារួមនៅតែមានលក្ខណៈប្រសើរ ព្រោះយ៉ាងហោចណាស់ដំណើរការប្រឡងទាំងមូលបានប្រព្រឹត្តទៅយ៉ាងល្អប្រពៃ ហើយលទ្ធផលជារួមបានបង្ហាញថា នៅតែបន្តកើនឡើង ២% ដែរ។ ទោះបីជាកំណើននេះមានលក្ខណៈតិចតួចក៏ពិតមែន ប៉ុន្តែក៏បង្ហាញនូវសញ្ញាណវិជ្ជមានសម្រាប់កិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំតាមឋានានុក្រម ព្រះមេគណ ព្រះអនុគណ គណៈគ្រប់គ្រងសាលាពុទ្ធិក និងភាគីពាក់ព័ន្ធផងដែរ។

### ខ- ធម្មវិន័យ

ការសិក្សានិងការបណ្តុះបណ្តាលធម្មវិន័យគឺជាមូលដ្ឋានគ្រឹះដ៏សំខាន់ មិនត្រឹមតែសម្រាប់បព្វជិតប៉ុណ្ណោះទេ សូម្បីគ្រហស្ថក៏ត្រូវការសិក្សារៀនសូត្រអំពីធម៌វិន័យ ដើម្បីបានយល់ស៊ីជម្រៅអំពីពុទ្ធោវាទ ព្រមទាំងជាមូលដ្ឋានគ្រឹះក្នុងការដឹកនាំជីវិតរស់នៅប្រកបដោយសុភមង្គល និងសេចក្តីស្ងប់សុខទាំងនៅក្នុងគ្រួសារនិងសង្គមជាតិផងដែរ។ ដើម្បីសិក្សាស្វែងយល់ឱ្យកាន់តែច្បាស់អំពីព្រះពុទ្ធសាសនា ចាំបាច់ត្រូវតែសិក្សាធម៌វិន័យដែលជាពុទ្ធោវាទបានប្រតិស្ឋានទុកប្រមាណជា ២៥៦៧ ឆ្នាំកន្លងមកហើយ ។ព្រះពុទ្ធោវាទទាំងនោះត្រូវបានអ្នកប្រាជ្ញខ្មែរជាច្រើនរូប បានបកប្រែពីមគធភាសា មកជាខេមរភាសានិងបង្រួមទុកនៅក្នុងព្រះត្រៃបិដកទាំង៣ គឺព្រះវិន័យបិដក ព្រះសុត្តន្តបិដក និងព្រះអភិធម្មបិដក។ ប៉ុន្តែសេចក្តីពន្យល់នៅក្នុងព្រះត្រៃបិដកនេះ មានភាពស៊ីជម្រៅធ្វើឱ្យអ្នកសិក្សាទូទៅពិបាកក្នុងការស្វែងយល់ ហេតុនេះហើយទើប បោរាណបណ្ឌិតទាំងឡាយបង្កើតនូវកម្មវិធីសិក្សាធម្មវិន័យនេះឡើង ឱ្យមានលំដាប់លំដោយនៃការសិក្សាដែលត្រូវបានបែងចែកជា ៣ ថ្នាក់ ឬ៣ កម្រិត គឺថ្នាក់ត្រី ថ្នាក់ទោ និងថ្នាក់ឯក ធ្វើយ៉ាងណា បង្កលក្ខណៈងាយស្រួលដល់សិក្ខាកាម ក្នុងការសិក្សារៀនសូត្រ បានស្វែងយល់ស៊ីជម្រៅអំពីអត្ថន័យនិងខ្លឹមសារដ៏វិសេសនៃព្រះពុទ្ធសាសនា ដែលជាមគ្គុទ្ទេសដ៏សំខាន់ក្នុងការដឹកនាំជីវិតរស់នៅប្រកបដោយសីលធម៌ គុណតម្លៃនិងសុភមង្គលជីវិតដ៏ពិតប្រាកដមួយ។ ការសិក្សាធម្មវិន័យគឺជាជំនាញទន់ដ៏មានសក្តានុពលល្អបំផុតក្នុងការប្រព្រឹត្តវត្តប្រតិបត្តិធ្វើឱ្យខ្លឹមសារជីវិតរបស់មនុស្សយើង កាន់តែមានតម្លៃនៅក្នុងសង្គមក៏ដូចជាការរស់នៅប្រចាំថ្ងៃរបស់ខ្លួន អាចសម្របខ្លួនបាននៅគ្រប់បរិយាកាសនៃសង្គម ចេះធ្វើឱ្យតម្លៃជីវិតរបស់យើងមានប្រយោជន៍ដល់ប្រទេសជាតិ និងពុទ្ធសាសនាផងដែរ។ ទាំងនេះគឺជាគុណតម្លៃដ៏សំខាន់នៃការសិក្សាធម្មវិន័យ គុណតម្លៃទាំងនេះមានលក្ខណៈអរូបី ដែលយើងពិបាកក្នុងការវាស់វែង និងកំណត់សូចនាករនៃការសម្រេចបាននូវភាពជោគជ័យក្នុងការបណ្តុះបណ្តាលណាស់ ព្រោះចំណេះដឹងរបស់មនុស្សយើងម្នាក់ៗមិនអាចគណនាជាតួលេខបានឡើយ។ ប៉ុន្តែ នៅក្នុងសង្គមទំនើបនាពេលបច្ចុប្បន្ន គេអាចវាស់វែងកម្រិតចំណេះដឹងទៅបានដោយផ្អែកទៅលើនីតិវិធីបែបវិទ្យាសាស្ត្រមួយចំនួន ក្នុងនោះមានការប្រឡង និងការធ្វើលំហាត់សាកល្បងជាដើម។

ការសិក្សាធម៌វិន័យក្នុងព្រះពុទ្ធសាសនាមានគុណតម្លៃមហាសាលសម្រាប់ដឹកនាំមនុស្ស ឱ្យបំពេញសេចក្ដីល្អ ចេះជួយយកអាសារគ្នា កាត់បន្ថយនូវអំពើអាក្រក់ទាំងនៅក្នុងសង្គម ធ្វើឱ្យមនុស្សមានសាមគ្គីភាព ចេះចែករំលែកសេចក្ដីសុខឱ្យគ្នានិងគ្នា មិនរើសអើងគ្នា មិនមើលបំណាំគ្នា ចេះជួយសង្គ្រោះគ្នាទៅតាមអធ្យាស្រ័យជាដើម។

បច្ចុប្បន្ន ការបណ្ដុះបណ្ដាលនិងការសិក្សារៀនសូត្រធម៌វិន័យក្នុងព្រះពុទ្ធសាសនានៅតែបន្តវត្តមានរបស់ខ្លួនយ៉ាងសកម្មដែលមានទាំងនៅក្នុងប្រព័ន្ធអប់រំពុទ្ធិកសិក្សា និងក្រៅប្រព័ន្ធអប់រំ ដែលធ្វើឡើងតាមរយៈព្រះសង្ឃទេសនា ឬការបង្ហាត់បង្ហាញរបស់ធម្មកោវិទអ្នកឆ្លៀវឆ្លាសក្នុងព្រះធម៌ដល់ពុទ្ធបរិស័ទជាដើម។ ចំពោះការអប់រំធម្មវិន័យក្នុងប្រព័ន្ធពុទ្ធិកសិក្សាមានទិន្នន័យបង្ហាញដូចខាងក្រោម៖

| ល.រ | រាជធានី-ខេត្ត | សមណសិស្ស សិស្ស | | | សរុប | | សាលា | គ្រូជួល |
|---|---|---|---|---|---|---|---|---|
| | | ថ្នាក់ត្រី | ថ្នាក់ទោ | ថ្នាក់ឯក | ថ្នាក់ | សិស្ស | | |
| ១ | បាត់ដំបង | ៨២៥ | ២៩៣ | ៣៦០ | ៧១ | ១,៤៧៨ | ៤២ | ៨៤ |
| ២ | បន្ទាយមានជ័យ | ៩៣៧ | ៥០០ | ២៧១ | ១០៦ | ១,៧០៨ | ៨៣ | ៩៨ |
| ៣ | ព្រៃវែង | ៧០៥ | ២៣៩ | ២៧៦ | ៨៥ | ១,២២០ | ៤៩ | ៤៩ |
| ៤ | ស្វាយរៀង | ២២៥ | ១២៥ | ៧៧ | ៣៩ | ៤២៧ | ៣១ | ៣១ |
| ៥ | តាកែវ | ៦ | ០ | ២០ | ២ | ២៦ | ២ | ២ |
| ៦ | កំពង់ធំ | ១,៦១៥ | ២៩៧ | ១១២ | ១៥០ | ២,០២៤ | ១១៣ | ១៥០ |
| ៧ | កំពង់ឆ្នាំង | ១,០៣៣ | ១៨១ | ៩២ | ៩០ | ១,៣០៦ | ៨២ | ៩០ |
| ៨ | កំពង់ស្ពឺ | ២៦២ | ៤៨ | ៣៥ | ៣៣ | ៣៤៥ | ២៤ | ៣២ |
| ៩ | កំពត | ១៧៥ | ១៣៦ | ១១៦ | ២៦ | ៤២៧ | ២៦ | ២៦ |
| ១០ | កោះកុង | ៨២ | ៣២ | ១៤ | ១០ | ១២៨ | ៦ | ១១ |
| ១១ | ព្រះសីហនុ | ១៥១ | ៨៩ | ៤៧ | ២២ | ២៨៧ | ១១ | ១១ |
| ១២ | ក្រចេះ | ៣២០ | ៩៣ | ៦៩ | ២២ | ៤៨២ | ១៦ | ២៤ |
| ១៣ | ស្ទឹងត្រែង | ១១៥ | ៣៨ | ២០ | ១០ | ១៧៣ | ៩ | ១៤ |
| ១៤ | ព្រះវិហារ | ១៨០ | ២២ | ១០១ | ១៩ | ៣០៣ | ៩ | ១៧ |
| ១៥ | ឧត្ដរមានជ័យ | ១០០ | ១០៨ | ១៤៥ | ២៣ | ៣៥៣ | ១០ | ១០ |
| ១៦ | រតនគិរី | ៦៣ | ៥៦ | ៤៦ | ១៥ | ១៦៥ | ៥ | ១២ |
| ១៧ | ប៉ៃលិន | ១០៤ | ៣០ | ១៥ | ១៦ | ១៤៩ | ១១ | ១៦ |
| **សរុប** | | **៦,៨៩៨** | **២,២៨៧** | **១,៨១៦** | **៧៣៩** | **១១,០០១** | **៥២៩** | **៦៧៧** |

កិច្ចដំណើរការនៃសាលាធម្មវិន័យជាទូទៅពុំត្រូវបាន បញ្ជាក់ពីចំនួនសរុបឱ្យបានច្បាស់លាស់នៅទូទាំងប្រទេសឡើយ ដោយសារសាលាធម្មវិន័យមួយចំនួនជ្រកក្រោមម្លប់នៃសាលាពុទ្ធិកបឋមសិក្សា ហេតុនេះហើយទើបពុំត្រូវបានរាប់ជាចំនួនឱ្យបានគ្រប់ទៅតាមបណ្តារាជធានីខេត្តនៅទូទាំងប្រទេស ប៉ុន្តែចំពោះការប្រឡងវិញ្ញាបនបត្រវិញត្រូវបានរៀបចំមណ្ឌលប្រឡងគ្រប់រាជធានី ខេត្តទាំងអស់។

យ៉ាងណាក៏ដោយសម្រាប់ឆ្នាំសិក្សា២០២៣-២០២៤ ការបណ្តុះបណ្តាលរបស់សាលាធម្មវិន័យមានការប្រែប្រួលនិងការវិវឌ្ឍគួរឱ្យកត់សម្គាល់។ បើយើងវិភាគទៅលើបរិមាណ គណៈកម្មការស្រាវជ្រាវនិងចងក្រងរបាយការណ៍បានពិនិត្យឃើញថា ចំនួនសាលា សមណសិស្ស សិស្សមានការកើនឡើង។ គួរបញ្ជាក់ផងដែរថា កិច្ចដំណើរការសាលាធម្មវិន័យគឺជាឆន្ទៈ មនសិការរបស់ព្រះគ្រូចៅអធិការនិងពុទ្ធបរិស័ទចំណុះជើងវត្តនីមួយៗ ព្រមទាំងជាកាតព្វកិច្ចរបស់អ្នកបួសក្នុងព្រះពុទ្ធសាសនា ចាំបាច់ត្រូវតែសិក្សារៀនសូត្រអំពីពុទ្ធោវាទដែលជាពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធ ដើម្បីជាមធ្យោបាយក្នុងការបតិបត្តិដ៏ល្អប្រពៃដែលជាប្រយោជន៍ដល់ជីវភាពរស់នៅរបស់ពុទ្ធសាសនិកគ្រប់រូប។

ចំពោះវឌ្ឍនភាពសាលាធម្មវិន័យដំណើរវិវឌ្ឍរីកចម្រើនយ៉ាងណានោះ សូមពិនិត្យមើលនូវទិន្នន័យប្រៀបធៀបដូចខាងក្រោម៖



ផ្អែកទៅលើទិន្នន័យដែលបានបង្ហាញខាងលើនេះសបញ្ជាក់ឱ្យឃើញថាចំនួនសមណសិស្ស សិស្សមានការកើនឡើង **៧.៨៥%** សាលាកើនឡើង **៣.៩៥%** និងចំនួនគ្រូកើនឡើង **២.៦៦%** នេះបើយោងទៅលើស្ថិតិពុទ្ធិកសិក្សាសម្រាប់ឆ្នាំសិក្សា២០២៣-២០២៤។ ចំពោះកំណើនសមណសិស្ស សិស្ស ឬកំណើនគ្រូសម្រាប់សាលាធម្មវិន័យនេះ គឺជាបន្ទុករបស់វត្ត ព្រះគ្រូចៅអធិការ និងពុទ្ធបរិស័ទទាំងស្រុងក្នុងការឧបត្ថម្ភ គាំទ្រ និងទ្រទ្រង់ដំណើរការបណ្តុះបណ្តាល ចង្ហាន់ព្រះសង្ឃ ព្រមទាំងបច្ច័យឧបត្ថម្ភដល់គ្រូធម្មាចារ្យផងដែរ។

ដើម្បីវាស់ស្ទង់សមត្ថភាពសមណសិស្សសិស្ស ដែលបានសិក្សារៀនសូត្រធម៌វិន័យ នៅក្នុងព្រះពុទ្ធសាសនា ទៅតាមកម្រិតថ្នាក់នីមួយៗ អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិបានរៀបចំការប្រឡងវិញ្ញាបនបត្រធម្មវិន័យទៅតាមកាលបរិច្ឆេទដែលកំណត់ប្រចាំឆ្នាំ ត្រូវបានដាក់ចេញជារៀងរាល់ឆ្នាំ។ សម្រាប់ឆ្នាំសិក្សា២០២៣-២០២៤ ការប្រឡងធម្មវិន័យបានប្រព្រឹត្តទៅនៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០២៤ ដោយមានបេក្ខសមណៈ បេក្ខជនចូលរួមប្រឡងសរុបចំនួន **២០,៣៨៥** រូប។ ចំពោះលទ្ធផលនៃការប្រឡងមានដូចខាងក្រោម៖




សម្រាប់បេក្ខសមណៈបេក្ខជនបានចូលរួមប្រឡងទាំងអស់ទទួលបានលទ្ធផលគិតជាភាគរយមានដូចទិន្នន័យដែលបង្ហាញខាងក្រោម៖




ជាលទ្ធផលបេក្ខសមណៈ បេក្ខជនដែលប្រឡងជាប់ទាំងអស់ស្មើនឹង **៧០%** ចំណែកឯបេក្ខសមណៈ បេក្ខជនដែលប្រឡងធ្លាក់ស្មើនឹង **៣០%** នេះជាលទ្ធផលរួមសម្រាប់ឆ្នាំសិក្សា ២០២៣-២០២៤។[១៩]

ដោយឡែក បើប្រៀបធៀបលទ្ធផលនៃការប្រឡងវិញ្ញាបនបត្រធម្មវិន័យទៅនឹងឆ្នាំសិក្សា ២០២២-២០២៣ យើងនឹងពិនិត្យឃើញថាមានការប្រែប្រួលគួរឱ្យកត់សម្គាល់។ ចំពោះលទ្ធផលមានការប្រែប្រួលដូចម្តេចនោះ សូមអង្កេតទៅលើការប្រៀបធៀបទិន្នន័យនៃការប្រឡងដូចខាងក្រោម៖




១៩ លិខិតលេខ ៣២/២៤ អ.ព.ស.ជ ស្តីពីសំណើសុំចុះហត្ថលេខាលើលទ្ធផលប្រឡងវិញ្ញាបនបត្រធម្មវិន័យ។

យោងទៅលើលទ្ធផលដែលបានបង្ហាញខាងលើនេះ សបញ្ជាក់ឱ្យឃើញថា បេក្ខសមណៈ បេក្ខជនដែលចូលរួមនៅក្នុងការប្រឡងបានកើនឡើង **៦.៩៨%** អត្រានៃការប្រឡងជាប់បានថយចុះ **២.២៨%** និងការប្រឡងធ្លាក់បានថយចុះ **៣៧.២០%** ។ ទាំងនេះគឺជាសមិទ្ធផលនៃការបណ្តុះបណ្តាល ដែលព្រះគ្រូចៅអធិការ លោកគ្រូធម្មាចារ្យ និងការជ្រោមជ្រែងសព្វបែបយ៉ាងពីពុទ្ធបរិស័ទ ព្រមទាំងថ្នាក់ដឹកនាំតាមឋានានុក្រម ដែលយកចិត្តទុកដាក់ខ្ពស់លើវិស័យអប់រំពុទ្ធិកសិក្សា ជាពិសេសសាលាធម្មវិន័យ ដែលជាគោលដ៏សំខាន់ក្នុងការសិក្សាស្វែងយល់អំពីព្រះពុទ្ធសាសនា និងការដឹកនាំដំណើរជីវិត ឆ្ពោះទៅរកភាពរីកចម្រើនឱ្យស្របទៅតាមដំណើរវិវឌ្ឍនៃសង្គមឌីជីថល។ ដូច្នេះ ដើម្បីអាចសិក្សាស្វែងយល់កាន់តែស៊ីជម្រៅអំពីព្រះពុទ្ធសាសនា និងពុទ្ធោវាទ ដែលជាពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធ ដល់វេនេយ្យសត្វឱ្យលុះក្នុងសម្មាទិដ្ឋិ ដែលជាសុភមង្គលជីវិតដ៏ឧត្តមទាំងនៅក្នុងបច្ចុប្បន្នជាតិនិងអនាគតជាតិខាងមុខផងដែរ ព្រមទាំងជាមធ្យោបាយដ៏ប្រសើរសម្រាប់មនុស្សសត្វគ្រប់រូប។

ការងារបច្ចេកទេសរបស់ផ្នែកពុទ្ធិកបឋមសិក្សានិងធម្មវិន័យ បានជួយជំរុញ លើកកម្ពស់ និងគាំទ្រឱ្យអង្គភាពអប់រំនៅថ្នាក់មូលដ្ឋានយកចិត្តទុកដាក់ខ្ពស់ និងបំពេញកិច្ចការរបស់ខ្លួនបានយ៉ាងល្អ និងធ្វើការបណ្តុះបណ្តាលប្រកបដោយប្រសិទ្ធភាពខ្ពស់ ក្នុងនោះដែរផ្នែកជំនាញបានចុះធ្វើអធិការកិច្ចបច្ចេកទេសទៅកាន់បណ្តាខេត្តមួយចំនួនរួមមានខេត្តតាកែវ ខេត្តកំពង់ស្ពឺ និងខេត្តស្វាយរៀងជាដើម។ នៅក្នុងដំណើរចុះអធិការកិច្ចនេះ ផ្នែកជំនាញបានពិនិត្យឃើញថា វិស័យអប់រំពុទ្ធិកបឋមសិក្សាកំពុងជួបប្រទះបញ្ហាប្រឈមមួយចំនួនរួមមាន ស្ថានភាពសមណសិស្ស សិស្សមិនមានស្ថិរភាព ដោយសារការផ្លាស់ទីស្នាក់អាស្រ័យញឹកញាប់ សមណសិស្ស សិស្សដែលចូលមកសិក្សាមានការថយចុះជាលំដាប់ ខ្វះខាតសម្ភារឧបទេសសម្រាប់បង្រៀននិងរៀន ជួបប្រទះការលំបាកផ្នែកប្រព័ន្ធត្រួតពិនិត្យរដ្ឋបាលដែលជាហេតុធ្វើឱ្យការគ្រប់គ្រងសមណសិស្ស សិស្សមិនមានភាពច្បាស់លាស់[១៥] ដើម្បីរក្សាបាននូវស្ថិរភាពនិងនិរន្តរភាពរបស់វិស័យពុទ្ធិកសិក្សា។

## ២.២.២- ផ្នែកពុទ្ធិកមធ្យមសិក្សា

ដំណើរវិវឌ្ឍអប់រំរបស់វិស័យពុទ្ធិកសិក្សា នៅក្នុងកម្រិតពុទ្ធិកមធ្យមសិក្សាបានប្រព្រឹត្តទៅយ៉ាងរលូន និងទទួលបានការគាំទ្រលើការងារបច្ចេកទេសជាច្រើន ក្នុងនោះដែរ ផ្នែកជំនាញបានធ្វើការសម្របសម្រួលការងាររដ្ឋបាលទូទៅដោយបានទទួលលិខិតចូលចំនួន **៦៥** ច្បាប់ ចេញលិខិតចំនួន **៦៨** ច្បាប់ទៅកាន់អង្គភាពពាក់ព័ន្ធ បានប្រគេន ជូនសញ្ញាបត្រពុទ្ធិកមធ្យមសិក្សា

[១៥] របាយការណ៍សង្ខេបស្តីពីការចុះអធិការកិច្ចរបស់ផ្នែកពុទ្ធិកបឋមសិក្សានិងធម្មវិន័យចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ ២០២៣។

បឋមភូមិបណ្តោះអាសន្នចំនួន ១,៤០៣ ច្បាប់ សញ្ញាបត្រពុទ្ធិកមធ្យមសិក្សាបឋមភូមិចំនួន ១០៩ ច្បាប់ បញ្ជាក់ភាពត្រឹមត្រូវលើសញ្ញាបត្រពុទ្ធិកមធ្យមសិក្សាបឋមភូមិចំនួន ១៣ ច្បាប់ ។ ប្រគេនជូនសញ្ញាបត្រពុទ្ធិកមធ្យមសិក្សាទុតិយភូមិចំនួន ៥៤៥ ច្បាប់ដល់សមណសិស្ស សិស្ស និង បញ្ជាក់ភាពត្រឹមត្រូវសញ្ញាបត្រពុទ្ធិកមធ្យមសិក្សាទុតិយភូមិចំនួន ៦០ សន្លឹ និងបញ្ជាក់ភាពត្រឹមត្រូវលើសញ្ញាបត្រពុទ្ធិកមធ្យមសិក្សាទុតិយភូមិបណ្តោះអាសន្នចំនួន ៤១៦ សន្លឹក ធ្វើសញ្ញាបត្រពុទ្ធិកមធ្យមសិក្សាទុតិយភូមិចំនួន ៧៥៩ សន្លឹក បានចេញលិខិតបញ្ជាក់ការសិក្សាថ្នាក់ទី១២ ចំនួន ១២២ សន្លឹក។ បានចូលរួមកិច្ចប្រជុំបច្ចេកទេសផ្ទៃក្នុងនិងខាងក្រៅអង្គភាពចំនួន ៤១ លើក បានរៀបចំវគ្គបណ្តុះបណ្តាលគ្រូកម្រិតមូលដ្ឋាននិងគ្រូកម្រិតឧត្តម (បង្រៀននៅវិទ្យាល័យ) ចំនួនមួយវគ្គដោយមានសិក្ខាកាមចូលរួមចំនួន៦០ រូប មកពីបណ្តាខេត្តចំនួន ១៨ ខេត្ត មានខេត្តបាត់ដំបង ខេត្តកណ្តាល និងខេត្តសៀមរាបជាដើម។ ជាងនេះទៅទៀត ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការត្រួតពិនិត្យ តាមដាន និងវាយតម្លៃគុណភាពសិក្សារបស់សមណសិស្ស សិស្ស ផ្នែកបានរៀបចំនិងធ្វើការបែងចែកសៀវភៅសិក្ខាគារិកចំនួន ៣,៣៥០ ក្បាល សៀវភៅតាមដានការសិក្សាចំនួន ៤,២៥០ ក្បាល ដល់សមណសិស្ស សិស្សនៅតាមបណ្តាពុទ្ធិកមធ្យមសិក្សាបឋមភូមិនិងពុទ្ធិកមធ្យមសិក្សាទុតិយភូមិទូទាំងប្រទេស។

ការងារទាំងឡាយ ដែលប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផលទៅបាន ចាំបាច់ត្រូវតែមានប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃដែលមានលក្ខណៈវិទ្យាសាស្ត្រ ដោយភ្ជាប់មកជាមួយនូវព័ត៌មានគ្រប់ជ្រុងជ្រោយ មានយន្តការវាយតម្លៃច្បាស់លាស់ កំណត់ទិសដៅក្នុងការវាយតម្លៃប្រកបដោយភាពជាក់លាក់និងប្រាកដនិយម ទើបធ្វើឱ្យដំណើរការវាយតម្លៃនោះមានភាពសុក្រឹត្យ យុត្តិធម៌ប្រកបដោយតម្លាភាព និងគណនេយ្យភាព។ ក្នុងនោះដែរ ផ្នែកជំនាញបានរៀបចំយន្តការច្បាស់លាស់ ដើម្បីចុះធ្វើអធិការកិច្ចទៅដំណើរការបណ្តុះបណ្តាលរបស់ពុទ្ធិកអនុវិទ្យាល័យ និងពុទ្ធិកវិទ្យាល័យនៅទូទាំងប្រទេសបានចំនួន ០៦ លើក ដោយពិនិត្យឃើញថាកិច្ចដំណើរការបណ្តុះបណ្តាលរបស់ពុទ្ធិកមធ្យមសិក្សាទូទាំងប្រទេស បានប្រព្រឹត្តទៅជាប្រក្រតី សមណសិស្ស សិស្សបានយកចិត្តទុកដាក់សិក្សារៀនសូត្រ ព្រមជាមួយគ្នានេះដែរ ព្រះគ្រូចៅអធិការនៅតាមបណ្តាវត្តមួយចំនួនដែលមានសមណសិស្ស សិស្សស្នាក់អាស្រ័យនៅ លោកបានយកព្រះទ័យទុកដាក់និងមានការដាស់តឿនក្រើនរំលឹកជារឿយៗ ឱ្យសមណសិស្ស ខិតខំរៀនសូត្រយកចំណេះដឹងទៅបម្រើប្រយោជន៍ផ្ទាល់ខ្លួន ព្រះពុទ្ធសាសនា ក៏ដូចជាសង្គមជាតិទាំងមូលផងដែរ។ ទាំងនេះគឺជាគោលដៅដ៏សំខាន់ក្នុងការពង្រីកនិងពង្រឹងគុណភាពអប់រំពុទ្ធិកសិក្សាកម្រិតពុទ្ធិកមធ្យមសិក្សាប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផល។

## ក-ពុទ្ធិកមធ្យមសិក្សាបឋមភូមិ

ការបណ្តុះបណ្តាលនិងការសិក្សារៀនសូត្ររបស់សមណសិស្ស សិស្សកម្រិតមធ្យមសិក្សាបឋមភូមិបានដំណើរការយ៉ាងល្អ ព្រមទាំងមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់។ ការងារនេះគឺជាការលះបង់និងកិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំនៅតាមមូលដ្ឋាន ដែលបានយកចិត្តទុកដាក់ខ្ពស់លើការរៀននិងការបង្រៀនរបស់លោកគ្រូ អ្នកគ្រូ ព្រមទាំងមានការគាំទ្រពីថ្នាក់ដឹកនាំតាមឋានានុក្រមចាប់ពីថ្នាក់មូលដ្ឋានរហូតដល់ថ្នាក់កណ្តាល និងក្រសួងធម្មការនិងសាសនាផងដែរ។ ជាសក្ខីកម្មនៃការបណ្តុះបណ្តាលរបស់ពុទ្ធិកមធ្យមសិក្សាបឋមភូមិមានទិន្នន័យបង្ហាញដូចខាងក្រោម៖

| ល.រ | រាជធានី-ខេត្ត | សមណសិស្ស សិស្ស | | | សរុប | | សាលា |
|---|---|---|---|---|---|---|---|
| | | ថ្នាក់ទី១ | ថ្នាក់ទី២ | ថ្នាក់ទី៣ | ថ្នាក់ | សិស្ស | |
| ១ | ព្រះសុរាម្រឹត | ២៣៣ | ១៦៨ | ១៣៨ | ១២ | ៥៣៩ | ១ |
| ២ | ភ្នំពេញ | ៣៥៩ | ២៥៨ | ២៤២ | ២២ | ៨៥៩ | ៧ |
| ៣ | កណ្តាល | ២៧៣ | ១៣៨ | ១៧១ | ១៩ | ៥៨២ | ៦ |
| ៤ | បាត់ដំបង | ២៣០ | ១៤១ | ១៩៥ | ១២ | ៥៦៦ | ៣ |
| ៥ | សៀមរាប | ២៤៦ | ១០៤ | ៦៣ | ១០ | ៤១៣ | ២ |
| ៦ | បន្ទាយមានជ័យ | ១១៩ | ១០០ | ៧៨ | ៦ | ២៩៧ | ១ |
| ៧ | ពោធិ៍សាត់ | ៧៩ | ៩៣ | ៨៨ | ៦ | ២៦០ | ២ |
| ៨ | ព្រៃវែង | ១៥៥ | ៨៩ | ៧១ | ៨ | ៣១៥ | ២ |
| ៩ | ស្វាយរៀង | ៧៣ | ៦០ | ២៤ | ៤ | ១៥៧ | ១ |
| ១០ | តាកែវ | ៤១ | ២៦ | ២៤ | ៣ | ៩១ | ១ |
| ១១ | ត្បូងឃ្មុំ | ១៩៦ | ១០១ | ១០៦ | ៩ | ៤០៣ | ២ |
| ១២ | កំពង់ចាម | ១៥២ | ១៤៧ | ៩៧ | ១៤ | ៣៩៦ | ៣ |
| ១៣ | កំពង់ធំ | ១១១ | ៥២ | ៧៤ | ៦ | ២៣៧ | ២ |
| ១៤ | កំពង់ឆ្នាំង | ១០៦ | ៦៧ | ៤៣ | ៤ | ២១៦ | ១ |
| ១៥ | កំពង់ស្ពឺ | ៤៩ | ៥២ | ៦០ | ៥ | ១៦១ | ១ |
| ១៦ | កំពត | ១០៨ | ៧១ | ៤៣ | ៥ | ២២២ | ១ |
| ១៧ | ព្រះសីហនុ | ៣៦ | ២៦ | ១០ | ៣ | ៧២ | ១ |
| ១៨ | ក្រចេះ | ៣១ | ៣៩ | ៣៥ | ៣ | ១០៥ | ១ |
| ១៩ | ប៉ៃលិន | ១៨ | ៦ | ១៨ | ៣ | ៤២ | ១ |
| សរុប | | ២,៦១៥ | ១,៧៣៨ | ១,៥៨០ | ១៥៤ | ៥,៩៣៣ | ៣៩ |

តាមបណ្តារាជធានី ខេត្តនីមួយៗ បានយកចិត្តទុកដាក់ខ្ពស់ក្នុងការទ្រទ្រង់វិស័យពុទ្ធិកសិក្សាឱ្យមាននិរន្តរភាពយូរអង្វែង និងទទួលបានលទ្ធផលល្អដូចបានបញ្ជាក់ខាងលើនេះស្រាប់។ ការបណ្តុះបណ្តាលរបស់វិស័យពុទ្ធិកសិក្សាបានដំណើរការល្អ និងទទួលបានការគាំទ្រពីប្រភពនានាជាច្រើន ដែលធ្វើឱ្យស្ថានភាពសិក្សារៀនសូត្រនិងការបង្រៀនមានសន្ទុះឆ្ពោះទៅមុខគួរឱ្យកត់សម្គាល់។យ៉ាងណាក៏ដោយកិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំតាមឋានានុក្រមចាប់ពីកម្រិតថ្នាក់មូលដ្ឋានរហូតដល់ថ្នាក់កណ្តាលនិងថ្នាក់ក្រសួងធម្មការនិងសាសនា ដែលបានសហការគ្នាយ៉ាងស៊ីជម្រៅ ធ្វើឱ្យវិស័យអប់រំពុទ្ធិកសិក្សាមានវត្តមានប្រកបដោយចីរភាពរហូតមកដល់បច្ចុប្បន្ន។ ដូច្នេះ ដើម្បីងាយសម្រួលដល់ការពិនិត្យនិងវាយតម្លៃអំពីដំណើរវិវឌ្ឍរបស់វិស័យអប់រំកម្រិតពុទ្ធិកមធ្យមសិក្សាបឋមភូមិដូចម្តេចនោះ សូមពិនិត្យទិន្នន័យប្រៀបធៀបដូចខាងក្រោម៖




ទិន្នន័យប្រៀបធៀបខាងលើនេះបានបញ្ជាក់ថា ស្ថានភាពសមណសិស្ស សិស្សកំពុងសិក្សារៀននៅក្នុងកម្រិតពុទ្ធិកមធ្យមសិក្សាបឋមភូមិមានការថយចុះ **១%** ចំនួនថ្នាក់កើនឡើង **៣%** និងចំនួនសាលាបានថយចុះ **១%**។ ចំពោះការថយចុះនេះ បើពិនិត្យជារួម យើងសង្កេតឃើញថានៅមានកម្រិតតិចតួចនៅឡើយ ដែលមិនមានអ្វីគួរបារម្ភប៉ុន្មាននោះទេ។ ប៉ុន្តែ បើពិចារណាឱ្យកាន់តែស៊ីជម្រៅ ផ្នែកជំនាញ ក៏ដូចជាអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិចាំបាច់ត្រូវគិតគូរឱ្យបានខ្ពស់ និងស្វែងរកដំណោះស្រាយឱ្យបានទាន់ពេលវេលា។ ព្រោះបើផ្អែកទៅលើដំណើរវិវឌ្ឍនៃស្ថានភាពសង្គមនាពេលបច្ចុប្បន្ន វិស័យអប់រំពុទ្ធិកសិក្សាអាចនឹងប្រឈមទៅនឹងការថយចុះនៃចំនួន

សមណសិស្ស សិស្សបន្តទៀត ដោយសារភាពរីកចម្រើននៃបច្ចេកវិទ្យានិងវិស័យអប់រំចំណេះដឹងទូទៅនៅគ្រប់ទីកន្លែង ចំនួនកុលបុត្រពុទ្ធសាសនិកដែលចូលមកបួសក៏មានការថយចុះនិងកំណើនសមណសិស្ស សិស្សស្វែរិនទៅប្រឡងនៅសាលាចំណេះទូទៅក៏មានការកើនឡើងខ្ពស់កត្តាទាំងនេះ ដែលធ្វើឱ្យចំនួនសមណសិស្ស សិស្សនៅក្នុងវិស័យពុទ្ធិកសិក្សាមានការថយចុះជារៀងរាល់ឆ្នាំ។ ហេតុនេះហើយថ្នាក់ដឹកនាំតាមឋានានុក្រមគ្រប់លំដាប់ថ្នាក់ចាំបាច់ត្រូវយកព្រះទ័យទុកដាក់ខ្ពស់ ដើម្បីធ្វើឱ្យវិស័យអប់រំកម្រិតពុទ្ធិកមធ្យមសិក្សាមាននិរន្តរភាពបន្តទៀត។

ការបន្តនិរន្តរភាពទៅបានរបស់ពុទ្ធិកមធ្យមសិក្សាបឋមភូមិដោយមានការជួយជ្រោមជ្រែងពីប្រភពជាច្រើន មានទាំងប្រភពរូបវន្ត ធនធានមនុស្ស និងហិរញ្ញវត្ថុជាដើម។ ក្នុងនោះដែរ ប្រភពធនធានមនុស្សគឺជាកត្តាចម្បងទី១ដែលជួយទ្រទ្រង់វិស័យអប់រំពុទ្ធិកសិក្សាជាពិសេសគ្រូបង្រៀនដែលជាធនធានមិនអាចខ្វះបាននៅក្នុងទម្រង់នៃការអប់រំគ្រប់រូបភាព។ បច្ចុប្បន្ន គ្រូបង្រៀនដែលកំពុងបំពេញការងារនៅក្នុងវិស័យអប់រំកម្រិតពុទ្ធិកមធ្យមសិក្សាបឋមភូមិមានដូចខាងក្រោម៖

| **ល.រ** | **រាជធានី-ខេត្ត** | **គ្រូ** | | | **សរុប** |
|---|---|---|---|---|---|
| | | **ក្របខណ្ឌ** | **កិច្ចសន្យា** | **ជួល** | |
| ១ | ព្រះសុរាម្រឹត | ៩ | ០ | ៤១ | ៥០ |
| ២ | ភ្នំពេញ | ២៤ | ០ | ៨៨ | ១១២ |
| ៣ | កណ្តាល | ១៤ | ០ | ៤២ | ៥៦ |
| ៤ | បាត់ដំបង | ៥ | ១៥ | ១៣ | ៣៣ |
| ៥ | សៀមរាប | ៣ | ៨ | ២៣ | ៣៤ |
| ៦ | បន្ទាយមានជ័យ | ២ | ០ | ១៧ | ១៩ |
| ៧ | ពោធិ៍សាត់ | ៥ | ២ | ១៥ | ២២ |
| ៨ | ព្រៃវែង | ៤ | ៣ | ៣១ | ៣៨ |
| ៩ | ស្វាយរៀង | ៧ | ៧ | ២ | ១៦ |
| ១០ | តាកែវ | ៦ | ០ | ៥ | ១១ |
| ១១ | ត្បូងឃ្មុំ | ៣ | ៩ | ២៤ | ៣៦ |
| ១២ | កំពង់ចាម | ១២ | ១៣ | ២១ | ៤៦ |
| ១៣ | កំពង់ធំ | ៥ | ០ | ១៨ | ២៣ |
| ១៤ | កំពង់ឆ្នាំង | ៧ | ០ | ១៤ | ២១ |
| ១៥ | កំពង់ស្ពឺ | ១ | ៤ | ៧ | ១២ |
| ១៦ | កំពត | ៣ | ៤ | ១០ | ១៧ |
| ១៧ | ព្រះសីហានុ | ២ | ០ | ៤ | ៦ |
| ១៨ | ក្រចេះ | ៥ | ៨ | ០ | ១៣ |
| ១៩ | ប៉ៃលិន | ១ | ០ | ៨ | ៩ |
| **សរុប** | | **១១៨** | **៧៣** | **៣៨៣** | **៥៧៤** |

ដើម្បីទ្រទ្រង់ដំណើរការបណ្តុះបណ្តាល នៅតាមបណ្ដាពុទ្ធិកមធ្យមសិក្សាបឋមភូមិទូទាំងប្រទេសទៅបាន ពុទ្ធិកមធ្យមសិក្សាបឋមភូមិត្រូវការគ្រូសរុបចំនួន **៥៧៤** រូប ចំពោះគ្រូទាំងអស់ដែលបានបញ្ជាក់ជូននេះ ត្រូវបានបែងចែកជា **៣** ប្រភេទ គឺគ្រូក្របខណ្ឌចំនួន **១១៨** រូប គ្រូកិច្ចសន្យាចំនួន **៧៣** រូប និងគ្រូជួលចំនួន **៣៨៣** រូប។ គួរបញ្ជាក់ផងដែរថា បើយោងទៅតាមច្បាប់បទដ្ឋានគតិយុត្តនៅក្នុងក្របខណ្ឌវិស័យអប់រំពុទ្ធិកមធ្យមសិក្សា ពុំត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់គ្រូកិច្ចសន្យាឡើយ គឺអាចប្រើប្រាស់គ្រូជួលជំនួសវិញ។ ប៉ុន្តែនៅក្នុងស្ថានភាពជាក់ស្តែង គ្រូដែលមានជំនាញពិតប្រាកដ ហើយជាគ្រូដែលកម្រ ដូចជាគ្រូភាសាបាលី និងភាសាសំស្ក្រឹតជាដើម គាត់មានវ័យជ្រេណាស់ទៅហើយ គាត់ពុំមានសញ្ញាបត្រ ដោយសារខូចខាតនិងបាត់បង់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែពួកគាត់មានឆន្ទៈខ្ពស់ ដើម្បីរួមចំណែកផ្ទេរចំណេះដឹងដល់បច្ឆាជនជំនាន់ក្រោយ ដោយមិនគិតពីការនឿយហត់។ អាស្រ័យហេតុនេះ ដើម្បីជាការលើកទឹកចិត្តដល់មតិកមនុស្សរស់ដ៏កម្របែបនេះ ពុទ្ធិកមធ្យមសិក្សាបឋមភូមិនៅតាមបណ្ដាខេត្តមួយចំនួននៅតែបន្តប្រើប្រាស់គ្រូកិច្ចសន្យារហូតមកដល់បច្ចុប្បន្ន។

ការប្រើប្រាស់គ្រូបង្រៀននៅក្នុងកម្រិតពុទ្ធិកមធ្យមសិក្សាបឋមភូមិ សម្រាប់ឆ្នាំសិក្សា២០២៣-២០២៤ មានការប្រែប្រួលមួយចំនួន ដូចមានទិន្នន័យប្រៀបធៀបខាងក្រោម៖




ការប្រើប្រាស់គ្រូក្របខណ្ឌមានការថយចុះ **៤%** គ្រូកិច្ចសន្យាថយចុះ **១%** គ្រូជួលកើនឡើង **៥%** ។ ចំពោះការថយចុះ ឬកើនឡើងនេះគឺផ្អែកទៅលើកំណើន ឬការថយចុះនៃចំនួនសមណសិស្ស សិស្ស ចំនួនថ្នាក់ និងចំនួនសាលាផងដែរ។ ដូច្នេះ ក្នុងចំណោមគ្រូទាំងបីប្រភេទដែលបានលើកឡើងមកបញ្ជាក់ខាងលើនេះ ប្រសិនបើគ្រូនៃប្រភេទណាមួយមានការថយចុះ គ្រូប្រភេទផ្សេងទៀតអាចនឹងកើនឡើងដោយស្វ័យប្រវត្តិ នេះគឺសច្ចភាពនៃការប្រើប្រាស់គ្រូនៅក្នុងវិស័យពុទ្ធិកសិក្សា។

កិច្ចខិតខំប្រឹងប្រែងរបស់គណៈគ្រប់គ្រងសាលា មន្ទីរធម្មការនិងសាសនា ថ្នាក់ដឹកនាំតាមឋានានុក្រម បានជួយជំរុញ និងគាំទ្រដល់ដំណើរការបណ្ដុះបណ្ដាល ផ្ដល់បរិយាកាសយ៉ាងល្អសម្រាប់សមណសិស្ស សិស្សក្នុងការសិក្សារៀនសូត្រ ក្រេបជញ្ជក់យកចំណេះដឹង ដើម្បីសុភមង្គលជីវិត និងការអភិវឌ្ឍសង្គមជាតិនិងព្រះពុទ្ធសាសនាឱ្យមានភាពរីកចម្រើនជានិរន្តរ៍។ ដូច្នេះ ដើម្បីអាចវាស់ស្ទង់ពីកម្រិតចំណេះដឹងរបស់សមណសិស្ស សិស្សទៅបានអង្គភាពអប់រំចាំបាច់ត្រូវតែមានយន្តការពិនិត្យ តាមដាន និងវាយតម្លៃប្រកបដោយតម្លាភាពនិងគណនេយ្យភាព។ ទន្ទឹមគ្នានេះដែរ យោងតាមនិយាមនៃការអប់រំរបស់វិស័យពុទ្ធិកសិក្សា អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិមានរៀបចំការប្រឡងសញ្ញាបត្រពុទ្ធិកមធ្យមសិក្សាបឋមភូមិ ដោយមានបេក្ខសមណៈបេក្ខជនចូលរួមក្នុងការប្រឡងសរុបចំនួន **១,៣០៦** រូប ប្រឡងជាប់ **៩១២** រូប និងប្រឡងធ្លាក់ចំនួន **៣៩៤** រូប។[១៦] លទ្ធផលប្រឡងសញ្ញាបត្រពុទ្ធិកមធ្យមសិក្សាបឋមភូមិដែលបានលើកឡើងខាងលើនេះ បើគណនាជាភាគរយមានដូចខាងក្រោម៖




លទ្ធផលនេះបានពីភាគរយនៃការប្រឡងជាប់សមណសិស្ស សិស្សមានកម្រិតខ្ពស់ជាងភាគរយនៃការប្រឡងធ្លាក់។ ម្យ៉ាងទៀតបើប្រៀបធៀបនិទ្ទេសសម្រាប់សមណសិស្ស សិស្សដែលបានប្រឡងជាប់សញ្ញាបត្រពុទ្ធិកមធ្យមសិក្សាបឋមភូមិទទួលបានលទ្ធផលដូចខាងក្រោម៖




[១៦] លិខិតលេខ ៤២/២៤ អ.ព.ស.ជ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីលទ្ធផលប្រឡងសញ្ញាបត្រពុទ្ធិកមធ្យមសិក្សាបឋមភូមិ ឆ្នាំសិក្សា២០២៣-២០២៤។

យោងទៅលើទិន្នន័យដែលបានបង្ហាញខាងលើនេះ បានសបញ្ជាក់ឱ្យឃើញថាសមណសិស្ស សិស្សដែលប្រឡងជាប់និទ្ទេសមធ្យមមានរហូតដល់ទៅ **៨៧%** ប៉ុន្តែសម្រាប់និទ្ទេសល្អណាស់ពុំមានសមណសិស្ស សិស្សប្រឡងជាប់ឡើយ។ លទ្ធផលនេះបានបញ្ជាក់ថា គុណភាពនៃការអប់រំកម្រិតពុទ្ធិកមធ្យមសិក្សាបឋមភូមិនៅមានកម្រិតនៅឡើយ ហើយក៏ទាមទារឱ្យមានការយកចិត្តទុកដាក់ពង្រឹងការអប់រំបន្ថែមទៀត។ ម្យ៉ាងទៀត ដើម្បីមើលឱ្យឃើញពីស្ថានភាពប្រែប្រួលនៅក្នុងការប្រឡងសញ្ញាបត្រពុទ្ធិកមធ្យមសិក្សាបឋមភូមិមានលក្ខណៈយ៉ាងណានោះ យើងត្រូវពិនិត្យទៅលទ្ធផលនៃការប្រឡងសម្រាប់ឆ្នាំចាស់កន្លងមក។ ដូច្នេះ ទើបអាចបង្កភាពងាយស្រួលដល់ការប្រៀបធៀបពីស្ថានភាពប្រែប្រួលទាំងនេះ ថាតើមានលក្ខណៈវិជ្ជមានឬអវិជ្ជមានបែបណា? ដើម្បីបានជាមូលដ្ឋានក្នុងការវាយតម្លៃពីកម្រិតលម្អៀង និងការវិវឌ្ឍដែលមានភាពវិជ្ជមានបានជាភស្តុតាងជាក់លាក់ក្នុងការវាយតម្លៃ។ គណៈកម្មការស្រាវជ្រាវនិងចងក្រងរបាយការណ៍សូមបង្ហាញទិន្នន័យប្រៀបធៀបដែលមានដូចខាងក្រោម៖




ដំណើរការបណ្តុះបណ្តាលនិងការប្រឡងសញ្ញាបត្រពុទ្ធិកមធ្យមសិក្សាបឋមភូមិ ចំនួនបេក្ខសមណៈ បេក្ខជនបានចូលរួមប្រឡងមានការកើន **១០%** ដែលចំនួនបេក្ខសមណៈ បេក្ខជនដែលបានប្រឡងជាប់បានថយចុះរហូតដល់ទៅ **២០%** ចំណែកឯបេក្ខសមណៈ បេក្ខជនដែលបានប្រឡងធ្លាក់មានរហូតទៅ **១២៤%** នេះបើប្រៀបទៅនឹងឆ្នាំសិក្សា២០២២-២០២៣ដែលជាកំណើនខ្ពស់បំផុតពុំធ្លាប់មានក្នុងដំណាក់កាលចុងក្រោយនេះ។ ចំពោះការប្រឡងធ្លាក់បានកើនឡើងខ្ពស់បែបនេះ មិនមែនជាការចៃដន្យឡើយ ដោយសារប្រព័ន្ធនៃការកែទម្រង់វិស័យអប់រំពុទ្ធិកសិក្សាត្រូវបានចាប់ផ្តើមឡើងពីការរៀបចំប្រឡងផ្សេងៗ "*គុណភាពគឺជាមូលដ្ឋានដ៏ចម្បងនៃការចាប់ផ្តើម*

*ពង្រឹងប្រព័ន្ធអប់រំពុទ្ធិកសិក្សាឱ្យមានប្រសិទ្ធភាពខ្ពស់*។ ដើម្បីពង្រឹងគុណភាពទៅបានត្រូវផ្ដើមចេញពីការប្រឡង ហេតុនេះហើយ បេក្ខសមណៈ បេក្ខជនទាំងអស់ត្រូវចាប់ផ្ដើមពង្រឹងសមត្ថភាពខ្លួនឯងឱ្យបានល្អប្រសើរ ពុំនោះទេ នឹងមិនអាចបន្តការសិក្សារបស់ខ្លួននៅក្នុងវិស័យពុទ្ធិកសិក្សាដល់កម្រិតពុទ្ធិកឧត្ដមសិក្សាឡើយ។ ការធ្វេសប្រហែសរបស់បេក្ខសមណៈ បេក្ខជននៅក្នុងការសិក្សារៀនសូត្រនឹងធ្វើឱ្យបាត់បង់ឱកាសទទួលបានការអប់រំបន្តទៅកម្រិតដទៃទៀត មានកម្រិតពុទ្ធិកឧត្ដមសិក្សាជាដើម។ ទាំងនេះគឺជាបដិការថ្មីមួយដែលបានឆ្លុះបញ្ចាំងពីការយកចិត្តទុកដាក់របស់ថ្នាក់ដឹកនាំគ្រប់ឋានានុក្រមនៅក្នុងវិស័យអប់រំពុទ្ធិកសិក្សា ដែលបានដើរតួយ៉ាងសំខាន់ក្នុងការអប់រំកុលបុត្រពុទ្ធសាសនិកខ្មែរឱ្យមានចំណេះ ជំនាញ និងអភិសមាចារសមរម្យនៅក្នុងសង្គមទំនើបនាពេលបច្ចុប្បន្ន។

លើសពីនេះទៅទៀត បើប្រៀបធៀបនិទ្ទេសដែលបេក្ខសមណៈ បេក្ខជនប្រឡងជាប់មានការប្រែប្រួលយ៉ាងច្រើនបើប្រៀបធៀបទៅនឹងឆ្នាំចាស់ ដែលទទួលបានលទ្ធផលដូចខាងក្រោម៖




សមណសិស្ស សិស្សដែលប្រឡងជាប់និទ្ទេសមធ្យមបានកើនឡើងរហូតដល់ទៅ **១១៨%** និងនិទ្ទេសល្អបានថយចុះដល់ទៅ **៩៤%** ដែលជាកម្រិតនៃការថយចុះដ៏ខ្ពស់បំផុត បើប្រៀបធៀបទៅនឹងឆ្នាំចាស់កន្លងមក។ ដោយឡែកសម្រាប់សមណសិស្ស សិស្សដែលទទួលបាននិទ្ទេសល្អណាស់ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ពុំមានបេក្ខសមណៈបេក្ខជនរូបណាមួយទទួលបានឡើយ ករណីនេះក៏ជាកត្តាដ៏សំខាន់ផងដែរ ថាតើបណ្ដាលមកពីមូលហេតុអ្វីខ្លះដែលបេក្ខសមណៈ បេក្ខជន ប្រឡងនៅក្នុងវិស័យអប់រំពុទ្ធិកសិក្សា មិនអាចទទួលបានលទ្ធផលល្អណាស់សូម្បីតែមួយរូបបែបនេះ?

ដូច្នេះករណីដែលបានលើកឡើងខាងលើ ផ្នែកជំនាញចាំបាច់ត្រូវតែធ្វើការសិក្សាឱ្យបានស៊ីជម្រៅអំពីមូលហេតុដែលបានបញ្ជាក់ខាងលើ ដើម្បីបង្កភាពងាយស្រួលដល់ការពង្រឹងនិងការអភិវឌ្ឍគុណភាពអប់រំរបស់ពុទ្ធិកមធ្យមសិក្សាបឋមភូមិឱ្យកាន់តែមានភាពប្រសើរឡើង។

យោងទៅតាមនិយាមនៃការអប់រំរបស់ពុទ្ធិកសិក្សា អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិនៅតែបន្តនីតិវិធីនៃការជ្រើសរើសសមណសិស្ស សិស្សឱ្យចូលរៀននៅពុទ្ធិកអនុវិទ្យាល័យនានា ទៅតាមប្រពៃណីដែលធ្លាប់អនុវត្តតាំងពីអតីតកាលរហូតមកដល់បច្ចុប្បន្ន ដោយបានរៀបចំការប្រឡងចូលរៀន ដែលមានបេក្ខសមណៈ បេក្ខជនចូលរួមប្រឡងសរុបចំនួន **២,៩៥៧** រូប ប្រឡងជាប់ចំនួន**២,៨២២** រូប និងប្រឡងធ្លាក់ចំនួន **១៣៥** រូប បើគណនាជាភាគរយមានដូចខាងក្រោម៖




ចំពោះបេក្ខសមណៈ បេក្ខជនដែលបានប្រឡងជាប់មានកម្រិតខ្ពស់ ដែលមានរហូតដល់ **៩៥.៤៣%** និងប្រឡងធ្លាក់មានត្រឹមតែ **៤.៥៧%** ប៉ុណ្ណោះ នេះគឺជាសញ្ញាណដ៏ល្អមួយសម្រាប់វិស័យពុទ្ធិកសិក្សា។ ប៉ុន្តែប្រៀបធៀបលទ្ធផលប្រឡងចូលរៀននេះ ទៅនឹងឆ្នាំសិក្សា២០២២-២០២៣ គណៈកម្មការស្រាវជ្រាវនិងចងក្រងរបាយការណ៍បានពិនិត្យឃើញថា មានការប្រែប្រួលមួយចំនួនគួរឱ្យកត់សម្គាល់ ដូចទិន្នន័យប្រៀបធៀបខាងក្រោម៖




សម្រាប់ការប្រឡងចូលរៀនកម្រិតពុទ្ធិកអនុវិទ្យាល័យ បេក្ខសមណៈ បេក្ខជន ដែលបានចូលរួមប្រឡងកើនឡើង **៣.៩៧%** បេក្ខសមណៈ បេក្ខជនដែលប្រឡងជាប់បានកើនឡើង **៥.៣៨%**ចំណែកឯបេក្ខសមណៈបេក្ខជនដែលប្រឡងធ្លាក់បានថយចុះ**១៨.៦៧%**។បេក្ខសមណៈ បេក្ខជនដែលប្រឡងធ្លាក់មានការថយចុះក្នុងកម្រិតមួយខ្ពស់គួរឱ្យចាប់អារម្មណ៍ ចំពោះករណីនេះ បានសបញ្ជាក់ឱ្យឃើញថា ការរឹតបន្តឹងនៅក្នុងការប្រឡងយកសញ្ញាបត្រពុទ្ធិកមធ្យមសិក្សាបឋមភូមិបានរួមចំណែកយ៉ាងច្រើនក្នុងការចម្រាញ់យកសមណសិស្ស សិស្សដែលមានសមត្ថភាព ដើម្បីអាចបន្តការសិក្សាតាមបណ្តាពុទ្ធិកអនុវិទ្យាល័យនានាបាន។ ដូច្នេះ គោលដៅនៃការកែទម្រង់ប្រព័ន្ធអប់រំពុទ្ធិកសិក្សា គឺជាការចេញដំណើរយ៉ាងសន្សឹមៗ ដោយផ្តើមចេញពីការរៀបចំប្រឡងនានា ដើម្បីឈានទៅរកកំណែទម្រង់លើគ្រប់វិស័យ ក្នុងបំណងពង្រឹងគុណភាពអប់រំពុទ្ធិកសិក្សាឱ្យកាន់តែមានភាពប្រសើរឡើង។

## ខ-ពុទ្ធិកមធ្យមសិក្សាទុតិយភូមិ

កម្រិតនៃការអប់រំដែលមានលក្ខណៈជាប្រព័ន្ធ គឺជាយន្តការដ៏សំខាន់ ដើម្បីបង្ហាញឱ្យឃើញពីការអភិវឌ្ឍនៃសមត្ថភាពរបស់សមណសិស្ស សិស្ស និងផ្អែកទៅលើដំណើរវិវឌ្ឍនៃវ័យវឌ្ឍនាការរបស់មនុស្សយើងផងដែរ។ ដូច្នេះ ដើម្បីអាចមើលឃើញពីភាពរីកចម្រើនក្នុងការសិក្សារៀនសូត្ររបស់មនុស្សយើង បោរាណបណ្ឌិតបានរៀបចំឱ្យមានប្រព័ន្ធអប់រំ ដោយបានបែងចែកកម្រិតថ្នាក់ច្បាស់លាស់ ដែលមានចាប់តាំងពីកម្រិតមតេយ្យសិក្សារហូតដល់កម្រិតឧត្តមសិក្សា។ សម្រាប់វិស័យអប់រំពុទ្ធិកសិក្សា ក៏បានរៀបចំប្រព័ន្ធអប់រំមិនខុសពីវិស័យអប់រំចំណេះដឹងទូទៅឡើយ។ យ៉ាងណាមិញ សម្រាប់ឆ្នាំសិក្សា២០២៣-២០២៤ វិស័យពុទ្ធិកសិក្សាកម្រិតពុទ្ធិកមធ្យមសិក្សាបានធ្វើការបណ្តុះបណ្តាលសមណសិស្ស សិស្ស នៅតាមបណ្តារាជធានី ខេត្តដែលមានទិន្នន័យដូចខាងក្រោម៖

| ល.រ | រាជធានី-ខេត្ត | សមណសិស្ស សិស្ស | | | សរុប | | សាលា |
|---|---|---|---|---|---|---|---|
| | | ថ្នាក់ទី១ | ថ្នាក់ទី២ | ថ្នាក់ទី៣ | ថ្នាក់ | សិស្ស | |
| ១ | ព្រះសុរាម្រឹត | ២៣៧ | ១៥០ | ១១៣ | ១២ | ៥០០ | ១ |
| ២ | រាជធានីភ្នំពេញ | ៥៩ | ៥៤ | ៤៤ | ៣ | ១៥៧ | ១ |
| ៣ | កណ្ដាល | ១០៤ | ៧៩ | ៣៨ | ៥ | ២២១ | ២ |
| ៤ | បាត់ដំបង | ១២៦ | ៨៩ | ៨១ | ៦ | ២៩៦ | ១ |
| ៥ | សៀមរាប | ៨៣ | ៤១ | ៥២ | ៤ | ១៧៦ | ១ |
| ៦ | បន្ទាយមានជ័យ | ៣២ | ២៧ | ២៤ | ៣ | ៨៣ | ១ |
| ៧ | ពោធិ៍សាត់ | ៤២ | ១៥ | ៦៣ | ៣ | ១២០ | ១ |
| ៨ | ព្រៃវែង | ៣០ | ១៩ | ១២ | ៣ | ៦១ | ១ |
| ៩ | ត្បូងឃ្មុំ | ៥០ | ៤២ | ៥៨ | ៣ | ១៥០ | ១ |
| ១០ | កំពង់ចាម | ៧៥ | ៣៣ | ៤៥ | ៤ | ១៥៣ | ១ |
| ១១ | កំពង់ធំ | ០ | ១៨ | ១៥ | ២ | ៣៣ | ១ |
| ១២ | កំពង់ឆ្នាំង | ២៧ | ២០ | ២០ | ៣ | ៦៧ | ១ |
| ១៣ | កំពត | ៤០ | ១៥ | ២៤ | ៣ | ៧៩ | ១ |
| **សរុប** | | **៩០៥** | **៦០២** | **៥៨៩** | **៥៤** | **២,០៩៦** | **១៤** |

ទាំងនេះគឺជាសមិទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំ គ្រប់លំដាប់ថ្នាក់រាប់ចាប់តាំងពីកម្រិតមូលដ្ឋានរហូតដល់ថ្នាក់ក្រសួងធម្មការនិងសាសនា ដែលបានយកចិត្តទុកដាក់ខ្ពស់ក្នុងការពង្រឹង ពង្រីក និងគាំទ្រសព្វបែបយ៉ាង ដើម្បីលើកកម្ពស់ដល់ដំណើរការបណ្ដុះបណ្ដាលសមណសិស្ស សិស្សប្រកបដោយការទទួលខុសត្រូវខ្ពស់ ឆ្ពោះទៅរកការអភិវឌ្ឍអប់រំពុទ្ធិកសិក្សាប្រកបដោយចីរភាព។ ជាមួយគ្នានេះដែរ ដើម្បីបង្កលក្ខណៈងាយស្រួល ដល់ការពិនិត្យ តាមដាន និងវាយតម្លៃសម្រាប់អ្នកអានទូទៅនិងអ្នកសិក្សាស្រាវជ្រាវ គណៈកម្មការស្រាវជ្រាវនិងចងក្រងរបាយការណ៍ នឹងធ្វើការបង្ហាញពីដំណើរវិវឌ្ឍអប់រំពុទ្ធិកសិក្សាកម្រិតពុទ្ធិកមធ្យមសិក្សាទុតិយភូមិថាតើមានវឌ្ឍនភាព ឬឱនភាពយ៉ាងណានោះ? សូមពិនិត្យមើលទិន្នន័យប្រៀបធៀបដូចខាងក្រោម៖



ផ្អែកទៅលើភស្តុតាងដែលបានបង្ហាញខាងលើនេះ សបញ្ជាក់ឱ្យឃើញថា ឆ្នាំសិក្សា ២០២៣-២០២៤ ចំនួនសមណសិស្ស សិស្សមានការថយចុះ **៤.៥១%** និងចំនួនថ្នាក់មានការថយចុះ **៥.២៦%** ចំណែកឯចំនួនសាលាបានស្ថិតនៅដដែល។ ទោះបីជាដំណើរវិវឌ្ឍនៃការអប់រំកម្រិតពុទ្ធិកមធ្យមសិក្សាទុតិយភូមិ មានឱនភាពតិចតួចក៏ពិតមែន ប៉ុន្តែក៏ជាកត្តាគួរឱ្យព្រួយបារម្ភផងដែរ ព្រោះវាពាក់ព័ន្ធទៅនឹងនិរន្តរភាព នៃការអប់រំរបស់វិស័យពុទ្ធិកសិក្សាទៅថ្ងៃអនាគតផងដែរ។ ហេតុនេះហើយ ផ្នែកជំនាញ គណៈគ្រប់គ្រងសាលាពុទ្ធិកមធ្យមសិក្សានីមួយៗ និងមន្ទីរធម្មការ និងសាសនារាជធានី ខេត្តទាំងអស់ចាំបាច់ត្រូវរកឱ្យឃើញពីកត្តាប្រឈមនានា បណ្តាលឱ្យសមណសិស្ស សិស្ស សិក្សានៅក្នុងវិស័យពុទ្ធិកសិក្សាមានការថយចុះដូច្នេះ ព្រមទាំងស្វែងរកមធ្យោបាយ ឬនីតិវិធីក្នុងការដោះស្រាយឱ្យបានទាន់ពេលវេលា។

ស្របពេលជាមួយគ្នានេះដែរ ការប្រើប្រាស់ធនធានមនុស្សនៅក្នុងប្រព័ន្ធអប់រំពុទ្ធិកសិក្សា គឺជារឿងចាំបាច់បំផុតដែលមិនអាចខ្វះបាន ជាពិសេសគ្រូបង្រៀន ព្រោះគ្រូបង្រៀនត្រូវបានគេប្រសិទ្ធនាមឱ្យថាជា **"វិស្វករព្រលឹង"** ដ៏មានសក្តានុពលក្នុងការកសាងមូលដ្ឋានគ្រឹះអប់រំដ៏រឹងមាំសម្រាប់សង្គមជាតិ។ យ៉ាងណាក៏ដោយ ការបណ្តុះបណ្តាលកម្រិតពុទ្ធិកមធ្យមសិក្សាទុតិយភូមិបច្ចុប្បន្នត្រូវការគ្រូបង្រៀនទាំង **៣** ប្រភេទ ដែលមានទិន្នន័យដូចខាងក្រោម៖

| ល.រ | រាជធានី-ខេត្ត | គ្រូ | | | សរុប |
|---|---|---|---|---|---|
| | | ក្របខណ្ឌ | កិច្ចសន្យា | ជួល | |
| ១ | ព្រះសុរាម្រឹត | ១១ | ០ | ៤២ | ៥៣ |
| ២ | រាជធានីភ្នំពេញ | ២ | ០ | ២១ | ២៣ |
| ៣ | កណ្តាល | ៥ | ០ | ១៦ | ២១ |
| ៤ | បាត់ដំបង | ០ | ១ | ២៣ | ២៤ |
| ៥ | សៀមរាប | ៤ | ៤ | ១៨ | ២៦ |
| ៦ | បន្ទាយមានជ័យ | ០ | ០ | ១១ | ១១ |
| ៧ | ពោធិ៍សាត់ | ១ | ១ | ១០ | ១២ |
| ៨ | ព្រៃវែង | ១ | ១ | ១៦ | ១៨ |
| ៩ | ត្បូងឃ្មុំ | ០ | ២ | ១៣ | ១៥ |
| ១០ | កំពង់ចាម | ៣ | ៩ | ១១ | ២៣ |
| ១១ | កំពង់ធំ | ៦ | ០ | ៦ | ១២ |
| ១២ | កំពង់ឆ្នាំង | ១ | ០ | ១៣ | ១៤ |
| ១៣ | កំពត | ១ | ៣ | ៧ | ១១ |
| **សរុប** | | **៣៥** | **២១** | **២០៧** | **២៦៣** |

ព្រះអង្គគ្រូ លោកគ្រូ អ្នកគ្រូទាំងអស់បានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្ទេរចំណេះដឹង និងបទពិសោធគ្រប់យ៉ាងដល់សមណសិស្ស សិស្ស ដោយមិនគិតពីការនឿយហត់ឡើយ។ ក្នុងនេះដែរ តម្រូវការចាំបាច់របស់វិស័យអប់រំពុទ្ធិកសិក្សាសម្រាប់ឆ្នាំសិក្សា២០២៣-២០២៤ មានទិន្នន័យដូចបានបញ្ជាក់ខាងលើនេះស្រាប់។ ចំពោះតម្រូវការទាំងនេះ មានការប្រែប្រួលទៅតាមស្ថានភាពជាក់ស្តែងនៃឆ្នាំសិក្សានីមួយៗរបស់ពុទ្ធិកសិក្សា ព្រោះផ្អែកទៅលើស្ថានភាពសមណសិស្ស សិស្សផងដែរ។ សម្រាប់ឆ្នាំសិក្សា២០២៣-២០២៤ តម្រូវការគ្រូមានការកើនឡើងដូចមានទិន្នន័យប្រៀបធៀបខាងក្រោម៖




ចំពោះការប្រើប្រាស់គ្រូទាំង៣ប្រភេទសម្រាប់ឆ្នាំសិក្សា២០២៣-២០២៤គណៈកម្មការស្រាវជ្រាវនិងចងក្រងរបាយការណ៍បានសង្កេតឃើញថា សម្រាប់គ្រូក្របខណ្ឌពុំមានការប្រែប្រួលឡើយ។ ដោយឡែកសម្រាប់គ្រូកិច្ចសន្យានិងគ្រូជួលមានការប្រែប្រួលមួយចំនួន សម្រាប់គ្រូកិច្ចសន្យាមានការកើនឡើងរហូតដល់ទៅ **៤០%** ដែលជាកំណើនមួយខ្ពស់គួរឱ្យកត់សម្គាល់ ប៉ុន្តែសម្រាប់គ្រូជួលបានកើនឡើងត្រឹមតែ **២%** ប៉ុណ្ណោះ។ យ៉ាងណាក៏ដោយ ថ្នាក់ដឹកនាំតាមឋានានុក្រមក៏ត្រូវគិតគូរឱ្យបានម៉ត់ចត់ផងដែរ ចំពោះការប្រើប្រាស់គ្រូនៅក្នុងវិស័យអប់រំពុទ្ធិកសិក្សានេះ ពីព្រោះបើប្រៀបធៀបទៅនឹងចំនួនសិស្ស និងចំនួនថ្នាក់យើងពិនិត្យឃើញថា ពុំមានសង្គតិភាពនឹងគ្នាឡើយ ព្រោះចំនួនសិស្សនិងចំនួនថ្នាក់មានការថយចុះ ចំណែកឯចំនួនគ្រូបែរជាកើនឡើងទៅវិញ។ ដូច្នេះត្រូវតែពិចារណាឱ្យបានម៉ត់ចត់និងប្រើប្រាស់គ្រូឱ្យអស់ពីលទ្ធភាពតាមដែលអាចធ្វើទៅបាន។

ដំណើរការបណ្តុះបណ្តាលនៃពុទ្ធិកមធ្យមសិក្សាទុតិយភូមិបានប្រព្រឹត្តទៅជាប្រក្រតី និងឈានឆ្ពោះទៅសម្រេចបាននូវសមិទ្ធផលដែលបានគ្រោងទុក ដើម្បីជាការវាស់ស្ទង់អំពីសមត្ថភាពសមណសិស្ស សិស្ស ក៏ដូចជាការបង្ហាញឱ្យឃើញអំពីគុណភាពនៃការអប់រំរបស់វិស័យពុទ្ធិកសិក្សាផងដែរ។ ដូច្នេះ ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការពិនិត្យ និងការវាយតម្លៃ គណៈកម្មការស្រាវជ្រាវនិងចងក្រងរបាយការណ៍ នឹងបង្ហាញនូវលទ្ធផលនៃការប្រឡងសញ្ញាបត្រពុទ្ធិកមធ្យមសិក្សាទុតិយភូមិដែលមានទិន្នន័យបញ្ជាក់ដូចខាងក្រោម៖




យោងទៅលើទិន្នន័យដែលបានបង្ហាញខាងលើនេះ បានឆ្លុះបញ្ចាំងអំពីដំណើរវិវឌ្ឍ និងសមិទ្ធផលនៃការបណ្តុះបណ្តាលដែលទទួលបានលទ្ធផលល្អគួរឱ្យកត់សម្គាល់ ក្នុងនោះដែរបើយើងពិនិត្យទៅមើលលទ្ធផលនៃការប្រឡងទាំងស្រុង បេក្ខសមណៈ បេក្ខជនដែលប្រឡងជាប់ស្មើនឹង**៧៥.៧៧%** និងប្រឡងធ្លាក់ស្មើនឹង **២៤.២៣%** ។ ត្រង់ចំណុចនេះ ស្ថិតិនៃបេក្ខសមណៈ បេក្ខជនដែលប្រឡងជាប់មានកម្រិតខ្ពស់គួរឱ្យកត់សម្គាល់។ ចំពោះបេក្ខសមណៈ បេក្ខជនដែលបានប្រឡងជាប់ទាំងអស់ទទួលបាននិទ្ទេសដូចខាងក្រោម៖




យោងទៅលើលទ្ធផលដែលបានបង្ហាញខាងលើនេះ យើងសង្កេតឃើញថា បេក្ខសមណៈ បេក្ខជនដែលបានប្រឡងជាប់និទ្ទេសមធ្យមមាន **៧២%** ដែលជាកម្រិតខ្ពស់បំផុត ប៉ុន្តែសម្រាប់បេក្ខសមណៈ បេក្ខជនដែលប្រឡងជាប់និទ្ទេសល្អប្រសើរមិនមានទាល់តែសោះ ដោយឡែកសម្រាប់បេក្ខសមណៈ បេក្ខជនដែលធ្វើបាននិទ្ទេសល្អណាស់មានត្រឹម **១%** ដែលជាកម្រិតទាបបំផុត។ អាស្រ័យហេតុនេះ ថ្នាក់ដឹកនាំតាមឋានានុក្រម គណៈគ្រប់គ្រងសាលា និងផ្នែកជំនាញចាំបាច់ត្រូវយកចិត្តទុកដាក់ខ្ពស់ ក្នុងការពង្រឹងគុណភាពអប់រំពុទ្ធិកសិក្សាឱ្យកាន់តែមានភាពប្រសើរឡើងបន្ថែមទៀត ព្រោះយើងអាចវាយតម្លៃទៅលើលទ្ធផលនៃការបណ្តុះបណ្តាលថាទទួលបានជោគជ័យកម្រិតណាមួយនោះ ត្រូវពឹងផ្អែកទៅលើការប្រឡង ដើម្បីវាស់ស្ទង់សមត្ថភាពពិតប្រាកដរបស់សមណសិស្ស សិស្ស និងគុណភាពអប់រំផងដែរ។

សម្រាប់សមណសិស្ស សិស្សដែលបានប្រឡងសញ្ញាបត្រពុទ្ធិកមធ្យមសិក្សាទុតិយភូមិបានចប់សព្វគ្រប់ហើយនោះ មានឱកាសផ្សេងៗដែលត្រូវបន្តដំណើរទៅមុខទៀត ដោយមានការប្រឡងចូលរៀននៅតាមបណ្ឌាពុទ្ធិកសាកលវិទ្យាល័យ ឬសាកលវិទ្យាល័យដទៃជាច្រើនទៀត។ ដោយឡែក សម្រាប់សមណសិស្ស សិស្ស ដែលបានប្រឡងបញ្ចប់ការសិក្សារបស់ខ្លួននៅកម្រិត

ពុទ្ធិកមធ្យមសិក្សាបឋមភូមិរួចហើយ នៅពុំទាន់បានចប់ភារកិច្ចឡើយ គឺត្រូវបន្តដាក់ពាក្យប្រឡងចូលរៀននៅតាមពុទ្ធិកវិទ្យាល័យនានាដើម្បីឆក់ឱកាសបន្តការសិក្សានៅកម្រិតពុទ្ធិកមធ្យមសិក្សាទុតិយភូមិបន្ថែមទៀតព្រោះកម្មវិធីសិក្សារបស់វិស័យពុទ្ធិកសិក្សាមិនដូចគ្នាទៅនឹងសាលាចំណេះទូទៅដែលបានប្រឡងជាប់សញ្ញាបត្ររួចហើយ មានសិទ្ធិដាក់ពាក្យចូលរៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិនោះឡើយ។ សម្រាប់សមណសិស្ស សិស្សនៅក្នុងវិស័យពុទ្ធិកសិក្សា ទោះបីជាប្រឡងជាប់សញ្ញាបត្ររួចហើយក៏ដោយ ចាំបាច់ត្រូវតែដាក់ពាក្យប្រឡងចូលរៀនមួយកម្រិតទៀត ប្រសិនបើប្រឡងចូលជាប់ នោះទើបមានសិទ្ធិចូលរៀននៅពុទ្ធិកមធ្យមសិក្សាទុតិយភូមិបាន បើពុំនោះទេនឹងមិនមានឱកាសបន្តការសិក្សាទៀតឡើយ។ សម្រាប់ឆ្នាំសិក្សា២០២៣-២០២៤ បេក្ខសមណៈ បេក្ខជនដែលបានចូលរួមប្រឡងចូលរៀនកម្រិតពុទ្ធិកមធ្យមសិក្សាទុតិយភូមិមានចំនួន **៨០៩** រូប ប្រឡងជាប់ **៧៨៦** រូប និងប្រឡងធ្លាក់ **២៣** រូប ជាលទ្ធផលគណនាជាភាគរយមានដូចខាងក្រោម៖




ដោយសារការរឹតបន្តឹងគ្រប់ការងារប្រឡងទាំងអស់ ធ្វើឱ្យលទ្ធផលនៃការប្រឡងចូលរៀននៅតាមបណ្តាពុទ្ធិកវិទ្យាល័យនានា សមណសិស្ស សិស្សដែលមានសមត្ថភាពក្នុងការប្រឡងជាប់មានកម្រិតខ្ពស់ ជាលទ្ធផល សមណសិស្ស សិស្សដែលប្រឡងជាប់មានរហូតដល់ទៅ **៩៧.១៦%** និងប្រឡងធ្លាក់មានត្រឹមតែ **២.៨៤%** ប៉ុណ្ណោះ។ ទាំងនេះមិនមែនជាការចៃដន្យឡើយ ដោយសារការប្រឡងសញ្ញាបត្រពុទ្ធិកមធ្យមសិក្សាបឋមភូមិបានចម្រាញ់យកអ្នកមានសមត្ថភាពមួយកម្រិតរួចទៅហើយ ហេតុនេះទើបធ្វើឱ្យលទ្ធផលនៃការប្រឡងចូលរៀនជាប់មានភាគរយខ្ពស់ដូចបានបង្ហាញខាងលើ។

យ៉ាងណាក៏ដោយ ប្រសិនបើយើងប្រៀបធៀបទៅនឹងលទ្ធផលឆ្នាំចាស់ យើងនឹងពិនិត្យឃើញថា ស្ថានភាពលទ្ធផលនៃការប្រឡងចូលរៀននៅតាមពុទ្ធិកវិទ្យាល័យនានាមានការប្រែប្រួលគួរឱ្យកត់សម្គាល់។ ដូច្នេះ ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការអង្កេត សម្រាប់សាធារណជនទូទៅ គណៈកម្មការស្រាវជ្រាវនិងចងក្រងរបាយការណ៍ សូមធ្វើការបង្ហាញទិន្នន័យប្រៀបធៀបដូចខាងក្រោម៖




ដ្យាក្រាមខាងលើបានបង្ហាញថា សម្រាប់ឆ្នាំសិក្សា២០២៣-២០២៤ ចំនួនបេក្ខសមណៈបេក្ខជន ដែលបានដាក់ពាក្យចូលរួមប្រឡងចូលរៀននៅតាមបណ្ដាពុទ្ធិកវិទ្យាល័យនានាមានការថយចុះ **១៣%** ប្រឡងជាប់ថយចុះ **១៤%** និងប្រឡងធ្លាក់បានកើនឡើងដល់ទៅ **១០%** ឯណោះ។ លទ្ធផលខាងលើនេះបានឆ្លុះបញ្ចាំងពីការយកចិត្តទុកដាក់របស់ថ្នាក់ដឹកនាំតាមឋានានុក្រម ផ្នែកជំនាញ គណៈគ្រប់គ្រងសាលា មន្ទីរធម្មការនិងសាសនាតាមបណ្ដារាជធានី ខេត្តបានរួមចំណែកយ៉ាងសំខាន់និងសហការគ្នាយ៉ាងជិតស្និទ្ធ ក្នុងការកែទម្រង់វិស័យអប់រំពុទ្ធិកសិក្សាឱ្យកាន់តែមានគុណភាពប្រសើរឡើងថែមទៀត។

## ២.២.៣- ផ្នែកពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត

ពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត មានលក្ខណៈពិសេសជាងពុទ្ធិកវិទ្យាល័យដទៃជាច្រើនទៀត ព្រោះបច្ចុប្បន្ន ពុទ្ធិកវិទ្យាល័យមួយនេះបានប្រែក្លាយទៅជាផ្នែក ដែលមានថ្នាក់ស្មើនឹងនាយកដ្ឋានមួយរបស់ក្រសួងធម្មការនិងសាសនា[១៧] ដើរតួនាទីចម្បងទៅលើការបណ្ដុះបណ្ដាល និងការ

[១៧] អនុក្រឹត្យលេខៈ ៧០ អនក្រ.បក ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២១ ស្ដីពីការដំឡើងពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹតមានថ្នាក់ស្មើការិយាល័យទៅជាថ្នាក់ស្មើនាយកដ្ឋានចំណុះផ្ទាល់អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ។

ផ្សព្វផ្សាយពីដំណើរការទូរសិក្សា ព្រមទាំងសកម្មភាពផ្សេងៗជាច្រើនទៀត ដើម្បីរួមចំណែកលើកកម្ពស់ប្រសិទ្ធភាពនៃការបង្រៀននិងការរៀនរបស់សមណសិស្ស សិស្សនៅក្នុងវិស័យពុទ្ធិកសិក្សា។

ជាងនេះទៅទៀត ពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹតបានធ្វើការសម្របសម្រួលលើការងារបច្ចេក-ទេស ការងាររដ្ឋបាលទូទៅនិងការផ្តល់សេវាផ្សេងៗសម្រាប់សមណសិស្ស សិស្ស និងអង្គភាពពាក់ព័ន្ធដទៃជាច្រើនទៀត។ ក្នុងនោះដែរ ពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹតបានទទួលលិខិតចូលចំនួន **៥៥** ច្បាប់ ចេញលិខិតទៅកាន់អង្គភាពនិងស្ថាប័នពាក់ព័ន្ធនានាចំនួន **១៣៥** ច្បាប់ និងចេញលិខិតបញ្ជាក់ការសិក្សាប្រគេន ជូនសមណសិស្ស សិស្សចំនួន **៤៥៦** ច្បាប់។ ទទួលគម្ពីរព្រះពុទ្ធសាសនានិងសៀវភៅផ្សេងៗថ្មីចំនួន **២១២** ក្បាលដើម្បីដាក់តម្កល់នៅបណ្ណាល័យ សមណសិស្ស សិស្សចំនួន **២៥១** រូបបានចូលអានសៀវភៅក្នុងបណ្ណាល័យ បានបើកវគ្គបណ្តុះបណ្តាលថ្នាក់ភាសាបាលី-សំស្ក្រឹតចំនួន **០២** វគ្គដែលមានសិក្ខាកាមចូលរួមសិក្សាសរុបចំនួន **៥៦០** រូប។

លើសពីនេះទៅទៀត សម្តេចព្រះមង្គលមុនីវង្សី **ហ៊ូ ឈីវនាថ** ព្រះនាយកនៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹតតែងតែយកព្រះទ័យទុកដាក់លើកទឹកចិត្តប្រគេន ជូនអាហារូបករណ៍ដល់មន្ត្រីសង្ឃ មន្ត្រីរាជការ លោកគ្រូ អ្នកគ្រូ ដែលមានបំណងចង់បន្តការសិក្សានៅថ្នាក់ឧត្តមសិក្សានិងថ្នាក់ក្រោយឧត្តមសិក្សា ដើម្បីអភិវឌ្ឍសមត្ថភាពបន្ថែម ព្រមទាំងទទួលបានចំណេះដឹងថ្មីៗយកមកអភិវឌ្ឍការងាររបស់អង្គភាព។ សម្រាប់ឆ្នាំ២០២៣ ក្នុងនាមសាលានិងសម្តេចព្រះមង្គលមុនីវង្សី **ហ៊ូ ឈីវនាថ** បានចំណាយថវិកាផ្ទាល់ឧបត្ថម្ភអាហារូបករណ៍ជូនមន្ត្រីបុគ្គលិកចំនួន ៣រូប គឺ ១-លោក **ហេង រតនៈ** នាយករងទទួលបន្ទុករដ្ឋបាល បន្តការសិក្សានៅថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាញបច្ចេកវិទ្យាព័ត៌មាន ២-លោកស្រី **សែមរ៉ី**បន្តការសិក្សានៅថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាញរដ្ឋបាលសាធារណៈ ៣-ព្រះមហា **យ៉ាន ស៊ុនទៀង** បន្តការសិក្សានៅសាលាប៉ែលជី អន្តរជាតិ ជំនាញនីតិសាស្ត្រ ក្នុងមន្ត្រី១រូបៗ នូវតម្លៃសិក្សាពេញ១ឆ្នាំ។

ដោយឡែកសម្រាប់ការបណ្តុះបណ្តាល ពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹតបានចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យពុទ្ធិកសិក្សាទាំងពីរកម្រិត គឺកម្រិតពុទ្ធិកមធ្យមសិក្សាបឋមភូមិនិងពុទ្ធិកមធ្យមសិក្សាទុតិយភូមិ ដែលមានទិន្នន័យដូចខាងក្រោម៖

| ល.រ | ពុទ្ធិកវិទ្យាល័យ | សមណសិស្ស សិស្ស | | | សរុប | |
|---|---|---|---|---|---|---|
| | | ថ្នាក់ទី១ | ថ្នាក់ទី២ | ថ្នាក់ទី៣ | សិស្ស | ថ្នាក់ |
| ១ | ព្រះសុរាម្រឹត(អនុ) | ២៣៣ | ១៦៨ | ១៣៨ | ៥៣៩ | ១២ |
| ២ | ព្រះសុរាម្រឹត | ២៣៧ | ១៥០ | ១១៣ | ៥០០ | ១២ |
| **សរុប** | | **៤៧០** | **៣១៨** | **២៥១** | **១,០៣៩** | **២៤** |

នៅក្នុងដំណើរការបណ្តុះបណ្តាលសមណសិស្ស សិស្សទាំងពីរកម្រិតសិក្សា បានប្រព្រឹត្តទៅជាប្រក្រតី ដោយសមណសិស្ស សិស្សបានយកចិត្តទុកដាក់សិក្សារៀនសូត្រ ដើម្បីអភិវឌ្ឍន៍ចំណេះដឹងឱ្យកាន់តែមានភាពរីកចម្រើន ដែលជាកិច្ចការពង្រឹងសមត្ថភាពផ្ទាល់ខ្លួន ឱ្យស្របទៅ

តាមដំណើរវិវឌ្ឍនៃសាកលភាវូបនីយកម្ម និងដំណើរការបដិវត្តអប់រំឌីជីថលនាពេលបច្ចុប្បន្ន ដែលជាការប្រកួតប្រជែងផ្នែកចំណេះដឹងនិងសមត្ថភាពលើបច្ចេកវិទ្យាជាចម្បង។ ដំណើរការអប់រំដែលអាចប្រព្រឹត្តទៅបានដោយមានការចូលរួមយ៉ាងសកម្មពីសំណាក់ ព្រះគ្រូ លោកគ្រូ អ្នកគ្រូ និងបុគ្គលិកអប់រំដទៃជាច្រើនទៀត។ យ៉ាងណាក៏ដោយសម្រាប់ឆ្នាំសិក្សា២០២៣-២០២៤ ពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹតបានប្រើប្រាស់គ្រូដែលមានទិន្នន័យបញ្ជាក់ដូចខាងក្រោមៈ

| ល.រ | ពុទ្ធិកវិទ្យាល័យ | ក្របខណ្ឌ | កិច្ចសន្យា | ជួល | សរុប |
|---|---|---|---|---|---|
| ១ | ព្រះសុរាម្រឹត(អនុ) | ៩ | ០ | ៤១ | ៥០ |
| ២ | ព្រះសុរាម្រឹត | ១១ | ០ | ៤២ | ៥៣ |
| **សរុប** | | ២០ | ០ | ៨៣ | ១០៣ |

ព្រះអង្គគ្រូ លោកគ្រូ និងអ្នកគ្រូគ្រប់រូបដែលបានបង្ហាញខាងលើនេះ គឺជាធនធានដ៏សំខាន់ដែលបានរួមចំណែកយ៉ាងច្រើនក្នុងការលើកកម្ពស់វិស័យអប់រំពុទ្ធិកសិក្សា ជាពិសេសពុទ្ធិកវិទ្យា-ល័យព្រះសុរាម្រឹតនាពេលបច្ចុប្បន្ន។ បើមិនមានវត្តមានរបស់គ្រូគ្រប់រូបនោះទេ ដំណើរការអប់រំបណ្តុះបណ្តាលរបស់ពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ក៏ពុំអាចអនុវត្តទៅបានដោយជោគជ័យឡើយ ទាំងនេះគឺជាការលះបង់ដ៏ធំដើម្បីសង្គមជាតិនិងព្រះពុទ្ធសាសនា។ ការចូលរួមយ៉ាងសកម្មរបស់លោកគ្រូ អ្នកគ្រូគ្រប់រូបក្នុងការបណ្តុះបណ្តាលសមណសិស្ស សិស្សនៅពុទ្ធិកវិទ្យាល័យព្រះសុរា-ម្រឹតទាំងអស់ គឺជានិមិត្តរូបដ៏សំខាន់ដែលមិនអាចខ្វះបាននៅក្នុងវិស័យអប់រំគ្រប់កម្រិតសិក្សា ព្រោះលោកគ្រូ អ្នកគ្រូទាំងអស់ត្រូវបានគេចាត់ទុកថា គឺជាឪពុកម្តាយទី២ ជាមគ្គុទ្ទេសក៍ដ៏ឆ្នើម ជាស្ថាបត្យករព្រលឹងដ៏មានសក្តានុពល និងជាទីប្រឹក្សាដែលពោរពេញដោយបទពិសោធ ដែលអាចបណ្តុះបណ្តាលសិស្សឱ្យក្លាយជាអ្នកដឹកនាំដ៏ល្អ ជាអ្នកជំនួញដ៏មានតម្លៃនិងប្រកបដោយសីលធម៌វិជ្ជាជីវៈ ជាមហាសេដ្ឋីដែលមានមនសិការខ្ពស់ក្នុងជួយសង្គ្រោះដល់អ្នកក្រខ្សត់ និងសង្គមជាតិផងដែរ។

ចំពោះដំណើរការបណ្តុះបណ្តាលសម្រាប់ឆ្នាំសិក្សា២០២៣-២០២៤ នេះ សមណសិស្ស សិស្សដែលចូលមកសិក្សានៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹតមានការប្រែប្រួលមួយចំនួន មិនត្រឹមតែប៉ុណ្ណោះចំពោះធនធានគ្រូក៏មានការប្រែប្រួលផងដែរ ចំពោះស្ថានភាពនៃការប្រែប្រួលទាំងនេះអាចបណ្តាលមកពីកត្តារួមផ្សំ ជារួមមានគ្រូផ្ទេរមកពីបណ្តាមន្ទីររាជធានី ខេត្ត ឬគ្រូដែលគ្រប់អាយុចូលនិវត្តន៍ជាដើម។ ដូច្នេះដើម្បីឱ្យជ្រាបកាន់តែច្បាស់លាស់អំពីស្ថានភាពរបស់ពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹតមានការប្រែប្រួលយ៉ាងណានោះ ចូរមើលទិន្នន័យប្រៀបធៀបដូចខាងក្រោមៈ




យោងទៅលើទិន្នន័យប្រៀបធៀបខាងលើ សម្រាប់ឆ្នាំសិក្សា២០២៣-២០២៤ សមណសិស្ស សិស្សដែលចូលមកសិក្សានៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹតមានការថយចុះ **៨%** គ្រូក្របខណ្ឌបានកើនឡើង **១១%** និងគ្រូជួលកើនឡើង **១៩%** ។ ដោយឡែកចំពោះចំនួនសមណសិស្ស សិស្សមានការថយចុះនេះបណ្តាលមកពីកត្តាពីរសំខាន់ ទី១ សមណសិស្ស សិស្សពិបាកក្នុងការរកកន្លែងស្នាក់អាស្រ័យនៅតាមបណ្តាវត្តនៅក្នុងទីក្រុងភ្នំពេញ ទី២ បណ្តាលមកពីកត្តាសេដ្ឋកិច្ចផ្ទាល់របស់សមណសិស្ស សិស្សមិនអាចទ្រទ្រង់ជីវភាពរស់នៅក្នុងក្រុង តម្រូវឱ្យព្រះសង្ឃបង្ខំចិត្តប្តូរចេញទៅសិក្សានៅសាលាពុទ្ធិកតាមបណ្តាខេត្តវិញ ទី៣ កត្តានៃការរឹតបន្តឹងវិន័យនិងបទបញ្ជាផ្ទៃក្នុងរបស់សាលាក៏ជាកត្តាចាំបាច់ផងដែរ។ សម្រាប់ការប្រើប្រាស់គ្រូមានការកើនឡើងចំពោះគ្រូក្របខណ្ឌ គឺឆ្នាំកន្លងមកមិនបានរាប់បញ្ចូលគ្រូ ដែលចូលទៅបម្រើការនៅតាមការិយាល័យទើបធ្វើឱ្យចំនួនគ្រូជាក់ស្តែងគ្រូសរុបទាំងអស់មាន **២០** រូប ជាងនេះទៅទៀតចំពោះគ្រូជួលកើនឡើងបណ្តាលមកពីគ្រូមួយចំនួន ដែលគាត់មានជំនាញច្រើន ប៉ុន្តែគាត់ពុំបានបន្តមកបង្រៀនទៀត ហេតុនេះហើយទើបតម្រូវឱ្យសាលាត្រូវជួលគ្រូបន្ថែម ប៉ុន្តែគ្រូដែលជំនួសនោះគាត់មិនមានជំនាញគ្រប់គ្រាន់ទៅតាមតម្រូវការ ដូច្នេះសាលាត្រូវជួលគ្រូលើសពីចំនួនដែលធ្លាប់បានអញ្ជើញមកបង្រៀនកន្លងមក។ ទាំងនេះគឺជាមូលហេតុដ៏សំខាន់ដែលបណ្តាលឱ្យចំនួនគ្រូជួលនៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹតមានការកើនឡើង។

កិច្ចខិតខំប្រឹងប្រែងបណ្តុះបណ្តាល និងការសិក្សារៀនសូត្ររបស់សមណសិស្ស សិស្សបានប្រព្រឹត្តទៅយ៉ាងរលូន ដើម្បីជាការវាស់ស្ទង់នូវសមត្ថភាពសមណសិស្ស សិស្ស សាលាបានរៀបចំការប្រឡងដំណាច់ឆ្នាំដែលមានសមណសិស្ស សិស្សចូលរួមការប្រឡងសរុបចំនួន **៧៩២** រូប ដោយទទួលបានលទ្ធផលដូចខាងក្រោម៖




ផ្អែកទៅលើទិន្នន័យប្រៀបធៀបនិទ្ទេសនៃការប្រឡងដំណាច់ឆ្នាំខាងលើ យើងសង្កេតឃើញថា សមណសិស្ស សិស្សដែលប្រឡងបាននិទ្ទេសល្អមានរហូតដល់ទៅ **៣៧%** ដោយឡែកសម្រាប់សមណសិស្ស សិស្សដែលប្រឡងបាននិទ្ទេសល្អណាស់មានត្រឹម **១%** ប៉ុណ្ណោះ នេះជាចំនួនមួយដែលគួរឱ្យចាប់អារម្មណ៍។ ប៉ុន្តែអ្វីដែលសំខាន់សមណសិស្ស សិស្សដែលធ្វើល្អគឺជាចំនួនមួយគួរឱ្យចាប់អារម្មណ៍ផងដែរ បើយើងប្រៀបធៀបក្នុងចំណោមនិទ្ទេសទាំងនេះ យើងមើលឃើញថាសមណសិស្ស សិស្សដែលប្រឡងបាននិទ្ទេសល្អគឺជាកម្រិតខ្ពស់បំផុតប្រចាំឆ្នាំសិក្សា ២០២៣-២០២៤នេះ។ កត្តាទាំងនេះក៏បង្ហាញអំពីសក្តានុពលនៃការបណ្តុះបណ្តាលប្រកបដោយគុណភាពផងដែរ។

យ៉ាងណាមិញ ប្រសិនបើយើងប្រៀបធៀបលទ្ធផលនៃការប្រឡងទៅនឹងឆ្នាំសិក្សា២០២២-២០២៣ យើងនឹងពិនិត្យឃើញថាសម្រាប់ឆ្នាំសិក្សា២០២៣-២០២៤ លទ្ធផលនៃការប្រឡងដំណាច់ឆ្នាំនេះមានការប្រែប្រួលជាច្រើនដូចមានទិន្នន័យបង្ហាញខាងក្រោម៖



ទិន្នន័យប្រៀបធៀបខាងលើនេះ សបញ្ជាក់ឱ្យឃើញថា គ្រប់ផ្នែកទាំងអស់មានការធ្លាក់ចុះគួរឱ្យបារម្ភ រាប់ចាប់តាំងពីចំនួនសមណសិស្ស សិស្សដែលបានថយចុះ **១៥%** និងសមណសិស្ស សិស្សដែលប្រឡងជាប់និទ្ទេសល្អណាស់បានថយចុះរហូតដល់ទៅ **៥០%** គឺជាកម្រិតនៃការថយចុះដ៏ខ្ពស់បំផុត។ ចំណុចនៃការថយចុះទាំងនេះបណ្ដាលមកពីកត្តាពីរសំខាន់រួមមានៈការរឹតបន្តឹងនៅក្នុងការប្រឡង ដើម្បីពង្រឹងគុណភាពអប់រំពុទ្ធិកសិក្សា និងកត្តាសមត្ថភាពរបស់សមណសិស្ស សិស្សនៅមានកម្រិតនៅឡើយ ហេតុនេះហើយនៅពេលដែលដាក់ចេញនូវគោលការណ៍ថ្មីដើម្បីគុណភាពអប់រំពុទ្ធិកសិក្សាឱ្យកាន់តែមានភាពប្រសើរឡើង សមណសិស្ស សិស្សមួយចំនួនពុំទាន់បានពង្រឹងសមត្ថភាពរបស់ខ្លួនឱ្យបានគ្រប់គ្រាន់ ទើបធ្វើឱ្យលទ្ធផលនៃការប្រឡងទទួលបានខុសពីការរំពឹងទុក។ យ៉ាងណាក៏ដោយនេះក៏ជាសារដាស់តឿនមួយដែរ សម្រាប់សមណសិស្ស សិស្សឱ្យខិតខំប្រឹងប្រែងរៀនសូត្រ ដើម្បីពង្រឹងសមត្ថភាពរបស់ខ្លួនឱ្យបានគ្រប់គ្រាន់សម្រាប់ការប្រឡងក្នុងឆ្នាំសិក្សាខាងមុខទៀត។

ចំពោះទិដ្ឋភាពទូទៅនៃការអប់រំរបស់វិស័យពុទ្ធិកសិក្សាទាំង ៤ កម្រិត ដែលរាប់ចាប់តាំងពីសាលាធម្មវិន័យឡើងទៅ គណៈកម្មការស្រាវជ្រាវនិងចងក្រងរបាយការណ៍បានពិនិត្យឃើញថា ស្ថានភាពអប់រំរបស់វិស័យពុទ្ធិកសិក្សាមានការរីកចម្រើនជាវិជ្ជមាន ទោះបីជាកម្រិតសិក្សាមួយចំនួនមានឱនភាពក៏ដោយ។ ដូច្នេះ ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការពិនិត្យ អង្កេតនិងវាយតម្លៃ ចូរមើលដ្យាក្រាមបង្ហាញការប្រៀបធៀបទិន្នន័យដូចខាងក្រោម៖



ការបង្ហាញខាងលើនេះបានបញ្ជាក់ថាវិស័យអប់រំពុទ្ធិកសិក្សាជារួមមានការកើនឡើង **៣%** ទោះបីជាកម្រិតសិក្សាខ្លះមានការថយចុះក៏ពិតមែនប៉ុន្តែយ៉ាងហោចណាស់ក៏បង្ហាញនូវសញ្ញាណវិជ្ជមានចំពោះភាពរីកចម្រើនយ៉ាងសន្សឹមៗនៃការអប់រំរបស់វិស័យពុទ្ធិកសិក្សាផងដែរ។

ទន្ទឹមគ្នាទៅនឹងភាពរីកចម្រើននេះដែរ វិស័យពុទ្ធិកសិក្សាក៏មានតម្រូវការខ្ពស់ផ្នែកធនធានគ្រូដើម្បីរួមចំណែកក្នុងការចែករំលែកចំណេះដឹងដល់សមណសិស្ស សិស្សប្រកបដោយគុណភាពសមត្ថភាព និងសីលធម៌ ដែលជាគុណប្រយោជន៍ដ៏សំខាន់ក្នុងការអភិវឌ្ឍមូលធនមនុស្សដ៏មានសក្តានុពលសម្រាប់សង្គមជាតិនិងព្រះពុទ្ធសាសនាផងដែរ។ ដូច្នេះ ធនធានស្នូលដ៏សំខាន់បំផុតនោះគឺគ្រូបង្រៀនគ្រប់កម្រិតសិក្សា។ បច្ចុប្បន្ន វិស័យអប់រំពុទ្ធិកសិក្សាបានប្រើប្រាស់គ្រូទាំង **៣** ប្រភេទ គឺគ្រូក្របខណ្ឌ គ្រូបង្រៀនជាប់កិច្ចសន្យា និងគ្រូជួល ដែលមានស្ថានភាពដូចមានទិន្នន័យបង្ហាញខាងក្រោម៖




គ្រប់កម្រិតសិក្សាដែលបានបង្ហាញខាងលើ ក៏មានតម្រូវការចាំបាច់ចំពោះធនធានមនុស្សដ៏សំខាន់ក្នុងការអភិវឌ្ឍអប់រំផងដែរ ក្នុងតម្រូវការគ្រូនៅកម្រិតពុទ្ធិកសិក្សាទាំង **៤** មានតម្រូវការបានកើនឡើងទាំងអស់ ប៉ុន្តែបើវិភាគជារួមកំណើនទាំងនេះមានត្រឹមតែ **១%** ប៉ុណ្ណោះ។ ដូច្នេះមិនសូវជាមានបន្ទុកធ្ងន់ប៉ុន្មានសម្រាប់រាជរដ្ឋាភិបាលឡើយ ប៉ុន្តែយ៉ាងណាក៏ដោយការប្រើប្រាស់ធនធានមនុស្សនៅក្នុងវិស័យអប់រំពុទ្ធិកសិក្សាចាំបាច់ត្រូវប្រើប្រាស់ឱ្យអស់លទ្ធភាព ដើម្បីរួមចំណែកក្នុងការកាត់បន្ថយបន្ទុករបស់រាជរដ្ឋាភិបាលផងដែរ។ ទាំងនេះ គឺជាសមិទ្ធផលដ៏សំខាន់ដែលវិស័យពុទ្ធិកសិក្សា បានរួមចំណែកក្នុងការអភិវឌ្ឍធនធានមនុស្សចាប់ពីកម្រិតសាលាធម្មវិន័យ ពុទ្ធិកបឋមសិក្សា និងពុទ្ធិកមធ្យមសិក្សា។

## ២.២.៤- ផ្នែកពុទ្ធិកឧត្តមសិក្សានិងក្រោយពុទ្ធិកឧត្តមសិក្សា

ការសម្របសម្រួលកិច្ចការងារឱ្យកាន់តែមានដំណើរការល្អនិងប្រសិទ្ធភាពខ្ពស់ ចាំបាច់ត្រូវតែមានប្រព័ន្ធត្រួតពិនិត្យនិងតាមដានពីដំណើរវិវឌ្ឍនៃការអប់រំ ដែលស្របទៅតាមស្តង់ដារអប់រំទូទៅនាពេលបច្ចុប្បន្ននេះ។ យ៉ាងណាមិញ វិស័យអប់រំពុទ្ធិកសិក្សាក៏ដូច្នេះដែរ ក្រោយពីសមណសិស្ស សិស្សបានបញ្ចប់ការសិក្សាកម្រិតពុទ្ធិកមធ្យមសិក្សាទុតិយភូមិហើយនោះ សមណសិស្ស សិស្សទាំងអស់មានសិទ្ធិបន្តការសិក្សានៅកម្រិតឧត្តមសិក្សាបាន។ ដូច្នេះសម្រាប់វិស័យអប់រំពុទ្ធិកសិក្សា មានផ្នែកពុទ្ធិកឧត្តមសិក្សានិងក្រោយពុទ្ធិកឧត្តមសិក្សាធ្វើការសម្របសម្រួលការងារទូទៅដើម្បីធានាបាននូវការផ្តល់សេវាអប់រំដ៏សមស្រប សម្រាប់អ្នកមកទទួលសេវាដែលនិមន្តនិងអញ្ជើញមកពីគ្រប់មជ្ឈដ្ឋាន និងធ្វើយ៉ាងណាឱ្យដំណើរការអប់រំកម្រិតពុទ្ធិកឧត្តមសិក្សាប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាពខ្ពស់ និងទទួលបានការគាំទ្រពីសាធារណជនទូទៅ។

សម្រាប់ឆ្នាំសិក្សា២០២៣-២០២៤ ផ្នែកពុទ្ធិកឧត្តមសិក្សានិងក្រោយពុទ្ធិកឧត្តមសិក្សាបានធ្វើការសម្របសម្រួលលើការងាររដ្ឋបាលទូទៅនិងការងារបច្ចេកទេសផ្សេងៗជាច្រើនទៀត រួមមាន ទទួលលិខិតចូលមកពីបណ្តាពុទ្ធិកសាកលវិទ្យាល័យ អង្គភាព និងស្ថាប័នពាក់ព័ន្ធសរុបចំនួន **៨៧** ច្បាប់ ចេញលិខិតទៅកាន់អង្គភាព និងស្ថាប័នផ្សេងៗចំនួន**៥៤** ច្បាប់ បានចុះធ្វើអធិការកិច្ចនៅតាមពុទ្ធិកសាកលវិទ្យាល័យទាំង **៣** ចំនួន **២** លើក ប្រជុំបច្ចេកទេសផ្ទៃក្នុងនិងខាងក្រៅអង្គភាពចំនួន **៥១** លើក។

ដើម្បីលើកកម្ពស់ដំណើរការបណ្តុះបណ្តាល របស់ពុទ្ធិកសាកលវិទ្យាល័យទាំងអស់ឱ្យប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាពខ្ពស់ ថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេសនៃផ្នែកពុទ្ធិកឧត្តមសិក្សានិងក្រោយពុទ្ធិកឧត្តមសិក្សាតែងចុះជួបពិភាក្សាជាមួយគណៈគ្រប់គ្រងពុទ្ធិកសាកលវិទ្យាល័យទាំងអស់ ដើម្បីសិក្សាស្វែងយល់អំពីបញ្ហាប្រឈមនានា សម្របសម្រួលលើការងារបច្ចេកទេស និងជំរុញលើកទឹកចិត្តឱ្យពុទ្ធិកសាកលវិទ្យាល័យទាំងអស់ ត្រូវខិតខំប្រឹងប្រែងពង្រឹងគុណភាពអប់រំពុទ្ធិកសិក្សា ឱ្យកាន់តែមានភាពល្អប្រសើរបន្ថែមទៀត ធ្វើយ៉ាងណាបណ្តុះបណ្តាលមូលធនមនុស្សឱ្យបានច្រើន ជាពិសេសធនធានព្រះសង្ឃដើម្បីរួមចំណែកលើកកម្ពស់ការអប់រំនិងអភិវឌ្ឍធនធានមនុស្សសម្រាប់សង្គមជាតិនិងព្រះពុទ្ធសាសនា ឱ្យស្របទៅតាមគោលនយោបាយអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា។

### ក-ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ

យោងតាមសាវតារនៃសាកលវិទ្យាល័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ គឺជាសាកលវិទ្យាល័យដែលមានវ័យចំណាស់ជាងគេ[១៨] ហើយបានបណ្តុះបណ្តាលបញ្ញវន្តសង្ឃខ្មែរជាច្រើនអង្គ មិនត្រឹមតែប៉ុណ្ណោះក៏បានបណ្តុះបណ្តាលនិស្សិតបញ្ញវន្ត

[១៨] ព្រះរាជក្រមលេខ ៨៧៩ ន.ស. ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ១៩៥៤។

ដែលជាគ្រូហាស្ដជាច្រើនរូបផងដែរ។ បញ្ញវន្តសង្ឃខ្មែរដែលបានប្រសូត្រចេញពីពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជជាច្រើនសម័យកាល បានបន្សល់ទុកនូវស្នាដៃជាច្រើនសម្រាប់សង្គមជាតិនិងព្រះពុទ្ធសាសនា ជាពិសេសវីរភាពដ៏អង់អាចក្នុងការកសាងនិងអភិវឌ្ឍធនធានព្រះសង្ឃតាំងពីអតីតកាលរហូតមកដល់បច្ចុប្បន្ន។ ទោះបីនៅក្នុងកាលៈទេសៈខ្លះដែលប្រទេសជាតិ ធ្លាក់ក្នុងស្ថានភាពភយន្តរាយយ៉ាងធំធេង ដែលតម្រូវឱ្យពុទ្ធិកសាកលវិទ្យាល័យមួយនេះត្រូវបិទទ្វារទាំងនៅក្នុងរបបផ្ដាច់ការកម្ពុជាប្រជាធិបតេយ្យក៏ដោយ ក៏ក្រោយរបបមួយនេះបានដួលរលំ ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជក៏បានបើកដំណើរការបណ្ដុះបណ្ដាលឡើងវិញ ដើម្បីរួមចំណែកអភិវឌ្ឍធនធានមនុស្សសម្រាប់សង្គមជាតិ និងព្រះពុទ្ធសាសនាឱ្យមានការរីកចម្រើនជាបន្តបន្ទាប់រហូតមកដល់សព្វថ្ងៃ មិនត្រឹមតែប៉ុណ្ណោះ ដើម្បីបំពេញតម្រូវការចាំបាច់របស់សង្គមក្នុងការអភិវឌ្ឍធនធានមនុស្ស ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជបានពង្រីកសាខាចំនួន ០២ បន្ថែមទៀត គឺសាខាពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជខេត្តកំពង់ឆ្នាំងនិងសាខាពុទ្ធិកសាកលវិទ្យាល័យខេត្តបាត់ដំបង។

បច្ចុប្បន្ន ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ ដឹកនាំដោយសម្ដេចព្រះមហាអរិយវង្សបណ្ឌិត **យ៉ន សេង យៀត** ជាព្រះសាកលវិទ្យាធិការ[១៩] និងមានព្រះសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោកគ្រូសាស្ត្រាចារ្យ ព្រមទាំងមន្ត្រីសង្ឃ មន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា និងមន្ត្រីស្ម័គ្រចិត្តសរុបទាំង ០៣ ទីតាំង មានចំនួន **៣១៩** រូប (បព្វជិត **៣២** អង្គ ប្រុស **២៥៥** នាក់ និងស្រី **៣២** នាក់)។

សម្រាប់ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ (រាជធានីភ្នំពេញ) កំពុងបើកដំណើរការបណ្ដុះបណ្ដាលសមណនិស្សិត និស្សិតថ្នាក់បរិញ្ញាបត្រចំនួន ០៤ មហាវិទ្យាល័យ និង ០៨ ឯកទេស ដែលមានទិន្នន័យដូចខាងក្រោម៖

### ១-ថ្នាក់បរិញ្ញាបត្រ

| ល.រ | មហាវិទ្យាល័យ | ឯកទេស | សរុប | | | |
|---|---|---|---|---|---|---|
| | | | ព្រះសង្ឃ | ប្រុស | ស្រី | សរុប |
| ១ | ទស្សនវិជ្ជានិងពុទ្ធសាសនា | ទស្សនវិជ្ជាពុទ្ធសាសនា | ៥ | ៣ | ២ | ១០ |
| | | នីតិសាស្ត្រ | ៤៧ | ៦៩ | ៨៣ | ១៩៩ |
| ២ | វិទ្យាសាស្ត្រអប់រំនិងព័ត៌មានវិទ្យា | រដ្ឋបាលអប់រំ | ៤៦ | ៤១ | ៦៧ | ១៥៤ |
| | | គ្រប់គ្រងទូទៅ | ១៩ | ២៧ | ៤២ | ៨៨ |
| ៣ | អក្សរសាស្ត្រ | អក្សរសាស្ត្រខ្មែរ | ៥៤ | ៤៦ | ១៨១ | ២៨១ |

[១៩] ព្រះរាជក្រឹត្យ នស/រកត/០១២៤/១៣១ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៤ មាត្រា១ តែងតាំងមុខតំណែង សម្ដេចព្រះមហាអរិយវង្សបណ្ឌិត **យ៉ន សេងយៀត** ជាព្រះសាកលវិទ្យាធិការនៃពុទ្ធិកសាលកវិទ្យាល័យព្រះសីហនុរាជ។

| | | | | | | |
|---|---|---|---|---|---|---|
| | | បរិស្ថាន | ១ | ៣ | ៧ | ១១ |
| ៤ | បាលី-សំស្ក្រឹតនិងភាសាបរទេស | ភាសាបាលី | ៣៥ | ៦ | ២ | ៤៣ |
| | | អក្សរស/អង់គ្លេស | ២៧ | ១៥ | ៣៥ | ៧៧ |
| សរុប | | | **២៣៤** | **២១០** | **៤១៩** | **៨៦៣** |

ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជបានបន្តបេសកកម្មរបស់ខ្លួន ក្នុងការបណ្តុះបណ្តាលសមណនិស្សិត និស្សិត ឱ្យទទួលបានចំណេះដឹង បំណិនជំនាញ និងអភិសមាចារប្រកបដោយការទទួលខុសត្រូវខ្ពស់ក្នុងសង្គម។ លើសពីនេះទៅទៀត ពុទ្ធិកសាកលវិទ្យាល័យមួយនេះត្រូវបានគេស្គាល់ជាទូទៅថា ជាសាកលវិទ្យាល័យសម្រាប់តែព្រះសង្ឃសិក្សាប៉ុណ្ណោះ ពុំសូវឃើញមានគ្រហស្ថ ឬត្រូវបានគេដឹងថាគ្រហស្ថអាចចូលមកសិក្សានៅសាកលវិទ្យាល័យមួយនេះបានឡើយ ប៉ុន្តែនៅក្នុងដំណាក់កាលប៉ុន្មានឆ្នាំចុងក្រោយនេះ គណៈកម្មការស្រាវជ្រាវនិងចងក្រងរបាយការណ៍បានពិនិត្យឃើញថា សមណនិស្សិត និស្សិតចូលមកសិក្សាមានភាពចំរុះ ដែលស្ថានភាពនេះមានការប្រែប្រួលគួរឱ្យចាប់អារម្មណ៍។ មិនត្រឹមតែប៉ុណ្ណោះ ព័ត៌មានសិក្សារបស់ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយ ធ្វើឱ្យសាធារណជនទូទៅបានស្គាល់ច្បាស់ និងចាប់ផ្តើមបញ្ជូនកូនចៅ ឬបងប្អូនឱ្យមកចូលរៀននៅពុទ្ធិកសាកលវិទ្យាល័យមួយនេះផងដែរ។ ការបើកទូលាយនេះ បានផ្តល់ឱកាសដល់កុលបុត្រខ្មែរទូទៅដែលមានស្ថានភាពគ្រួសារក្រីក្រលំបាក បានបន្តការសិក្សារបស់ខ្លួននៅកម្រិតឧត្តមសិក្សាបាន ព្រោះពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ គឺជាសាកលវិទ្យាល័យរបស់រដ្ឋ ដែលផ្តល់អាហារូបករណ៍ **១០០%** ដល់សមណនិស្សិត និស្សិតសិក្សារយៈពេល **៤** ឆ្នាំ ដើម្បីជួយកាត់បន្ថយបន្ទុកនៃការចំណាយរបស់គ្រួសារ ព្រមទាំងបានផ្តល់នូវចំណេះដឹង សមត្ថភាព ជំនាញយ៉ាងពិតប្រាកដ មិនត្រឹមតែប៉ុណ្ណោះ បានបណ្តុះសីលធម៌វិជ្ជាជីវៈ ដែលជាមូលដ្ឋានគ្រឹះដ៏សំខាន់ក្នុងការអភិវឌ្ឍខ្លួនឯង និងសង្គមជាតិឱ្យមានការរីកចម្រើនប្រកបដោយនិរន្តរភាព។ សមណនិស្សិត និស្សិត ដែលចូលមកសិក្សានៅពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជមានសន្ទុះកើនឡើងគួរឱ្យចាប់អារម្មណ៍។ យ៉ាងណាក៏ដោយចំពោះសមណនិស្សិត និស្សិត ដែលចូលមកសិក្សានៅពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជមានស្ថានភាពដូចខាងក្រោម៖



យោងទៅលើទិន្នន័យប្រៀបធៀបខាងលើនេះ សបញ្ជាក់ឱ្យឃើញថា សមណនិស្សិតនៅពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជមានត្រឹមតែ **២៧%** ប៉ុណ្ណោះ ក្រៅពីនេះសុទ្ធតែជាគ្រហស្ថទាំងអស់។ អ្វីដែលកាន់តែពិសេសជាងនេះ ទៅទៀត គឺនិស្សិតស្រីមានរហូតដល់ទៅ **៤៩%** គឺជាកម្រិតដែលខ្ពស់បំផុត នេះបើប្រៀបធៀបទៅនឹងនិស្សិតទាំង **៣** ប្រភេទដែលបានបង្ហាញខាងលើ គឺ (បព្វជិត ប្រុស និងស្រី)។

ទិន្នន័យទាំងនេះក៏បានឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរនៃរបត់សង្គមផងដែរ ដូច្នេះ គំនាបប្រពៃណីលែងជាឧបសគ្គធ្ងន់ធ្ងរសម្រាប់យុវតី ឬនិស្សិតស្រី នៅក្នុងសង្គមខ្មែរទៀតហើយ។ ជាងនេះទៅទៀត សន្ទុះនិស្សិតស្រីដែលបានបន្តការសិក្សានៅកម្រិតពុទ្ធិកឧត្តមសិក្សាតែងតែមានការកើនឡើងជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ។ ទាំងនេះគឺដោយសារតែការយល់ដឹងរបស់ប្រជាពលរដ្ឋដែលបានផ្តល់តម្លៃខ្ពស់ទៅលើការអប់រំ មិនត្រឹមតែប៉ុណ្ណោះការយកចិត្តដាក់ខ្ពស់របស់ប្រមុខរាជ-រដ្ឋាភិបាលដែលដឹកនាំដោយសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងថ្នាក់ដឹកនាំតាមឋានានុក្រមបានលើកកម្ពស់នូវសមភាពយេនឌ័រនាពេលបច្ចុប្បន្ន។

ម្យ៉ាងទៀត សមណនិស្សិត និស្សិតកំពុងសិក្សានៅពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជមានការប្រែប្រួលជាច្រើនដែលមានទិន្នន័យប្រៀបធៀបដូចខាងក្រោម៖



ដូច្នេះ សម្រាប់ឆ្នាំសិក្សា២០២៣-២០២៤ សមណនិស្សិត និស្សិត មានការកើនឡើងសរុប ស្មើនឹង **១%** ដោយឡែក សមណនិស្សិត បានថយចុះ **១៣%** និស្សិតស្រីបានកើនឡើងរហូតដល់ទៅ**៣៤%**នេះបើប្រៀបធៀបទៅនឹងឆ្នាំសិក្សា២០២២-២០២៣។ទាំងនេះបានបង្ហាញនូវសញ្ញាណវិជ្ជមានសម្រាប់ពុទ្ធិកសាកលវិទ្យាល័យ ប៉ុន្តែក៏ជាចំណែកដែលគួរឱ្យព្រួយបារម្ភផងដែរ ព្រោះសមណនិស្សិតដែលបន្តការសិក្សានៅកម្រិតពុទ្ធិកឧត្តមសិក្សាតែងមានការថយចុះជាបន្តបន្ទាប់។

ដើម្បីអាចដំណើរការបណ្តុះបណ្តាលសមណនិស្សិត និស្សិតប្រកបដោយប្រសិទ្ធភាពខ្ពស់ ពុទ្ធិកសាកលវិទ្យាល័យបានប្រើប្រាស់គ្រូសាស្ត្រាចារ្យ **០២** ប្រភេទ គឺគ្រូក្របខណ្ឌ និងគ្រូជួល ដែលមានទិន្នន័យដូចខាងក្រោម៖




គ្រូសាស្ត្រាចារ្យដែលមានក្របខណ្ឌ កំពុងបំពេញការងារនៅពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជបច្ចុប្បន្នបានថយចុះ **១៩%** ដោយឡែកចំពោះការប្រើប្រាស់គ្រូទាំងពីរប្រភេទនេះបានថយចុះជារួមស្មើនឹង **៣%** ចំពោះការថយចុះនេះ គឺដោយសារគ្រូក្របខណ្ឌមួយចំនួនបានធ្វើនិយត្តិទៅជាមន្ត្រី ឬផ្ទេរការងារទៅកាន់អង្គភាពផ្សេង មួយវិញទៀតការបង្កើតម៉ោងទទួលខុសត្រូវរបស់គ្រូក្របខណ្ឌដើម្បីឱ្យស្របទៅតាមច្បាប់បទដ្ឋានគតិយុត្តទាក់ទងទៅនឹងម៉ោងកាតព្វកិច្ចរបស់គ្រូសាស្ត្រាចារ្យគ្រប់រូបដែលត្រូវបំពេញ។ ហេតុនេះហើយទើបធ្វើឱ្យចំនួនគ្រូសាស្ត្រាចារ្យដែលត្រូវប្រើប្រាស់នៅក្នុងការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រមានការថយចុះ ដូចអ្វីដែលបង្ហាញនៅក្នុងដ្យាក្រាមខាងលើនេះស្រាប់។

ដើម្បីពង្រីកចំណេះដឹងឱ្យកាន់តែទូលំទូលាយ សមណនិស្សិត និស្សិត មានឆន្ទៈខ្ពស់ក្នុងការអភិវឌ្ឍសមត្ថភាពរបស់ខ្លួនឱ្យកាន់តែប្រសើរឡើងបន្ថែមទៀត ក៏ជំរុញឱ្យមានការបើកបណ្តុះបណ្តាលកម្រិតថ្នាក់បរិញ្ញាជាន់ខ្ពស់ បំពេញតាមតម្រូវការជាក់ស្តែងរបស់សមណនិស្សិត និស្សិតដែលមានទិន្នន័យដូចខាងក្រោម៖

| ល.រ | មហាវិទ្យាល័យ | ឯកទេស | សមនិស្សិត និស្សិត | | | |
|---|---|---|---|---|---|---|
| | | | ព្រះសង្ឃ | ប្រុស | ស្រី | សរុប |
| ១ | ទស្សនវិជ្ជានិងសាសនា | ទស្សនវិជ្ជា | ១៦ | ៣៣ | ៧ | ៥៦ |
| ២ | អក្សរសាស្ត្រ | អក្សរសាស្ត្រខ្មែរ | ១១ | ១៤ | ៥ | ៣០ |
| ៣ | វិទ្យាសាស្ត្រអប់រំនិងព័ត៌មានវិទ្យា | គ្រប់គ្រងអប់រំ | ១៣ | ៧ | ១ | ២១ |
| ៤ | បាលី សំស្ក្រឹតនិងភាសាបរទេស | ភាសាបាលី | ១២ | ៩ | ០ | ២១ |
| ៥ | នីតិសាស្ត្រនិងរដ្ឋបាលសាធារណៈ | នីតិសាស្ត្រ | ២១ | ២១ | ១១ | ៥៣ |
| **សរុប** | | | ៧៣ | ៨៤ | ២៤ | ១៨១ |

ការបន្តការសិក្សារបស់សមណនិស្សិត និស្សិតនៅកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ គណៈកម្មការស្រាវជ្រាវនិងចងក្រងរបាយការណ៍សង្កេតឃើញថាស្ថានភាពព្រះសង្ឃមានការកើនឡើងគួរឱ្យកត់សម្គាល់។ ដូច្នេះ ដើម្បីឱ្យជ្រាបកាន់តែច្បាស់ថា តើមានការកើនឡើងកម្រិតណានោះ? សូមអង្កេតមើលទិន្នន័យប្រៀបធៀបដូចខាងក្រោម៖




ផ្អែកទៅលើភស្តុតាងដែលបានបង្ហាញខាងលើនេះសបញ្ជាក់ឱ្យឃើញថា សមណនិស្សិតនិស្សិត ដែលមានឆន្ទៈក្នុងការបន្តការសិក្សានៅថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់បានកើនឡើងខ្ពស់នេះបើប្រៀបធៀបទៅនឹងថ្នាក់បរិញ្ញាបត្រមានភាពខុសគ្នាច្រើន។ ដោយឡែកសម្រាប់និស្សិតស្រី

ដែលបន្តការសិក្សាមកដល់កម្រិតបរិញ្ញាបត្រជាន់ខ្ពស់មានត្រឹមតែ **១៣%** ប៉ុណ្ណោះ ចំណែកឯនិស្សិតប្រុសមានរហូតដល់ទៅ **៨៦%** ឯណោះ។ ដូច្នេះយើងអាចវាយតម្លៃបានថា គំនាបប្រពៃណីនៅតែមានសម្ពាធខ្លះដែរសម្រាប់ស្ត្រី បើទោះបីជា មានអង្គភាព ឬស្ថាប័នជាច្រើនព្យាយាមបញ្ជ្រាបចំណេះដឹងទាក់ទងទៅនឹងសមភាពយេនឌ័រយ៉ាងណាក៏ដោយ។

សម្រាប់ឆ្នាំសិក្សា២០២៣-២០២៤ សមណនិស្សិត និស្សិតដែលបន្តការសិក្សានៅកម្រិតបរិញ្ញាបត្រជាន់ខ្ពស់មានការកើនឡើងគួរឱ្យចាប់អារម្មណ៍ ដូច្នេះដើម្បីងាយស្រួលដល់ការពិនិត្យ និងការវាយតម្លៃគណៈកម្មការស្រាវជ្រាវនិងចងក្រងរបាយការណ៍នឹងធ្វើការបង្ហាញនូវទិន្នន័យប្រៀបធៀបមានដូចខាងក្រោម៖




ផ្អែកទៅលើដ្យាក្រាមដែលបានបង្ហាញខាងលើ សបញ្ជាក់ឱ្យឃើញថា ទិន្នន័យជារួមសមណនិស្សិត និស្សិតមានការកើនឡើង **៤១%** ក្នុងនោះសមណនិស្សិតកើនឡើង **៤៩%** និស្សិតប្រុសកើនឡើង **៣៨%** និងនិស្សិតស្រីកើនឡើង **៣៣%** ។ ដូច្នេះសន្ទុះនៃការចាប់អារម្មណ៍បន្តការសិក្សានៅកម្រិតបរិញ្ញាបត្រជាន់ខ្ពស់មានការកើនឡើងខ្ពស់គួរឱ្យកត់សម្គាល់។ យ៉ាងណាក៏ដោយ ថ្នាក់ដឹកនាំតាមឋានានុក្រមក៏គប្បីបន្តយកចិត្តទុកដាក់បន្ថែមទៀត ដើម្បីទាក់ទាញការចាប់អារម្មណ៍ពីសមណនិស្សិត និស្សិតបានបន្តការសិក្សានៅពុទ្ធិកសាកលវិទ្យាល័យ ក៏ដូចជាការលើកកម្ពស់និរន្តរភាពនៃការបណ្តុះបណ្តាលកម្រិតពុទ្ធិកឧត្តមសិក្សាបន្ថែមទៀត។

ដំណើរការបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ត្រូវបានបើកដំណើរការ និងទ្រទ្រង់លើសកម្មភាពបណ្តុះបណ្តាលផ្សេងៗដោយសាលាផ្ទាល់ ហេតុនេះហើយ សាលាត្រូវប្រើប្រាស់គ្រូជួលទាំងស្រុង ចំពោះការចំណាយលើប្រាក់ម៉ោងបន្ថែមនេះ ពុទ្ធិកសាកលវិទ្យាល័យត្រូវស្វែងរកការគាំទ្រនិងការឧបត្ថម្ភលើហិរញ្ញប្បទានផ្សេងៗពីពុទ្ធបរិស័ទ ឬសមណនិស្សិត និស្សិតត្រូវបង់ថ្លៃសិក្សា ដើម្បីជាការរួមចំណែកក្នុងការគាំទ្រដល់កិច្ចដំណើរការបណ្តុះបណ្តាលទាំងមូលនិងការចំណាយទៅលើប្រាក់ម៉ោងលោកគ្រូសាស្ត្រាចារ្យផងដែរ។ សម្រាប់ឆ្នាំសិក្សា២០២៣-២០២៤ ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ បានប្រើប្រាស់គ្រូសាស្ត្រាចារ្យត្រឹមតែ**៣២** រូបប៉ុណ្ណោះ។

ដំណើរការបណ្តុះបណ្តាលសមណនិស្សិត និស្សិតដែលមានលក្ខណៈជាប្រព័ន្ធកន្លងមកនេះ សមណនិស្សិត និស្សិតថ្នាក់បរិញ្ញាបត្រចំនួន **១០២** រូបបានការពារសារណាបញ្ចប់ការសិក្សារបស់ខ្លួនដោយជោគជ័យ។

## ខ- ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ (សាខាខេត្តកំពង់ឆ្នាំង)

ការអប់រំកម្រិតពុទ្ធិកឧត្តមសិក្សា គឺជាមូលដ្ឋានគ្រឹះដ៏សំខាន់ក្នុងការអភិវឌ្ឍមូលដ្ឋានប្រកបដោយគុណភាព សមត្ថភាព និងសីលធម៌ ដើម្បីចូលរួមអភិវឌ្ឍសង្គមកម្ពុជាប្រកបដោយនិរន្តរភាព។ ក្នុងនោះដែរ ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ សាខាខេត្តកំពង់ឆ្នាំង បានចូលរួមយ៉ាងសកម្មក្នុងការបន្តបេសកកម្មរបស់ខ្លួននៅក្នុងវិស័យអប់រំ ដើម្បីអភិវឌ្ឍធនធានមនុស្សកម្រិតឧត្តមសិក្សាប្រកបដោយការទទួលខុសត្រូវខ្ពស់។

បច្ចុប្បន្ន ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជសាខាខេត្តកំពង់ឆ្នាំង បានបណ្តុះបណ្តាលសមណនិស្សិត និស្សិតថ្នាក់ឧត្តមសិក្សាទាំងពីរកម្រិត គឺកម្រិតបរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់។ ដោយឡែកសម្រាប់ការបណ្តុះបណ្តាលសមណនិស្សិត និស្សិតថ្នាក់បរិញ្ញាបត្រ ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជសាខាខេត្តកំពង់ឆ្នាំង បានបើកដំណើរការមហាវិទ្យាល័យចំនួន **០៣** និង **០៥** ឯកទេស ដែលមានទិន្នន័យដូចខាងក្រោម៖

| ល.រ | មហាវិទ្យាល័យ | ឯកទេស | សមណនិស្សិត និស្សិត | | | |
|---|---|---|---|---|---|---|
| | | | ព្រះសង្ឃ | ប្រុស | ស្រី | សរុប |
| ១ | នីតិសាស្ត្រ | នីតិសាស្ត្រ | ១៧ | ៩ | ២៨ | ៥៤ |
| ២ | វិទ្យាសាស្ត្រអប់រំនិងព័ត៌មានវិទ្យា | រដ្ឋបាលអប់រំ | ១២ | ៣២ | ១០១ | ១៤៥ |
| | | គ្រប់គ្រងទូទៅ | ៩ | ៣៨ | ៤៨ | ៩៥ |
| ៣ | បាលី-សំស្ក្រឹតនិងភាសាបរទេស | អក្សរសាស្ត្រខ្មែរ | ៥ | ២០ | ៥៨ | ៨៣ |
| | | អក្សរស/អង់គ្លេស | ០ | ៥ | ១១ | ១៦ |
| **សរុប** | | | **៤៣** | **១០៤** | **២៤៦** | **៣៩៣** |

មិនខុសគ្នាទៅនឹងពុទ្ធិកសាកលវិទ្យាល័យដទៃទៀតនោះទេ ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ សាខាខេត្តកំពង់ឆ្នាំង មានសមណនិស្សិត និស្សិតមានសភាពប្រែប្រួលទៅតាមស្ថានភាពជាក់ស្តែង។ យ៉ាងណាមិញ សមណនិស្សិតមានចំនួនតិចជាងនិស្សិតដែលជាគ្រហស្ថ ចំពោះភាពខុសគ្នានេះមិនមានអ្វីប្លែកឡើយ ដោយសារសមណនិស្សិត បួសហើយបានបន្តការសិក្សារបស់ខ្លួនរហូតដល់កម្រិតមហាវិទ្យាល័យនេះ មិនមែនជាការងាយឡើយ ព្រោះព្រះសង្ឃដែលបានបួសបានរៀនជាច្រើនរូប តែងជ្រុះចេញពីសង្វៀនជីវិតនៃការអប់រំជាបន្តបន្ទាប់តាមរយៈការលាចាកសិក្ខាបទ (សឹក) ទៅជាយរាវាស (គ្រហស្ថ) ឬត្រឡប់ទៅកាន់ស្រុកកំណើតរបស់ខ្លួនវិញ ដើម្បីគ្រប់គ្រងវត្តនៅតាមមូលដ្ឋានរបស់ខ្លួនវិញជាដើម ហើយក៏ពុំបានបន្តការសិក្សាទៀតឡើយ។ ព្រះសង្ឃអង្គខ្លះក៏បោះបង់ការសិក្សារបស់ខ្លួនតាំងពីកម្រិតពុទ្ធិកបឋមសិក្សា ឬពីកម្រិតពុទ្ធិកមធ្យមសិក្សាជាដើម កត្តាទាំងនេះហើយដែលនាំឱ្យព្រះសង្ឃដែលអាចបន្តការសិក្សានៅកម្រិតពុទ្ធិកឧត្តមសិក្សាមានចំនួនតិច។ នៅមានកត្តាជាច្រើនផ្សេងទៀត ដែលគណៈកម្មការស្រាវជ្រាវនិងចងក្រងរបាយការណ៍ពុំបានលើកមកបង្ហាញទីនេះ។ ទន្ទឹមនឹងអ្វីដែលបានលើកឡើងខាងលើ គណៈកម្មការស្រាវជ្រាវនិងចងក្រងរបាយការណ៍សូមធ្វើការបង្ហាញទិន្នន័យប្រៀបធៀបសមណនិស្សិត និស្សិតមានដូចខាងក្រោម៖




បើពិនិត្យទៅលើទិន្នន័យដែលបានបង្ហាញខាងលើ បញ្ជាក់ថា ព្រះសង្ឃដែលបន្តការសិក្សានៅមហាវិទ្យាល័យមានត្រឹមតែ **១១%** ប៉ុណ្ណោះ ប៉ុន្តែនិស្សិតស្រីមានដល់ទៅ **៦៣%** ដែលករណីនេះមិនខុសពីគ្នាប៉ុន្មាន ពីពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជនៅទីក្រុងភ្នំពេញឡើយ ដែលចំនួននិស្សិតស្រីនៅតែមានចំនួនច្រើនជាងចំនួននិស្សិតប្រុស និងព្រះសង្ឃ ដោយសារបរិបទសង្គមបានផ្តល់ឱកាសនិងលើកទឹកចិត្តដល់ស្ត្រី ឱ្យបន្តការសិក្សានៅកម្រិតពុទ្ធិកឧត្តមសិក្សាកាន់តែច្រើនឡើងបន្ថែមទៀត។

ជាងនេះទៅទៀត សម្រាប់ឆ្នាំសិក្សា២០២៣-២០២៤ សមណនិស្សិត និស្សិតនៃពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជមានកំណើនតិចតួចផងដែរ ដូច្នេះដើម្បីជ្រាបកាន់តែច្បាស់សូមពិនិត្យមើលទិន្នន័យប្រៀបធៀបដូចខាងក្រោម៖




បើសង្កេតជារួម យើងពិនិត្យឃើញថា សមណនិស្សិត និស្សិតនៃពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជសាខាខេត្តកំពង់ឆ្នាំងមានការកើនឡើង ១% សមណនិស្សិតថយចុះ ២% និស្សិតប្រុសថយចុះ ១២% និងនិស្សិតស្រីកើនឡើង ១៨%។ ទោះបីជាមានការប្រែប្រួលយ៉ាងណាក៏ដោយ ក៏ដំណើរការបណ្តុះបណ្តាលរបស់ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជសាខាខេត្តកំពង់ឆ្នាំង បានបង្ហាញនូវសញ្ញាណវិជ្ជមាននៃការកើនឡើងនៃសមណនិស្សិត និស្សិតផងដែរ។ នេះគឺជាកិច្ចខិតខំប្រឹងប្រែងដោយមិនដាក់ធុរៈរបស់ថ្នាក់ដឹកនាំតាមឋានានុក្រម ដែលបានយកចិត្តទុកដាក់ខ្ពស់ចំពោះការអប់រំរបស់ពុទ្ធិកឧត្តមសិក្សា ធ្វើយ៉ាងណាក៏ផ្តល់ឱកាសឱ្យបានច្រើនសម្រាប់កុលបុត្រពុទ្ធសាសនិកដែលមានស្ថានភាពគ្រួសារក្រីក្រ បានទទួលការអប់រំប្រកបដោយភាពស្មើគ្នាដោយមិនប្រកាន់រើសអើងវណ្ណៈ ពណ៌សម្បុរ ឬសាសនាឡើយ។

ដើម្បីទ្រទ្រង់ដំណើរការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រឱ្យទទួលបានជោគជ័យ ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជសាខាខេត្តកំពង់ឆ្នាំងបានប្រើប្រាស់គ្រូជួលទាំងស្រុង ព្រោះគ្រូក្របខណ្ឌដែលបំពេញការងារនៅពុទ្ធិកសាកលវិទ្យាល័យមួយនេះមានតែ ១ រូប ប៉ុណ្ណោះ ហើយបានផ្ទេរចេញទៅទីតាំងរាជធានីភ្នំពេញទៀត នេះគឺជាហេតុផលដែលពុទ្ធិកសាកលវិទ្យាល័យមួយនេះប្រើប្រាស់តែគ្រូជួល មិនមានគ្រូក្របខណ្ឌ។ ចំពោះការប្រើប្រាស់គ្រូជួលនេះទៀតសោត មានការប្រែប្រួលទៅតាមស្ថានភាពជាក់ស្តែងដូចមានទិន្នន័យប្រៀបធៀបខាងក្រោម៖




ការប្រើប្រាស់គ្រូសាស្ត្រាចារ្យសម្រាប់ឆ្នាំសិក្សា២០២៣-២០២៤ មានការប្រែប្រួលតិចតួច មិនមានអ្វីដែលជាបញ្ហាប្រឈមធ្ងន់ធ្ងរគួរឱ្យកត់សម្គាល់ឡើយ ដូច្នេះអ្វីដែលថ្នាក់ដឹកនាំត្រូវធ្វើបន្តទៀតគ្រាន់តែពង្រឹងបន្ថែមលើការប្រើប្រាស់គ្រូឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ដើម្បីធ្វើឱ្យដំណើរការរបស់អប់រំពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជសាខាខេត្តកំពង់ឆ្នាំង កាន់តែមានភាពរឹងមាំមន្ថែមទៀត។

ទន្ទឹមគ្នាទៅនឹងភាពរីកចម្រើនលើវិស័យអប់រំពុទ្ធិកសិក្សានេះ ដើម្បីបំពេញតម្រូវជាក់ស្តែងរបស់សមណនិស្សិត និស្សិត ដែលមានបំណងបន្តការសិក្សារបស់ខ្លួនបន្ថែមទៀត ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជសាខាខេត្តកំពង់ឆ្នាំង ក៏បានបន្តបើកបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ឱ្យតាមសេចក្តីត្រូវការរបស់សង្គមជាតិ ក្នុងនោះដែរ សមណនិស្សិត និស្សិតដែលបានបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មានទិន្នន័យដូចខាងក្រោម៖

| ល.រ | មហាវិទ្យាល័យ | ឯកទេស | សមណនិស្សិត និស្សិត | | | |
|---|---|---|---|---|---|---|
| | | | ព្រះសង្ឃ | ប្រុស | ស្រី | សរុប |
| ១ | វិទ្យាសាស្ត្រអប់រំ និងព័ត៌មានវិទ្យា | គ្រប់គ្រងអប់រំ | ៣ | ២០ | ១០ | ៣៣ |
| **សរុប** | | | ៣ | ២០ | ១០ | ៣៣ |

សម្រាប់ឆ្នាំសិក្សា២០២៣-២០២៤ ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជសាខាខេត្តកំពង់ឆ្នាំង បានបើកដំណើរការថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ត្រឹមតែមួយមហាវិទ្យាល័យនិងមួយឯកទេសប៉ុណ្ណោះ ដោយសារស្ថានភាពសមណនិស្សិត និស្សិតដែលចុះឈ្មោះចូលរៀននៅមហាវិទ្យាល័យផ្សេងទៀតមិនគ្រប់ចំនួនទៅតាមតម្រូវការជាក់ស្តែងរបស់សាលា ហេតុនេះហើយ ទើបសាលាសម្រេចបើកបណ្តុះបណ្តាលត្រឹមតែមួយមហាវិទ្យាល័យប៉ុណ្ណោះ។ ហើយការបណ្តុះបណ្តាលនេះបានប្រើប្រាស់គ្រូជួលត្រឹមតែ ១៤ រូបប៉ុណ្ណោះ។

ចំពោះការបណ្តុះបណ្តាលសមណនិស្សិត និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់សម្រាប់ឆ្នាំសិក្សា២០២៣-២០២៤ មានការថយចុះគួរឱ្យកត់សម្គាល់។ ដូច្នេះដើម្បីងាយស្រួលដល់ការពិនិត្យ និងការវាយតម្លៃគណៈកម្មការស្រាវជ្រាវនិងចងក្រងរបាយការណ៍ សូមធ្វើការបង្ហាញទិន្នន័យប្រៀបធៀបដូចខាងក្រោម៖




ផ្អែកទៅលើភស្តុតាងនៃការប្រៀបធៀបទិន្នន័យខាងលើនេះ សបញ្ជាក់ឱ្យឃើញយ៉ាងច្បាស់ថា ដំណើរការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ នៃពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ សាខាខេត្តកំពង់ឆ្នាំងមានការធ្លាក់ចុះយ៉ាងគំហុកគួរឱ្យបារម្ភ ព្រោះបើគណនាជារួមសមណនិស្សិត និស្សិតបានធ្លាក់ចុះរហូតដល់ទៅ **៥៦%** ដែលជាការថយចុះពុំធ្លាប់មានពីមុនមកសម្រាប់ដំណាក់កាលចុងក្រោយនេះ។ ដូច្នេះថ្នាក់ដឹកនាំតាមឋានានុក្រម និងផ្នែកជំនាញគួរគប្បីចុះធ្វើការត្រួតពិនិត្យឱ្យបានដិតដល់ ស្វែងរកឱ្យឃើញនូវបញ្ហាប្រឈមដែលពុទ្ធិកសាកលវិទ្យាល័យកំពុងជួបប្រទះ និងរកដំណោះស្រាយឱ្យបានសមស្រប ដើម្បីឆ្លើយតបចំពោះបញ្ហាទាំងនេះឱ្យបានទាន់ពេលវេលា។

ដោយឡែកការប្រើប្រាស់គ្រូនៅថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នេះ ក៏មានការថយចុះទៅតាមស្ថានភាពជាក់ស្តែងនៃការថយចុះរបស់សមណនិស្សិត និស្សិតផងដែរ។ សម្រាប់ឆ្នាំសិក្សា ២០២៣-២០២៤ ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ បានប្រើប្រាស់គ្រូសរុបចំនួន **១៤** រូប។

ចំពោះការប្រើប្រាស់គ្រូសាស្ត្រាចារ្យខាងលើនេះ ស្របទៅតាមស្ថានភាពជាក់ស្តែងនៃតម្រូវការចាំបាច់ក្នុងការបណ្តុះបណ្តាល ដើម្បីធ្វើឱ្យដំណើរការបណ្តុះបណ្តាលនេះប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាពខ្ពស់ ព្រមទាំងប្រើប្រាស់ធនធានឱ្យអស់លទ្ធភាព។

## គ- ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ (សាខាខេត្តបាត់ដំបង)

ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ (សាខាខេត្តបាត់ដំបង) ជាពុទ្ធិកសាកលវិទ្យាល័យមួយដែលស្ថិតនៅឆ្ងាយពីទីក្រុងភ្នំពេញ បានផ្តល់ឱកាសយ៉ាងច្រើនដល់សមណនិស្សិត និស្សិតដែលមានស្ថានភាពគ្រួសារក្រលំបាក មកពីតំបន់ដាច់ស្រយាលបានទទួលអាហារូបករណ៍ ១០០% ពីរាជរដ្ឋាភិបាលសិក្សាថ្នាក់បរិញ្ញាបត្ររយៈពេល៤ឆ្នាំ មិនត្រឹមតែប៉ុណ្ណោះថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់បានយកចិត្តទុកខ្ពស់ កសាងអគារសិក្សាថ្មីបន្ថែមទៀត ដើម្បីផ្តល់ឱកាសដល់សមណនិស្សិតនិស្សិតឱ្យបានកាន់តែច្រើន ទទួលបានការអប់រំកម្រិតពុទ្ធិកឧត្តមសិក្សា ក៏ដូចជាការរួមចំណែកអភិវឌ្ឍន៍ធនធានមនុស្សប្រកបបដោយគុណភាព សមត្ថភាព និងសីលធម៌សម្រាប់សង្គមកម្ពុជា។ លើសពីនេះទៅទៀតពុទ្ធិកសាកលវិទ្យាល័យបានកសាងអន្តេវាសិកដ្ឋានសម្រាប់និស្សិតស្រីដែលមកពីតំបន់ឆ្ងាយដាច់ស្រយាលបានស្នាក់អាស្រ័យផងដែរ។

បច្ចុប្បន្ន ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជសាខាខេត្តបាត់ដំបងកំពុងបណ្តុះបណ្តាលឧត្តមសិក្សាទាំងពីកម្រិតគឺថ្នាក់បរិញ្ញាបត្រនិងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់។ ចំពោះថ្នាក់បរិញ្ញាកំពុងបើកដំណើរការបណ្តុះបណ្តាលមាន ០៣ មហាវិទ្យាល័យនិង ០៥ ឯកទេសដែលមានទិន្នន័យដូចខាងក្រោម៖

### ១-ថ្នាក់បរិញ្ញាបត្រ

| ល.រ | មហាវិទ្យាល័យ | ឯកទេស | សមណនិស្សិត និស្សិត | | | |
|---|---|---|---|---|---|---|
| | | | ព្រះសង្ឃ | ប្រុស | ស្រី | សរុប |
| ១ | នីតិសាស្ត្រ | នីតិសាស្ត្រ | ២៧ | ៥៤ | ១០៥ | ១៨៦ |
| ២ | វិទ្យាសាស្ត្រអប់រំនិងព័ត៌មានវិទ្យា | រដ្ឋបាលអប់រំ | ២៨ | ៤៩ | ២០៤ | ២៨១ |
| | | គ្រប់គ្រងទូទៅ | ១២ | ២៧ | ៧៤ | ១១៣ |
| ៣ | បាលី-សំស្ក្រឹតនិងភាសាបរទេស | អក្សរសាស្ត្រខ្មែរ | ៣៩ | ៦៣ | ២៤៨ | ៣៥០ |
| | | អក្សរស/អង់គ្លេស | ១៦ | ១៨ | ៥៩ | ៩៣ |
| **សរុប** | | | **១២២** | **២១១** | **៦៩០** | **១,០២៣** |

ស្ថានភាពនៃការបណ្តុះបណ្តាលសមណនិស្សិត និស្សិតថ្នាក់បរិញ្ញាបត្របានប្រព្រឹត្តទៅជាប្រក្រតី និងទទួលបានការគាំទ្រពីគ្រប់មជ្ឈដ្ឋាន ដើម្បីធ្វើឱ្យវិស័យអប់រំពុទ្ធិកឧត្តមសិក្សាប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាពខ្ពស់ ព្រមទាំងការរួមចំណែកដ៏សំខាន់ដែលមិនអាចខ្វះបាននៅក្នុងបរិបទអប់រំឌីជីថលនាពេលបច្ចុប្បន្ន។ ចំពោះការងារបណ្តុះបណ្តាលរបស់ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជសាខាខេត្តបាត់ដំបងមានការប្រែប្រួលមួយចំនួនគួរឱ្យកត់សម្គាល់ ដូច្នេះដើម្បីងាយស្រួលដល់ការអង្កេត និងវាយតម្លៃពីស្ថានភាពទាំងនេះចូរពិនិត្យមើលទិន្នន័យប្រៀបធៀបដូចខាងក្រោម៖




ទិន្នន័យប្រៀបធៀបខាងលើនេះ ជាភស្តុតាងបង្ហាញឱ្យឃើញថា កិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំតាមឋានានុក្រមបានរួមចំណែកយ៉ាងច្រើន ធ្វើឱ្យការបណ្តុះបណ្តាលរបស់ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជសាខាខេត្តបាត់ដំបងអាចរក្សានិរន្តរភាពបាន ព្រមទាំងបន្តធ្វើឱ្យកំណើនសមណនិស្សិត និស្សិតជាបន្តបន្ទាប់ផងដែរ។ ក្នុងនោះយើងពិនិត្យជារួមយើងសង្កេតឃើញថា សមណនិស្សិត និស្សិតបានកើនឡើង **៣%** បើទោះបីជាកំណើននេះមានស្ថានភាពតិចតួច ក៏ពិតមែន យ៉ាងហោចណាស់ក៏អាចបង្ហាញពីសញ្ញាណវិជ្ជមានមួយសម្រាប់ការអប់រំកម្រិតពុទ្ធិកឧត្តមសិក្សាផងដែរ។ ទន្ទឹមទៅនឹងភាពរីកចម្រើននេះ ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ក៏មានក្តីបារម្ភមួយចំនួនផងដែរ ក្នុងនោះយើងសង្កេតឃើញថា សមណនិស្សិតមានការថយចុះដល់ទៅ **២០%** សម្រាប់ឆ្នាំសិក្សា២០២៣-២០២៤នេះ។ យោងតាមការសិក្សាស្រាវជ្រាវ ជារៀងរាល់ឆ្នាំសមណនិស្សិតដែលបន្តការសិក្សានៅកម្រិតពុទ្ធិកឧត្តមសិក្សាមានការថយចុះជាបន្តបន្ទាប់ ដែលតម្រូវឱ្យថ្នាក់ដឹកនាំ ផ្នែកជំនាញ និងភាគីពាក់ព័ន្ធត្រូវការសិក្សាឱ្យបានច្បាស់លាស់ថាតើការថយចុះនៃសមណនិស្សិតនេះបណ្តាលមកពីកត្តាអ្វីខ្លះ? ទើបអាចស្វែងរកដំណោះស្រាយឱ្យបានសមស្របទៅតាមស្ថានភាពជាក់ស្តែងបាន។ ព្រមជាមួយគ្នានេះដែរ បើយើងប្រៀបធៀបទៅនឹងចំនួនសមណនិស្សិត និងនិស្សិតយើងនឹងពិនិត្យឃើញថា ភាពខុសប្លែកគ្នាយ៉ាងច្រើន។ ដើម្បីឱ្យជ្រាប កាន់តែច្បាស់អំពីស្ថានភាពពិតប្រាកដរបស់សមណនិស្សិត និស្សិតថាមានការភាពខុសប្លែកគ្នាយ៉ាងណានោះសូមពិនិត្យមើលទិន្នន័យប្រៀបធៀបខាងក្រោម៖




យោងតាមផាឆាតដែលបានបង្ហាញខាងលើនេះ សបញ្ជាក់ឱ្យឃើញថា សមណនិស្សិតសម្រាប់ឆ្នាំសិក្សា២០២៣-២០២៤ នេះមានត្រឹមតែ **១៩%** ប៉ុណ្ណោះ ចំណែកឯនិស្សិតស្រី មានដល់ទៅ **៥៧%** និស្សិតប្រុសមាន **២៤%** បើពិនិត្យទៅលើទិន្នន័យយើងសង្កេតឃើញថា សមណនិស្សិតពិតជាមានចំនួនតិចណាស់ ព្រោះពុទ្ធិកសាកលវិទ្យាល័យត្រូវបានគេស្គាល់ទូទៅថា ជាសាកលវិទ្យាល័យសម្រាប់ព្រះសង្ឃសិក្សា ច្រើនជាងគ្រហស្ថ ប៉ុន្តែផ្ទុយទៅវិញចំនួនព្រះសង្ឃត្រូវបានថយចុះជាលំដាប់គួរឱ្យមានការបារម្ភសម្រាប់ថ្នាក់ដឹកនាំគ្រប់រូប។ ត្រង់ចំណុចនេះគណៈកម្មការស្រាវជ្រាវនិងចងក្រងរបាយការណ៍ មិនមែនផ្តោតទៅលើតែពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជសាខាខេត្តបាត់ដំបងមួយទេ ប៉ុន្តែនៅគ្រប់ពុទ្ធិកសាកលវិទ្យាល័យទាំងអស់។

នៅក្នុងការបណ្តុះបណ្តាលសមណនិស្សិត និស្សិតថ្នាក់បរិញ្ញាបត្រនេះ ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជសាខាខេត្តបាត់ដំបង បានប្រើប្រាស់គ្រូពីរប្រភេទគឺគ្រូក្របខណ្ឌនិងគ្រូជួល ដែលមានទិន្នន័យដូចខាងក្រោម៖



ដូច្នេះការប្រើប្រាស់គ្រូនៅកម្រិតបរិញ្ញាបត្រពុំមានអ្វីប្រែប្រួលច្រើននោះទេ គឺគ្រូក្របខណ្ឌស្ថិតនៅថេរដដែល ចំណែកឯគ្រូជួលបានកើនឡើងត្រឹម ៥% ប៉ុណ្ណោះ គឺស្របទៅតាមកំណើននៃសមណនិស្សិត និស្សិតផងដែរ។

ដោយឡែកចំពោះការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជសាខាខេត្តបាត់ដំបងបានបើកដំណើរការចំនួន ៣ មហាវិទ្យាល័យ និង ៣ ឯកទេស ដែលមានសមណនិស្សិត និស្សិតកំពុងសិក្សាដូចមានទិន្នន័យបង្ហាញខាងក្រោម៖

| ល.រ | មហាវិទ្យាល័យ | ឯកទេស | សមណនិស្សិត និស្សិត | | | |
|---|---|---|---|---|---|---|
| | | | ព្រះសង្ឃ | ប្រុស | ស្រី | សរុប |
| ១ | ទស្សនវិជ្ជានិងសាសនា | ទស្សនវិជ្ជា | ៧ | ៩ | ១ | ១៧ |
| ២ | អក្សរសាស្ត្រ | អក្សរសាស្ត្រខ្មែរ | ៣ | ៨ | ១២ | ២៣ |
| ៣ | វិទ្យាសាស្ត្រអប់រំនិងព័ត៌មានវិទ្យា | គ្រប់គ្រងអប់រំ | ៦ | ៩ | ១៧ | ៣២ |
| សរុប | | | ១៦ | ២៦ | ៣០ | ៧២ |

នៅក្នុងកិច្ចដំណើរការបណ្តុះបណ្តាលនេះ សមណនិស្សិត និស្សិតបានចាប់អារម្មណ៍ និងយកចិត្តទុកដាក់ខ្ពស់ក្នុងការសិក្សារៀនសូត្រ ព្រមជាមួយគ្នានេះដែរ ការបណ្តុះបណ្តាលសមណនិស្សិត និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់សម្រាប់ឆ្នាំសិក្សា២០២៣-២០២៤ នេះក៏មានការប្រែប្រួលមួយចំនួនផងដែរ។ ដូច្នេះ ដើម្បីជ្រាបកាន់តែច្បាស់អំពីស្ថានភាពនៃការប្រែប្រួលសូមពិនិត្យមើលទិន្នន័យប្រៀបធៀបដូចខាងក្រោម៖



យោងតាមទិន្នន័យប្រៀបធៀបខាងលើបានបង្ហាញឱ្យឃើញថា ស្ថានភាពសមណនិស្សិត និស្សិតដែលកំពុងសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ នៃពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជសាខាខេត្តបាត់ដំបង មានការថយចុះរហូតដល់ទៅ **៤៨%** នេះជាកម្រិតនៃការថយចុះដ៏ខ្ពស់បំផុតមិនធ្លាប់ មានពីមុនមក ហើយក៏ជាកត្តាដែលផ្នែកជំនាញត្រូវការសិក្សាស្វែងយល់ឱ្យបានស៊ីជម្រៅអំពីកត្តាប្រឈមទាំងឡាយ ដែលបណ្តាលឱ្យមានការរាំងស្ទះដល់ដំណើរការបណ្តុះបណ្តាលក៏ដូចជាការធ្លាក់ចុះចំនួនសមណនិស្សិត និស្សិតផងដែរ ដើម្បីឱ្យស្វែងរកដំណោះស្រាយឱ្យបានសមស្របឆ្លើយតបឱ្យត្រូវនឹងបញ្ហា ក្នុងវត្ថុបំណងនៃការអភិវឌ្ឍវិស័យពុទ្ធិកសិក្សាឱ្យមានស្ថិរភាពយូរអង្វែងសម្រាប់អនាគតរបស់សង្គមជាតិ និងព្រះពុទ្ធសាសនា។

សម្រាប់គ្រូសាស្ត្រាចារ្យដែលបំពេញការងារបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ត្រូវបានប្រើប្រាស់គ្រូជួលទាំងស្រុងដូចមានទិន្នន័យបង្ហាញខាងក្រោម៖




ចំពោះការប្រើប្រាស់គ្រូពុំមានការប្រែប្រួលឡើយ បើទោះបីជា យ៉ាងណាក៏ដោយ ក៏នៅត្រូវការគ្រូដែលមានជំនាញនិងបទពិសោធបង្រៀនទៅលើឯកទេសនិងមុខវិជ្ជាដែលត្រូវបង្រៀនទាំងនេះជាចាំបាច់មិនអាចខ្វះបានឡើយ កត្តានេះហើយដែលធ្វើឱ្យទិន្នន័យនៃការប្រើប្រាស់គ្រូសាស្ត្រាចារ្យមានចំនួនស្ថិតនៅដដែល។

ពុទ្ធិកសាកលវិទ្យាលព្រះសីហនុរាជទាំង **៣** ទីតាំង គណៈកម្មការស្រាវជ្រាវនិងចងក្រងរបាយការណ៍បានសង្កេតឃើញថា ស្ថានភាពសមណនិស្សិត និស្សិត កំពុងសិក្សារៀនសូត្រថ្នាក់បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មានភាពខុសគ្នាយ៉ាងច្រើន ហើយក៏ជាចំណែកដែលគួរឱ្យចាប់អារម្មណ៍ផងដែរ។ ដូច្នេះ សូមពិនិត្យមើលទិន្នន័យប្រៀបធៀបខាងក្រោម៖




យោងតាមការវិភាគទិន្នន័យខាងលើ យើងសង្កេតឃើញថា និស្សិតស្រីដែលកំពុងសិក្សានៅពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជទាំង**៣** ទីតាំង មានភាគរយខ្ពស់ជាងគេបង្អស់គឺមានរហូតដល់ទៅ **៥៩.៤៦%** ចំណែកឯសមណនិស្សិតមានត្រឹមតែ **១៧.៥១%** ប៉ុណ្ណោះ។ ត្រង់ចំណុចនេះហើយដែលជាកត្តាគួរឱ្យចាប់អារម្មណ៍ ព្រោះវាពាក់ព័ន្ធទៅនឹងអត្តសញ្ញាណរបស់វិស័យពុទ្ធិកសិក្សាផងដែរ ហេតុអ្វីបានជាចំនួនសមណនិស្សិត មានភាគរយតិចបែបនេះ? តើទៅថ្ងៃអនាគតការងារបណ្តុះបណ្តាលរបស់ពុទ្ធិកសាកលវិទ្យាល័យអាចនឹងបាត់បង់ចំនួនព្រះសង្ឃទាំងស្រុងដែរឬទេ? តើផ្នែកជំនាញ ពុទ្ធិកសាកលវិទ្យាល័យ និងថ្នាក់ដឹកនាំតាមឋានានុក្រមត្រូវធ្វើដូចម្តេចដើម្បីរក្សាបាននូវនិរន្តរភាពនៃការបណ្តុះបណ្តាល? ជាពិសេសរក្សាឱ្យចំនួនព្រះសង្ឃបន្តការសិក្សាទៅកម្រិតពុទ្ធិកឧត្តមសិក្សា។

ដោយឡែក បើយើងពិនិត្យទៅមើលជំនាញឯកទេសដែលសមណនិស្សិត និស្សិតពេញនិយមក្នុងការសិក្សារៀនសូត្រនៅកម្រិតបរិញ្ញាបត្រ សូមពិនិត្យមើលទិន្នន័យប្រៀបធៀបដូចខាងក្រោម៖



ផ្អែកទៅលើទិន្នន័យដែលបានធ្វើការប្រៀបធៀបបង្ហាញខាងលើនេះ យើងសង្កេតឃើញថា ជំនាញឯកទេសដែលពេញនិយមបំផុតសម្រាប់សមណនិស្សិត និស្សិតសិក្សានៅពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជទាំង ៣ ទីតាំងគឺជំនាញអក្សរសាស្ត្រខ្មែរដែលមានរហូតដល់ ៣១.៣៣%។ ដោយឡែកជំនាញឯកទេដែលទទួលរងនូវហានិភ័យខ្ពស់ជាងគេគឺទស្សនវិជ្ជាពុទ្ធសាសនា ដែលមានសមណនិស្សិត និស្សិតត្រឹមតែ ០.៤៤% ប៉ុណ្ណោះ ដែលបានចាប់យកឯកទេសមួយនេះ។ យោងតាមការសិក្សាស្រាវជ្រាវនិងវិភាគទិន្នន័យដែលបានបង្ហាញខាងលើ គណៈកម្មការស្រាវជ្រាវនិងចងក្រងរបាយការណ៍ នៅពុំទាន់បានធ្វើការសិក្សាឱ្យស៊ីជម្រៅ ថាតើបណ្តាលមកពីកត្តាអ្វីខ្លះដែលធ្វើឱ្យសមណនិស្សិត និស្សិតពុំសូវចាប់អារម្មណ៍សិក្សាឯកទេសទស្សនវិជ្ជាពុទ្ធសាសនានិងឯកទេសដទៃមួយចំនួនទៀតនៅឡើយទេ។ ដើម្បីទទួលបានព័ត៌មានកាន់តែលម្អិតបន្ថែមទៀត គណៈកម្មការស្រាវជ្រាវនិងចងក្រងរបាយការណ៍ នឹងធ្វើការឱ្យបានជិតស្និទ្ធជាមួយពុទ្ធិកសាកលវិទ្យាល័យ ផ្នែកជំនាញ និងអង្គភាពពាក់ព័ន្ធ ដើម្បីស្វែងយល់បន្ថែមអំពីបញ្ហាប្រឈមដែលពុទ្ធិកសាកលវិទ្យាល័យកំពុងជួបប្រទះ និងស្វែងរកដំណោះស្រាយឱ្យបានសមស្របឆ្លើយតបទៅនឹងបញ្ហាទាំងនោះ។

សម្រាប់ឆ្នាំសិក្សា២០២៣-២០២៤ សមណនិស្សិត និស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្រនៅពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជទាំង ៣ ទីតាំងមានស្ថានភាពដូចខាងក្រោម៖



ក្នុងចំណោមទីតាំងទាំង ៣ នៃពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ យើងសង្កេតឃើញថា ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជសាខាខេត្តបាត់ដំបងមានចំនួនសមណនិស្សិត និស្សិតច្រើនជាងគេសម្រាប់ឆ្នាំសិក្សា២០២៣-២០២៤ ដូចមានទិន្នន័យបង្ហាញខាងលើស្រាប់។

ចំពោះការវិភាគទិន្នន័យជារួមយើងពិនិត្យឃើញថា សម្រាប់ឆ្នាំសិក្សា២០២៣-២០២៤ សមណនិស្សិត និស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្រនៅពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជទាំង ៣ ទីតាំងមានការកើនឡើងគួរឱ្យកត់សម្គាល់ ដូច្នេះដើម្បីឱ្យជ្រាបកាន់តែច្បាស់សូមពិនិត្យមើលទិន្នន័យប្រៀបធៀបដូចខាងក្រោម៖




ដូច្នេះបើអង្កេតជារួម សមណនិស្សិត និស្សិតនៃពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជមានការកើនឡើង ២% ក្នុងនោះពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជសាខាខេត្តបាត់ដំបងបានកើនឡើងរហូតដល់ទៅ ៣០% ដែលជាកំណើនខ្ពស់បំផុត បើប្រៀបធៀបទៅនឹងទីតាំង ២ ផ្សេងទៀត។

ចំពោះថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ គណៈកម្មការស្រាវជ្រាវ និងចងក្រងរបាយការណ៍នឹងមិនធ្វើការប្រៀបធៀបទិន្នន័យសមណនិស្សិត និស្សិតកម្រិតនេះឡើយ ដោយសារមានចំនួនតិច ដូច្នេះលោកអ្នកអានទូទៅអាចធ្វើការអង្កេតតាមរយៈរបាយការណ៍នេះ ឬតាមប្រភពផ្សេងៗទៅតាមអធ្យាស្រ័យរបស់ខ្លួនចុះ។

បន្ទាប់ពីការបណ្តុះបណ្តាលអស់រយៈពេលពេញមួយឆ្នាំ សមណនិស្សិត និស្សិតនៃពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជទាំង ៣ ទីតាំងសរុបចំនួន ៣២៣ រូប ក្នុងនោះពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជភ្នំពេញមានសមណនិស្សិត និស្សិតចំនួន ១០២ រូប ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជសាខាខេត្តកំពង់ឆ្នាំងចំនួន ៨៣ រូប និងពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ

សាខាខេត្តបាត់ដំបងចំនួន **១៣២** រូប បានការពារសារណាបញ្ចប់ការសិក្សារបស់ខ្លួន ក្នុងចំណោមនោះសមណនិស្សិត និស្សិតដែលបានការពារជាប់ជាស្ថាពរមានចំនួន **៣១៩** រូបស្មើនឹង **៩៩%** ធ្លាក់ **៤** រូបស្មើនឹង **១%**។

ព្រមជាមួយគ្នានេះដែរ ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជបានធ្វើការប្រឡងជ្រើសរើសសមណសិស្ស សិស្សឱ្យចូលរៀនថ្នាក់ឆ្នាំសិក្សាមូលដ្ឋានសម្រាប់ឆ្នាំសិក្សា២០២៤-២០២៥ ដែលមានបេក្ខសមណៈ បេក្ខជនចូលរួមប្រឡងសរុបមានដូចខាងក្រោម៖

| ល.រ | ពុទ្ធិកសាកលវិទ្យាល័យ ព្រះសីហនុរាជ | សមណសិស្ស សិស្ស | ប្រឡងជាប់ | ភាគរយ | ប្រឡងធ្លាក់ | ភាគរយ |
|---|---|---|---|---|---|---|
| ១ | ភ្នំពេញ | ៤៩៦ | ៤៦៨ | ៩៤% | ២៨ | ៦% |
| ២ | កំពង់ឆ្នាំង | ១២២ | ១១៣ | ៩៣% | ៩ | ៧% |
| ៣ | បាត់ដំបង | ៣៤៥ | ៣៤០ | ៩៩% | ៥ | ១% |
| **សរុប** | | **៩៦៣** | **៩២១** | **៩៦%** | **៤២** | **៤%** |

ក្នុងចំណោមបេក្ខសមណៈ បេក្ខជនដែលប្រឡងជាប់ទាំងអស់ ក្នុងនោះគណៈកម្មការស្រាវជ្រាវនិងចងក្រងរបាយការណ៍នឹងធ្វើការប្រៀបធៀបទៅលើចំនួនសមណសិស្ស សិស្សប្រុស និងសិស្សស្រីដែលបានចូលរួមប្រឡងយកអាហារូបករណ៍១០០%សិក្សារយៈពេល ៤ ឆ្នាំ ដោយមិនមានការបង់ប្រាក់ ព្រោះជាអាហារូបករណ៍ដែលត្រូវបានផ្តល់ប្រគេន ជូនដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់វិស័យពុទ្ធិកសិក្សា ជាពិសេសពុទ្ធិកឧត្តមសិក្សា។

ដូច្នេះ ដើម្បីបានជាមូលដ្ឋានក្នុងការវិភាគនិងវាយតម្លៃពីដំណើរវិវឌ្ឍរបស់ពុទ្ធិកសាកលវិទ្យាល័យ ក៏ដូចជាសក្ខីកម្មបង្ហាញឱ្យឃើញពីការប្រែប្រួលរបស់វិស័យពុទ្ធិកសិក្សាផងដែរ ចូរពិនិត្យនូវទិន្នន័យប្រៀបធៀបដូចខាងក្រោម៖



ផ្អែកទៅលើទិន្នន័យប្រៀបធៀបដែលបានបង្ហាញខាងលើនេះ មានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងទិន្នន័យសមណនិស្សិត និស្សិតដែលកំពុងសិក្សានៅថ្នាក់បរិញ្ញាបត្រផងដែរ គឺនៅតែចំនួនសិស្សស្រីដែលចូលរួមប្រឡងមានភាគរយខ្ពស់ជាងគេ ដែលមានរហូតដល់ទៅ **៦១.២៤%** ចំណែកឯ សមណសិស្សមានត្រឹមតែ **១២.៣៨%** ប៉ុណ្ណោះ សម្រាប់ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជទាំង **០៣** ទីតាំង។

ក្រៅពីការបណ្តុះបណ្តាលពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជទាំង **៣** ទីតាំងបានសម្របសម្រួលលើការងារបច្ចេកទេស និងការងាររដ្ឋបាលទូទៅផ្សេងៗជាច្រើនទៀតក្នុងនោះដែរ ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជបានទទួលលិខិតចូលចំនួន **២១១** ច្បាប់ ចេញលិខិតទៅកាន់ស្ថានប័ននិងអង្គភាពពាក់ព័ន្ធចំនួន **២,៣៨៤** ច្បាប់ បញ្ជូនលិខិតបន្តទៅកាន់អង្គភាពឬស្ថាប័នផ្សេងៗចំនួន**១០០** ច្បាប់ បានរៀបចំបាឋកថាចំនួន **៣១** លើក បានចុះអនុស្សារណៈនៃការយោគយល់ជាមួយស្ថាប័នអប់រំនានាចំនួន **១១** ស្ថាប័ន ប្រជុំបច្ចេកទេសផ្ទៃក្នុងនិងខាងក្រៅអង្គភាពចំនួន **២៦៤**លើក ចេញវិញ្ញាបនបត្របញ្ជាក់ការសិក្សាប្រគេន ជូនសមណនិស្សិត និស្សិតចំនួន **១២៦** សន្លឹក ចេញព្រឹត្តិបត្រពិន្ទុចំនួន **៣១៤** សន្លឹក ចេញវិញ្ញាបនបត្រថ្នាក់ឆ្នាំសិក្សាមូលដ្ឋានចំនួន **១៩៣** សន្លឹក ប្រជុំរៀបចំវាយតម្លៃគុណភាពអប់រំជាមួយគណៈកម្មការវាយតម្លៃគុណភាពអប់រំកម្ពុជា (ACC) ចំនួន **៥២** លើក ចេញសញ្ញាបត្រថ្នាក់បរិញ្ញាបត្របណ្តោះអាសន្នចំនួន**២៨១**សន្លឹកចេញសញ្ញាបត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់បណ្តោះអាសន្នចំនួន**២១**សន្លឹកនិងចូលរួមការងារសប្បុរសធម៌ផ្សេងៗចំនួន **៣៥៩** លើក។

## ឃ- ពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជា

ពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជា គឺជាគ្រឹះស្ថានឧត្តមសិក្សាសាធារណៈរបស់រដ្ឋ ដែលទទួលបានការប្រោសព្រះរាជទានព្រះនាមពីព្រះករុណាព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ដោយមានព្រះនាមថា ពុទ្ធិកមហាវិទ្យាល័យព្រះសីហមុនីរាជា[២០] និងបានបើកដំណើរការបណ្តុះបណ្តាលជាផ្លូវការចាប់តាំងពីឆ្នាំ២០០៧[២១] រហូតមកដល់បច្ចុប្បន្ន។ ជាងនេះទៅទៀត ពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជា ត្រូវបានទទួលស្គាល់ពីគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា (ACC)[២២] ក្នុងការបណ្តុះបណ្តាលថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ស្តីពីការទទួលស្គាល់កម្មវិធីសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋានលើពុទ្ធិកមហាវិទ្យាល័យទស្សនវិជ្ជាសាសនា និងនីតិសាស្ត្រ ពុទ្ធិកមហាវិទ្យាល័យ បាលី-សំស្ក្រឹត និងភាសាបរទេស ពុទ្ធិកមហាវិទ្យាល័យវិទ្យាសាស្ត្រអប់រំ និងអក្សរសាស្ត្រ និងពុទ្ធិកមហាវិទ្យាល័យព័ត៌មានវិទ្យាផងដែរ។

[២០] ថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០៤

[២១] អនុក្រឹត្យលេខ៨៣ អនក្រ ប.ក ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៧

[២២] ស.ជ.ណ លេខ ០៤/២៣ ចុះថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២៣

ពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជា បានចូលជាសមាជិកសមាគមសាកលវិទ្យាល័យអន្តរជាតិ នៃអង្គការសហប្រជាជាតិ (IAU)[២៣] ដែលមានសាកលវិទ្យាល័យជាង **៦០០** ជាសមាជិកមកពី **១៣០** ប្រទេស ទូទាំងពិភពលោក នេះគឺជាប្រវត្តិសាស្ត្រថ្មី ដែលពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជា នៃព្រះរាជាណាចក្រកម្ពុជាក្នុងការលើកកម្ពស់ឧត្តមភាពអប់រំរបស់វិស័យពុទ្ធិកសិក្សាលើឆាកអន្តរជាតិ។

បច្ចុប្បន្ន ពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជា មានសម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតីកិត្តិឧទ្ទេសបណ្ឌិត **ប៊ូរ គ្រី** ជាព្រះសាកលវិទ្យាធិការ និងអមដោយព្រះសាកលវិទ្យាធិការរង សាកលវិទ្យាធិការរងចំនួន **៥** រូប (ស្រី **១**នាក់) ព្រឹទ្ធបុរស **៣** រូប ព្រឹទ្ធបុរសរង **៤** រូប គ្រូក្រុបខណ្ឌ **២** នាក់ និងមន្ត្រីជាប់កិច្ចសន្យាចំនួន **២** នាក់។

នៅក្នុងបេសកកម្មនៃការអភិវឌ្ឍធនធានមនុស្សក្រមិតពុទ្ធិកឧត្តមសិក្សា ពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជាបាននិងកំពុងបើកដំណើរការបណ្តុះបណ្តាលសមណនិស្សិត និស្សិតថ្នាក់បរិញ្ញាបត្រចំនួន **៤** មហាវិទ្យាល័យនិង**៧**ឯកទេសនិងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ចំនួន **៥** ឯកទេសផងដែរ។

**១-ថ្នាក់បរិញ្ញាបត្រ**

| ល.រ | មហាវិទ្យាល័យ | ឯកទេស | សមណនិស្សិត និស្សិត | | | |
|---|---|---|---|---|---|---|
| | | | ព្រះសង្ឃ | ប្រុស | ស្រី | សរុប |
| ១ | ទស្សនវិជ្ជាពុទ្ធសាសនា និងនីតិសាស្ត្រ | នីតិសាស្ត្រ | ១២៤ | ៣៨៦ | ១៩៩ | **៧០៩** |
| | | ទស្សនវិជ្ជា | ១១ | ៣៦ | ១៥ | **៦២** |
| ២ | វិទ្យាសាស្ត្រអប់រំ អក្សរសាស្ត្រ | វិទ្យាសាស្ត្រអប់រំ | ១៣ | ១១៧ | ២៥ | **១៥៥** |
| | | គ្រប់គ្រងទូទៅ | ២៥ | ១៧៤ | ១១៤ | **៣១៣** |
| ៣ | បាលី-សំស្ក្រឹត ភាសាបរទេស | អក្សរសាស្ត្រខ្មែរ | ៨ | ៧០ | ៨៦ | **១៦៤** |
| | | អក្សរសាស្ត្រអង់គ្លេស | ១៦ | ១៨៧ | ១៨០ | **៣៨៣** |
| ៤ | ព័ត៌មានវិទ្យា | ព័ត៌មានវិទ្យា | ១៦ | ១៤២ | ៣៣ | **១៩១** |
| **សរុប** | | | **២១៣** | **១,១១២** | **៦៥២** | **១,៩៧៧** |

នៅក្នុងដំណើរការបណ្តុះបណ្តាលនេះ សមណនិស្សិត និស្សិតទាំងអស់បានយកចិត្តទុកដាក់ខ្ពស់ក្នុងការសិក្សារៀនសូត្រ ដើម្បីទទួលបានចំណេះដឹង ជំនាញ និងសមត្ថភាពទាំងផ្លូវលោកនិងផ្លូវធម៌ ដែលជាប្រយោជន៍ដល់ការអភិវឌ្ឍជីវភាពរស់នៅរបស់ខ្លួនឱ្យកាន់តែមានភាពប្រសើរឡើង និងរក្សាបាននូវគុណតម្លៃដ៏ល្អនៅក្នុងសង្គម។ មិនត្រឹមតែប៉ុណ្ណោះក៏ជាការរួមចំណែកលើកមុខមាត់សង្គមជាតិ ដោយសារការប្រតិបត្តិដ៏ត្រឹមត្រូវទៅតាមគន្លងធម៌ ដែលជាកត្តាដ៏សំខាន់ក្នុងការរក្សានូវតម្លៃរបស់មនុស្សឱ្យមានកិត្យានុភាពនៅក្នុងសង្គមផងដែរ។ ផ្អែកទៅ

[២៣] ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២២

លើទិន្នន័យដែលបានបង្ហាញខាងលើនេះ បានបញ្ជាក់ពីការយកចិត្តទុកដាក់ខ្ពស់របស់សមណនិស្សិត និស្សិតក្នុងការសិក្សារៀនសូត្រទៅលើមុខជំនាញ ឬឯកទេសផ្សេងៗពីគ្នា ទៅតាមចំណូលចិត្តរៀងៗខ្លួន។

សម្រាប់ឆ្នាំសិក្សា២០២៣-២០២៤ សមណនិស្សិត និស្សិតនៃពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជាមានការប្រែប្រួល កើនឡើង ឬថយចុះយ៉ាងណានោះ ចូរអង្កេតទៅលើទិន្នន័យប្រៀបធៀបដូចខាងក្រោម៖




យោងទៅលើទិន្នន័យប្រៀបធៀបខាងលើនេះ បានបង្ហាញឱ្យឃើញថា សមណនិស្សិត និស្សិតមានការកើនឡើងជារួម **១២%** និស្សិតស្រីកើនឡើង **១%** និស្សិតប្រុសកើនឡើង **២១%** ដោយឡែកសម្រាប់សមណនិស្សិតមានការថយចុះរហូតដល់ទៅ **១២%** ទៅវិញ។ ប៉ុន្តែយ៉ាងណាក៏ដោយជាទិដ្ឋភាពរួមយើងសង្កេតឃើញថា ការអប់រំថ្នាក់បរិញ្ញាបត្រនៃពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជា ក៏បានបង្ហាញនូវសញ្ញាណវិជ្ជមានក្នុងការរួមចំណែកអភិវឌ្ឍធនធានមនុស្សកម្រិតឧត្តមសិក្សាគួរឱ្យកត់សម្គាល់ផងដែរ។ ម្យ៉ាងវិញទៀត សម្រាប់សមណនិស្សិត និស្សិតទាំង **៣** ភេទ កំពុងសិក្សានៅពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជា មានចំនួនខុសៗគ្នាគួរឱ្យកត់សម្គាល់ ដូច្នេះដើម្បីងាយស្រួលដល់ការអង្កេតគណៈកម្មការស្រាវជ្រាវនិងចងក្រងរបាយការណ៍ នឹងបង្ហាញនូវទិន្នន័យប្រៀបធៀបដូចខាងក្រោម៖




សម្រាប់ទិន្នន័យប្រៀបធៀបនេះ គណៈកម្មការស្រាវជ្រាវនិងចងក្រងរបាយការណ៍បានសង្កេតឃើញថា និស្សិតប្រុសមានរហូតដល់ទៅ **៥៦.២៥%** ដោយឡែកសមណនិស្សិតមានត្រឹមតែ **១០.៧៧%** ប៉ុណ្ណោះ ដែលជាភាគរយទាបបំផុតសម្រាប់ពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជា ក៏ដូចជាពុទ្ធិកសាកលវិទ្យាល័យដទៃទៀតដែរ។ ការចាប់អារម្មណ៍ត្រង់ចំណុចនេះ ចង់បង្ហាញឱ្យឃើញពីអត្តសញ្ញាណនៃពុទ្ធិកសាកលវិទ្យាល័យ ដែលត្រូវបានគេស្គាល់ជាទូទៅថាជាសាកលវិទ្យាល័យសម្រាប់ព្រះសង្ឃ ប៉ុន្តែផ្ទុយទៅវិញ ចំនួនព្រះសង្ឃដែលសិក្សានៅតាមពុទ្ធិកសាកលវិទ្យាល័យតែងមានការថយចុះជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ។ ទាំងនេះក៏ជាក្ដីបារម្ភសម្រាប់ថ្នាក់ដឹកនាំតាមឋានានុក្រមពីអនាគតរបស់វិស័យអប់រំពុទ្ធិកសិក្សានៅកម្រិតឧត្តមសិក្សាផងដែរ។

ព្រមជាមួយគ្នានេះដែរ គណៈកម្មការស្រាវជ្រាវនិងចងក្រងរបាយការណ៍បានសង្កេតឃើញថា សមណនិស្សិត និស្សិតកំពុងសិក្សានៅពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជា បានចាប់អារម្មណ៍សិក្សារៀនសូត្រលើឯកទេសផ្សេងៗពីគ្នាទៅតាមចំណូលចិត្តរៀងៗខ្លួន។ ដូច្នេះដើម្បីជ្រាបកាន់តែច្បាស់ថា តើឯកទេសណាមួយ ដែលមានភាពពេញនិយមជាងគេសម្រាប់សមណនិស្សិត និស្សិតនៃពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជា ចូរមើលទិន្នន័យប្រៀបធៀបដូចខាងក្រោម៖




ភស្តុតាងបង្ហាញខាងលើនេះ បានបញ្ជាក់យ៉ាងច្បាស់ថា បច្ចុប្បន្នសមណនិស្សិត និស្សិតបានចាប់អារម្មណ៍ខ្ពស់ទៅលើឯកទេសនីតិសាស្ត្រដែលមានរហូតដល់ទៅ **៣៥.៨៦%** សម្រាប់ជំនាញដែលជាអត្តសញ្ញាណរបស់ពុទ្ធិកសាកលវិទ្យាល័យ គឺទស្សនវិជ្ជាព្រះពុទ្ធសាសនាមានត្រឹមតែ **៣.១៤%** ប៉ុណ្ណោះដែលទទួលបានការចាប់អារម្មណ៍ពីសមណនិស្សិត និស្សិត។

ដើម្បីបណ្តុះបណ្តាលសមណនិស្សិត និស្សិតប្រកបដោយប្រសិទ្ធភាពខ្ពស់ចាំបាច់ត្រូវតែមានការចូលរួមយ៉ាងសកម្មពីសំណាក់លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ ដែលមានចំណេះដឹង ជំនាញ និងបទពិសោធគ្រប់គ្រាន់ទៅលើមុខវិជ្ជាដែលខ្លួនបង្ហាត់ ដែលជាកត្តាដ៏សំខាន់ក្នុងការផ្ទេរចំណេះដឹងដល់សមណនិស្សិត និស្សិតឱ្យស្របនឹងភាពរីកចម្រើននៃសង្គមនាពេលបច្ចុប្បន្ន។ ឆ្នាំសិក្សា ២០២៣-២០២៤ ពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជាបានប្រើប្រាស់គ្រូ **២** ប្រភេទគឺគ្រូក្របខណ្ឌចំនួន **៤** រូប និងគ្រូជួលចំនួន **១១១** សរុបស្មើនឹង **១១៥** រូប ដើម្បីបង្ហាត់បង្រៀននៅថ្នាក់បរិញ្ញាបត្រ។ ចំពោះការប្រើប្រាស់គ្រូសាស្ត្រាចារ្យ របស់ពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជាមានភាពប្រែប្រួលទៅតាមស្ថានភាពជាក់ស្តែងសមណនិស្សិត និស្សិតនិងទៅតាមតម្រូវការចាំបាច់ និងគោលការណ៍ដែលបានកំណត់នៅក្នុងផែនការប្រចាំឆ្នាំ ក្នុងការជ្រើសរើសសមណសិស្ស សិស្សអាហារូបករណ៍ **១០០%** ឱ្យសិក្សារយៈពេល **៤** ឆ្នាំ ដោយមិនមានការបង់ថ្លៃ។

ដូច្នេះ ដើម្បីជ្រាបកាន់តែច្បាស់អំពីភាពប្រែប្រួលនៃការប្រើប្រាស់គ្រូសាស្ត្រាចារ្យនៅពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជាមានស្ថានភាពយ៉ាងណានោះសូមពិនិត្យមើលទិន្នន័យប្រៀបធៀបដូចខាងក្រោម៖




ផ្អែកទៅលើទិន្នន័យប្រៀបធៀបនេះ បានបង្ហាញឱ្យឃើញថា ការប្រើប្រាស់គ្រូសម្រាប់ឆ្នាំ ២០២៣-២០២៤ របស់ពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជាបានថយចុះ **៤៩%** បើប្រៀបធៀបទៅនឹងឆ្នាំចាស់។ ប៉ុន្តែចំពោះប្រសិទ្ធភាពនៃការបង្រៀននិងការគ្រប់គ្រងថ្នាក់គួរតែត្រូវបានសិក្សាបន្ថែមទៀត ព្រោះបើពិនិត្យទៅមើលពីចំនួនសមណនិស្សិត និស្សិត និងសមតុល្យរបស់គ្រូអាចជួបប្រទះនូវបញ្ហាប្រឈមច្រើន ដោយសារគ្រូសាស្ត្រាចារ្យមានចំនួនថយចុះស្មើតែ **៥០%** តើពុទ្ធិកសាកលវិទ្យាល័យចាត់ចែងប្រើប្រាស់ដោយរបៀបណា ដើម្បីឱ្យការបណ្តុះបណ្តាលមានប្រសិទ្ធភាពខ្ពស់។ យ៉ាងណាក៏ដោយ ពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជាបានរួមចំណែកជាច្រើនក្នុងការប្រើប្រាស់ធនធានគ្រូសាស្ត្រាចារ្យឱ្យអស់ពីលទ្ធភាព និងទទួលបានលទ្ធផលល្អក្នុងការបណ្តុះបណ្តាលផងដែរ។

## ២-ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

| ល.រ | ឯកទេស | សមណនិស្សិត និស្សិត | | | |
|---|---|---|---|---|---|
| | | ព្រះសង្ឃ | ប្រុស | ស្រី | សរុប |
| ១ | រដ្ឋបាលសាធារណៈ | ៣៨ | ១៣៧ | ៥១ | ២២៦ |
| ២ | នីតិឯកជន | ៤ | ៣១ | ២៨ | ៦៣ |
| ៣ | គ្រប់គ្រងទូទៅ | ១៥ | ៦០ | ២៨ | ១០៣ |
| ៤ | វិទ្យាសាស្ត្រអប់រំ | ១១ | ២៦ | ២៦ | ៦៣ |
| ៥ | អក្សរសាស្ត្រខ្មែរ | ១ | ១៤ | ០ | ១៥ |
| **សរុប** | | **៦៩** | **២៦៨** | **១៣៣** | **៤៧០** |

ដំណើរការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ របស់ពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជាបានប្រព្រឹត្តទៅជាប្រក្រតី ដោយមានសមណនិស្សិត និស្សិតបានសិក្សារៀនសូត្រយ៉ាងយកចិត្តទុកដាក់ និងប្រកបដោយភាពសកម្ម។ យ៉ាងណាក៏ដោយ ចំពោះស្ថានភាពនៃការបណ្តុះបណ្តាលនេះក៏មានភាពប្រែប្រួលទៅតាមដំណើរវិវឌ្ឍនៃសេដ្ឋកិច្ចនិងសង្គមកម្ពុជាផងដែរ។ ព្រោះកត្តាសេដ្ឋកិច្ចគឺជាចំណុចស្នូល របស់សាធារណជនទូទៅ ក៏ដូចជាសមណនិស្សិត និស្សិតដែលអាចមានលទ្ធភាពក្នុងការចំណាយទៅលើការសិក្សារបស់ខ្លួន ដោយសារការសិក្សាចាប់ពីកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ឡើងទៅ សម្រាប់ការសិក្សានៅតាមបណ្តាពុទ្ធិកសាកលវិទ្យាល័យទាំងអស់នឹងពុំទទួលបានអាហារូបករណ៍សិក្សាដោយអត់បង់ថ្លៃនោះឡើយ។ ហេតុនេះហើយ សាមីជនចាំបាច់ត្រូវត្រៀមថវិកាបង់ថ្លៃសិក្សាដោយខ្លួនឯង ម្យ៉ាងទៀត ការបន្តការសិក្សានៅកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ក៏ត្រូវពឹងផ្អែកទៅលើឆន្ទៈរបស់សិក្ខាកាមទាំងអស់នោះផងដែរ។ ទាំងនេះហើយដែលជាកត្តាដ៏សំខាន់នាំឱ្យសមណនិស្សិត និស្សិតសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មានចំនួនតិចជាងនៅកម្រិតបរិញ្ញាបត្រ។ ដើម្បីឱ្យបានជ្រាបកាន់តែច្បាស់អំពីស្ថានភាពសមណនិស្សិត និស្សិតដែលបានបន្តការសិក្សានៅថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មានឱនភាពឬរីកចម្រើនយ៉ាងណានោះ សូមពិនិត្យមើលទិន្នន័យប្រៀបធៀបដូចខាងក្រោម៖



សម្រាប់ឆ្នាំសិក្សា២០២៣-២០២៤ សមណនិស្សិត និស្សិតមានការកើនឡើងជារួម **៣២%** ដោយឡែកសមណនិស្សិតបានថយចុះ **៧%** នេះបើយោងទៅលើទិន្នន័យប្រៀបធៀបដែលបានបង្ហាញខាងលើ។

នៅក្នុងការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ របស់ពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជានាពេលបច្ចុប្បន្ន បានប្រើប្រាស់គ្រូជួលទាំងស្រុងសរុបមានចំនួន **៣២** រូប។

ក្រៅពីនេះ ពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជាបានរៀបចំប្រឡងជ្រើសរើសសមណនិស្សិត និស្សិតអាហារូបករណ៍ **១០០%** ឱ្យចូលរៀនថ្នាក់ឆ្នាំសិក្សាមូលដ្ឋានឆ្នាំ២០២៤-២០២៥ ចំនួន**១,៣៦២** រូប ប្រឡងជាប់**១,២៥៥** រូប និងប្រឡងធ្លាក់**១០៧** រូប។ ចំណែកឯសមណនិស្សិត និស្សិតចំនួន**១៧២** រូបបានការពារសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រដោយជោគជ័យ។

សម្រាប់ការងារបច្ចេកទេសរដ្ឋបាលទូទៅ ពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជា បានទទួលលិខិតចូលចំនួន**៤២** ច្បាប់ ចេញលិខិតទៅកាន់អង្គភាពនិងស្ថាប័នពាក់ព័ន្ធនានាចំនួន **៥៤** ច្បាប់ ប្រជុំបច្ចេកទេសផ្ទៃក្នុងនិងខាងក្រៅអង្គភាពចំនួន **១៤** លើក បានរៀបចំពិធីចែកសញ្ញាបត្រថ្នាក់បរិញ្ញាបត្រនិងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដល់សមណនិស្សិត និស្សិតចំនួន **៥៧១** ច្បាប់។

## ខ- ពុទ្ធិកសាកលវិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

សកម្មភាពនៃការបណ្តុះបណ្តាលសមណនិស្សិត និស្សិតកម្រិតពុទ្ធិកឧត្តមសិក្សាបានប្រព្រឹត្តទៅជាប្រក្រតី និងមានភាពសកម្ម ធ្វើយ៉ាងណាផ្តល់ឱកាសឱ្យបានច្រើនដល់កុលបុត្រខ្មែរទូទៅដែលមានស្ថានភាពគ្រួសារក្រីក្រលំបាក ទទួលបានការអប់រំថ្នាក់ឧត្តមសិក្សាប្រកបដោយភាពស្មើគ្នា ដោយមិនមានការប្រកាន់ជាតិសាសន៍ ពណ៌សម្បុរ ឬសាសនាឡើយ។ ក្នុងន័យនេះ វិស័យអប់រំពុទ្ធិកសិក្សាបានបើកទូលាយ សម្រាប់មហាជនទូទៅក្នុងការបន្តការអប់រំរបស់ខ្លួនឱ្យកាន់តែមានភាពប្រសើរឡើងថែមទៀត ដើម្បីរួមចំណែកអភិវឌ្ឍសង្គមជាតិនិងព្រះពុទ្ធសាសនាប្រកបដោយការទទួលខុសត្រូវខ្ពស់។

ពុទ្ធិកសាកលវិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** មានគណៈគ្រប់គ្រងព្រះមន្ត្រីសង្ឃ មន្ត្រីរាជការ សាស្ត្រាចារ្យក្របខណ្ឌ និងមន្ត្រីជាប់កិច្ចសន្យាកំពុងបម្រើការងារសរុបចំនួន **៥១** រូប (ព្រះសាកលវិទ្យាធិការ **០១** អង្គ សាកលវិទ្យាធិការរង **០២** នាក់ ព្រឹទ្ធបុរស **០៣** នាក់ ព្រឹទ្ធបុរសរង **០៧** នាក់ ប្រធានការិយាល័យ **០៦** រូប អនុប្រធានការិយាល័យ **០៤** នាក់ មន្ត្រីក្របខណ្ឌ **០៥** នាក់ មន្ត្រីជាប់កិច្ចសន្យា **១៧** រូប និងគ្រូសាស្ត្រាចារ្យក្របខណ្ឌ **០៦** នាក់)។

ដើម្បីសម្របសម្រួលការងារទូទៅឱ្យមានដំណើរការល្អ ពុទ្ធិកសាកលវិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន បានទទួលលិខិតចូលមកពីប្រភពនានាចំនួន **១០៧** ច្បាប់ ចេញលិខិតទៅកាន់អង្គភាពនិងស្ថាប័នពាក់ព័ន្ធចំនួន **៩៦១** ច្បាប់ ប្រជុំបច្ចេកទេសផ្ទៃក្នុងនិងខាង

ក្រៅអង្គភាពចំនួន **៨២** លើក ធ្វើបាឋកថាចំនួន **០៥** លើក ចេញសញ្ញាបត្រថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ចំនួន **៧៩៨** ច្បាប់ប្រគេន ជូនសមណនិស្សិត និស្សិតយកទៅប្រើប្រាស់ ចេញសញ្ញាបត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ចំនួន **១៦៧** ច្បាប់។

សម្រាប់ឆ្នាំសិក្សា២០២៣-២០២៤ ពុទ្ធិកសាកលវិទ្យាល័យសម្ដេចអគ្គមហាសេនាបតី តេជោ **ហ៊ុន សែន** បាននិងកំពុងបន្តបណ្ដុះបណ្ដាលសមណនិស្សិត និស្សិតទាំងពីរកម្រិតគឺថ្នាក់បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់។ ក្នុងនោះដែរ សម្រាប់ថ្នាក់បរិញ្ញាបត្រ ដែលពុទ្ធិកសាកលវិទ្យាល័យបាននិងកំពុងដំណើរការបណ្ដុះបណ្ដាលមានចំនួន **០៣** មហាវិទ្យាល័យនិង **០៣** ឯកទេស។

### ១-ថ្នាក់បរិញ្ញាបត្រ

| ល.រ | មហាវិទ្យាល័យ | ឯកទេស | សរុប | | | |
|---|---|---|---|---|---|---|
| | | | **ព្រះសង្ឃ** | **ប្រុស** | **ស្រី** | **សរុប** |
| ១ | ទស្សនវិជ្ជានិងសាសនា | ទស្សនពុទ្ធសាសនា | ១ | ០ | ៣ | ៤ |
| | | នីតិសាស្ត្រ | ២២ | ៩១ | ៨២ | ១៩៥ |
| ២ | វិទ្យាសាស្ត្រសង្គម | រដ្ឋបាលអប់រំ | ៣១ | ១១០ | ២២១ | ៣៦២ |
| | | គ្រប់គ្រងទូទៅ | ៤ | ៥៦ | ៦៨ | ១២៨ |
| ៣ | បាលី-សំស្ក្រឹតនិងភាសាបរទេស | អក្សរសាស្ត្រខ្មែរ | ១៤ | ៧៣ | ២៦២ | ៣៤៩ |
| | | អក្សរស/អង់គ្លេស | ៣ | ១៦ | ២០ | ៣៩ |
| **សរុប** | | | **៧៥** | **៣៤៦** | **៦៥៦** | **១,០៧៧** |

ដំណើរការបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្របានប្រព្រឹត្តទៅជាប្រក្រតី និងមានការចូលរួមយ៉ាងសកម្មពីសមណនិស្សិត និស្សិតក្នុងការសិក្សារៀនសូត្រយ៉ាងយកចិត្តទុកដាក់ប្រកបដោយការទទួលខុសត្រូវខ្ពស់ មិនត្រឹមតែប៉ុណ្ណោះក៏ជាការរួមចំណែកពង្រឹងសមត្ថភាពរបស់ខ្លួនក្នុងការលើកកម្ពស់គុណតម្លៃ នៃការអប់រំនិងអភិវឌ្ឍចំណេះដឹងឱ្យកាន់តែមានភាពទូលំទូលាយបន្ថែមទៀត។

ក្នុងនេះដែរពុទ្ធិកសាកលវិទ្យាល័យសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** បានដើរតួនាទីយ៉ាងសំខាន់ក្នុងការកៀរគរនិងផ្ដល់ឱកាសឱ្យសមណនិស្សិត និស្សិត គ្រប់ស្រទាប់វណ្ណៈ បានទទួលការអប់រំកម្រិតឧត្តមសិក្សាប្រកបដោយភាពស្មើគ្នា ដោយមិនប្រកាន់វណ្ណៈ ពណ៌សម្បុរ ឬសាសនាឡើយ។ សម្រាប់ឆ្នាំសិក្សា២០២៣-២០២៤ សមណនិស្សិត និស្សិតដែលសិក្សាថ្នាក់បរិញ្ញាបត្រនៅពុទ្ធិកសាកលវិទ្យាល័យសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** មានស្ថានភាពប្រែប្រួលមួយចំនួនដូចមានទិន្នន័យប្រៀបធៀបខាងក្រោម៖




យោងតាមទិន្នន័យប្រៀបធៀបខាងលើនេះ បានបង្ហាញឱ្យឃើញចំណុចវិជ្ជមានច្រើននៅក្នុងនោះសមណនិស្សិត និស្សិតមានការកើនរហូតដល់ទៅ **២៩%** នេះបើគិតជារួម។ បើវិភាគដោយផ្នែក គណៈកម្មការស្រាវជ្រាវនិងចងក្រងរបាយការណ៍បានពិនិត្យឃើញថា សមណនិស្សិតកើនឡើង **២៩%** និស្សិតប្រុសកើនឡើង **៣៦%** និងនិស្សិតស្រីកើនឡើង **២៦%** ។ ដូច្នេះទាំងនេះគឺជាការរួមចំណែកយ៉ាងច្រើន របស់ពុទ្ធិកសាកលវិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**ក្នុងការអភិវឌ្ឍធនធានមនុស្សសម្រាប់សង្គមកម្ពុជានិងព្រះពុទ្ធសាសនា។

សម្រាប់ឆ្នាំសិក្សា២០២៣-២០២៤ បើយើងធ្វើការវិភាគប្រៀបធៀបទៅលើទិន្នន័យសមណនិស្សិត និស្សិតទាំង ០៣ ភេទ (បព្វជិត ប្រុស និងស្រី) មានភាពខុសគ្នាដូចខាងក្រោម៖



សម្រាប់សមណនិស្សិត និស្សិតទាំង ០៣ ភេទនៃពុទ្ធិកសាកលវិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន យើងពិនិត្យឃើញថា និស្សិតប្រុសមានចំនួនច្រើនលើសលប់គឺមានរហូតដល់ទៅ **៦០.៩១%** ចំណែកឯសមណនិស្សិតមានត្រឹមតែ **៦.៩៦%** ប៉ុណ្ណោះ ដែលជាចំនួនតិចបំផុតគួរឱ្យបារម្ភ ព្រោះនេះជាពុទ្ធិកសាកលវិទ្យាល័យ ដូច្នេះអត្តសញ្ញាណអាចប្រឈមទៅនឹងហានិភ័យច្រើន ដែលថ្នាក់ដឹកនាំតាមឋានានុក្រមគប្បីយកព្រះទ័យទុកដាក់ឱ្យបានច្រើនបន្ថែមទៀត ដើម្បីពង្រឹងវិស័យអប់រំពុទ្ធិកឧត្តមសិក្សាឱ្យមានស្ថិរភាពយូរអង្វែងបន្តទៀត ពុំនោះទេអាចប្រឈមទៅនឹងមាត់ជ្រោះ នៃការបាត់បង់អត្តសញ្ញាណពុទ្ធិកសិក្សាទាំងស្រុងជាក់ជាមិនខានឡើយ។ ម្យ៉ាងទៀត បើយើងធ្វើការប្រៀបធៀបទៅលើជំនាញឯកទេសដែលជាអត្តសញ្ញាណរបស់វិស័យពុទ្ធិកសិក្សាផងដែរនោះ សាធារណជនទូទៅនឹងមើលឃើញថា តើជំនាញឯកទេសអ្វីខ្លះដែលសមណនិស្សិត និស្សិតបានយកចិត្តទុកដាក់និងជ្រើសរើសយកជាជំនាញអាជីពសម្រាប់ថ្ងៃអនាគតរបស់ខ្លួន។

ដូច្នេះ ដើម្បីជ្រាបកាន់តែច្បាស់សូមពិនិត្យមើលទិន្នន័យប្រៀបធៀបដូចខាងក្រោម៖




បើសង្កេតទៅលើស្ថានភាពជាក់ស្តែងនៃការវិភាគប្រៀបធៀបទិន្នន័យខាងលើ គណៈកម្ម-ការស្រាវជ្រាវនិងចងក្រងរបាយការណ៍ ពិនិត្យឃើញថា ជំនាញឯកទេសដែលសមណនិស្សិតនិស្សិតចាប់អារម្មណ៍ជាងគេមានរដ្ឋបាលអប់រំ **៣៣.៦%**និងអក្សរសាស្ត្រខ្មែរមាន **៣២.៣%** ដោយឡែកសម្រាប់ជំនាញឯកទេសដែលប្រឈមទៅនឹងហានិភ័យខ្ពស់បំផុត សម្រាប់វិស័យអប់រំពុទ្ធិកឧត្តមសិក្សានោះគឺទស្សនវិជ្ជាពុទ្ធសាសនាមានត្រឹមតែ **០.៤%** ប៉ុណ្ណោះ។ យោងតាមទិន្នន័យ

ដែលបានរកឃើញនេះ បានជាមូលដ្ឋានសម្រាប់ថ្នាក់ដឹកនាំតាមឋានានុក្រមអាចធ្វើការវិភាគពិចារណា និងស្វែងរកឫសគល់ឱ្យបានច្បាស់លាស់បន្ថែមទៀតថា តើបណ្តាលមកពីកត្តាអ្វីខ្លះដែលនាំឱ្យសមណនិស្សិត និស្សិតមិនសូវចាប់អារម្មណ៍ទៅលើជំនាញឯកទេសទាំងនោះ? តើពុទ្ធិកសាកលវិទ្យាល័យត្រូវធ្វើអ្វីខ្លះដើម្បីពង្រឹង និងទាក់ទាញការចាប់អារម្មណ៍ឡើងវិញ?

ដើម្បីអាចដំណើរការបណ្តុះបណ្តាលសមណនិស្សិត និស្សិតប្រកបដោយប្រសិទ្ធភាពខ្ពស់ និងទទួលបានការគាំទ្រពីសាធារណជនទូទៅនោះ ដោយសារមានការចូលរួមយ៉ាងសកម្មពីសំណាក់ព្រះអង្គគ្រូ លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ ដែលមានចំណេះដឹង សមត្ថភាព និងបទពិសោធខ្ពស់ក្នុងការផ្ទេរចំណេះដឹងដល់សមណនិស្សិត និស្សិត ប្រកបដោយឆន្ទៈ មនសិការដោយមិនគិតពីការនឿយហត់នោះឡើយ។ ក្នុងនោះដែរព្រះអង្គគ្រូ លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យទាំង ០២ ប្រភេទគឺគ្រូក្របខណ្ឌនិងគ្រូជួលដែលបម្រើការងារនៅពុទ្ធិកសាកលវិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** មានទិន្នន័យដូចខាងក្រោម៖




ថ្វីដ្បិតតែចំនួនសមណនិស្សិត និស្សិតមានការកើនឡើងក៏ពិតមែន ប៉ុន្តែចំពោះការប្រើប្រាស់គ្រូពុំមានការប្រែប្រួលច្រើនឡើយ ដូចមានទិន្នន័យដែលបានបង្ហាញខាងលើស្រាប់ ត្រង់ចំណុចនេះ គណៈកម្មការស្រាវជ្រាវនិងចងក្រងរបាយការណ៍គ្រាន់តែចង់បង្ហាញឱ្យឃើញពីភាពលម្អៀងគ្នាតិចតួចរវាងសមាមាត្រសមណនិស្សិត និស្សិតនិងចំនួនគ្រូបង្រៀន ដែលអាចប្រព្រឹត្តទៅជាប្រក្រតីបាន។ ព្រោះចំនួនគ្រូបានថយចុះត្រឹមតែ **២%** ប៉ុណ្ណោះ បើមើលទៅលើតួលេខ ចំនួនគ្រូបានថយចុះត្រឹមតែមួយប៉ុណ្ណោះ ដូច្នេះពុំមានបញ្ហាប្រឈមអ្វីធ្ងន់ធ្ងរសម្រាប់ការបណ្តុះបណ្តាលនោះឡើយ ព្រោះពុទ្ធិកសាកលវិទ្យាល័យអាចសម្របសម្រួលបំពេញបន្ថែមនៅចំណុចខ្វះចន្លោះទាំងនោះបាន។

## ២- ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

| ល.រ | មហាវិទ្យាល័យ | ឯកទេស | សមណនិស្សិត និស្សិត | | | |
|---|---|---|---|---|---|---|
| | | | ព្រះសង្ឃ | ប្រុស | ស្រី | សរុប |
| ១ | អក្សរសាស្ត្រ | អក្សរសាស្ត្រខ្មែរ | ៣ | ៩ | ១៣ | ២៥ |
| ២ | វិទ្យាសាស្ត្រអប់រំ និងព័ត៌មានវិទ្យា | រដ្ឋបាលសាធារណៈ | ១៤ | ៥៩ | ១៦ | ៨៩ |
| **សរុប** | | | **១៧** | **៦៨** | **២៩** | **១១៤** |

សម្រាប់ការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់បានប្រព្រឹត្តទៅជាប្រក្រតី ក្នុងនោះដែរ ស្ថានភាពសមណនិស្សិត និស្សិតអាចមានការប្រែប្រួលខ្លះ បើប្រៀបធៀបទៅនឹងឆ្នាំសិក្សា ២០២២-២០២៣។ ដូច្នេះ ដើម្បីងាយស្រួលដល់ការពិនិត្យនិងវាយតម្លៃ គណៈកម្មការស្រាវជ្រាវ និងចងក្រងរបាយការណ៍នឹងបង្ហាញទិន្នន័យប្រៀបធៀបដូចខាងក្រោម៖




សមណនិស្សិត និស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅពុទ្ធិកសាកលវិទ្យាល័យសម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន នាពេលបច្ចុប្បន្នមានការថយចុះជារួម **១៨%** ក្នុងនោះដែរ ចំពោះនិស្សិតប្រុសថយចុះ **១៥%** និងនិស្សិតស្រីថយចុះ **៣៤%**។

ដោយឡែកសម្រាប់ធនធានគ្រូបង្រៀនកំពុងបម្រើការងារនាពេលបច្ចុប្បន្នមានចំនួន **១៨** រូប សម្រាប់ធនធានគ្រូទាំងអស់នេះគឺជាគ្រូជួលសុទ្ធសាធ មិនមានគ្រូក្របខណ្ឌឡើយ។

ក្រៅពីការងារបណ្ដុះបណ្ដាលខាងលើ ពុទ្ធិកសាកលវិទ្យាល័យសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** បានធ្វើការប្រឡងជ្រើសរើសសមណសិស្ស សិស្សអាហារូបករណ៍ **១០០%** ឱ្យចូលរៀនថ្នាក់ឆ្នាំសិក្សាមូលដ្ឋានចំនួន**៥៣៨**រូប ប្រឡងជាប់ចំនួន **៤៨៥**រូប និងប្រឡងធ្លាក់ **៥៣**រូប។ ម្យ៉ាងទៀត សមណនិស្សិត និស្សិតថ្នាក់បរិញ្ញាបត្រចំនួន **១០៦** រូប បានការពារសារណាបញ្ចប់ការសិក្សារបស់ខ្លួនដោយជោគជ័យផងដែរ។

ក្នុងចំណោមពុទ្ធិកសាកលវិទ្យាល័យទាំង ៣ គឺពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ ពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជា និងពុទ្ធិកសាកលវិទ្យាល័យសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន មានស្ថានភាពសមណនិស្សិត និស្សិត កំពុងសិក្សាមានភាពខុសគ្នាដូចមានទិន្នន័យបង្ហាញខាងក្រោម៖




យោងទៅលើទិន្នន័យដែលបានបង្ហាញខាងលើសបញ្ជាក់ឱ្យឃើញថា ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជនៅតែស្ថិតនៅលំដាប់កំពូលក្នុងចំណោម ពុទ្ធិកសាកលវិទ្យាល័យទាំង ៣ ដែលទទួលបានការគាំទ្រ មានទំនុកចិត្តខ្ពស់ពីសមណនិស្សិត និស្សិតក៏ដូចជាសាធារណជនទូទៅផងដែរ។ មិនត្រឹមតែប៉ុណ្ណោះសម្រាប់សមណនិស្សិតក៏នៅតែមានចំនួនច្រើនបើប្រៀបធៀបទៅនឹងពុទ្ធិកសាកលវិទ្យាល័យដទៃទៀត។ ទោះជាយ៉ាងក៏ដោយ ពុទ្ធិកសាកលវិទ្យាល័យទាំងអស់បាន

រួមចំណែកយ៉ាងច្រើនក្នុងការអភិវឌ្ឍធនធានមនុស្ស ជាពិសេសធនធានព្រះសង្ឃកម្រិតពុទ្ធិកឧត្តមសិក្សាសម្រាប់សង្គមជាតិនិងព្រះពុទ្ធសាសនាឱ្យមាននិរន្តរភាពយូរអង្វែង និងលើកកម្ពស់គុណតម្លៃនៃការអប់រំឱ្យកាន់តែមានភាពប្រសើរបន្ថែមទៀត។

លើសពីនេះទៅទៀត គណៈកម្មការស្រាវជ្រាវនិងចងក្រងរបាយការណ៍នឹងបង្ហាញឱ្យឃើញបន្ថែមទៀត អំពីបរិបទអប់រំក្នុងវិស័យពុទ្ធិកឧត្តមសិក្សាដែលមានការប្រែប្រួលយ៉ាងច្រើនបើប្រៀបធៀបទៅនឹងសម័យអតីតកាល។ ព្រោះពីអតីតកាល មានព្រះសង្ឃស្ទើរតែ ១០០% សិក្សានៅពុទ្ធិកសាកលវិទ្យាល័យ ប៉ុន្តែបើប្រៀបធៀបឆ្នាំសិក្សា២០២៣-២០២៤ ស្ថានភាពសមណនិស្សិត និស្សិត មានដូចខាងក្រោម៖




ទិន្នន័យដែលបានធ្វើការវិភាគបង្ហាញខាងលើនេះ សបញ្ជាក់ឱ្យឃើញថា ដំណើរការបណ្តុះបណ្តាលរបស់វិស័យពុទ្ធិកឧត្តមសិក្សា មានការប្រែប្រួលលើសពីការរំពឹងទុកដែលធ្លាប់មានកន្លងមក ពីព្រោះទិន្នន័យបានបង្ហាញថា ក្នុងចំណោមពុទ្ធិកសាកលវិទ្យាល័យទាំង ៣ មានសមណនិស្សិតសិក្សាត្រឹមតែ ១២.៩% ប៉ុណ្ណោះ ហើយអ្វីដែលពិសេសជាងនេះទៅទៀត និស្សិតស្រីមានរហូតដល់ទៅ ៤៩.៩% ដែលជាចំនួនច្រើនលើសលប់គួរឱ្យកត់សម្គាល់។ ត្រង់ចំណុចនេះ គណៈ-កម្មការស្រាវជ្រាវនិងចងក្រងរបាយការណ៍នឹងធ្វើការសិក្សាបន្ថែមទៀត ថាតើមានកត្តាជំរុញអ្វីខ្លះដែលនាំឱ្យនិស្សិតស្រីមានការចាប់អារម្មណ៍បន្តការសិក្សា នៅកម្រិតពុទ្ធិកឧត្តមសិក្សាមានការកើនឡើងជាបន្តបន្ទាប់ជារៀងរាល់ឆ្នាំ?

សម្រាប់ឆ្នាំសិក្សា ២០២៣-២០២៤ ពុទ្ធិកសាកលវិទ្យាល័យទាំងអស់មានសមណនិស្សិតនិស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្រដែលមានទិន្នន័យប្រៀបធៀបដូចខាងក្រោម៖




គ្រប់ពុទ្ធិកសាកលវិទ្យាល័យទាំងអស់មានសមណនិស្សិត និស្សិតកើនឡើងគួរឱ្យកត់សម្គាល់ ក្នុងនោះដែរបើគណនាជារួមសមណនិស្សិត និស្សិតបានកើនឡើងសរុប **១៨%** ។ ទាំងនេះគឺជាសញ្ញាណវិជ្ជមានសម្រាប់វិស័យអប់រំពុទ្ធិកឧត្តមសិក្សា ក្នុងការលើកកម្ពស់ការអភិវឌ្ឍអប់រំនៅក្នុងសង្គមកម្ពុជា។

ដោយឡែកសម្រាប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ មានសមណនិស្សិត និស្សិតកំពុងសិក្សាទាំង **៣** ពុទ្ធិកសាកលវិទ្យាល័យមានទិន្នន័យដូចខាងក្រោម៖




ទោះបីជាមានពុទ្ធិកសាកលវិទ្យាល័យខ្លះចំនួនសមណនិស្សិត និស្សិតមានការថយចុះក៏ពិតមែន ប៉ុន្តែគណនាជារួមសមណនិស្សិត និស្សិតទាំងអស់មានការកើនឡើង **៥%** នេះបើយោងទៅលើទិន្នន័យបានធ្វើការវិភាគនិងប្រៀបធៀបខាងលើ។



ចំពោះថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់សម្រាប់ពុទ្ធិកសាកលវិទ្យាល័យទាំង **៣** យើងសង្កេតឃើញ ថា ចំនួនសមណនិស្សិតនិងចំនួននិស្សិតស្រីមានការថយចុះ ដោយឡែកចំនួននិស្សិតប្រុសមាន ដល់ទៅ **៥៣.៦%** នេះគឺជាចំនួនច្រើនលើសលប់បើប្រៀបធៀបទៅនឹងថ្នាក់បរិញ្ញាបត្រមានភាព ខុសគ្នាច្រើនគួរឱ្យកត់សម្គាល់។

ទាំងនេះគឺជាសមិទ្ធផលដែលពុទ្ធិកសាកលវិទ្យាល័យទាំង **៣** បានរួមចំណែកក្នុងការអភិវឌ្ឍ ធនធានមនុស្ស ជាពិសេសធនធានព្រះសង្ឃកម្រិតឧត្តមសិក្សា សម្រាប់សង្គមជាតិនិងព្រះពុទ្ធ សាសនា ដែលជាការរួមចំណែកដ៏សំខាន់មិនអាចខ្វះបាន ក្នុងការកាត់បន្ថយនៃការចំណាយរបស់ គ្រួសារ ក៏ដូចជាការលើកកម្ពស់គុណភាពអប់រំពុទ្ធិកឧត្តមសិក្សាឱ្យមានភាពរីកចម្រើននិងអភិវឌ្ឍ ប្រកបដោយនិរន្តរភាព។ លើសពីនេះទៅទៀត ពុទ្ធិកសាកលវិទ្យាល័យបានចូលរួមយ៉ាងសកម្ម ក្នុងការអភិវឌ្ឍមូលធនមនុស្សប្រកបដោយគុណភាព សមត្ថភាពនិងសីលធម៌ ដោយមិនប្រកាន់ រើសអើងវ័យ វណ្ណៈ ភេទ ពណ៌សម្បុរ ឬសាសនាឡើយ ដោយប្រជាពលរដ្ឋកម្ពុជាគ្រប់រូប គ្រប់ ស្រទាប់វណ្ណៈនិងសាសនាអាចចូលរៀនបានគ្រប់ពេល។

## ២.២.៥-ផ្នែករដ្ឋបាលនិងគណនេយ្យ

គ្រប់ស្ថាប័នឬអង្គភាពទាំងអស់អង្គភាពរដ្ឋបាលនិងគណនេយ្យនេះ គឺជាអង្គភាពដ៏សំខាន់ មិនអាចខ្វះបានឡើយ ព្រោះអង្គភាពនេះមានតួនាទីក្នុងការសម្របសម្រួលលើកិច្ចការងារទូទៅ ការផ្តល់សេវា ការទ្រទ្រង់សកម្មភាពការងារ និងការផ្គត់ផ្គង់លើសកម្មភាពផ្សេងៗរបស់គម្រោង ឬ ផ្នែកជំនាញដែលមានតម្រូវការចាំបាច់ និងរួមចំណែកដោះស្រាយបញ្ហានានារបស់ស្ថាប័ន ដែល ស្របទៅតាមដែនសមត្ថកិច្ចរបស់ខ្លួនតាមលទ្ធភាពដែលអាចធ្វើទៅបាន។ ក្នុងនោះដែរ ផ្នែករដ្ឋ បាលនិងគណនេយ្យបានធ្វើការសម្រួលលើកិច្ចការរដ្ឋបាលទូទៅដោយបានទទួលលិខិតចូលមក ពីអង្គភាពឬស្ថាប័ននានាចំនួន **៣០៤** ច្បាប់ បញ្ជូនលិខិតចេញទៅអង្គភាពជំនាញនិងក្រសួងធម្ម ការនិងសាសនានិងក្រសួងពាក់ព័ន្ធចំនួន **២៧៧** ច្បាប់ បានបញ្ជូនលិខិតបន្តទៅក្រសួងធម្មការ និងសាសនាចំនួន**៦៤** ច្បាប់ បានរៀបចំការប្រជុំផ្ទៃក្នុងនិងខាងក្រៅចំនួន **៨២** លើក ដើម្បីពង្រឹង ប្រសិទ្ធភាពនិងគុណភាពការងារឱ្យកាន់តែមានភាពប្រសើរឡើង។

បានធ្វើបច្ចុប្បន្នភាពមន្ត្រីសង្ឃ និងមន្ត្រីរាជការស៊ីវិល ដែលកំពុងបំពេញការងារនៅក្នុងវិស័យ ពុទ្ធិកសិក្សាទាំងថ្នាក់កណ្តាលនិងថ្នាក់ក្រោមជាតិសរុបចំនួន **៤៦៤** រូប (ថ្នាក់កណ្តាលចំនួន **១១២** រូប និងថ្នាក់រាជធានី ខេត្តចំនួន **៣៥២** រូប) ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការគ្រប់គ្រងនិងការ រៀបចំផែនការអភិវឌ្ឍពុទ្ធិកសិក្សាឱ្យកាន់តែល្អប្រសើរបន្ថែមទៀត។

លើសពីនេះទៅទៀត ផ្នែករដ្ឋបាលនិងគណនេយ្យបានធ្វើការត្រួតពិនិត្យលើការងារបច្ចេកទេសរបស់ផ្នែកជំនាញមួយចំនួនផងដែរ រួមមានការពិនិត្យគោលបញ្ជីវិញ្ញាបនបត្រធម្មវិន័យថ្នាក់ត្រី-ទោ-ឯកចំនួន **១១,៨១៣** សន្លឹក វិញ្ញាបនបត្រពុទ្ធិកបឋមសិក្សាចំនួន**៥,៨០៤** សន្លឹក សញ្ញាបត្រពុទ្ធិកមធ្យមសិក្សាបឋមភូមិចំនួន **២,៣៧០** សន្លឹក សញ្ញាបត្រពុទ្ធិកមធ្យមសិក្សាទុតិយភូមិចំនួន **៨២៣** សន្លឹក។

ម្យ៉ាងវិញទៀត ដើម្បីគាំទ្រដល់ដំណើរការអប់រំបណ្តុះបណ្តាលរបស់វិស័យពុទ្ធិកសិក្សាឱ្យមានដំណើរការល្អ បំពេញតាមតម្រូវការចាំបាច់នៅក្នុងដំណើរការបណ្តុះបណ្តាលសមណសិស្ស សិស្ស សមណនិស្សិត និស្សិតឱ្យប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាពខ្ពស់ ផ្នែករដ្ឋបាលនិងគណនេយ្យបានរៀបចំធ្វើការបែងចែកសម្ភារ ឱ្យផ្នែកជំនាញរួមមានសៀវភៅពុទ្ធប្បវត្តិ ពុទ្ធសាសនា បាលី ពុទ្ធវិន័យសរុបចំនួន **២,២០០** ក្បាល បើកវិញ្ញាបនបត្រធម្មវិន័យបោះពុម្ពរួចចំនួន **២៩,១៧៨** សន្លឹកនិងវិញ្ញាបនបត្រពុទ្ធិកបឋមសិក្សាបោះពុម្ពរួចចំនួន**៧៤៨** សន្លឹក សញ្ញាបត្រពុទ្ធិកមធ្យមសិក្សាបឋមភូមិបោះពុម្ពចំនួន **៧,៥០០** សន្លឹក។ ទន្ទឹមគ្នានេះដែរ ដើម្បីគាំទ្រដល់ដំណើរការប្រឡងរបស់វិស័យពុទ្ធិកសិក្សាគ្រប់កម្រិត ផ្នែកបានបើកទឹកបរិសុទ្ធចំនួន **៩៥** កែសក្រដាសការិយកិច្ចនិងសីមីចំនួន **១៨៤,៥០០** ឈុត ដល់ផ្នែកជំនាញក្នុងការរៀបចំកម្មវិធីផងដែរ។

ក្រៅពីនេះ ផ្នែករដ្ឋបាលនិងគណនេយ្យក៏មានកម្មវិធីស្នូលដ៏សំខាន់មួយទៀត ដែលផ្នែកតែងតែរៀបចំជាប្រចាំចាប់តាំងពីឆ្នាំ២០១៧ មក គឺប្រឡងសូត្របាតិមោក្ខ សម្តែងធម្មទេសនា និងសូត្រធម៌បទ។ សម្រាប់ឆ្នាំ២០២៣-២០២៤ ផ្នែកបានរៀបចំតែការប្រឡងសូត្របាតិមោក្ខមួយប៉ុណ្ណោះ សម្រាប់សកម្មភាពពីរផ្សេងៗទៀត ពុំត្រូវបានធ្វើឡើយ ដោយសារបេក្ខសមណៈនិងបេក្ខជនមិនមានចំនួនគ្រប់ទៅតាមលក្ខខណ្ឌដែលបានកំណត់ ដោយឡែក ចំពោះការប្រឡងសូត្របាតិមោក្ខមានបេក្ខសមណៈចូលរួមប្រឡងសរុបចំនួន **៦១** អង្គ ត្រូវបានបែងចែកជា **៤** បន្ទប់ គឺបន្ទប់លេខ **១**, **៣** និងលេខ **៤** មានបេក្ខសមណៈ **១៥** អង្គក្នុងមួយបន្ទប់ សម្រាប់បន្ទប់លេខ **២** មានបេក្ខសមណៈ **១៦** អង្គ ហើយបេក្ខសមណៈចំនួន **១៧** អង្គបានអវត្តមាន។ ក្នុងនោះបេក្ខសមណៈដែលបានចូលរួមប្រឡងទាំងអស់មានបេក្ខសមណៈត្រឹមតែ **០៥** អង្គប៉ុណ្ណោះ ដែលប្រឡងជាប់ជ័យលាភី។ ចំពោះនីតិវិធីនៃការប្រឡងដែលមានការបែងចែកជាបន្ទប់បែបនេះ ត្រូវបានរៀបចំដោយធ្វើការប្រឡងជំរុះទៅតាមបន្ទប់នីមួយៗ ក្នុងមួយបន្ទប់ជ្រើសរើសយកពីចំណាត់ថ្នាក់លេខ **១** ដល់លេខ **៥** ដើម្បីយកមកប្រគួតប្រជែងចម្រាញ់ចុងក្រោយយកចំណាត់ថ្នាក់ពីលេខ **១** ដល់លេខ **៥** ក្នុងការទទួលជ័យលាភី។

ចំពោះការប្រើប្រាស់គ្រូពុទ្ធិកជាប់កិច្ចសន្យា អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិតែងទទួលបានគោលការណ៍ដែលត្រូវបានផ្តល់ជូនដោយក្រសួងមុខងារសាធារណៈ សម្រាប់ឆ្នាំសិក្សា២០២៣-

២០២៤ សរុបមានចំនួន **១,៨៤៦** រូប[២៤] ដើម្បីធ្វើការបែងចែកឱ្យទៅបំពេញការងារនៅតាមពុទ្ធិក បឋមសិក្សានានានៅទូទាំងប្រទេស។ ក្នុងករណីនេះ អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិធ្វើការផ្ដល់ ជូនតែចំនួនតួលេខមូល[២៥]ប៉ុណ្ណោះ សម្រាប់ការជ្រើសរើសគ្រូពុទ្ធិកជាប់កិច្ចសន្យានៅតាមបណ្ដា រាជធានី ខេត្តទាំងនោះ គឺជាការទទួលខុសត្រូវរបស់ព្រះបាឡាត់គណនិងមន្ទីរធម្មការនិងសាសនា រាជធានី ខេត្ត ក្នុងការរៀបចំជ្រើសរើសទៅតាមនីតិវិធីរៀងៗខ្លួន។ ដូច្នេះចំពោះសមត្ថភាព គុណ ភាព និងគុណវុឌ្ឍិរបស់គ្រូពុទ្ធិកជាប់កិច្ចសន្យាទាំងអស់ អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិមាន ជំនឿនិងទំនុកចិត្តយ៉ាងមុតមាំ ទៅលើព្រះបាឡាត់គណនិងមន្ទីរធម្មការនិងសាសនាតាមបណ្ដា រាជធានី ខេត្ត ធ្វើយ៉ាងណាជ្រើសរើសគ្រូពុទ្ធិកជាប់កិច្ចសន្យាទាំងអស់ប្រកបដោយតម្លាភាពនិង គណនេយ្យភាព ដើម្បីជាប្រយោជន៍ដល់ការអភិវឌ្ឍវិស័យពុទ្ធិកសិក្សានិងសង្គមជាតិប្រកបដោយ ចីរភាព។

### ២.២.៥.១-ការរៀបចំផែនការថវិកា

ក្នុងការទ្រទ្រង់សកម្មភាពការងាររបស់វិស័យពុទ្ធិកសិក្សា ឱ្យប្រព្រឹត្តទៅប្រកបដោយ ប្រសិទ្ធភាពខ្ពស់ អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិបានធ្វើការរៀបចំផែនការសកម្មភាពនិងផែនការ ចំណាយយ៉ាងលម្អិត ដើម្បីទ្រទ្រង់ក្នុងការអភិវឌ្ឍវិស័យពុទ្ធិកសិក្សាឆ្ពោះទៅរកវឌ្ឍនភាពនិងភាព ជោគជ័យ ឈានទៅសម្រេចគោលនយោបាយរបស់ក្រសួងធម្មការនិងសាសនាស្ដីពី **"ការលើក កម្ពស់សាសនារបស់រដ្ឋ តម្លៃសីលធម៌សង្គម និងសុខដុមនីយកម្មសាសនា"** ដែលជាចំណែកមួយ នៃគោលដៅអភិវឌ្ឍជាតិ។ ជាងនេះទៅទៀត អគ្គាធិការដ្ឋានពុទ្ធិកសិក្សាមានតួនាទីសំខាន់ក្នុង ការជំរុញដំណើរការអភិវឌ្ឍដែលស្ថិតនៅក្នុងអនុកម្មវិធីទី១ ស្ដីពី **"ការពង្រឹងគុណភាពនិងពង្រីក វិស័យពុទ្ធិកសិក្សា"** ដែលជាការទទួលខុសត្រូវខ្ពស់សម្រាប់ការអភិវឌ្ឍគុណភាពអប់រំពុទ្ធិកសិក្សា និងការអភិវឌ្ឍមូលធនមនុស្សប្រកបដោយប្រសិទ្ធភាពខ្ពស់។ ក្នុងនោះដែរ អគ្គាធិការដ្ឋានពុទ្ធិក សិក្សាជាតិបានធ្វើការកសាងផែនការនិងការពារកញ្ចប់ថវិកា ដែលត្រូវចំណាយលើសកម្មភាព នានា ចាប់ពីកម្រិតជំនាញដល់កម្រិតថ្នាក់ដឹកនាំទទួលបានជោគជ័យ ព្រមទាំងបានអនុវត្តក្នុង ការចំណាយថវិកាទៅតាមផែនការប្រកបដោយតម្លាភាពនិងគណនេយ្យភាព។

[២៤] លិខិតរបស់ក្រសួងមុខងារសាធារណៈលេខៈ ១០៥/២៤ មស.ន.កវអ ចុះថ្ងៃទី ០៨ ខែមករា ឆ្នាំ២០២៤ ស្ដីពីគោល ការណ៍ប្រើប្រាស់ក្របខណ្ឌមន្ត្រីរាជការស៊ីវិល មន្ត្រីជាប់កិច្ចសន្យា និងគ្រូបង្រៀនប្រភេទផ្សេងទៀតជូនមន្ត្រីក្រសួង ប្រធានស្ថាប័ន សម្រាប់ឆ្នាំ២០២៣។

[២៥] សេចក្ដីសម្រេចរបស់ក្រសួងធម្មការនិងសាសនាលេខៈ ០៧/២៤ ក.ធ.ស.ស.រ ចុះថ្ងៃទី ៩ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពី ការបែងចែកគ្រូបង្រៀនពុទ្ធិកជាប់កិច្ចសន្យាទៅតាមមន្ទីររាជធានី ខេត្តសម្រាប់ផែនការឆ្នាំ២០២៤។

### ២.២.៥.២- អនុកម្មវិធី

**ការអប់រំវិស័យពុទ្ធិកសិក្សា** គឺការបណ្តុះបណ្តាលអប់រំសមណសិស្សសិស្សសមណនិស្សិតនិស្សិតចាប់ពីកម្រិតពុទ្ធិកបឋមសិក្សារហូតដល់ពុទ្ធិកឧត្តមសិក្សា និងក្រោយពុទ្ធិកឧត្តមសិក្សា ដើម្បីធានាបាននូវគុណភាព និងប្រសិទ្ធភាពខ្ពស់ក្នុងវិស័យអប់រំពុទ្ធិកសិក្សាទូទាំងប្រទេស។ អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិស្ថិតនៅក្នុងអនុកម្មវិធីទី១ ដែលមានសម្តេចព្រះពោធិវ័ង្សកិត្តិបណ្ឌិត **អ៊ំ លីមហេង** ព្រះអគ្គាធិការ ជាប្រធានគ្រប់គ្រងដឹកនាំ ដោយមានចង្កោមសកម្មភាពចំនួន ៦ ទទួលខុសត្រូវអនុវត្តប្រកបដោយតម្លាភាពនិងគណនេយ្យភាពដែលមានដូចខាងក្រោម៖

**ចង្កោមសកម្មភាពទី១**: ការអប់រំពុទ្ធិកបឋមសិក្សា និងធម្មវិន័យទទួលខុសត្រូវអនុវត្តដោយផ្នែកពុទ្ធិកបឋមសិក្សានិងធម្មវិន័យដែលមានព្រះពុទ្ធវង្ស **សុខ សុភាព** ជាប្រធាន។

**ចង្កោមសកម្មភាពទី២**: ការអប់រំពុទ្ធិកមធ្យមសិក្សា ទទួលអនុវត្តដោយផ្នែកពុទ្ធិកមធ្យមសិក្សា ដែលមានព្រះសង្ឃាលង្ការមុនី **យ៉ន កុសល្យ** ជាប្រធាន។

**ចង្កោមសកម្មភាពទី៣**: ការអប់រំពុទ្ធិកឧត្តមសិក្សានិងក្រោយពុទ្ធិកឧត្តមសិក្សា ទទួលអនុវត្តដោយផ្នែកពុទ្ធិកឧត្តមសិក្សានិងក្រោយពុទ្ធិកឧត្តមសិក្សា ដែលមានព្រះសុមេធវង្ស **សុខ ម៉ុនធឿន** ជាប្រធាន។

**ចង្កោមសកម្មភាពទី៤**: ការបណ្តុះបណ្តាលនិង ស្រាវជ្រាវនៃពុទ្ធិកឧត្តមសិក្សា ទទួលអនុវត្តដោយពុទ្ធិកសាកលវិទ្យាល័យសីហនុរាជ ដែលមានសម្តេចព្រះអរិយវង្ស បណ្ឌិត **យ៉ន សេង យៀត** ជាប្រធាន។

**ចង្កោមសកម្មភាពទី៥**: ការពង្រឹងគុណភាពអប់រំនិងការស្រាវជ្រាវ ទទួលអនុវត្តដោយពុទ្ធិកសាកលវិទ្យាល័សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ដែលមានព្រះសោមវេទី **អ៊ឹម សុភក្តិ** ជាប្រធាន។

**ចង្កោមសកម្មភាពទី៦**: សេវាទ្រទ្រង់វិស័យពុទ្ធិកសិក្សា ទទួលអនុវត្តដោយផ្នែករដ្ឋបាលនិងគណនេយ្យ ដែលមានលោក **ទន់ ផាន់លី** ជាប្រធាន។

ចង្កោមសកម្មភាពទាំង០៦នេះ ដើរតួនាទីយ៉ាងសំខាន់ក្នុងការអនុវត្តសកម្មភាពឱ្យសម្រេចទៅតាមផែនការ ដែលបានដាក់ចេញដោយអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិនៃក្រសួងធម្មការនិងសាសនា ហើយក៏ជាអង្គភាពស្នូលធានាបាននូវនិរន្តរភាពនៃការអនុវត្តផែនការប្រកបដោយជោគជ័យ ដើម្បីសម្រេចវត្ថុបំណងក្នុងការអប់រំវិស័យពុទ្ធិកសិក្សាប្រកបដោយគុណភាព សមត្ថភាពនិងសីលធម៌ ដែលជាគុណតម្លៃមហាសាលសម្រាប់បច្ឆាជនជំនាន់ក្រោយ ព្រះពុទ្ធសាសនានិងសង្គមជាតិទាំងមូលផងដែរ។

## ២.២.៥.៣- ការកំណត់ចេនាសម្ព័ន្ធថវិកាសមិទ្ធកម្ម

ដើម្បីសម្រេចគោលដៅក្នុងការអនុវត្តផែនការថវិកាប្រកបដោយប្រសិទ្ធភាពខ្ពស់ គ្រប់ក្រសួងស្ថាប័នទាំងអស់ចាំបាច់ត្រូវតែសម្រេចឱ្យបាននូវផែនការចំណាយរបស់ខ្លួន ដោយឈរលើមូលដ្ឋាននៃការចំណាយ ស្របទៅតាមគោលការណ៍ផែនការថវិកាសមិទ្ធកម្មសម្រាប់ឆ្នាំ២០២៣-២០២៤ ដែលអាចឆ្លើយតបទៅនឹងការអនុវត្តគោលនយោបាយបញ្ចកោណដំណាក់កាលទី១ ក្នុងការអភិវឌ្ឍមូលធនមនុស្ស ពោរពេញដោយចំណេះដឹង សមត្ថភាពនិងជំនាញ ក្នុងនោះអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិបានអនុវត្តយ៉ាងខ្ជាប់ខ្ជួន ដោយឈរលើគោលការណ៍អនុវត្តផែនការថវិកាប្រកបដោយតម្លាភាពនិងគណនេយ្យភាពមានដូចខាងក្រោម៖

## ក-ការកំណត់សូចនាករសមិទ្ធកម្ម និងគោលដៅនៃកម្មវិធី និងអនុកម្មវិធី

| សេចក្តីពណ៌នា | គម្រោងថវិកា | គោលដៅសូចនាករសមិទ្ធកម្ម | | | | | |
|---|---|---|---|---|---|---|---|
| សូចនាករលទ្ធផលក្នុងឆ្នាំនីមួយៗ | ឆ្នាំ២០២៥ (លានរៀល) | ឆ្នាំមុន -២០២៣ | ឆ្នាំបច្ចុប្បន្ន (ឆ្នាំ ២០២៤) | ឆ្នាំគ្រោងថវិកា (២០២៥) | | ឆ្នាំគ្រោងថវិកា -២០២៦ | ឆ្នាំគ្រោងថវិកា -២០២៧ |
| | | | | គោលដៅ | មូលហេតុនៃការផ្លាស់ប្តូរ (ធៀបនឹងគោលដៅឆ្នាំ ២០២៣) | | |
| គោលបំណងគ.ប.ទី១:លើកកម្ពស់សាសនារបស់រដ្ឋ តម្លៃសីលធម៌សង្គម និងសុខដុមនីយកម្មសាសនា | | | | | | | |
| ១. កម្មវិធីទី១:សុខដុមនីយកម្មសាសនានៅកម្ពុជា | | | | | | | |
| ១.១. អនុកម្មវិធីទី១:ការអប់រំវិស័យពុទ្ធិកសិក្សា | ៥,៤៤៦.០ | | | | ៥,៩៨៤.៣ | ៦,១២៩.៩ | ៦,២៧៩.៩ |
| សូចនាករលទ្ធផលក្នុងឆ្នាំទី ១.១.ក: %សមណសិស្ស និស្សិត និងសិស្ស និស្សិតទទួលបាន ជោគជ័យក្នុងការសិក្សាគ្រប់កម្រិត | | យ៉ាងហោចណាស់ ៨០% ទទួលបានជោគជ័យក្នុងការប្រឡង | យ៉ាងហោចណាស់ ៨០% ទទួលបានជោគជ័យក្នុងការប្រឡង | យ៉ាងហោចណាស់ ៨០% ទទួលបានជោគជ័យក្នុងការប្រឡង | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំទី ១.១.ខ: ចំនួនសមណសិស្ស និស្សិត និងសិស្ស និស្សិតបានទទួលការអប់រំគ្រប់កម្រិត | | ៤៤,២៦៥<br>អ/ន | ៤៧,៣៤៨<br>អ/ន | ៤៨,៣០០<br>អ/ន | | | |

## ខ.១- ការកំណត់សូចនាករសមិទ្ធកម្ម (ភាគរយ)

<table>
<tr><td>ក្រសួង៖<br>ធម្មការ និងសាសនា</td><td>អនុកម្មវិធីទី១៖<br>ការអប់រំវិស័យពុទ្ធិកសិក្សា</td><td>អង្គភាពទទួលបន្ទុក៖<br>អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ</td><td>កាលបរិច្ឆេទ៖<br>១៥ មីនា ២០២៤</td></tr>
<tr><td colspan="4">គោលបំណងអនុកម្មវិធី៖ ផ្តល់ការអប់រំលើវិស័យពុទ្ធិកសិក្សា ដើម្បីលើកកម្ពស់ចំណេះដឹងផ្នែកពុទ្ធចក្រ និងអាណាចក្រក្នុងការកសាងធនធានមនុស្សប្រកបដោយសមត្ថភាព សីលធម៌ និងចរិយាធម៌</td></tr>
<tr><td colspan="2">ប្រភេទសូចនាករ៖ សូចនាករលទ្ធផលក្នុងឆ្នាំ២០២៣</td><td colspan="2">លេខកូដសូចនាករ៖ PI 1.01-01</td></tr>
<tr><td colspan="4">ឈ្មោះសូចនាករវែង៖ ភាគរយ(%) សមណសិស្ស សមណនិស្សិត និងសិស្ស និស្សិតទទួលបាន ជោគជ័យក្នុងការសិក្សាគ្រប់កម្រិត</td></tr>
<tr><td colspan="4">ឈ្មោះសូចនាករខ្លី៖ ភាគរយ(%)សមណសិស្ស សមណនិស្សិត និងសិស្ស និស្សិត ទទួលបានជោគជ័យក្នុងការសិក្សាគ្រប់កម្រិត</td></tr>
<tr><td colspan="4">គោលបំណង/ សារៈសំខាន់នៃសូចនាករ៖<br>ក-ដើម្បីធ្វើការវាស់វែងពីប្រសិទ្ធភាពក្នុងការទទួលបានការសិក្សាដោយជោគជ័យ របស់សមណសិស្ស សមណនិស្សិត និងសិស្ស និស្សិតគ្រប់កម្រិត។<br>ខ-ដើម្បីធ្វើការវាស់វែងអំពីប្រសិទ្ធភាពនៃការអប់រំវិស័យពុទ្ធិកសិក្សា</td></tr>
<tr><td colspan="4">សេចក្តីពណ៌នា៖ ភាគរយខ្ពស់ នៃការទទួលបានជោគជ័យក្នុងការសិក្សារបស់ សមណសិស្ស សមណនិស្សិត និងសិស្ស និស្សិត បង្ហាញពីប្រសិទ្ធភាព នៃការអប់រំពុទ្ធិកសិក្សា និងធនធានមនុស្សប្រកបដោយគុណភាព ដែលបានចូលរួមលើកកម្ពស់វិស័យព្រះពុទ្ធសាសនានៅកម្ពុជា</td></tr>
<tr><td colspan="4">ការគណនា៖ ចំនួនសមណសិស្ស សមណនិស្សិត និងសិស្ស និស្សិត ដែលបានប្រឡងជាប់ធៀបនឹងសមណសិស្ស សិស្ស និងសមណនិស្សិត និស្សិត ដែលបានចូលរួមប្រឡង</td></tr>
<tr><td colspan="4">ប្រភពទិន្នន័យ៖ របាយការណ៍ប្រឡងប្រចាំឆ្នាំក្នុងវិស័យពុទ្ធិកសិក្សាដែលជាទិន្នន័យកត់ត្រាផ្ទាល់អគ្គាធិការ-ដ្ឋានពុទ្ធិកសិក្សាជាតិ។</td></tr>
<tr><td colspan="4">ថ្ងៃកំណត់នៃទិន្នន័យ៖ នៅរៀងរាល់ការបញ្ចប់ឆ្នាំសិក្សាពុទ្ធិកសិក្សា</td></tr>
<tr><td colspan="4">កាលបរិច្ឆេទកែប្រែចុងក្រោយ៖</td></tr>
</table>

## ខ.២- ការកំណត់សូចនាករសមិទ្ធកម្ម (ចំនួន)

| **ក្រសួង៖**<br>ធម្មការ និងសាសនា | **អនុកម្មវិធីទី១៖**<br>ការអប់រំវិស័យពុទ្ធិកសិក្សា | **អង្គភាពទទួលបន្ទុក៖**<br>អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ | **កាលបរិច្ឆេទ៖**<br>១៥ មីនា ២០២៤ |
|---|---|---|---|
| **គោលបំណងអនុកម្មវិធី៖** ផ្តល់ការអប់រំលើវិស័យពុទ្ធិកសិក្សា ដើម្បីលើកកម្ពស់ចំណេះដឹងផ្នែកពុទ្ធចក្រ និងអាណាចក្រក្នុងការកសាងធនធានមនុស្សប្រកបដោយសមត្ថភាព សីលធម៌ និងចរិយាធម៌ | | | |
| **ប្រភេទសូចនាករ៖** សូចនាករលទ្ធផលក្នុងឆ្នាំ២០២៣ | | **លេខកូដសូចនាករ៖ PI 1.01-02** | |
| **ឈ្មោះសូចនាករវែង៖** ចំនួនសមណសិស្ស សមណនិស្សិត និងសិស្ស និស្សិតបានទទួលការអប់រំគ្រប់កម្រិត | | | |
| **ឈ្មោះសូចនាករខ្លី៖** ចំនួនសមណសិស្ស សមណនិស្សិត និងសិស្ស និស្សិតបានទទួលការអប់រំគ្រប់កម្រិត | | | |
| **គោលបំណង/ សារៈសំខាន់នៃសូចនាករ៖**ដើម្បីធ្វើការវាស់វែងពីចំនួនសមណសិស្ស និស្សិត និងសិស្ស និស្សិត ដែលបានទទួលការអប់រំក្នុងរយៈពេលនៃឆ្នាំសិក្សាពុទ្ធិកសិក្សា។ | | | |
| **សេចក្តីពណ៌នា៖** ចំនួននៃសមណសិស្ស សមណនិស្សិត និងសិស្ស និស្សិត ដែលបានទទួលការអប់រំក្នុងពុទ្ធិកសិក្សាគ្រប់កម្រិតនិងធនធានមនុស្សប្រកបដោយចំណេះដឹង គុណភាព ដែលបានចូលរួមលើកកម្ពស់វិស័យព្រះពុទ្ធសាសនានៅកម្ពុជា | | | |
| **ការគណនា៖** ចំនួននៃសមណសិស្ស សមណនិស្សិត និងសិស្ស និស្សិត ដែលបានអប់រំក្នុងឆ្នាំសិក្សាមានចំនួន **៤៩,៤១១** រូប ស្មើនឹង **៨២.៦%** នេះបើធៀបទៅនឹងសមណសិស្ស សិស្សនិងសមណនិស្សិត និស្សិត ដែលគ្រោងក្នុងផែនការសរុបចំនួន **៥៩,៨៥៣** រូប ។ | | | |
| **ប្រភពទិន្នន័យ៖** របាយការណ៍ទទួលបានចំនួនសមណសិស្ស សមណនិស្សិត និងសិស្ស និស្សិត អប់រំតាមសាលាពុទ្ធិកសិក្សាប្រចាំឆ្នាំក្នុងវិស័យពុទ្ធិកសិក្សា។ | | | |
| **ថ្ងៃកំណត់នៃទិន្នន័យ៖** នៅរៀងរាល់ឆមាសទី១ ឆ្នាំសិក្សាពុទ្ធិកសិក្សា | | | |
| **កាលបរិច្ឆេទកែប្រែចុងក្រោយ៖** | | | |

## គ-រចនាសម្ពន្ធថវិកាសមិទ្ធកម្មឆ្នាំ ២០២៣

| |
|---|
| បេសកកម្ម (Mission Statement)របស់ក្រសួង-ស្ថាប័ន៖ ក្រសួងធម្មការនិងសាសនា មានបេសកកម្មដឹកនាំ និងគ្រប់គ្រងវិស័យធម្មការ និងសាសនា តាមរយៈការអប់រំពុទ្ធិកសិក្សា,ការសិក្សាស្រាវជ្រាវពាក់ព័ន្ធនិងវប្បធម៌, អក្សរសាស្ត្រ ប្រពៃណី និងវប្បធម៌ និងទំនៀមទម្លាប់ដែលមានទំនាក់ទំនងនិងសាសនា។ |
| គោលបំណងគោលនយោបាយទី ១៖ **លើកកម្ពស់សាសនារបស់រដ្ឋ តម្លៃសីលធម៌សង្គម និងសុខដុមនីយកម្មសាសនា** |

| | |
|---|---|
| **ឈ្មោះកម្មវិធីទី ១៖ សុខដុមនីយកម្មសាសនានៅកម្ពុជា** | |
| **ឈ្មោះអនុកម្មវិធីទី១.១៖ ការអប់រំពុទ្ធិកសិក្សា** | |
| តួនាទីអ្នកទទួលខុសត្រូវ៖ សម្តេចព្រះអគ្គាធិការ | ឈ្មោះអង្គភាពទទួលខុសត្រូវ៖ អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ |
| ផ្តល់ការអប់រំលើវិស័យពុទ្ធិកសិក្សា ដើម្បីលើកកម្ពស់ចំណេះដឹងផ្នែកពុទ្ធចក្រ និងអាណាចក្រក្នុងការកសាងធនធានមនុស្សប្រកបដោយសមត្ថភាព សីលធម៌ និងចរិយាធម៌ | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.១.ក៖* ភាគរយ(**៧៨.៣៦%**) សមណសិស្ស សមណនិស្សិតនិងសិស្ស និស្សិតទទួលបានជោគជ័យក្នុងការសិក្សាគ្រប់កម្រិត | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.១.ខ៖* សមណសិស្ស សមណនិស្សិតនិងសិស្ស និស្សិតចំនួន **៤៩,៤១១** រូប បានទទួលការអប់រំគ្រប់កម្រិត | |
| ***ឈ្មោះចង្កោមសកម្មភាព ១.១.១៖ ការអប់រំពុទ្ធិកបឋមសិក្សា និងធម្មវិន័យ*** | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.១.១.ក៖* ភាគរយ (**៨០%**) សមណសិស្ស សិស្ស ទទួលបានជោគជ័យ ក្នុងការសិក្សា(កម្រិតធម្មវិន័យ) | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.១.១.ខ៖* ភាគរយ(**៧៥%**)សមណសិស្ស សិស្ស ទទួលបានជោគជ័យក្នុងការសិក្សា (កម្រិតពុទ្ធិកបឋមសិក្សា) | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.១.១.គ៖* សមណសិស្ស សិស្សចំនួន **១១,៧៤៧** រូប បានទទួលការអប់រំ (កម្រិតធម្មវិន័យ) | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.១.១.ឃ៖* សមណសិស្ស សិស្សចំនួន **២៥,០៤៥** រូបបានទទួលការអប់រំ (កម្រិតពុទ្ធិកបឋមសិក្សា) | |
| ***ឈ្មោះចង្កោមសកម្មភាព ១.១.២ ៖ ការអប់រំពុទ្ធិកមធ្យមសិក្សា*** | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.១.២.ក៖* ភាគរយ (**៧០%**) សមណសិស្ស សិស្ស ទទួលបានជោគជ័យក្នុងការសិក្សា(កម្រិតពុទ្ធិកមធ្យមសិក្សាបឋមភូមិ) | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.១.២.ខ៖* ភាគរយ(**៧៦%**) សមណសិស្ស សិស្ស ទទួលបានជោគជ័យក្នុងការសិក្សា(កម្រិតពុទ្ធិកមធ្យមសិក្សាទុតិយភូមិ) | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.១.២.គ៖* សមណសិស្ស សិស្សចំនួន **៥,៩៣៣** រូប បានទទួលការអប់រំ (កម្រិតពុទ្ធិកមធ្យមសិក្សាបឋមភូមិ) | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.១.២.ឃ៖* សមណសិស្ស សិស្សចំនួន **២,០៩៦** រូប បានទទួលការអប់រំ (កម្រិតពុទ្ធិកមធ្យមសិក្សាទុតិយភូមិ) | |
| ***ឈ្មោះចង្កោមសកម្មភាព ១.១.៣ ៖ ការអប់រំពុទ្ធិកឧត្តមសិក្សា និងក្រោយពុទ្ធិកឧត្តមសិក្សា*** | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.១.៣.ក៖* ភាគរយ(៩៨%)សមណនិស្សិត និស្សិតទទួលបានជោគជ័យក្នុងការសិក្សា | |

| |
|---|
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.១.៣.ខ៖* សមណនិស្សិត និស្សិតចំនួន **១,៩៧៧** រូប បានទទួលការអប់រំ |
| ***ឈ្មោះចង្កោមសកម្មភាព ១.១.៤ ៖ ការបណ្តុះបណ្តាល និងស្រាវជ្រាវនៃពុទ្ធិកឧត្តមសិក្សា និងក្រោយពុទ្ធិកឧត្តមសិក្សា*** |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.១.៤.ក៖* ភាគរយ(**៩៨**%)សមណនិស្សិត និស្សិតទទួលបានជោគជ័យក្នុងការសិក្សា |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.១.៤.ខ៖* សមណនិស្សិត និស្សិតចំនួន **២,២៧៩** រូប បានទទួលការអប់រំ |
| ***ឈ្មោះចង្កោមសកម្មភាព ១.១.៥ ៖ ការពង្រឹងគុណភាពអប់រំ និងការស្រាវជ្រាវ*** |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.១.៥.ក៖* ភាគរយ(**១០០**%)សមណនិស្សិត និស្សិតទទួលបានជោគជ័យក្នុងការសិក្សា |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.១.៥.ខ៖* សមណនិស្សិត និស្សិតចំនួន **១,០៧៧** រូប បានទទួលការអប់រំ |
| ***ឈ្មោះចង្កោមសកម្មភាព ១.១.៦ ៖ ការពង្រឹងគុណភាពអប់រំ និងការស្រាវជ្រាវ*** |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.១.៦.ក៖* ការប្រឡងគ្រប់កម្រិតសិក្សាត្រូវបានរៀបចំ |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.១.៦.ខ៖* ប្រសិទ្ធភាពនៃការផ្តល់សេវារដ្ឋបាល |

## ២.២.៥.៤- ការកំណត់ធនធាន

| តម្រូវការឥណទានតាមប្រភេទចំណាយ | ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៤ | គ្រោងតម្រូវការឥណទានសម្រាប់ឆ្នាំ២០២៥ | គ្រោងតម្រូវការឥណទានសម្រាប់ឆ្នាំ២០២៦ | គ្រោងតម្រូវការឥណទានសម្រាប់ឆ្នាំ២០២៧ |
|---|---|---|---|---|
| **កម្មវិធីទី ២** ការអប់រំវិស័យពុទ្ធិកសិក្សា | **៥,៤៤៤.០** | **៨,២៧៧.១** | **៨,៧៧៣.៧** | **៩,៣០០.១** |
| **ក-សរុបចំណាយចរន្ត** | **៥,៤៤៤.០** | **៨,២៧៧.១** | **៨,៧៧៣.៧** | **៩,៣០០.១** |
| បន្ទុកបុគ្គលិក | ១,០១៧.០ | ១,១៧០.០ | ១,២៤០.២ | ១,៣១៤.៦ |
| ក្រៅបន្ទុកបុគ្គលិក | ៤,៤២៧.០ | ៧,១០៧.១ | ៧,៥៣៣.៥ | ៧,៩៨៥.៥ |
| **១-អនុកម្មវិធីទី១** ពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការអប់រំ ពុទ្ធិកបឋមសិក្សា និងធម្មវិន័យ ពុទ្ធិកមធ្យម ពុទ្ធិកឧត្តម និងក្រោយពុទ្ធិកឧត្តម | **២,៣៩៨.៥** | **៤,៥០៩.១** | **៤,៧៧៩.៦** | **៥,០៦៦.៤** |

| | | | | |
|---|---|---|---|---|
| **ក-សរុបចំណាយចរន្ត** | **២,៣៩៨.៥** | **៤,៥០៩.១** | **៤,៧៧៩.៦** | **៥,០៦៦.៤** |
| បន្ទុកបុគ្គលិក | ៩៥៧.០ | ១,១១០.០ | ១,១៧៦.៦ | ១,២៤៧.២ |
| ក្រៅបន្ទុកបុគ្គលិក | ១,៤៤១.៥ | ៣,៣៩៩.១ | ៣,៦០៣.០ | ៣,៨១៩.២ |
| **១-ចង្កោមសកម្មភាពទី១** | **៣៥៤.៨** | **៤៥៩.១** | **៤៨៦.៦** | **៥១៥.៨** |
| **ក-សរុបចំណាយចរន្ត** | **៣៥៤.៨** | **៤៥៩.១** | **៤៨៦.៦** | **៥១៥.៨** |
| បន្ទុកបុគ្គលិក | ០.០ | ៣០.០ | ៣១.៨ | ៣៣.៧ |
| ក្រៅបន្ទុកបុគ្គលិក | ៣៥៤.៨ | ៤២៩.១ | ៤៥៤.៨ | ៤៨២.១ |
| **២-ចង្កោមសកម្មភាពទី២** | **៣៨៣.៤** | **២,០០០.៦** | **២,១២០.៦** | **២,២៤៧.៩** |
| **ក-សរុបចំណាយចរន្ត** | **៣៨៣.៤** | **២,០០០.៦** | **២,១២០.៦** | **២,២៤៧.៩** |
| បន្ទុកបុគ្គលិក | ១១៧.០ | ១៣០.០ | ១៣៧.៨ | ១៤៦.១ |
| ក្រៅបន្ទុកបុគ្គលិក | ២៦៦.៤ | ១,៨៧០.៦ | ១,៩៨២.៨ | ២,១០១.៨ |
| **៣-ចង្កោមសកម្មភាពទី៣** | **៦០១.២** | **៨៣១.១** | **៨៨១.០** | **៩៣៣.៨** |
| **ក-សរុបចំណាយចរន្ត** | **៦០១.២** | **៨៣១.១** | **៨៨១.០** | **៩៣៣.៨** |
| បន្ទុកបុគ្គលិក | ៣៣០.០ | ៤១០.០ | ៤៣៤.៦ | ៤៦០.៧ |
| ក្រៅបន្ទុកបុគ្គលិក | ២៧១.២ | ៤២១.១ | ៤៤៦.៤ | ៤៧៣.១ |
| **៤-ចង្កោមសកម្មភាពទី៤** | **៧៣២.៩** | **៧៧៤.៤** | **៨២០.៩** | **៨៧០.១** |
| **ក-សរុបចំណាយចរន្ត** | **៧៣២.៩** | **៧៧៤.៤** | **៨២០.៩** | **៨៧០.១** |
| បន្ទុកបុគ្គលិក | ៣៩០.០ | ៤២០.០ | ៤៤៥.២ | ៤៧១.៩ |
| ក្រៅបន្ទុកបុគ្គលិក | ៣៤២.៩ | ៣៥៤.៤ | ៣៧៥.៧ | ៣៩៨.២ |
| **៥-ចង្កោមសកម្មភាពទី៥** | **៣២៦.២** | **៤៤៣.៩** | **៤៧០.៥** | **៤៩៨.៨** |
| **ក-សរុបចំណាយចរន្ត** | **៣២៦.២** | **៤៤៣.៩** | **៤៧០.៥** | **៤៩៨.៨** |
| បន្ទុកបុគ្គលិក | ១២០.០ | ១២០.០ | ១២៧.២ | ១៣៤.៨ |

| | | | | |
|---|---|---|---|---|
| ក្រៅបន្ទុកបុគ្គលិក | ២០៦.២ | ៣២៣.៩ | ៣៤៣.៣ | ៣៦៣.៩ |
| ១- អនុកម្មវិធីទី២ សេវាទ្រទ្រង់វិស័យពុទ្ធិកសិក្សា | **៣,០៤៥.៥** | **៣,៧៦៨.០** | **៣,៩៩៤.១** | **៤,២៣៣.៧** |
| **ក-សរុបចំណាយចរន្ត** | **៣,០៤៥.៥** | **៣,៧៦៨.០** | **៣,៩៩៤.១** | **៤,២៣៣.៧** |
| បន្ទុកបុគ្គលិក | ៦០.០ | ៦០.០ | ៦៣.៦ | ៦៧.៤ |
| ក្រៅបន្ទុកបុគ្គលិក | ២,៩៨៥.៥ | ៣,៧០៨.០ | ៣,៩៣០.៥ | ៤,១៦៦.៣ |
| **១-ចង្កោមសកម្មភាពទី១** | **០.០** | **២៨០.០** | **២៩៦.៨** | **៣១៤.៦** |
| **ក-សរុបចំណាយចរន្ត** | **០.០** | **២៨០.០** | **២៩៦.៨** | **៣១៤.៦** |
| បន្ទុកបុគ្គលិក | | ០.០ | ០.០ | ០.០ |
| ក្រៅបន្ទុកបុគ្គលិក | | ២៨០.០ | ២៩៦.៨ | ៣១៤.៦ |
| ១-ចង្កោមសកម្មភាពទី២ | **០.០** | **៣២០.០** | **៣៣៩.២** | **៣៥៩.៦** |
| **ក-សរុបចំណាយចរន្ត** | **០.០** | **៣២០.០** | **៣៣៩.២** | **៣៥៩.៦** |
| បន្ទុកបុគ្គលិក | ០.០ | ០.០ | ០.០ | ០.០ |
| ក្រៅបន្ទុកបុគ្គលិក | ០.០ | ៣២០.០ | ៣៣៩.២ | ៣៥៩.៦ |
| **២-ចង្កោមសកម្មភាពទី៣** | **៣,១០៥.៥** | **៣,២២៨.០** | **៣,៤២១.៧** | **៣,៦២៧.០** |
| **ក-សរុបចំណាយចរន្ត** | **៣,០៤៥.៥** | **៣,១៦៨.០** | **៣,៣៥៨.១** | **៣,៥៥៩.៦** |
| បន្ទុកបុគ្គលិក | ៦០.០ | ៦០.០ | ៦៣.៦ | ៦៧.៤ |
| ក្រៅបន្ទុកបុគ្គលិក | ២,៩៨៥.៥ | ៣,១០៨.០ | ៣,២៩៤.៥ | ៣,៤៩២.១ |

## ៣- បញ្ហាប្រឈម

ការទ្រទ្រង់ដំណើរការបណ្តុះបណ្តាលរបស់វិស័យពុទ្ធិកសិក្សា ត្រូវបានធ្វើឡើងដោយមានការគាំទ្រពីប្រភពពីរធំៗសំខាន់ គឺ១- ការគាំទ្រថវិកាពីរាជរដ្ឋាភិបាល ២- ប្រជាពុទ្ធបរិស័ទចំណុះជើងវត្តនិងប្រភពនានា ដើម្បីអាចធ្វើឱ្យការសិក្សារបស់សមណសិស្ស សិស្ស សមណនិស្សិត និស្សិតប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាពខ្ពស់និងប្រសិទ្ធផល ដែលជាគុណសម្បត្តិដ៏ប្រសើរសម្រាប់ការចូលរួមអភិវឌ្ឍប្រទេសជាតិឱ្យមានភាពរីកចម្រើនស្របទៅតាមដំណើរវិវឌ្ឍនៃសកលភាវូបនីយកម្មបច្ចុប្បន្ន។ នៅក្នុងកិច្ចដំណើរការអប់រំរបស់វិស័យពុទ្ធិកសិក្សាថ្វីដ្បិតតែអាចប្រព្រឹត្តិទៅបានជាប្រក្រតីក៏ពិតមែន ប៉ុន្តែនៅក្នុងនោះក៏ជួបប្រទះនូវបញ្ហាប្រឈមជាច្រើន ដែលចាំបាច់ត្រូវមានការចូលរួមពីភាគីពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ហាទាំងនោះឱ្យបានទាន់ពេលវេលានិងស្របទៅតាមតម្រូវការចាំបាច់របស់វិស័យអប់រំ តាមបែបសាសនាមួយនេះឱ្យមានដំណើរការល្អនិងមាន

និរន្តរភាពយូរអង្វែង ក្នុងការបណ្តុះស្មារតីទទួលខុសត្រូវខ្ពស់ចំពោះសីលធម៌សង្គម ព្រះពុទ្ធសាសនា និងប្រទេសជាតិទាំងមូល។ ចំពោះបញ្ហាប្រឈមដែលវិស័យអប់រំពុទ្ធិកសិក្សាតែងជួបប្រទះកន្លងមករួមមានដូចខាងក្រោម៖

### ក- របបប្រាក់ម៉ោងបន្ថែម

ការអនុវត្តរបបប្រាក់ម៉ោងបន្ថែមនៅក្នុងវិស័យពុទ្ធិកសិក្សា នៅតែបន្តជួបប្រទះបញ្ហាប្រឈមខ្លាំង ព្រោះវិស័យពុទ្ធិកសិក្សាត្រូវអនុវត្តរបបប្រាក់ម៉ោងនេះទៅតាមអនុក្រឹត្យលេខ **៣៨**[២៦] ដែលមានកំណត់នៅមានកម្រិតទាប បើធៀបទៅនឹងស្ថានភាពសេដ្ឋកិច្ច ដំណើរវិវឌ្ឍនៃវិស័យអប់រំនិងអនុវត្តក្រឹត្យលេខ **១០**[២៧] ដែលត្រូវបានអនុវត្តយ៉ាងទូលំទូលាយនៅក្រសួងអប់រំ យុវជន និងកីឡា។ កាលបើរបបប្រាក់ម៉ោងបន្ថែមមានកម្រិតទាប យើងពិតជាមានការលំបាកក្នុងការពង្រឹងគុណភាពអប់រំរបស់វិស័យពុទ្ធិកសិក្សាណាស់ ពីព្រោះគ្រូប្រាក់ម៉ោងបន្ថែមភាគច្រើន ត្រូវអញ្ជើញមកពីអង្គភាពឬស្ថាប័នផ្សេងក្រៅពីស្ថាប័នក្រសួងធម្មការនិងសាសនា ហេតុនេះហើយ យើងនឹងពុំអាចអញ្ជើញគ្រូល្អៗ ឬគ្រូដែលមានសមត្ថភាពខ្ពស់មកបង្រៀននៅក្នុងវិស័យពុទ្ធិកសិក្សាបានឡើយ។ ទាំងនេះគឺជាកត្តាប្រឈមដ៏ធ្ងន់ធ្ងរសម្រាប់វិស័យអប់រំពុទ្ធិកសិក្សា ដែលជាវិស័យអប់រំលំដាប់ទី២ បន្ទាប់ពីវិស័យអប់រំចំណេះទូទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា។ មានគ្រូសាស្ត្រាចារ្យជាច្រើនដែលមកបង្រៀននៅក្នុងវិស័យអប់រំពុទ្ធិកសិក្សាតែងលើកឡើងថា ហេតុអ្វីបានជារបបប្រាក់ម៉ោងបន្ថែមនៅក្នុងវិស័យពុទ្ធិកសិក្សាមានគម្លាតឆ្ងាយពីគ្នាខ្លាំងម្លេះ? កត្តាទាំងនេះអាចជះឥទ្ធិពលអវិជ្ជមានជាច្រើន ដែលនាំឱ្យមានការលំបាកដល់ការអញ្ជើញគ្រូមកបង្រៀនក្នុងវិស័យអប់រំពុទ្ធិកសិក្សា រហូតមានសាស្ត្រាចារ្យមួយចំនួនសម្រេចចិត្តមិនបន្តបង្រៀននៅពុទ្ធិកសិក្សាទៀតឡើយ។

### ខ- បញ្ហាមន្ត្រីសង្ឃប្រាក់និច្ចភត្ត និងមន្ត្រីក្របខណ្ឌ

ការខ្វះមន្ត្រីសង្ឃប្រាក់និច្ចភត្តក៏ជាកត្តាប្រឈមមួយដែរ ត្រូវដោះស្រាយដើម្បីឆ្លើយតបតាមតម្រូវការជាក់ស្តែងនៃវិស័យអប់រំពុទ្ធិកសិក្សា ព្រោះមន្ត្រីសង្ឃប្រាក់និច្ចភត្តត្រូវបានដាក់ពិដានកំណត់ត្រឹមតែ **៣៥២** អង្គប៉ុណ្ណោះសម្រាប់បំពេញការងារក្នុងវិស័យពុទ្ធិកសិក្សាទាំងថ្នាក់កណ្តាល ពុទ្ធិកសាកលវិទ្យាល័យ និងថ្នាក់រាជធានី ខេត្ត។ មិនត្រឹមតែប៉ុណ្ណោះ ក្នុងចំណោមមន្ត្រីសង្ឃបច្ច័យនិច្ចភត្តទាំងអស់អាចនឹងមានការប្រែប្រួល ព្រោះពេលខ្លះព្រះសង្ឃមួយចំនួនលោកបានលាចាកសិក្ខាបទទៅជាឃរាវាស (សឹក) ដូច្នេះហើយអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិត្រូវការជ្រើសរើសមន្ត្រី

---

[២៦] អនុក្រឹត្យលេខ ៣៨ អនក្រ.បក ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៩៩៦ ស្តីពី ការកម្រិតរបបម៉ោងកំណត់ ម៉ោងបន្ថែម និងប្រាក់ម៉ោងបន្ថែមសម្រាប់ការបង្រៀនក្នុងគ្រឹះស្ថានសិក្សាសាធារណៈ។

[២៧] អនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ ស្តីពី ការកម្រិតរបបម៉ោងកំណត់ ម៉ោងបន្ថែម និងប្រាក់ម៉ោងបន្ថែមសម្រាប់ការបង្រៀនក្នុងគ្រឹះស្ថានសិក្សាសាធារណៈ។

សង្ឃមកតែងតាំង ដើម្បីបំពេញការងារនៅក្នុងវិស័យពុទ្ធិកសិក្សាឱ្យគ្រប់តាមចំនួនដែលបានកំណត់ ក៏ជួបប្រទះការលំបាកក្នុងការតែងតាំងជំនួស ឬធ្វើឱ្យមានការយល់ច្រឡំចំពោះការតែងតាំងនេះធ្វើឱ្យចរន្តការងារមានភាពយឺតយ៉ាវក៏មាន។ ម្យ៉ាងទៀតចំពោះភាពខ្វះខាតមន្ត្រីសង្ឃបច្ច័យនិច្ចភត្ត ឬគ្រូក្របខណ្ឌនេះត្រូវបានលើកឡើងជាបន្តបន្ទាប់ ដោយសារតែចាប់តាំងពីឆ្នាំ២០១៧ រហូតមកដល់បច្ចុប្បន្ន អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ នៃក្រសួងធម្មការនិងសាសនានូវពុំទាន់ទទួលបានគោលការណ៍ដើម្បីជ្រើសរើសមន្ត្រី ឬគ្រូក្របខណ្ឌបន្ថែមនោះឡើយ។ ព្រោះបើគិតចាប់តាំងពីឆ្នាំ២០១៧ រហូតមកដល់ឆ្នាំ២០២៤ មន្ត្រីឬគ្រូក្របខណ្ឌមួយចំនួនបានដល់អាយុចូលនិវត្តន៍ ទទួលមរណភាព ឬទុពលភាពមិនអាចមកបំពេញការងារបាន ក៏ជាកត្តារួមចំណែកធ្វើឱ្យបន្ទុកនៃការអភិវឌ្ឍវិស័យពុទ្ធិកសិក្សាកាន់តែមានការលំបាកបន្ថែមទៀត។

### គ- សមត្ថភាពមន្ត្រីនៅមានកម្រិត

ការអនុវត្តគោលនយោបាយបញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល គឺជាការចាប់ផ្តើមយ៉ាងស្វាហាប់ពោរពេញទៅដោយថាមពល ជាពិសេសផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើវិស័យអប់រំ។ ដូច្នេះវិស័យអប់រំពុទ្ធិកសិក្សាក៏ជាវិស័យអាទិភាពមួយដែរ ដែលចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍធនធានមនុស្ស ប៉ុន្តែផ្ទុយទៅវិញ សមត្ថភាពមន្ត្រីសង្ឃនិងមន្ត្រីរាជការជាច្រើននៃអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិនៅមានកម្រិតនៅឡើយ ដែលជាកត្តាប្រឈមមួយយ៉ាងធ្ងន់ធ្ងរចំពោះការអភិវឌ្ឍនិងកំណែទម្រង់របស់វិស័យពុទ្ធិកសិក្សា ឱ្យស្របទៅតាមដំណើរវិវឌ្ឍរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភានាពេលបច្ចុប្បន្ន។ យ៉ាងណាក៏ដោយស្ថាប័នខ្លាំងទៅបានលុះត្រាតែមានធនធានមនុស្សដែលមានសមត្ថភាព ទើបអាចជួយជ្រោងអង្គភាព ឬស្ថាប័ននោះឱ្យរឹងមាំនិងមានការរីកចម្រើនទៅបាន។

### ឃ-ប្រព័ន្ធគ្រប់គ្រងទិន្នន័យពុទ្ធិកសិក្សា

ដោយសារភាពខ្វះខាតមន្ត្រីជំនាញនិងសមត្ថភាពមន្ត្រី ដែលបំពេញការងារនៅអគ្គាធិការ-ដ្ឋានពុទ្ធិកសិក្សាជាតិនៅមានកម្រិត វាក៏ជះឥទ្ធិពលមកដល់ការគ្រប់គ្រងវិស័យពុទ្ធិកសិក្សាតាមប្រព័ន្ធបច្ចេកវិទ្យាដែលមានការវិវឌ្ឍនាពេលបច្ចុប្បន្នផងដែរ។ ហេតុនេះហើយរបៀបនៃការគ្រប់គ្រងទិន្នន័យពុទ្ធិកសិក្សានៅមានលក្ខណៈបុរាណ ដែលធ្វើឱ្យទិន្នន័យជាច្រើនមានភាពរាយប៉ាយពុំទាន់មានលក្ខណៈជាប្រព័ន្ធដែលបង្កភាពងាយស្រួលដល់ថ្នាក់ដឹកនាំ គណៈកម្មការជំនាញ ឬអ្នកសិក្សាស្រាវជ្រាវទូទៅ អាចស្វែងរកព័ត៌មានពុទ្ធិកសិក្សាបានគ្រប់ជ្រុងជ្រោយនោះឡើយ។ ម្យ៉ាងទៀត បច្ចុប្បន្នរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានយកចិត្តទុកដាក់ខ្ពស់ ចំពោះការអភិវឌ្ឍមូលធនមនុស្សឱ្យស្របទៅនឹងដំណើរវិវឌ្ឍនៃបដិវត្តន៍ឌីជីថល ៤.០ ដែលបង្កភាពងាយស្រួលដល់គ្រប់វិស័យ ជាពិសេសវិស័យអប់រំ។ យ៉ាងណាមិញ វិស័យអប់រំពុទ្ធិកសិក្សាក៏មានតម្រូវការងារចាំបាច់ដែលមិនអាចខ្វះបានចំពោះការអភិវឌ្ឍពុទ្ធិកសិក្សាតាមរយៈបច្ចេកវិទ្យា ដើម្បីឱ្យស្របទៅតាមសម័យកាលដ៏ទំនើបនេះផងដែរ។

ករណីដែលបានលើកឡើងខាងលើទាំងប៉ុន្មាន គឺជាកត្តាប្រឈមដ៏សំខាន់ដែលវិស័យពុទ្ធិកសិក្សាតែងជួបប្រទះ ដែលតម្រូវឱ្យថ្នាក់ដឹកនាំតាមឋានានុក្រម ផ្នែកជំនាញនិងអង្គភាពពាក់ព័ន្ធទាំងអស់រួមចំណែកដោះស្រាយទៅតាមលទ្ធភាពនិងតាមតម្រូវការចាំបាច់ ដើម្បីជំរុញការអភិវឌ្ឍវិស័យពុទ្ធិកសិក្សាឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់បន្ថែមទៀត។

## ៤- ទិសដៅឆ្នាំសិក្សា ២០២៤-២០២៥

ដើម្បីធ្វើឱ្យដំណើរការអភិវឌ្ឍវិស័យពុទ្ធិកសិក្សា កាន់តែមានភាពរឹងមាំនិងមាននិរន្តរភាពយូរអង្វែងបន្ថែមទៀត អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិបានដាក់ចេញនូវទិសដៅបន្ត ដែលជាសូចនាករចង្អុលបង្ហាញផ្លូវដ៏សំខាន់ ក្នុងការអនុវត្តការងារប្រកបដោយប្រសិទ្ធភាព ដូចខាងក្រោម៖

- បន្តរៀបចំគោលនយោបាយពុទ្ធិកសិក្សា
- ធ្វើកំណែទម្រង់ប្រព័ន្ធគ្រប់គ្រងនិងប្រព័ន្ធការងារពុទ្ធិកសិក្សា
- បន្តធ្វើវិក្រឹតការគ្រូគ្រប់កម្រិតនៃភូមិសិក្សា
- ចូលរួមអនុវត្តផែនការយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ នៃរាជរដ្ឋាភិបាលដោយផ្តោតទៅលើការអភិវឌ្ឍមូលធនមនុស្សក្នុងវិស័យអប់រំ
- អភិវឌ្ឍកម្មវិធីសិក្សា សៀវភៅគោល និងធ្វើអធិការកិច្ច ដើម្បីពង្រឹងគុណភាពអប់រំវិស័យពុទ្ធិកសិក្សា
- បន្តសិក្សាស្រាវជ្រាវ និងចងក្រងការងារវិស័យពុទ្ធិកសិក្សា
- ចុះផ្សាយសកម្មភាពការងារពុទ្ធិកសិក្សាក្នុងគេហទំព័រផ្លូវការរបស់អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិជាផ្លូវការ
- បន្តរៀបចំបាឋកថាប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ
- បន្តអនុវត្តការងារពុទ្ធិកសិក្សាទៅតាមផែនការសកម្មភាពដែលបានដាក់ចេញ
- រៀបចំប្រឡងសិស្សពូកែផ្នែកភាសាបាលី
- បន្តចងក្រងទស្សនាវដ្តីពុទ្ធិកសិក្សា។

## ៥- សេចក្តីសន្និដ្ឋាន

ដំណើរការអប់រំរបស់វិស័យពុទ្ធិកសិក្សា បានប្រព្រឹត្តទៅជាប្រក្រតីតាមនិយាមនៃការអប់រំដែលមានតាំងពីអតីតកាលបន្តរហូតមកដល់បច្ចុប្បន្ន ដោយគោរពយ៉ាងខ្ជាប់ខ្ជួនតាមគោលការណ៍អប់រំជាសកល ការចង្អុលបង្ហាញនិងការណែនាំរបស់ប្រមុខរាជរដ្ឋាភិបាលដែលដឹកនាំ ដោយសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជានិងថ្នាក់ដឹកនាំសាមីក្រសួង ក៏ដូចជាថ្នាក់ដឹកនាំនៃអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិផងដែរ ដែលលោកតែងយក

ចិត្តទុកដាក់ខ្ពស់ទៅលើការអភិវឌ្ឍអប់រំពុទ្ធិកសិក្សាឱ្យស្របទៅតាមសម័យកាល ធ្វើយ៉ាងណាឱ្យការអប់រំរបស់វិស័យពុទ្ធិកសិក្សាទទួលបានលទ្ធផលល្អប្រកបដោយគុណភាព សមត្ថភាពនិងសីលធម៌ដែលគោលដៅដ៏សំខាន់ក្នុងការដឹកនាំជីវិតប្រកបដោយភាពសុខដុម សម្រាប់អនាគតព្រះពុទ្ធសាសនានិងប្រទេសជាតិ។

គោលការណ៍អប់រំពុទ្ធិកសិក្សាតែងប្រកាន់ខ្ជាប់តាមនិយាមចន្ទគតិ ដែលមានការបើកបវេសនកាលរៀងរាល់ថ្ងៃទី៥ ខែឧសភានៃឆ្នាំសិក្សានីមួយៗ ដែលទទួលបានលទ្ធផលគាប់ប្រសើរដូចអ្វីដែលបានបង្ហាញខាងលើស្រាប់ ព្រមទាំងបានធ្វើការវិភាគទិន្នន័យទៅតាមកម្រិតនៃការសិក្សានីមួយៗយ៉ាងលម្អិត ដើម្បីបង្ហាញឱ្យឃើញកាន់តែច្បាស់អំពីអ្វីដែលវិស័យពុទ្ធិកសិក្សាបានខិតខំប្រឹងប្រែងក្នុងការរួមចំណែកអភិវឌ្ឍធនធានមនុស្សប្រកបដោយការទទួលខុសត្រូវខ្ពស់ក្នុងនាមជាអង្គភាពអប់រំដ៏សំខាន់របស់ក្រសួងធម្មការនិងសាសនា ជាពិសេសបានផ្តល់ឱកាសយ៉ាងច្រើនដល់សមណសិស្ស សិស្ស សមណនិស្សិត និស្សិតដែលមានស្ថានភាពគ្រួសារក្រីក្រលំបាក ខ្វះលទ្ធភាពក្នុងការបន្តការសិក្សា ឱ្យទទួលបានការអប់រំប្រកបដោយភាពស្មើគ្នា។ ជាងនេះទៅទៀត វិស័យអប់រំពុទ្ធិកសិក្សាបានផ្តល់ប្រគេន ជូន សមណសិស្ស សិស្ស សមណនិស្សិត និស្សិតនូវចំណេះដឹងទូទៅទាំងផ្លូវលោកនិងផ្លូវធម៌ សមត្ថភាព ជំនាញ និងចរិយាធម៌ ដើម្បីអាចរស់នៅនិងធ្វើការជាមួយអ្នកដទៃប្រកបដោយភាពវិស្សាសៈ និងសាមគ្គីភាព។

ក្នុងអំឡុងពេលនៃការអនុវត្តការងាររយៈពេលមួយឆ្នាំកន្លងមកនេះ បានជួបបញ្ហាប្រឈមជាច្រើន ដែលថ្នាក់ដឹកនាំតាមឋានានុក្រមនិងភាគីពាក់ព័ន្ធ គប្បីរួមចំណែកដោះស្រាយឱ្យស្របតាមតម្រូវការជាក់ស្តែងរបស់វិស័យពុទ្ធិកសិក្សាក្នុងការអភិវឌ្ឍធនធានមនុស្ស ដើម្បីលើកកម្ពស់ការអប់រំរបស់ពុទ្ធិកសិក្សាកម្ពុជាឱ្យកាន់តែមានភាពរឹងមាំបន្ថែមទៀត ព្រមទាំងធានាបាននូវនិរន្តរភាពនៃប្រព័ន្ធតាមបែបសាសនាមួយនេះឱ្យស្ថិតស្ថេរចីរកាលតទៅ។

ដើម្បីជាដំណោះស្រាយ ឆ្លើយតបទៅនឹងបញ្ហាដែលបានជួបប្រទះកន្លងមកនេះ អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ ជាពិសេសសម្តេចព្រះអគ្គាធិការ ព្រះអគ្គាធិការរងនិងថ្នាក់ដឹកនាំតាមឋានានុក្រមបានព្យាយាមដោះស្រាយទៅតាមស្ថានភាពជាក់ស្តែងនិងតាមលទ្ធភាពដែលអាចធ្វើទៅបាន។ ប៉ុន្តែចំពោះដំណោះស្រាយទាំងនេះ ពុំអាចធានាបាននូវនិរន្តរភាពយូរអង្វែងឡើយ ព្រោះត្រឹមតែអាចដោះស្រាយទៅតាមស្ថានភាពបញ្ហាប៉ុណ្ណោះ ដូច្នេះ ដើម្បីអាចធ្វើឱ្យមានស្ថិរភាពយូរអង្វែង អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិចាំបាច់ត្រូវតែបង្កើតយន្តការដោះស្រាយដែលមានលក្ខណៈជាប្រព័ន្ធ និងមានផែនការយុទ្ធសាស្ត្រច្បាស់លាស់សម្រាប់ការងារពុទ្ធិកសិក្សា ដោយមានការចូលរួមពីភាគីពាក់ព័ន្ធទាំងអស់ ជាពិសេសគណៈគ្រប់គ្រងសាលាពុទ្ធិក សាលាគណ និងមន្ទីរធម្មការនិងសាសនារាជធានី ខេត្តផងដែរ។

យ៉ាងណាក៏ដោយអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ នៅតែមានជំនឿយ៉ាងមុតមាំថា កិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំតាមឋានានុក្រម សម្ដេចព្រះអគ្គាធិការ ព្រះអគ្គាធិការរង សម្ដេចព្រះសាកលវិទ្យាធិការ ព្រះសាកលវិទ្យាធិការរង ព្រះមេគណ គណៈគ្រប់គ្រងសាលាពុទ្ធិក មន្ទីរធម្មការនិងសាសនារាជធានី ខេត្ត និងពុទ្ធបរិស័ទទាំងអស់បានរួមចំណែកយ៉ាងច្រើន ដើម្បីទ្រទ្រង់អភិរក្សនិងអភិវឌ្ឍវិស័យពុទ្ធិកសិក្សារហូតទទួលបានសមិទ្ធផលដូចពេលនេះ នឹងបន្តធ្វើការងារទាំងនេះឱ្យកាន់តែមានភាពរឹងមាំបន្ថែមទៀត។ ក្តីសង្ឃឹមរបស់វិស័យអប់រំពុទ្ធិកសិក្សា គឺពឹងផ្អែកទៅលើឧបការបុគ្គលទាំងអស់ដែលបានបញ្ជាក់ខាងលើនេះ ក្នុងការពង្រីកវិសាលភាពនៃការបណ្តុះបណ្តាលនិងពង្រឹងគុណភាពអប់រំឱ្យកាន់តែមានភាពប្រសើរឡើងបន្ថែមទៀត ដើម្បីជាប្រយោជន៍ដល់ការផ្សព្វផ្សាយនិងការបដិបត្តិ ពុទ្ធសាសនាឱ្យមានសង្គតិភាពសម្រាប់បច្ឆាជនជំនាន់ក្រោយ៕

# ផ្នែកទី២

# សន្ធានុក្រម

# កម្រងរូបភាព

# ឧបសម្ព័ន្ធ

# សទ្ទានុក្រម

- **គណនេយ្យភាព** (ន) ភាពទទួលខុសត្រូវ, ការទទួលខុសត្រូវ។
- **គ្រហស្ថ** (ន) អ្នកមានផ្ទះ, អ្នកគ្រប់គ្រងផ្ទះគឺអ្នកមានគ្រួសារ។
- **ឃរាវាស** (ន) ការគ្រប់គ្រងផ្ទះ, អ្នកនៅគ្រប់គ្រងផ្ទះ
- **ចិរភាព** (ន) ភាពយឺតយូរ, ភាពដ៏យូរ។
- **ចុតិ** (ន.) (ច្យុតិ) ដំណើរដែលឃ្លាតចាកជីវិត គឺសេចក្តីស្លាប់ ។
- **ឆន្ទៈ** (ន) សេចក្តីប្រាថ្នា, បំណង, គំនិត, ការយល់ព្រម...។
- **តម្លាភាព** (ន) ភាពភ្លឺថ្លា, ភាពថ្លាស្អាត, ភាពភ្លឺស្វាង។
- **និរន្តរ៍** (កិ.វិ) ដែលឥតមានចន្លោះ, ឥតស្រាក, ឥតឈប់, ឥតល្ហែ។
- **បដិសន្ធិ** (ន.) (ប្រតិ-) តំណកំណើតសត្វៈ ចាប់បដិសន្ធិក្នុងផ្ទៃមាតា ។
- **បព្វជិត** (ន) អ្នកបួស។
- **បរិមាណ** (ន) ការរាប់,ការគ្នេរមើលដោយសព្វគ្រប់,ប្រមាណ, ចំនួន
- **បសំសកិច្ច** (ន) កិច្ចនៃការសរសើរ, ពាក្យសរសើរ។
- **ប្រតិស្ឋាន** ( ន) ការស្ថិត,ស្ថិតនៅ, ការតាំង,ការតាំងនៅ, តម្កល់, ការសាង, កសាង។
- **ប្រសិទ្ធផល** (ន) កម្រិតនៃលទ្ធផលដែលធ្វើឱ្យសម្រេចទៅតាមបំណង
- **ប្រសិទ្ធភាព** (ន) គុណភាពដែលសម្រេចបាន
- **មូលធនមនុស្ស** (ន) មនុស្សដែលមានតម្លៃជាទ្រព្យសំខាន់របស់ប្រទេសជាតិ ប្រកបដោយសក្តានុពលខាងចំណេះដឹង សមត្ថភាព ជំនាញ បទពិសោធ និងភាពច្នៃប្រឌិត ដែលជាធនធានឬជាទុនសម្រាប់អភិវឌ្ឍប្រទេសបាន
- **មោទកភាព** (ន) ភាព ឬភាវៈជាអ្នករីករាយ, ភាវៈនៃសេចក្តីត្រេកអរ, សេចក្តីអរគុណ
- **វិធាន** (ន) វិធី, បែប, បែបផែន, កិរិយាអំពើ...។
- **វិវឌ្ឍន៍** (ន) សេចក្តីចម្រើន។
- **វិវត្តន៍** (ន) ការប្រែប្រួល, ការផ្លាស់ប្តូរ។
- **វិសយៈ** (ន) អារម្មណ៍, គំនិត, ទី,តំបន់,ទីអាស្រ័យ, ភូមិ,ស្រុក, ប្រទេស, ខេត្ត,ដែន, បរិវេណ, មណ្ឌល,ទីបំផុត (នៃការមើលឃើញ),នាទី,ផ្នែក។ល។
- **វិស្សាសៈ** (ន) សេចក្តីស្និទ្ធស្នាល, ដំណើរជឿចិត្តគ្នា, ការទុកចិត្តគ្នា : មានវិស្សាសៈនឹងគ្នា។
- **វេយ្យាវច្ចៈ** (ន) ការខ្វល់ខ្វាយ, ការខ្នះខ្នែង, ការមិនប្រចាំគ្នា, ការយកចិត្តទុកដាក់។
- **សង្គតិ** (ន) ការរាប់រកគ្នា, ការរាប់អានគ្នា, ការរួបរួមគំនិតគ្នា, ការចូបប្រសព្វគ្នា សេចក្តីស្មោះស្មើទៅវិញទៅមករកគ្នា, ការប្រជុំ, ការចូបជុំគ្នា, សមាគម។ សង្គតិភាព ភាពនៃសង្គតិ ។

- **សញ្ញាណ** (ន) សេចក្ដីដឹងជាក់, ការយល់ដឹងច្បាស់, សេចក្ដីចូលចិត្តស៊ប់, គ្រឿងសម្គាល់, អ្វីៗដែលប្រើជាគ្រឿងសម្គាល់កិច្ចការនីមួយ, យីហោ។
- **សមធម៌** (ន) ស្ថានភាពដែលមនុស្សគ្រប់រូបត្រូវបានគេយកចិត្តទុកដាក់ដោយស្មើភាព បំពេញតាមតម្រូវការរបស់ពួកគេ ហើយគ្មានក្រុមមនុស្សណាមួយត្រូវបានផ្ដល់ជូនដោយលក្ខខណ្ឌពិសេសនោះឡើយ។
- **សមភាព** (ន) សិទ្ធិនៃក្រុមមនុស្សផ្សេងគ្នា ដែលមានតួនាទីក្នុងសង្គមដូចគ្នា និងទទួលបានការយកចិត្តទុកដាក់ដូចគ្នា។
- **សមិទ្ធកម្ម** (គុ) ដែលសម្រេចឬដែលស្រេចហើយ ។
- **សុខដុមនីយកម្ម** (ន) សកម្មភាព ឬដំណើរការនៃការធ្វើអ្វីមួយដែលស្របគ្នា ឬត្រូវគ្នា។ សកម្មភាពដែលធ្វើឱ្យមនុស្សមានគំនិត ផែនការ ស្ថានភាពផ្សេងៗគ្នា អាចរស់នៅសមរម្យ និងទទួលបានរួមគ្នាបាន។
- **សុគតិ** (ន.) ដំណើរល្អ, ការទៅដោយល្អ (ចំពោះការស្លាប់កើត),ការប្រព្រឹត្តត្រូវផ្លូវ, ត្រូវគន្លងធម៌, គន្លងឬលំអានយុត្តិធម៌ ។
- **សូចនាករ** (ន) កត្តាអ្វីមួយដែលបង្ហាញពីស្ថានភាព ឬរបៀបដែលវាកំពុងផ្លាស់ប្ដូរ
- **សេក្ខ** (ន) អ្នកដែលនៅកំពុងសិក្សា, អ្នករៀន។ ខ្មែរបុរាណហៅក្មេងដែលនៅរៀនអក្សរក្នុងវត្តថា សេក្ខលោក ឬកូនសេក្ខ (សិស្សលោក ឬកូនសិស្ស), ក្នុងសម័យឥឡូវក៏នៅមានប្រើខ្លះដែរ។
- **ស្ថិរភាព** (គុ) ភាពឋិតថេរ។
- **ហិរញ្ញប្បទាន** (ន) ប្រាក់ដែលបានផ្ដល់ជូន, ប្រាក់ដែលប្រគល់ជូន។
- **ឯកច្ឆន្ទ** (ន) ចំណង់តែមួយ, បំណងតែមួយ, បំណងត្រូវគ្នាតែមួយ, ដែលមានបំណងត្រូវគ្នាតែមួយ, ដែលព្រមចិត្តគ្នា។

# កម្រងរូបភាព

សកម្មភាពបណ្តុះបណ្តាលនិងសកម្មភាពថ្នាក់ដឹកនាំ មន្ត្រីសង្ឃ មន្ត្រីរាជការចូលរួមក្នុងការងារពុទ្ធិកសិក្សាសម្រាប់ឆ្នាំសិក្សា២០២៣-២០២៤។



ប្រជុំបូកសរុបលទ្ធផលការងារពុទ្ធិកសិក្សាប្រចាំឆ្នាំ២០២៣ ក្រោមព្រះអធិបតីភាពសម្តេចព្រះពោធិវ័ង្ស កិត្តិបណ្ឌិត **អំ លីមហេង** ព្រះអគ្គាធិការពុទ្ធិកសិក្សា។





សម្តេចព្រះពោធិវ័ង្ស កិត្តិបណ្ឌិត **អំ លីមហេង** និមន្តត្រួតពិនិត្យសកម្មភាពសិក្សារបស់សមណសិស្សនៃពុទ្ធិកបឋមសិក្សា **ម៉ុន ស៊ាងលី** (ចំពុះក្អែក)។





*ឯកឧត្តម **ចាយ បូរិន** រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា អញ្ជើញជាអធិបតីក្នុងកម្មវិធីប្រឡងសញ្ញាបត្រពុទ្ធិកមធ្យមសិក្សាទុតិយភូមិឆ្នាំសិក្សា២០២៣-២០២៤។*





*សម្តេចព្រះពោធិវង្សកិត្តិបណ្ឌិត **អំ លីមហេង** ព្រះអគ្គាធិការ និងឯកឧត្តម **ចាយ បូរិន** រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា ព្រមទាំងថ្នាក់ដឹកនាំអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិនិងថ្នាក់ដឹកនាំក្រសួងធម្មការនិងសាសនា ចូលរួមក្នុងកម្មវិធីប្រឡងសញ្ញាបត្រពុទ្ធិកមធ្យមសិក្សាទុតិយភូមិ។*





*សម្តេចព្រះពោធិវង្ស **អំ លីមហេង** ព្រះអគ្គាធិការ និងឯកឧត្តម **ចាយ បូរិន** រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា កាត់វិញ្ញាសាទី១នៃការប្រឡងសញ្ញាបត្រពុទ្ធិកមធ្យមសិក្សាទុតិយភូមិសម្រាប់ឆ្នាំសិក្សា២០២៣-២០២៤។*



ព្រះសង្ឃាលង្ការមុនីបណ្ឌិត ***យ៉ន កុសល្យ*** ប្រធានផ្នែកពុទ្ធិកមធ្យមសិក្សាចុះធ្វើអធិការកិច្ចតាមបណ្ដាពុទ្ធិកវិទ្យាល័យ។



កិច្ចប្រជុំពង្រឹងប្រសិទ្ធភាពការងារនៃអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ។





ព្រះពុទ្ធវង្ស ***សុខ សុភាព*** ប្រធានផ្នែកពុទ្ធិកបឋមសិក្សានិងធម្មវិន័យ បានដឹកនាំគណៈប្រតិភូចុះធ្វើអធិការកិច្ចបច្ចេកទេសតាមបណ្ដាសាលាពុទ្ធិកបឋមសិក្សាក្នុងខេត្តតាកែវ ។



កិច្ចប្រជុំពង្រឹងប្រសិទ្ធភាពការងារនិងនវានុវត្តន៍នៃការសិក្សា ក្រោមព្រះអធិបតីភាពសម្ដេចព្រះមង្គលមុនីវង្សី ***ហ៊ី ឈីវនាថ*** ព្រះអគ្គាធិការរងនិងជាព្រះនាយកពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត។



ព្រះសង្ឃាលង្ការមុនី បណ្ឌិត ***យ៉ន កុសល្យ*** ព្រះប្រធានផ្នែកពុទ្ធិកមធ្យមសិក្សា បានដឹកនាំព្រះមន្ត្រីសង្ឃនៃផ្នែកពុទ្ធិកមធ្យមសិក្សាជួបប្រជុំជាមួយព្រះនាយកនិងគណៈគ្រប់គ្រងនៃសាលាពុទ្ធិកអនុវិទ្យាល័យស្វាយរៀង។



ពិធីការពារនិក្ខេបបទបញ្ចប់ និងប្រឡងបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៃពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជា ក្រោមអធិបតីភាពឯកឧត្តម ***មាស សំណាង*** រដ្ឋលេខាធិការ តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម ***ចាយ បូរិន*** រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា។



សម្តេចព្រះមហាអរិយវង្ស បណ្ឌិត ***យ៉ន សេង យៀត*** ព្រះសាកលវិទ្យាធិការ នៃពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ និងសហការី បាននិមន្តជួបប្រជុំជាមួយលោកបណ្ឌិត Peter Gyallay-Pap នាយកប្រតិបត្តិគម្រោងជំនួយការពុទ្ធិកសិក្សាខ្មែរ (KEAP) ។



ផ្នែកពុទ្ធិកឧត្តមសិក្សានិងក្រោយពុទ្ធិកឧត្តមសិក្សាចុះអធិការកិច្ចនៅពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជា។



សម្តេចព្រះមង្គលមុនីវង្សី ***ហ៊ី ឈីវនាថ*** ព្រះអគ្គាធិការរងនិងជាព្រះនាយកពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹតនិមន្តកាត់វិញ្ញាសាប្រឡងសញ្ញាបត្រពុទ្ធិកមធ្យមសិក្សាទុតិយភូមិ។





សកម្មភាពបេក្ខសមណៈ បេក្ខជនចូលរួមក្នុងការប្រឡងសញ្ញាបត្រពុទ្ធិកមធ្យមសិក្សាទុតិយភូមិ ឆ្នាំសិក្សា២០២៣-២០២៤(ទីតាំង ពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត រាជធានីភ្នំពេញ)។

នស/រកត/០១២៤/ ១៤៧

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការនិងសាសនា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០៦/២០៧ ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០០៦ ស្តីពីការបង្កើតគណៈសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១:** តែងតាំងមុខតំណែង សម្តេចព្រះមហាសុមេធាធិបតីកិត្តិឧទ្ទេសបណ្ឌិត **នន្ទ ង៉ែត** ជាព្រះអធិបតីកិត្តិយស នៃអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ។

**មាត្រា២:** សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

រាជ.២៤០១.១៤៧

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣១ ខែមករា ឆ្នាំ២០២៤

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**

# ព្រះរាជក្រឹត្យ

នស/រកត/០១២៤/១៣៧០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការនិងសាសនា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០៦/២០៧ ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ២០០៦ ស្តីពីការបង្កើតគណៈសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១:** តែងតាំងមុខតំណែង សម្តេចព្រះពោធិវ័ង្សកិត្តិបណ្ឌិត **អំ លីមហេង** ជាព្រះអគ្គាធិការនៃអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ។

**មាត្រា២:** សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

៣១.០១.១៣៧០

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣១ ខែមករា ឆ្នាំ២០២៤

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**

# ព្រះរាជក្រឹត្យ

នស/រកត/០១២៤/ ១៧៧១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការនិងសាសនា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០៦/២០៧ ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០០៦ ស្តីពីការបង្កើតគណៈសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : តែងតាំងមុខតំណែង សម្តេចព្រះមហាអរិយវង្សបណ្ឌិត **យ៉ន សេងយៀត** ជាព្រះសាកលវិទ្យាធិការនៃពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ។

**មាត្រា២** : សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

នរោត្តម សីហមុនី

[illegible]

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣១ ខែមករា ឆ្នាំ២០២៤*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**

# ផ្នែកទី៣
# ស្ថិតិពុទ្ធិកសិក្សាសខ្មែរ

# ស្ថិតិសង្ខេបពុទ្ធិកសិក្សាទូទាំងប្រទេស

# ឆ្នាំសិក្សា២០២៣-២០២៤

ពុទ្ធសករាជ ២៥៦៧ គ្រិស្តសករាជ ២០២៣

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និងសាសនា
អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ

## តារាងស្ថិតិសង្ខេបពុទ្ធិកសិក្សាទូទាំងប្រទេស
## ឆ្នាំសិក្សា ២០២៣-២០២៤

| ល.រ | កម្រិត | ថ្នាក់ទី១ (ត្រី) | | ថ្នាក់ទី២ (ទោ) | | ថ្នាក់ទី៣ (ឯក) | | សរុប | | សាលា | គ្រូ | | | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ថ្នាក់ | សិស្ស | ថ្នាក់ | សិស្ស | ថ្នាក់ | សិស្ស | ថ្នាក់ | សិស្ស | | ក្របខ័ណ្ឌ | កិច្ចសន្យា | ជួល | |
| ១ | ធម្មវិន័យ | 434 | 6,898 | 170 | 2,287 | 135 | 1,816 | 739 | 11,001 | 529 | 0 | 0 | 677 | 677 |
| ២ | ពុទ្ធិកបឋមសិក្សា | 815 | 14,863 | 365 | 5,912 | 267 | 4,270 | 1,447 | 25,045 | 950 | 173 | 1,368 | 741 | 2,282 |
| ៣ | ពុទ្ធិកអនុវិទ្យាល័យ | 57 | 2,592 | 51 | 1,737 | 46 | 1,593 | 154 | 5,922 | 38 | 118 | 73 | 383 | 574 |
| ៤ | ពុទ្ធិកវិទ្យាល័យ | 19 | 905 | 18 | 602 | 17 | 589 | 54 | 2,096 | 14 | 35 | 21 | 207 | 263 |
| សរុប | | 1,325 | 25,258 | 604 | 10,538 | 465 | 8,268 | 2,394 | 44,064 | 1,531 | 326 | 1,462 | 2,008 | 3,796 |

ថ្ងៃច័ន្ទ ២កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ២០២៣
**ប្រធាន**
**ការិយាល័យរដ្ឋបាល និង សរុប**

**ព្រះសមណឧត្តម ឆេង សុមឿ**

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃអង្គារ ៣កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ២០២៣
**ប្រធាន**
**ផ្នែករដ្ឋបាល និងគណនេយ្យ**

**ទន់ ផាន់លី**

បានឃើញ និងឯកភាព
ថ្ងៃពុធ ៤កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ២០២៣
**ជ.សម្តេចព្រះអគ្គាធិការ**
**ព្រះអគ្គាធិការរង**

**សម្តេចព្រះពោធិវ័ង្ស អ៊ំ លឹមហេង**

ក្រសួងធម្មការ និងសាសនា
អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# តារាងស្ថិតិសង្ខេប សាលា-សមណសិស្ស-សិស្ស ពុទ្ធិកសិក្សាគ្រប់កម្រិត
# ទូទាំងប្រទេស ឆ្នាំសិក្សា ២០២៣-២០២៤

| ល.រ | រាជធានី/ខេត្ត | សាលាធម្មវិន័យ | | | | | | សរុប | | | សាលាពុទ្ធិកបឋមសិក្សា | | | | | | សរុប | | | ពុទ្ធិកមធ្យមសិក្សាបឋមភូមិ | | | | | | សរុប | | | ពុទ្ធិកមធ្យមសិក្សាទុតិយភូមិ | | | | | | សរុប | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ត្រី | | ទោ | | ឯក | | | | | ថ្នាក់ទី ១ | | ថ្នាក់ទី ២ | | ថ្នាក់ទី ៣ | | | | | ថ្នាក់ទី ១ | | ថ្នាក់ទី ២ | | ថ្នាក់ទី ៣ | | | | | ថ្នាក់ទី ១ | | ថ្នាក់ទី ២ | | ថ្នាក់ទី ៣ | | | | |
| | | ថ្នាក់ | សិស្ស | ថ្នាក់ | សិស្ស | ថ្នាក់ | សិស្ស | សាលា | ថ្នាក់ | សិស្ស | ថ្នាក់ | សិស្ស | ថ្នាក់ | សិស្ស | ថ្នាក់ | សិស្ស | សាលា | ថ្នាក់ | សិស្ស | ថ្នាក់ | សិស្ស | ថ្នាក់ | សិស្ស | ថ្នាក់ | សិស្ស | សាលា | ថ្នាក់ | សិស្ស | ថ្នាក់ | សិស្ស | ថ្នាក់ | សិស្ស | ថ្នាក់ | សិស្ស | សាលា | ថ្នាក់ | សិស្ស |
| 1 | អគ្គាធិការដ្ឋាន | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 4 | 233 | 4 | 168 | 4 | 138 | 1 | 12 | 539 | 4 | 237 | 4 | 150 | 4 | 113 | 1 | 12 | 500 |
| 2 | រាជធានីភ្នំពេញ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 43 | 1,055 | 32 | 606 | 20 | 358 | 50 | 95 | 2,019 | 8 | 359 | 7 | 258 | 7 | 242 | 7 | 22 | 859 | 1 | 59 | 1 | 54 | 1 | 44 | 1 | 3 | 157 |
| 3 | កណ្តាល | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 68 | 1,458 | 28 | 556 | 29 | 499 | 75 | 125 | 2,513 | 7 | 273 | 6 | 138 | 6 | 171 | 6 | 19 | 582 | 2 | 104 | 2 | 79 | 1 | 38 | 2 | 5 | 221 |
| 4 | បាត់ដំបង | 33 | 825 | 18 | 293 | 20 | 360 | 42 | 71 | 1,478 | 53 | 1,068 | 21 | 325 | 22 | 378 | 58 | 96 | 1,771 | 4 | 230 | 4 | 141 | 4 | 195 | 3 | 12 | 566 | 2 | 126 | 2 | 89 | 2 | 81 | 1 | 6 | 296 |
| 5 | សៀមរាប | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 38 | 748 | 26 | 483 | 15 | 263 | 51 | 79 | 1,494 | 5 | 246 | 3 | 104 | 2 | 63 | 2 | 10 | 413 | 2 | 83 | 1 | 41 | 1 | 52 | 1 | 4 | 176 |
| 6 | បន្ទាយមានជ័យ | 54 | 937 | 32 | 500 | 20 | 271 | 83 | 106 | 1,708 | 66 | 1,096 | 37 | 566 | 20 | 286 | 95 | 123 | 1,948 | 3 | 119 | 2 | 100 | 1 | 78 | 1 | 6 | 297 | 1 | 32 | 1 | 27 | 1 | 24 | 1 | 3 | 83 |
| 7 | ពោធិ៍សាត់ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 33 | 466 | 5 | 57 | 9 | 102 | 39 | 47 | 625 | 2 | 79 | 2 | 93 | 2 | 88 | 2 | 6 | 260 | 1 | 42 | 1 | 15 | 1 | 63 | 1 | 3 | 120 |
| 8 | ព្រៃវែង | 45 | 705 | 18 | 239 | 22 | 276 | 49 | 85 | 1,220 | 45 | 703 | 17 | 194 | 22 | 279 | 49 | 84 | 1,176 | 3 | 155 | 3 | 89 | 2, | 71 | 2 | 8 | 315 | 1 | 30 | 1 | 19 | 1 | 12 | 1 | 3 | 61 |
| 9 | ស្វាយរៀង | 18 | 225 | 12 | 125 | 9 | 77 | 31 | 39 | 427 | 23 | 514 | 19 | 330 | 11 | 191 | 31 | 53 | 1,035 | 2 | 73 | 1 | 60 | 1 | 24 | 1 | 4 | 157 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 10 | តាកែវ | 1 | 6 | 0 | 0 | 1 | 20 | 2 | 2 | 26 | 62 | 1,047 | 43 | 653 | 19 | 279 | 54 | 124 | 1,979 | 1 | 41 | 1 | 26 | 1 | 24 | 1 | 3 | 91 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 11 | ត្បូងឃ្មុំ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 19 | 390 | 10 | 155 | 9 | 168 | 23 | 38 | 713 | 3 | 196 | 3 | 101 | 3 | 106 | 2 | 9 | 403 | 1 | 50 | 1 | 42 | 1 | 58 | 1 | 3 | 150 |
| 12 | កំពង់ចាម | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 48 | 1,093 | 28 | 568 | 25 | 492 | 67 | 101 | 2,153 | 5 | 152 | 5 | 147 | 4 | 97 | 3 | 14 | 396 | 2 | 75 | 1 | 33 | 1 | 45 | 1 | 4 | 153 |
| 13 | កំពង់ធំ | 111 | 1,615 | 26 | 297 | 13 | 112 | 113 | 150 | 2,024 | 94 | 1,288 | 31 | 359 | 12 | 110 | 99 | 137 | 1,757 | 2 | 111 | 2 | 52 | 2 | 74 | 2 | 6 | 237 | 0 | 0 | 1 | 18 | 1 | 15 | 1 | 2 | 33 |
| 14 | កំពង់ឆ្នាំង | 72 | 1,033 | 12 | 181 | 6 | 92 | 82 | 90 | 1,306 | 72 | 1,033 | 12 | 181 | 6 | 92 | 82 | 90 | 1,306 | 2 | 106 | 1 | 67 | 1 | 43 | 1 | 4 | 216 | 1 | 27 | 1 | 20 | 1 | 20 | 1 | 3 | 67 |
| 15 | កំពង់ស្ពឺ | 23 | 262 | 7 | 48 | 3 | 35 | 24 | 33 | 345 | 62 | 1,117 | 20 | 304 | 18 | 279 | 69 | 100 | 1,700 | 1 | 49 | 2 | 52 | 2 | 60 | 1 | 5 | 161 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 16 | កំពត | 10 | 175 | 8 | 136 | 8 | 116 | 26 | 26 | 427 | 14 | 302 | 11 | 192 | 14 | 211 | 26 | 39 | 705 | 2 | 108 | 2 | 71 | 1 | 43 | 1 | 5 | 222 | 1 | 40 | 1 | 15 | 1 | 24 | 1 | 3 | 79 |
| 17 | កោះកុង | 6 | 82 | 3 | 32 | 1 | 14 | 6 | 10 | 128 | 5 | 61 | 2 | 22 | 0 | 0 | 5 | 7 | 83 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 18 | ព្រះសីហនុ | 11 | 151 | 7 | 89 | 4 | 47 | 11 | 22 | 287 | 9 | 235 | 3 | 82 | 1 | 26 | 11 | 13 | 343 | 1 | 13 | 1 | 25 | 1 | 23 | 0 | 3 | 61 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |

| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 19 | ក្រចេះ | 13 | 320 | 5 | 93 | 4 | 69 | 16 | 22 | 482 | 12 | 312 | 5 | 93 | 4 | 69 | 15 | 21 | 474 | 1 | 31 | 1 | 39 | 1 | 35 | 1 | 3 | 105 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 20 | ស្ទឹងត្រែង | 7 | 115 | 2 | 38 | 1 | 20 | 9 | 10 | 173 | 7 | 115 | 2 | 38 | 1 | 20 | 9 | 10 | 173 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 21 | ព្រះវិហារ | 10 | 180 | 3 | 22 | 6 | 101 | 9 | 19 | 303 | 11 | 216 | 3 | 22 | 5 | 65 | 9 | 19 | 303 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 22 | ឧត្តរមានជ័យ | 6 | 100 | 7 | 108 | 10 | 145 | 10 | 23 | 353 | 9 | 147 | 1 | 19 | 1 | 18 | 9 | 11 | 184 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 23 | មណ្ឌលគិរី | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 2 | 75 | 2 | 18 | 0 | 0 | 2 | 4 | 93 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 24 | រតនគិរី | 5 | 63 | 5 | 56 | 5 | 46 | 5 | 15 | 165 | 4 | 74 | 3 | 36 | 2 | 20 | 4 | 9 | 130 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 25 | ប៉ៃលិន | 9 | 104 | 5 | 30 | 2 | 15 | 11 | 16 | 149 | 13 | 171 | 3 | 33 | 1 | 44 | 13 | 17 | 248 | 1 | 18 | 1 | 6 | 1 | 18 | 1 | 3 | 42 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 26 | កែប | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 3 | 79 | 1 | 20 | 1 | 21 | 5 | 5 | 120 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| សរុប | | 434 | 6,898 | 170 | 2,287 | 135 | 1,816 | 529 | 739 | 11,001 | 815 | 14,863 | 365 | 5,912 | 267 | 4,270 | 950 | 1,447 | 25,045 | 57 | 2,592 | 51 | 1,737 | 46 | 1,593 | 38 | 154 | 5,922 | 19 | 905 | 18 | 602 | 17 | 589 | 14 | 54 | 2,096 |

ថ្ងៃច័ន្ទ ៤រោច ខែ ភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ២០២៣
**ប្រធាន**
**ការិយាល័យរដ្ឋបាល និង សរុប**

**ព្រះសមណឧត្តម ឆេង សុម៉ី**

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃអង្គារ ៣រោច ខែ ភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ២០២៣
**ប្រធាន**
**ផ្នែករដ្ឋបាល និងគណនេយ្យ**

**ទន់ ផាន់លី**

បានឃើញ និងឯកភាព
ថ្ងៃពុធ ៤រោច ខែ ភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ២០២៣
**ជ.សម្តេចព្រះអគ្គាធិការ**
**ព្រះអគ្គាធិការរង**

**សម្តេចព្រះពោធិវ័ង្ស អំ លីមហេង**

# ស្ថិតិសង្ខេបពុទ្ធិកសាកលវិទ្យាល័យទូទាំងប្រទេស

## ( បរិញ្ញាបត្រ )

## ឆ្នាំសិក្សា២០២៣-២០២៤

ពុទ្ធសករាជ ២៥៦៧ គ្រិស្តសករាជ ២០២៣

ក្រសួងធម្មការ និងសាសនា
អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## តារាងស្ថិតិ សាលា-គ្រូ-សមណនិស្សិត-និស្សិត ពុទ្ធិកសាកលវិទ្យាល័យ ទូទាំងប្រទេស
## កម្រិតថ្នាក់បរិញ្ញាបត្រ ឆ្នាំសិក្សា ២០២៣-២០២៤

| ល.រ | ពុទ្ធិកសាកលវិទ្យាល័យ | ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន | ថ្នាក់ឆ្នាំទី២ | ថ្នាក់ឆ្នាំទី៣ | ថ្នាក់ឆ្នាំទី៤ | សរុប | | គ្រូ | | | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | សាលា | និស្សិត | ក្របខណ្ឌ | ស្ម័គ្រចិត្ត | ជួល | |
| ១ | ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ(ភ្នំពេញ) | 321 | 278 | 156 | 108 | 1 | 863 | 32 | 0 | 55 | 87 |
| ២ | ពុទ្ធិកសាកលវិ.ព្រះសីហនុរាជសាខាកំពង់ឆ្នាំង | 124 | 123 | 65 | 81 | 1 | 393 | 0 | 0 | 54 | 54 |
| ៣ | ពុទ្ធិកសាកលវិ.ព្រះសីហនុរាជសាខាបាត់ដំបង | 330 | 347 | 200 | 146 | 1 | 1,023 | 6 | 0 | 66 | 72 |
| ៤ | ពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជា | 766 | 559 | 415 | 237 | 1 | 1,977 | 4 | 0 | 111 | 115 |
| ៥ | ពុទ្ធិក.សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន | 421 | 360 | 223 | 103 | 1 | 1,107 | 5 | 0 | 58 | 63 |
| សរុប | | 1,962 | 1,667 | 1,059 | 675 | 5 | 5,363 | 47 | 0 | 344 | 391 |

ថ្ងៃចន្ទ ២កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២៣
**ប្រធាន**
**ការិយាល័យរដ្ឋបាល និង សរុប**

**ព្រះសមណឧត្តម ឆេង សុម៉ឺ**

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃអង្គារ ៣កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៣
**ប្រធាន**
**ផ្នែករដ្ឋបាល និងគណនេយ្យ**

**ទន់ ផាន់លី**

បានឃើញ និងឯកភាព
ថ្ងៃពុធ ៤កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៣
**ជ.សម្តេចព្រះអគ្គាធិការ**
**ព្រះអគ្គាធិការរង**

**សម្តេចព្រះពោធិវ័ង្ស អ៊ំ លឹមហេង**

# ស្ថិតិសង្ខេបពុទ្ធិកសាកលវិទ្យាល័យទូទាំងប្រទេស

## ( បរិញ្ញាបត្រជាន់ខ្ពស់ )

## ឆ្នាំសិក្សា២០២៣-២០២៤

ពុទ្ធសករាជ ២៥៦៧ គ្រិស្តសករាជ ២០២៣

ក្រសួងធម្មការ និងសាសនា
អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# តារាងស្ថិតិ សាលា-គ្រូ-សមណនិស្សិត-និស្សិត ពុទ្ធិកសាកលវិទ្យាល័យ ទូទាំងប្រទេស
# កម្រិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ឆ្នាំសិក្សា ២០២៣-២០២៤

| ល.រ | ពុទ្ធិកសាកលវិទ្យាល័យ | ថ្នាក់ឆ្នាំទី១ | ថ្នាក់ឆ្នាំទី២ | សរុប | | គ្រូ | | សរុប |
|---|---|---|---|---|---|---|---|---|
| | | | | សាលា | និស្សិត | ក្របខណ្ឌ | ជួល | |
| ១ | ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ(ភ្នំពេញ) | 105 | 76 | 1 | 181 | 0 | 16 | 16 |
| ២ | ពុទ្ធិកសាកលវិ.ព្រះសីហនុរាជសាខាកំពង់ឆ្នាំង | 0 | 33 | 1 | 33 | 0 | 14 | 14 |
| ៣ | ពុទ្ធិកសាកលវិ.ព្រះសីហនុរាជសាខាបាត់ដំបង | 38 | 34 | 1 | 72 | 0 | 38 | 38 |
| ៤ | ពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជា | 237 | 233 | 1 | 470 | 0 | 32 | 32 |
| ៥ | ពុទ្ធិក.សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន | 62 | 52 | 1 | 114 | 0 | 18 | 18 |
| សរុបរួម | | 442 | 428 | 5 | 870 | 0 | 118 | 118 |

ថ្ងៃចន្ទ ២កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២៣
**ប្រធាន**
**ការិយាល័យរដ្ឋបាល និង សរុប**

**ព្រះសមណឧត្តម ឆេង សុមឿ**

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃអង្គារ ៣កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៣
**ប្រធាន**
**ផ្នែករដ្ឋបាល និងគណនេយ្យ**

**ទន់ ផាន់លី**

បានឃើញ និងឯកភាព
ថ្ងៃពុធ ៤កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៣
**ជ.សម្តេចព្រះអគ្គាធិការ**
**ព្រះអគ្គាធិការរង**

**សម្តេចព្រះពោធិវ័ង្ស អំ លឹមហេង**